# ទស្សនវិជ្ជានិងទ្រឹស្តី ស្តីពីការអប់រំ



ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា
Sipar
២០២១

ហង់ជួន ណារ៉ុន

ទស្សនវិជ្ជានិងទ្រឹស្តីស្តីពីការអប់រំ



សង្គមមួយត្រូវបានរៀបចំឱ្យមានស្ថិរភាព ពេលដែលបុគ្គលនីមួយៗកំពុងធ្វើនូវអ្វីដែលជាសមត្ថភាពពីធម្មជាតិ ដើម្បីប្រើជាផលប្រយោជន៍ដល់អ្នកដទៃ...ហើយការធ្វើដូចនេះគឺជាដំណើរការនៃការអប់រំ។ គោលដៅនៃការអប់រំ គឺបង្រៀនមនុស្សនូវបញ្ហាសំខាន់ៗ តាមរយៈចំណេះដឹង បណ្តុះចរិយាធម៌ និងការគោរពភាពថ្លៃថ្នូរបស់មនុស្ស។ ការ «គិតពិចារណា» ជាប្រចាំ គឺជាមធ្យោបាយផង និងជាគោលបំណងផងនៃការអប់រំ។ គោលបំណងនៃគរុកោសល្យ គឺការអប់រំមនុស្សឱ្យក្លាយទៅជាទ្រព្យសម្បត្តិរបស់សង្គម។ ដើម្បីសម្រេចបានគោលដៅនេះ ការគ្រប់គ្រងការអប់រំត្រូវតែធ្វើកំណែទម្រង់ជាបន្តបន្ទាប់៖ (១) ការពង្រឹងប្រសិទ្ធភាព និងដំណើរការសាលារៀន ជាពិសេស ការកែលម្អវិធីសាស្ត្របង្រៀន និងដំណើរការនៃការរៀន និងការបង្រៀន (២) ការពង្រឹងប្រព័ន្ធអប់រំទាំងមូល ក្នុងគោលបំណងទទួលបាននូវគុណភាពអប់រំ និងភាពប្រកួតប្រជែងរបស់ប្រទេសលើទីផ្សារការងារ និង (៣) ការឆ្លើយតបទៅនឹងសតវត្សទី ២១ និងជានាទំនាក់ទំនងរវាងការរៀនក្នុងសាលា និងបរិបទនៃសកល-ភាវូបនីយកម្មមូលដ្ឋាន ភាវូបនីយកម្ម និងបុគ្គលភាវូបនីយកម្ម។

ISBN: 978-9924-34-096-6

# ទស្សនវិជ្ជា និងទ្រឹស្ដី
# ស្ដីពីការអប់រំ

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

២០២១

រចនាទំព័រ និងសម្រួលអត្ថបទដោយអង្គការ Sipar
© ហង់ជួន ណារ៉ុន
រក្សាសិទ្ធិគ្រប់យ៉ាង

# មាតិកា


**សេចក្ដីផ្ដើម** .................................................. ix

**ជំពូកទី ១ ទស្សនវិជ្ជានៃការអប់រំ** .................................................. ១៥

*ទ្រឹស្ដីស្ដីពីការអប់រំ* .................................................. ១៥

១. Desiderius Erasmus (1469-1536) .................................................. ១៦

២. Michel Eyquem De MONTAIGNE (1533-1592) .................................................. ១៨

៣. Johann Amos COMENIUS (1592-1670) .................................................. ២០

៤. Jean-Baptiste de LA SALLE (1651-1719) .................................................. ២២

៥. Jean-Jacques ROUSSEAU (1712-1778) .................................................. ២៣

៦. Wilhelm von HUMBOLDT (1767- 1835) .................................................. ២៦

៧. Friedrich SCHLEIERMACHER (1768-1834) .................................................. ២៨

៨. Johann Friedrich HERBART (1776-1841) .................................................. ៣៣

៩. John DEWEY (1859-1952) .................................................. ៣៥

១០. Ellen KEY (1849-1926) .................................................. ៤៤

១១. Heinrich PESTALOZZI (1746-1827) .................................................. ៤៨

១២. Pauline KERGOMARD (1838-1925) .................................................. ៥៦

១៣. Maria MONTESSORI (1870-1952) .................................................. ៦០

១៤. Janusz KORCZAK (1878-1942) .................................................. ៧០

១៥. Alexander Sutherland NEILL (1883-1973) .................................................. ៧៤

១៦. Celestin FREINET (1896-1966) .................................................. ៧៩

១៧. Pierre FAURE (1904-1988) .................................................. ៨៥

១៨. Françoise DOLTO (1908-1988) .................................................. ៩៣




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៩. Paulo FREIRE (1921-1997)........................................ ១០២

២០. Raymond FONVIEILLE (1923-2000)................................ ១០៨

២១. Georges LAPASSADE (1924-2008)................................ ១១៨

**ជំពូកទី ២ ទ្រឹស្តីនៃការអប់រំ** ........................................ ១២៧

២.១. *តួនាទីនៃការអប់រំក្នុងការអភិវឌ្ឍ*........................................ ១២៧

២.២. *តួនាទីបំណិន ចំណេះដឹង និងបំណិនទន់ក្នុងការអភិវឌ្ឍ សេដ្ឋកិច្ច* ........................................ ១៣៣

២.៣. *ចំណេះដឹងក្នុងយុគសម័យឌីជីថល*........................................ ១៣៧

**ជំពូកទី ៣ ទ្រឹស្តីនៃការគ្រប់គ្រងអប់រំ** ........................................ ១៤៨

៣.១. *ទស្សនាទាននៃការគ្រប់គ្រងអប់រំ* ........................................ ១៤៨

៣.២. *ទ្រឹស្តីនៃការគ្រប់គ្រងអប់រំ* ........................................ ១៥២

**ជំពូកទី ៤ ទ្រឹស្តីស្តីពីកំណែទម្រង់ការអប់រំ**........................................ ១៦១

៤.១. *ការវិវត្តនៃទ្រឹស្តីនៃកំណែទម្រង់ការអប់រំ*........................................ ១៦១

៤.២. *ទ្រឹស្តីពលរដ្ឋមានគុណភាព* ........................................ ១៦៩

៤.៣. *លក្ខខណ្ឌចាំបាច់សម្រាប់កំណែទម្រង់ការអប់រំ ប្រកបដោយជោគជ័យ* ........................................ ១៨០

៤.៤. *កំណែទម្រង់ជាប្រព័ន្ធនៃការគ្រប់គ្រងអប់រំ*........................................ ១៨៣

៤.៥. *ការសម្របសម្រួលរវាងកំណែទម្រង់ពីលើ ចុះក្រោម និងកំណែទម្រង់ពីក្រោមឡើងលើ*........................................ ១៩៤

៤.៦. *ការសម្របសម្រួលរវាងការផ្គត់ផ្គង់ និងតម្រូវការរបស់ សាលារៀន*........................................ ១៩៧



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤.៧. កំណែទម្រង់ជាប្រព័ន្ធ និងការគ្រប់គ្រង តាមសាលារៀន.២០០
៤.៨. គំនិតផ្តួចផ្តើមសកល និងទិដ្ឋភាពនៃ កំណែទម្រង់ការអប់រំ .២០២

**សេចក្តីសន្និដ្ឋាន** ...................................................................២០៧

**ឯកសារយោង** .........................................................................២១១



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សេចក្ដីផ្ដើម

នៅដើមសតវត្សទី ២១ ពិភពលោកទាំងមូលបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ដូចជា អំពើភេរវកម្ម វិបត្តិហិរញ្ញវត្ថុ បម្រែបម្រួលអាកាសធាតុ ជម្លោះតាមតំបន់ ភាពក្រីក្រ និងបញ្ហាដែលពាក់ព័ន្ធនឹងបច្ច័យអវិជ្ជមាននៃសកលភាវូបនីយកម្មជាដើម។ ក្នុងបរិបទនេះ ទស្សនាទានស្ដីពី «ប្រជាពលរដ្ឋប្រកបដោយគុណភាព» (Quality Citizenship) កាន់តែត្រូវបានគេទទួលស្គាល់ថា ជាគោលដៅដ៏សំខាន់នៃការអប់រំ ហើយនិយមន័យនៃពាក្យនេះត្រូវបានពង្រីកបន្ថែម និងរួមបញ្ចូលនូវទិដ្ឋភាពសកល និងទិដ្ឋភាពអប់រំជាច្រើនទៀតដូចជាវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងការចូលរួមក្នុងកិច្ចការនយោបាយ និងសង្គម។

ម្យ៉ាងវិញទៀត ពិភពលោកបច្ចុប្បន្នស្ថិតនៅចំណុចចាប់ផ្ដើមនៃបដិវត្តន៍ឧស្សាហកម្មទីបួនដែលបានកំនត់រូបរាងដោយសារសកលភាវូបនីយកម្ម និងរបត់ផ្លាស់ប្ដូរបច្ចេកវិទ្យាដែលកំពង់លេចឡើង។ បដិវត្តន៍នេះជាគន្លឹះចាប់ផ្ដើម ដែលស្របគ្នានឹងការផ្ទុះឡើងនៃបច្ចេកវិទ្យាផ្សេងទៀតដែលនឹងគ្របដណ្ដប់លើគ្រប់វិស័យដូចជា គ្រឿងយន្តវៃឆ្លាតសិប្បនិម្មិត (artificial intelligence) គ្រឿងយន្ត បណ្ដាញតភ្ជាប់ឧបករណ៍អេឡិចត្រូនិច (the Internet of things) រថយន្តគ្មានមនុស្សបើក ការបោះពុម្ពស្រ៊ីឌី (Printing 3D) បច្ចេកវិទ្យាណាណូ បច្ចេកវិទ្យាជីវសាស្ត្រ វិទ្យាសាស្ត្ររូបធាតុការស្តុកថាមពល និងប្រព័ន្ធគណនាតួលេខ (quantum computing)។ បដិវត្តន៍ថ្មីនេះនឹងមានឥទ្ធិពលធំធេងលើរបៀប ដែលអ្នកជំនាន់ថ្មីនឹងត្រូវការអប់រំក្នុងគោលបំណងត្រៀមសម្រាប់ទីផ្សារនាពេលអនាគត (Schwab, ២០១៦)។ យោងទៅតាមការស្រាវជ្រាវពីវេទិកាសេដ្ឋកិច្ចពិភពលោក ៣៥% នៃជំនាញចាំបាច់សម្រាប់ទទួលបានការងារមួយនាពេលបច្ចុប្បន្ន នឹងមានភាពខុសគ្នាក្នុងរយៈពេល១០ឆ្នាំខាងមុខទៀត។ បដិវត្តន៍ឧស្សាហកម្មទី៤មានន័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាទៅ១០ឆ្នាំខាងមុខមួយភាគបីនៃជំនាញដែលសេដ្ឋកិច្ចត្រូវការនឹងផ្លាស់ប្តូរដោយការងារស្វ័យប្រវត្តិ។ ក្មេងមួយរូបនាពេលបច្ចុប្បន្ន នឹងត្រូវផ្លាស់ប្តូរការងារយ៉ាងតិចចំនួន៧ដងក្នុងមួយវដ្តជីវិត ហើយការងារ៥ក្នុងចំណោមការងារទាំងនោះមិនទាន់មាននៅឡើយនោះទេ។ ដូច្នេះ វាមានការលំបាកក្នុងការព្យាករពី «ជំនាញរឹង»ណាមួយរបស់ក្មេងត្រូវការក្នុងថ្នាក់រៀននាពេលបច្ចុប្បន្ន សម្រាប់ការងារនាពេលអនាគត។ ជំនាញទាំងនេះរួមមានការងារជាក្រុមចំណេះដឹងផ្នែកឧបករណ៍អេឡិចត្រូនិច យល់ដឹងពីបទបញ្ញានិងនីតិបញ្ញត្តិ ការទទួលខុសត្រូវ និងការប្តេជ្ញាចិត្ត។ ការងារដែលគ្រឿងយន្តវៃឆ្លាតមិនអាចជំនួសបានគឺការងារទាំងឡាយណាដែលតម្រូវឱ្យមានភាពរឹងមាំនៃចរិតលក្ខណៈរបស់មនុស្សជាតិ។ កម្មករ នឹងត្រូវការអាកប្បកិរិយាជាវិជ្ជមាន ដើម្បីរៀនសូត្រឡើងវិញ និងទទួលយកស្ថានភាពថ្មី ពេលដែលជំនាញចាស់លែងត្រូវប្រើប្រាស់ (Thomson, ២០១៦)។ ដូច្នេះ ការផ្លាស់ប្តូរបច្ចេកវិទ្យា សេដ្ឋកិច្ច និងទិដ្ឋភាពនយោបាយពិភពលោកយ៉ាងឆាប់រហ័សតម្រូវឱ្យយកគោលនយោបាយជំនាញ និងការអប់រំជាចំណុចស្នូល។ ការអប់រំ និងជំនាញមានឥទ្ធិពលជាវិជ្ជមានគួរឱ្យកត់សម្គាល់ទៅលើសមត្ថភាពសង្គមនិងបុគ្គល ដើម្បីទទួលយកការផ្លាស់ប្តូរ និងចាប់យកឱកាសឧត្តមភាពដែលកើតចេញពីសកលភាវូបនីយកម្ម (Woessmann, ២០១១)។

ផ្អែកតាមការវិភាគខាងលើ ការអប់រំបានក្លាយជាកត្តាដ៏សំខាន់ក្នុងការទទួលបាន និងទាញយកផលប្រយោជន៍ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដែលមាន ហើយការអប់រំត្រូវបានគិតថាជាផ្នែកមួយនៃដំណោះស្រាយចំពោះបញ្ហាប្រឈមសកល។ ប្រជាជនដែលទទួលការអប់រំ គឺជាប្រភេទនៃកម្លាំងពលកម្មចាំបាច់សម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ហើយវាជាគ្រឹះនៃការរួបរួមសង្គម និង និរន្តរភាពពិភពលោក។ ជំនាញដឹងដោយញាណ និងមិនមែនញាណ (Cognitive and non-cognitive skill) គឺមានសារៈសំខាន់សម្រាប់ផលិតភាព និងលទ្ធផលសង្គម។ ដូច្នេះ ការពិភាក្សាផ្អែក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោលនយោបាយមានសារៈសំខាន់ចំពោះគុណភាពការអប់រំ។ ទោះបីជាយ៉ាងណាក៏ដោយ ជំនាញមិនស៊ីគ្នាបានលេចឡើងក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០៨ ដែលជាលទ្ធផលនៃការផ្លាស់ទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមយ៉ាងឆាប់រហ័ស នៅពេលដែលវិទ្យាស្ថានអប់រំក្នុងប្រទេសកម្ពុជាមានភាពយឺតយ៉ាវខ្លាំងក្នុងការចាប់យកការផ្លាស់ប្តូរនេះ។ យុទ្ធសាស្ត្រជោគជ័យមួយតម្រូវឱ្យមានការអនុវត្តកំណែទម្រង់ការអប់រំជាប្រព័ន្ធ ក្នុងគោលបំណងដោះស្រាយជាមួយនឹងអត្តភាពស្មុគស្មាញ និងដោះស្រាយបញ្ហាជាច្រើននៅពេលដំណាលគ្នា។ ប្រាកដណាស់ កំណែទម្រង់គួរធ្វើឡើងនៅកម្រិតសាលារៀន។ មាននិន្នាការមួយក្នុងប្រទេសជាច្រើនឆ្ពោះទៅរកការបង្កើនភាពស្វ័យប្រវត្តិ និងការផ្ទេរអំណាចទទួលខុសត្រូវដល់កម្រិតសាលារៀនដោយជំរុញការទទួលខុសត្រូវតាមតម្រូវការរបស់ថ្នាក់ក្រោម។ គោលបំណងនៃកំណែទម្រង់សាលារៀន គឺដើម្បីលើកកម្ពស់ការប្រតិបត្តិតាមរយៈការអនុវត្តការគ្រប់គ្រងផ្អែកលើសាលារៀន។ ដូចនេះ ប្រទេសកំពុងអភិវឌ្ឍគួរចាប់ផ្តើមជាមួយកំណែទម្រង់ការអប់រំ ក្នុងគោលបំណងកែលម្អចរិតលក្ខណៈគ្រូបង្រៀន និងសាលារៀនព្រមទាំងចរិតលក្ខណៈគ្រួសារ និងក្មេង។

ក្នុងន័យនេះ គុណភាពអប់រំមិនត្រឹមតែការទទួលបានការអប់រំនោះទេ ប៉ុន្តែវាគួរតែជាបេះដូងនៃគោលនយោបាយអប់រំ។ ការអប់រំត្រូវតែផ្សារភ្ជាប់សិស្សទាំងជំនាញយល់ដឹងដោយញាណ និងមិនមែនញាណ ដូចនេះពួកគេនឹងអាចប្រឈមមុខនឹងអនាគតមិនច្បាស់លាស់ និងដោះស្រាយជាមួយនឹងបញ្ហាប្រឈមសកល។ កំណែទម្រង់ការអប់រំគួរតែអនុវត្តទាំងប្រទេសកំពុងអភិវឌ្ឍនិងប្រទេសអភិវឌ្ឍន៍ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការសិក្សាពេញមួយជីវិតដែលជាជំនាញសំខាន់ក្នុងសតវត្សទី២១។ ការធ្វើឱ្យប្រសើរជំនាញត្រិះរិះពិចារណា និងការដោះស្រាយបញ្ហារបស់សិស្សគឺមានសារៈសំខាន់ និងអាចឱ្យសិស្សទទួលយកកាន់តែប្រសើរនូវការផ្លាស់ប្តូរបច្ចេកវិទ្យា និងទីផ្សារពលកម្មយ៉ាងឆាប់

រហ័ស។ ឆ្លើយតបទៅនឹងបញ្ហាប្រឈមការអប់រំខាងលើក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្ដើមកម្មវិធីកំណែទម្រង់ការអប់រំមួយដោយអនុម័តការពិនិត្យពាក់កណ្ដាលគម្រោងនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ដោយព្យាករណ៍អាចប្រើដល់ឆ្នាំ២០២០ដែលគូសបញ្ជាក់ពីរបៀបវារៈអប់រំសតវត្សទី២១ (MoEYS, ២០១៦)។

សតវត្សទី២១ ក្លាយជាសក្ខីភាពនៃភាពប្រឈមជាច្រើនក្នុងពិភពលោកដែលមានចាប់ពីបម្រែបម្រួលអាកាសធាតុ ការធ្លាក់ចុះនៃសមាហរណកម្មសកល រហូតដល់អំពើភេរវកម្មសកល។ លើសពីនេះទៅទៀត ការចាប់ផ្ដើមមិនសូវល្អនៃបដិវត្តន៍ឧស្សាហកម្មលើកទី៤ បានធ្វើឱ្យមានការប្រកួតប្រជែងកាន់តែខ្លាំងក្លាបន្ថែមទៀតរវាងបណ្ដាប្រទេសក្នុងពិភពលោក។ ជំនាញចាស់ៗ នឹងត្រូវបំភ្លេចចោលយ៉ាងឆាប់រហ័ស។ ប្រជាជនវ័យក្មេងនឹងត្រូវបដិសេធនាពេលអនាគត ប្រសិនជាពួកគេមិនមានជំនាញត្រូវនឹងទីផ្សារការងារ។ កំណែទម្រង់ការអប់រំត្រូវបានចាត់ទុកជាអាទិភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់រៀបចំប្រជាជនវ័យក្មេង ឱ្យអាចប្រឈមដោយជោគជ័យនឹងភាពប្រឈមសកលនេះ។ ម្ចាស់ស្នាដៃអត្ថបទនេះយល់ឃើញថា កំណែទម្រង់ការអប់រំជាប្រព័ន្ធគួរតែរៀបចំសម្រាប់ប្រជាពលរដ្ឋ ដើម្បីប្រឈម និងដោះស្រាយបញ្ហាប្រឈមជាច្រើនរបស់មនុស្សជាតិ ដោយពង្រឹងគុណភាពប្រជាពលរដ្ឋ។ ឯកសារនេះ ស្រាវជ្រាវពីបដិវត្តន៍គំនិតស្ដីពីគុណភាពប្រជាពលរដ្ឋ និងកំនត់បង្ហាញពីទិដ្ឋភាពទាំង៤ នៃកំណែទម្រង់ការគ្រប់គ្រងអប់រំ (ការគ្រប់គ្រងធនធានមនុស្ស ហិរញ្ញវត្ថុ ការសិក្សា និងរដ្ឋបាល) ដែលជាលទ្ធផលក្នុងការពង្រឹងគុណភាពប្រជាពលរដ្ឋជាតិមួយឱ្យល្អ។ ឯកសារនេះឆ្លុះបញ្ចាំងឃើញថាតាមរយៈការអប់រំ ប្រជាពលរដ្ឋតម្រូវឱ្យមានចំណេះដឹង ជំនាញទុនទិងវិជ ការប្ដេជ្ញាចិត្តឆ្ពោះទៅរកយុត្តិធម៌សង្គម ការការពារបរិស្ថាន និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពព្រមទាំង ដើម្បីក្លាយជាប្រជាពលរដ្ឋសកលល្អមួយរូបគួរឱ្យគោរព និងឱ្យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តម្លៃពិតពិធភាព និងមានធន្ទះធ្វើឱ្យពិភពលោកក្លាយជាកន្លែងកាន់តែមាននិរន្តរភាព និងសមធម៌។

សៀវភៅនេះចែកចេញជា ៤ ជំពូក៖

ជំពូកទី១ ទស្សនវិជ្ជានៃការអប់រំ

ជំពូកទី២ ទ្រឹស្តីស្តីពីការអប់រំ

ជំពូកទី៣ ទ្រឹស្តីស្តីពីការគ្រប់គ្រងអប់រំ

ជំពូកទី៤ ទ្រឹស្តីស្តីពីកំណែទម្រង់ការអប់រំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ១
# ទស្សនវិជ្ជានៃការអប់រំ

## ទ្រឹស្តីស្តីពីការអប់រំ

តាំងពីយូរលង់ណាស់មកហើយ ការអប់រំត្រូវបានចាត់ទុកថា ជាការវិនិយោគដ៏សំខាន់បំផុតដើម្បីសម្រេចបានពិភពលោកមួយកាន់តែប្រសើរ។ ការអប់រំ គឺការកសាងសមត្ថភាពខាងរាងកាយ ចំណេះដឹង ប្រាជ្ញាស្មារតី បំណិន និងអត្តចរិតរបស់មនុស្ស។ ការអប់រំមិនមែនតែការសិក្សារៀនសូត្រនៅក្នុងសាលារៀនប៉ុណ្ណោះទេ តែក៏ជាការសិក្សាពេញមួយជីវិតនៅក្នុងស្ថាប័នសង្គមដែរ។ ការអប់រំមានគោលបំណងធ្វើឱ្យមនុស្សនិងសង្គមមនុស្សកាន់តែល្អទៅៗគ្មានទីបញ្ចប់។

សូក្រាត យល់ឃើញថាសេរីភាពបង្រៀន និងការសិក្សា គឺមានសារៈសំខាន់ដើម្បីឱ្យមនុស្សទទួលបានចំណេះដឹង និងធ្វើឱ្យសង្គមកាន់តែប្រសើរឡើង (Nelson, et al., ២០១២)។ ប្លាតុង គិតថា«សង្គមមួយត្រូវបានរៀបចំឱ្យមានស្ថិរភាព ពេលដែលបុគ្គលនីមួយៗកំពុងធ្វើនូវអ្វីដែលជាសមត្ថភាពពីធម្មជាតិដើម្បីប្រើជាផលប្រយោជន៍ដល់អ្នកដទៃ...ហើយការធ្វើដូចនេះ គឺជាដំណើរការនៃការអប់រំ។ តូម៉ាស អាគីណាស (Thomas Aquina) យល់ថា «គោលដៅនៃការអប់រំ គឺបង្រៀនមនុស្សនូវបញ្ហាសំខាន់ៗ តាមរយៈចំណេះដឹងនៃមុខវិជ្ជាផ្សេងៗ។ ការសិក្សា គឺការទទួលចំណេះដឹងវិទ្យាសាស្ត្រពីអ្នកផ្សេង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តួនាទីនៃការអប់រំ គឺការបណ្តុះបណ្តាលប្រជាជនឱ្យកាន់តែមានប្រយោជន៍សម្រាប់សង្គម។ ទស្សនវិទូជនជាតិបារាំងសតវត្សទី១៨ រ៉ូសូ (Jean-Jacques Rousseau) ជឿថាការអប់រំគួរផ្សារភ្ជាប់ជាមួយនឹងធម្មជាតិ ពោលគឺការអប់រំ គឺដើម្បីជានាថាសង្គមផ្តោតលើសង្គមកាន់តែខ្លាំង។ ទស្សនវិទូអាឡឺម៉ង់ កង់ (Immanuel Kant) ប្រកាន់ភ្ជាប់ជាមួយនឹងការយល់ឃើញថាការអប់រំ គឺសំខាន់សម្រាប់ការអភិវឌ្ឍមនុស្សជាតិ។ ក្នុងអត្ថបទបង្រៀនរបស់គាត់ «គរុកោសល្យ» Kant និយាយថា «ការអប់រំល្អគឺជាប្រភពនៃអ្វីៗទាំងអស់ដែលល្អក្នុងពិភពលោកនេះ» (Kanz, ១៩៩៩)។ Kant គិតថាការងារដ៏សំខាន់នៃការអប់រំរួមមាន (ក) ទម្លាប់នៃការគិត (ខ) ការបង្កើតទស្សនៈវិស័យរួមមួយ (គ) ការពង្រឹងអាកប្បកិរិយា និង (ឃ) ការផ្តល់ការយល់ដឹងពីក្រមសីលធម៌ត្រឹមត្រូវ ពោលគឺឥរិយាបថក្នុងការជ្រើសរើសគោលបំណងល្អ (Kanz, ១៩៩៩)។

យើងនឹងពិភាក្សានូវទ្រឹស្តីធំៗរបស់អ្នកអប់រំចាប់ពីសតវត្សទី ១៥ មកទល់បច្ចុប្បន្ននេះ។

## ១. Desiderius Erasmus (1469-1536)

Erasmus ប្រសូតនៅក្រុង Rotterdam អំឡុងឆ្នាំ១៤៦៩ និងបានលា ចាកលោកនៅក្រុង Bâle ឆ្នាំ១៥៣៦។ Erasmus បានប្រឆាំង និងប្រយុទ្ធតទល់នឹងលទ្ធិបង្រៀនបែបចាស់គំរិល ដើម្បីលុបបំបាត់គ្រឹះស្ថានសិក្សាដែលមានលក្ខណៈ «ព្រៃ» ដែលតំណាងឱ្យភាពល្ងង់ខ្លៅ ភាពព្រៃ និងទង្វើប្រចាំថ្ងៃជ្រុលហួសហេតុនៅក្នុងការអប់រំសិស្ស។ តួអង្គទាំងនោះរួមចំណែកក្នុងការធ្វើឱ្យកើតឡើងវិញនូវពលរដ្ឋថ្មីដែលសប្បាយរីករាយ ព្រោះពួកគេមានសេរីភាពក្នុងការក្លាយខ្លួនទៅជាអ្វីដែលគេចង់ក្លាយទៅជាពលរដ្ឋម្នាក់ ដែលអាចរុញច្រានព្រំដែនសកម្មភាព និងចំណេះដឹងរបស់ខ្លួនទៅមុខបន្ថែមទៀត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## មនុស្សថ្មីផ្នែកតាមទស្សនៈរបស់ RABELAIS និង ERASMUS

មនុស្សម្នាក់មិនមានព្រំដែនអ្វីផ្សេង លើសពីអ្វីដែលខ្លួនអាចផ្តល់ឱ្យខ្លួនឯងទេ។ មនុស្សម្នាក់ដែលកំណត់ជោគវាសនារបស់ខ្លួនដោយខ្លួនឯង។ មនុស្សនោះនឹងបង្កើតសេរីភាព ហើយក៏នឹងបង្កើតមូលដ្ឋានគ្រឹះនៃវប្បធម៌លោកិយ និងការអប់រំមួយដែលស្របទៅតាមអ្វីដែលគេគិតជាត្រឹមត្រូវ បើទោះបីជាគេស្មោះត្រង់នឹងគ្រិស្តសាសនាក៏ដោយ គឺដោយហេតុនេះ ហើយបានជាព្រះបង្កើតគេមក គឺដើម្បីឱ្យគេធ្វើអ្វីបានដោយខ្លួនឯង និងលើសពីអ្វីដែលកំណត់ដោយព្រះ។ ក្នុងពិភពលោកដែលបើកទូលាយមនុស្សនឹងមានសេរីភាពក្នុងសាសនា ក្នុងគំនិតវិទ្យាសាស្ត្រ និងបច្ចេកទេសក៏ដូចជាក្នុងអភិក្រមមនុស្សជាតិ។

មនុស្សចាត់ទុកខ្លួនឯងជាការៈដែលល្អជាងគេ និងជាអព្ភូតហេតុដ៏អស្ចារ្យរបស់ធម្មជាតិ។ ទស្សនៈនេះ គឺជាប្រើប្រាស់ឡើងវិញនូវទស្សនៈក្រិករ៉ូម៉ាំងដើម្បីយកនូវគោលគំនិតពាក់ព័ន្ធនឹងទម្រង់តុល្យភាព និងសុខដុមដែលលើកសរសើរលើកតម្កើងសម្រស់របស់មនុស្ស និងពិភពលោក។ តាមរយៈទស្សនៈក្រិក រ៉ូម៉ាំងដដែល គេបានរកឃើញជាថ្មី និងបានផ្តល់និយមន័យឡើងវិញចំពោះពាក្យថាសុកមង្គល៖ «គឺជាសភាព ដែលសម្រេចបានដោយជ្រាលជ្រៅ និងដោយភាពជាមនុស្សលោក ក្នុងសហគមន៍មនុស្សជាតិ និងក្នុងធម្មជាតិ»។

កម្មវិធីថ្មីសម្រាប់ការអប់រំនាពេលនោះមានការលាយគ្នារវាងការធ្វើលំហាត់រាងកាយ និងស្មារតី រវាងអ្វីដែលធ្លាប់បានរៀនពីពេលកន្លងមកជាមួយនឹងអ្នកប្រាជ្ញផ្នែកអក្សរសាស្ត្រ រវាងល្បែងសេរីនិងការប៉ះពាល់ដោយផ្ទាល់ជាមួយនឹងទស្សនីយភាពសំខាន់នានានៃធម្មជាតិ។ មិនមានព្រំដែនកំណត់នោះទេក្នុងការស្វែងរកដោយសប្បាយរីករាយនិងពេញចិត្តសម្រាប់បំពេញមនោរម្មណ៍។ ភាពពេញលេញដែលទទួលបានតាមរយៈចំណេះដឹងប្រកបដោយបញ្ញាញាណនេះកាត់ផ្តាច់ចេញពីប្រពៃណីនៃយុគសម័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កណ្តាល។ ភាពពេញលេញនេះផ្តោតទៅលើចំណេះដឹងផ្ទាល់របស់មនុស្ស បើទោះជាបានមកតែពីទ្រឹស្តី ឬក៏មានការផ្សារភ្ជាប់នឹងការសិក្សាពីធម្មជាតិក៏ដោយ។ ការស្វែងរកដោយស្រលាញ់ពេញចិត្តនូវសច្ចភាព ដូចជាមនុស្សនៅសម័យថ្មបំបែក នឹងនាំឆ្ពោះទៅរកសម្បជញ្ញៈនៃសេចក្តីល្អ។ ដើម្បីរៀនថាតើត្រូវធ្វើបែបណាដើម្បីរស់នៅជាមួយគ្នា ត្រូវរៀនក្នុងភាពនៃការគោរពគ្នាទៅវិញទៅមក។

## ២. Michel Eyquem De MONTAIGNE (1533-1592)

លោក Michel Eyquem de Montaigne ត្រូវបានចាត់ទុកជាអ្នកអភិរក្សការពារសាលារៀនប្រពៃណី។ របៀបបង្រៀនបែបថ្មីដែលរូបលោកប្រើប្រាស់ គឺសង្កត់ធ្ងន់ទៅលើលទ្ធិមនុស្សនិយមនៃសម័យកាលករកើតឡើងវិញនៃអរិយធម៌ (La renaissance)។ ស្នាដៃធំៗរបស់លោក ត្រូវបានចងក្រងជាកម្រងបទពិសោធន៍ «Les essais»។ ក្នុងជំពូកមួយក្រោមចំណងជើងជា «De l'institution des enfants » (ស្ថាប័នរបស់កុមារ) លោកបានសរសេរអំពីការអប់រំមនុស្សឱ្យថ្លៃថ្នូរ។ ជំពូកនេះរៀបរាប់ពីការធ្វើដូចម្តេចដើម្បីធ្វើឱ្យមនុស្សថ្លៃថ្នូរម្នាក់មានបញ្ញាញាណគ្រប់គ្រាន់ មានន័យថាមិនមែនគ្រាន់តែឱ្យគេមានខួរក្បាលមួយដែលមានត្រឹមតែចំណេះដឹងនោះទេ។ តាមរយៈសំណួរនេះ លោកទាញចេញជាទ្រឹស្តីមួយ៖ «ស៊ូមានក្បាលមួយដែលមានសតិគ្រប់គ្រាន់ ជាជាងក្បាលមួយដែលមានចំណេះដឹងពេញ»។

មានការរកឃើញចិត្តវិទ្យារបស់កុមារ តាមការរីកចម្រើនផ្នែកខួរក្បាលនិងរាងកាយទៅតាមដំណាក់កាលអាយុ។ មានការព្យាយាមក្នុងការសម្របសម្រួលការបង្រៀន ដោយផ្តោតការយកចិត្តទុកដាក់ទៅលើភាពសប្បាយរីករាយ និងភាពស្ងប់សុខរបស់សិស្ស។ តឹកតាងមួយដែលបរិយាយពីទ្រឹស្តីនេះគឺគេឃើញមានរូបភាពមនុស្សពាក់កណ្តាលពេញវ័យម្នាក់នៅលើរូបគំនូរបុរាណ ដែលស្លៀកពាក់ជាមនុស្សប្រុសពេញវ័យតែមានរូបរាងជាកុមារ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## មនុស្សថ្លៃថ្នូរតាមគោលគំនិតរបស់ Michel de Montaigne

តាមរយៈសម្រង់អត្ថបទដែលយកចេញច្រើនជាងគេពីជំពូកទី XXV ក្នុងសៀវភៅភាគ ១ ដែលមានចំណងជើងថា «De l'institution des enfants» យើងនឹងបរិយាយពីការរិះគន់ដែលធ្វើឡើងដោយ Montaigne លើការអប់រំក្នុងសម័យកាលរបស់គាត់ក៏ដូចជាគម្រោងការអប់រំរបស់គាត់។ គាត់ប្រឆាំងដាច់ណាត់ចំពោះហិង្សាដែលមាននៅក្នុងគ្រឹះស្ថានសិក្សា។ Montaigne បានបែកដាច់ស្រឡះរវាងការអប់រំដែលលើកតម្កើងដោយគ្រឹះស្ថានសិក្សា និងការអប់រំដែលមានលក្ខណៈជាមនុស្ស។ ក្នុងការប្រឆាំងចំពោះការរៀនដោយចងចាំ គាត់បានបែកដាច់រវាងការអប់រំតាមបែបសុភវិនិច្ឆ័យ និងការអប់រំតាមបែបអភិវឌ្ឍន៍សតិបញ្ញា។ ដោយមិនឱ្យសិស្សរៀនប្រវត្តិសាស្ត្រតាមបែបទន្ទេញចាំ គាត់បានដាក់ចេញនូវគរុកោសល្យសម្រាប់បង្រៀនប្រវត្តិសាស្ត្រដែលនាំសិស្សឱ្យរិះគន់ និងអនុវត្តបទពិសោធន៍ល្អៗនានាក្នុងសតវត្សរ៍ផ្សេងៗ នេះជាការរៀនតាមបែបរិះគន់ និងតាមបែបវិនិច្ឆ័យ។ សំណួរសំខាន់មួយរបស់គាត់ក្នុងការបង្រៀន គឺ៖ «តើខ្ញុំដឹងពីរឿងអ្វីខ្លះ?»

## តើគ្រូបង្រៀនជាអ្នកនាំផ្លូវសម្រាប់ធ្វើអ្វី?

«ខ្ញុំមិនចង់ឱ្យគាត់ប្រឌិត និងនិយាយតែម្នាក់ឯងនោះទេ។ ខ្ញុំចង់ឱ្យគាត់ស្ដាប់សិស្សរបស់គាត់ មិនចង់ឱ្យគាត់បញ្ជាទៅសិស្សរបស់គាត់រាប់ពាក្យក្នុងមេរៀន តែឱ្យសិស្សរបស់គាត់យល់ពីអត្ថន័យនៃមេរៀន និងដឹងថាតើមានខ្លឹមសារយ៉ាងណានៅក្នុងមេរៀន ចង់ឱ្យគាត់វិនិច្ឆ័យពីផលដែលគាត់ទទួលបានពីអ្វីដែលសិស្សគាត់បានរៀន តាមរយៈការវិនិច្ឆ័យរបស់សិស្ស គឺមិនមែនតាមរយៈការចងចាំរបស់សិស្សនោះទេ។»

ការអប់រំនឹងទទួលបានជោគជ័យប្រសិនណាគ្រូអាចនាំសិស្សឱ្យមានសមត្ថភាពក្នុងការបញ្ចេញគំនិតដែលគិតឃើញដោយពួកគេ។ គោលបំណងនៃការអប់រំគឺដើម្បីកសាងមនុស្សពិតប្រាកដមួយ មានន័យថា ថ្លៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថ្ងៃទាំងចិត្តគំនិតថៃថ្នូរទាំងរាងកាយ។

លោក Montaigne ស្វែងរកបំពេញបន្ថែមដល់ផ្នែកសីលធម៌មួយដែលមនុស្សគ្រប់គ្នាអាចឈោងចាប់បាន ដែលគេអាចឱ្យឈ្មោះថាវិទ្យាសាស្ត្រជីវិត។ ក្នុងន័យនេះ គាត់បានដាក់ចេញនូវគរុកោសល្យមួយដែលមានលក្ខណៈដោយផ្ទាល់ផង និងដោយពេញលេញផង។

គរុកោសល្យនេះមានគោលបំណងទីមួយគឺធ្វើយ៉ាងណាឱ្យសិស្សចង់រៀន«ឱ្យសិស្សសាកល្បងវិទ្យាសាស្ត្រនិងករណីកិច្ចតាមរយៈឆន្ទៈរបស់ខ្លួនដោយមិនបង្ខិតបង្ខំ និងដោយការពេញចិត្ត ព្រមទាំងចិញ្ចឹមចិត្តគំនិតនិងស្មារតីប្រកបដោយភាពទន់ភ្លន់ និងដោយសេរី ដោយមិនបង្ខិតបង្ខំ និងគ្មានគំនាបៗ»

គរុកោសល្យនេះរួមបញ្ចូលគ្នាដោយសុខដុមរវាងលំហាត់វិនិច្ឆ័យជាមួយនឹងការគិតពិចារណាដោយស្មោះត្រង់។ គរុកោសល្យនេះក៏រួមមានវិធីសាស្ត្រក្នុងការពង្រីកគំនិតតាមរយៈការអានសៀវភៅជំនួសឱ្យការរៀនច្រើនលើសលប់នៅសាលារៀន និងការហាត់ពត់រាងកាយតាមរយៈការងារដែលមានប្រយោជន៍សម្រាប់ធ្វើឱ្យរាងកាយរឹងមាំ។ មានការណែនាំឱ្យមានការធ្វើដំណើរឱ្យបានច្រើន ការទៅជួបជាមួយអ្នកដទៃដើម្បីស្គាល់គ្នាជាដើម។ ការអប់រំនេះមានលក្ខណៈបែបធម្មជាតិ ហើយមិនកម្រិតនៅត្រឹមការអប់រំដោយប្រើប្រាស់តែសៀវភៅសិក្សានោះទេ។

ក្នុងគ្រប់ចំណេះដឹងទាំងអស់ គឺទស្សនវិជ្ជាដែលបង្កើតចំណេះដឹងដ៏ឧត្តុងឧត្តមសម្រាប់មហាគរុកោសល្យនៃការអប់រំសីលធម៌មួយនេះ។ ទស្សនវិជ្ជាត្រូវតែបង្រៀននៅគ្រប់កម្រិតអាយុទាំងអស់។

## ៣. Johann Amos COMENIUS (1592-1670)

លោក Comenius ត្រូវបានស្គាល់ជាពិសេសក៏ព្រោះគាត់គឺជាអ្នកគរុកោសល្យម្នាក់ក្នុងចំណោមអ្នកគរុកោសល្យមួយចំនួនដែលល្បីល្បាញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្នុងសតវត្សរ៍ទី១៧។ «សិល្បៈពេញលេញនេះដែលទាមទារឱ្យបង្រៀនសព្វគ្រប់បែបយ៉ាងទៅដល់មនុស្សគ្រប់រូប»។ ពាក់ព័ន្ធនឹងការអប់រំ មានការកំណត់ពីគោលបំណងប្រជាធិបតេយ្យនៃការចូលរៀនរបស់មនុស្សគ្រប់រូប ដោយមិនគិតពីប្រភព ភេទ និងវប្បធម៌ ហើយចោទជាបញ្ហាមួយចំនួនដែលនៅបន្តកើតមានឡើងរហូតមកទល់បច្ចុប្បន្ន ដូចជាបញ្ហាពាក់ព័ន្ធនឹងការបង្រៀនចំណេះដឹងទូទៅធៀបនឹងឯកទេស លក្ខណៈវិនិច្ឆ័យ និងចំណេះដឹងមូលដ្ឋានជាដើម។ យុវជនទាំងអស់ត្រូវទទួលបាននូវការអប់រំតាមបែប «រហ័ស មេត្រីភាព និងដោយស៊ីជម្រៅ» ជាមួយនឹង «វិធីសាស្ត្រតែមួយដូចគ្នា បើទោះជាមានសម្បទាមកពីកំណើតខុសគ្នាយ៉ាងណាក្តី» សិល្បៈគរុកោសល្យមិនទាមទារអ្វីផ្សេងក្រៅពី «ការរៀបចំពេលវេលា មុខវិជ្ជា និងវិធីសាស្ត្រឱ្យមានសណ្តាប់ធ្នាប់» តែប៉ុណ្ណោះ។

ស្នាដៃល្បីមួយដែលមានចំណងជើងថា «Orbis Pictus» (សៀវភៅរូបភាព) ដែលតំណាងឱ្យពិភពលោកទាំងមូលតាមរយៈរូបភាព និងអត្ថបទត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងឈ្មោះរបស់ Comenius។ រូបភាពតំណាងបែបនេះបានធ្វើឱ្យទស្សនវិជ្ជារបស់ Comenius កាន់តែលេចធ្លោឡើង ហើយបានក្លាយទៅជាមូលដ្ឋានគ្រឹះនៃគរុកោសល្យរបស់គាត់ គឺជា Pansophie ឬជាគតិបណ្ឌិតនៃអ្វីៗគ្រប់យ៉ាង។

នៅចំណុចស្នូលនៃការអប់រំសាកលនេះមានសកម្មភាពមនុស្ស ក្នុងការធ្វើឱ្យពិភពលោកកាន់តែប្រសើរឡើង។ «យើងចង់ឱ្យមនុស្សទាំងអស់ក្លាយទៅជាមនុស្ស Pansophie [...] ឱ្យគ្រប់គ្នាឈានទៅចាប់យកបាននូវចំណេះដឹងគ្រប់សព្វបែបយ៉ាងទាំងអស់។ [...] ប្រសិនណាជាមនុស្សទាំងអស់ទទួលបាននូវការអប់រំមួយដែលមានលក្ខណៈស៊ីជម្រៅ ក៏ដូចជាអ្វីៗទាំងអស់នៅលើលោកបែបនេះ មនុស្សប្រាកដជានឹងក្លាយទៅជាអ្នកប្រាជ្ញ ហើយពិភពលោកនឹងមានរបៀបរៀបរយ ភ្លឺស្វាង និងសន្តិភាព»។ ទស្សនៈនៃវប្បធម៌ទូទៅរបស់មនុស្សជាតិ៖ បង្រៀនគ្រប់រឿងទាំងអស់ ហើយបង្រៀន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រប់គ្នាទាំងអស់ជាលក្ខណៈសាកល។ ទស្សនៈនេះទាមទារការបណ្ដុះបណ្ដាលមួយជាសាកលទូវញាណសក្តិរបស់មនុស្ស៖ ហេតុផល របៀបនិយាយ និងរបៀបប្រតិបត្តិ៖ ញាណសក្តិក្នុងការគិត ក្នុងការនិយាយ និងក្នុងការប្រតិបត្តិ។

## ៤. Jean-Baptiste de LA SALLE (1651-1719)

លទ្ធិ J.-B. de La Salle ត្រូវបានបរិយាយនៅក្នុងការអប់រំដែលផ្ដល់មធ្យោបាយ និងទ្រព្យសម្បត្តិផ្នែកស្មារតីចាំបាច់ ដើម្បីចូលរួមចំណែកក្នុងការកសាងពិភពលោកថ្មីដែលមានការគោរពគ្នាទៅវិញទៅមក និងសាមគ្គីភាពពេញលេញ។ គឺទាំងនេះហើយដែលហៅថា មនុស្សពេញលេញ។

មេរៀនលែងបង្រៀនជាលក្ខណៈបុគ្គលទៀតហើយ តែត្រូវបង្រៀននៅក្នុងថ្នាក់រៀន មានន័យថាសិស្សត្រូវរៀនអានជាភាសាបារាំង គឺលែងរៀនជាឡាតាំងដូច ពីមុនទៀតហើយ។ លើសពីនោះ J.-B. de La Salle បែងចែកសាលារៀនជាច្រើនថ្នាក់ខុសៗគ្នាទៅតាមកម្មវិធីបង្រៀន ក៏ដូចជាទៅតាមចំនួនសិស្ស និងចំណេះដឹងរបស់សិស្ស។ សាលារៀនមានបីកម្រិត៖ ថ្នាក់ដំបូង មធ្យម និងខ្ពស់។ វិធីសាស្ត្រនេះទាមទារឱ្យគ្រូបង្រៀនយកចិត្តទុកដាក់លើសិស្សម្នាក់ៗ ហើយផ្ដល់ឱកាសដល់សិស្សក្នុងការបន្សាំខ្លួនទៅក្នុងស្ថានភាពផ្សេងៗក្នុងថ្នាក់រៀន ដោយគោរពទៅតាមវឌ្ឍនភាពរបស់សិស្សម្នាក់ៗ។ បញ្ហាសម្រាប់គ្រូបង្រៀន គឺថាតើត្រូវធ្វើយ៉ាងណាដើម្បីឱ្យសិស្សទាំងអស់ដែលមានកម្រិតចំណេះដឹងស្មើគ្នារៀនជាមួយគ្នា។

តាមការយល់ឃើញរបស់ J.-B. de La Salle ការរៀនភាសាបារាំង និងប្រយោជន៍របស់វាក្នុងន័យគរុកោសល្យ គឺស្ថិតនៅលើសារៈសំខាន់របស់ភាសានេះក្នុងការប្រើប្រាស់ប្រចាំថ្ងៃ។ កុមារឮសូរភាសានេះក្នុងជីវិតប្រចាំថ្ងៃរបស់គេ។ តាមរបៀបនេះ កុមារអាចរៀនបានប្រសើរដោយប្រើប្រាស់ភាសាមួយដែលគេប្រើប្រាស់ប្រចាំថ្ងៃ នោះគឺភាសាដើមរបស់ពួកគេ។ ពួក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គេត្រូវប្រើពេលវេលាច្រើនលើសលប់ដើម្បីអាចរៀនជាភាសាឡាតាំងបើធៀបជាមួយនឹងភាសាបារាំង។ គ្រូបង្រៀនត្រូវស្គាល់សិស្សរបស់ខ្លួនម្នាក់ៗ និងគ្រួសាររបស់ពួកគេឱ្យបានច្រើនបំផុតដើម្បីមានលទ្ធភាពក្នុងការជួយពួកគេប្រកបដោយប្រសិទ្ធភាព។

## ៥. Jean-Jacques ROUSSEAU (1712-1778)

**ការវិភាគពីច្បាប់ និងសង្គមដោយ Rousseau**

***ទី ១ គឺជាភាសាពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ និងសិល្បៈ៖*** ដែលបរិយាយពីអត្ថប្រយោជន៍រវាងសីលធម៌ និងវិទ្យាសាស្ត្រ។ សំណួរ ដែលចោទសួរគឺដើម្បីដឹងថា៖«តើការកសាងវិទ្យាសាស្ត្រ និងសិល្បៈឡើងវិញបានចូលរួមចំណែកក្នុងការបន្សុទ្ធទំនៀមទម្លាប់ដែរឬយ៉ាងណា?»។ Rousseau ផ្តល់ចម្លើយអវិជ្ជមានចំពោះសំណួរនេះ។ លោកបានវាយប្រហារ គំនិតដែលលើកឡើងដោយពួកអ្នកនិពន្ធកាល Lumières ដែលគិតថា វិទ្យាសាស្ត្រនឹងនាំមកនូវការកែលម្អផ្នែកសីលធម៌ដល់មនុស្សជាតិ។

***ទី២ គឺជាភាសាបរិយាយពីប្រភពកំណើត និងមូលដ្ឋានគ្រឹះនៃអសមភាព៖*** លោកបានបង្ហាញទ្រឹស្តីស្តីពីប្រភពកំណើតនៃមនុស្សស្តីពីជីវិតក្នុងសង្គម និងអត្ថប្រយោជន៍ដែលសង្គមបានបង្កើតឱ្យមាន។ តាមគំនិតរបស់លោកមនុស្សលោកខុសពីសត្វ ដោយផ្អែកលើចំណុចសំខាន់ពីរ៖ សេរីភាព និងភាពល្អឥតខ្ចោះ។ មនុស្សលោកមានសមត្ថភាពក្នុងការកែលម្អខ្លួនឯង (ក្នុងន័យសីលធម៌) តែមនុស្សលោកក៏អាចបរាជ័យដែរ ព្រោះមនុស្សលោកមានសេរីភាព ឬក៏ព្រោះតែមនុស្សលោកប្រើសេរីភាពខ្លួនឯងនេះជ្រុល។

**ទ្រឹស្តីអប់រំ**

ក្នុង «Émile ou de l'éducation, (1762)» (Emile ឬការអប់រំ) ដែលជាស្នាដៃចម្បងស្តីពីគរុកោសល្យ លោក Rousseau ចាត់ទុកការអប់រំក្នុងន័យទូលាយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាមទស្សនៈរបស់ Rousseau អ្វីគ្រប់យ៉ាងពឹងផ្អែកទៅលើការអប់រំ ជាពិសេសទៅលើការអប់រំ «តាមបែបធម្មជាតិ»។ Rousseau បែងចែកអ្នកអប់រំជាបី៖ ធម្មជាតិ (នៃមនុស្សជាតិ) មនុស្ស និងវត្ថុ។ ធម្មជាតិ «អភិវឌ្ឍសមត្ថភាព និងកម្លាំងរបស់យើង» (=ការអភិវឌ្ឍ) មនុស្សជាតិ «បង្រៀនយើងពីការប្រើប្រាស់សមត្ថភាព និងកម្លាំងទាំងនោះ» (ការបង្រៀន) និងវត្ថុ «បង្រៀនយើងតាមរយៈបទពិសោធន៍ដែលយើងធ្លងកាត់ និងតាមរយៈការបង្ហាញ» (=បទពិសោធន៍ និងចំនួននៃការអនុវត្ត)។ ដើម្បីកុំឱ្យមនុស្សក្លាយទៅជាផលិតផលសុទ្ធសាធនៃទេសកាល Rousseau ព្យាយាមក្នុងការសម្របសម្រួលវិចទ័រអប់រំទាំងបី៖ មនុស្ស វត្ថុ និងធម្មជាតិ។

ដើម្បីអប់រំ គឺគ្រាន់តែឱ្យធម្មជាតិរបស់កុមារផ្តល់តម្លៃដល់សិទ្ធិរបស់គេ។ ធម្មជាតិរួមមាន៖ (១) សេរីភាព និង (២) ភាពល្អឥតខ្ចោះរបស់មនុស្ស។ អ្នកអប់រំដែលមិនគោរពសេរីភាព និងភាពល្អឥតខ្ចោះរបស់មនុស្សនឹងបង្កើតហិង្សាចំពោះធម្មជាតិ។ មាក់ងាយដល់ធម្មជាតិមានន័យថាបោះបង់តម្លៃខ្លួនឯង។ មានតែ «មនុស្សមានសេរីភាព» ទេដែលអាចក្លាយជា «មនុស្សជាតិ» បាន។ ការគោរពធម្មជាតិមនុស្ស គឺជាការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្សដែលកំពុងលូតលាស់ធំធាត់។

Rousseau គិតថាមនុស្សជាតិល្អបរិសុទ្ធពីធម្មជាតិ ហើយថាមនុស្សម្នាក់ៗចង់រីករាយក្នុងជីវិតរបស់ខ្លួន។ ដោយហេតុនេះហើយបានជាមានទំនាក់ទំនងដោយផ្ទាល់រវាងសុភមង្គល និងសីលធម៌។ Rousseau គិតថាការអភិវឌ្ឍអត្តចរិត ផ្នែកសីលធម៌ត្រូវផ្សារភ្ជាប់ទៅនឹងភាពជោគជ័យនៃការអប់រំ។ ការអប់រំនេះមិនត្រូវជាបទដ្ឋាន ហើយក៏មិនត្រូវជាការគាបសង្កត់។ ការអប់រំត្រូវគោរពសេរីភាពនិងភាពថ្លៃថ្នូររបស់កុមារ និងក្មេងជំទង់។

Rousseau បែងចែកការអប់រំជាពីរដំណាក់កាលធំៗគឺ៖ ការអប់រំអវិជ្ជមាន អំឡុងពេលកុមារភាព និងការអប់រំវិជ្ជមានអំឡុងពេលជំទង់ភាព។ លោកបានផ្តល់និយមន័យការអប់រំអវិជ្ជមានថា ជាការអប់រំទៅលើហេតុ

ផល។ គោលបំណងធំនៃកិច្ចអន្តរាគមន៍អប់រំនានាអំឡុងពេលកុមារភាព គឺផ្តល់ឱកាសដល់ការអភិវឌ្ឍសញ្ញាណហេតុផល។

អំឡុងពេលកុមារភាព អ្នកអប់រំត្រូវធ្វើយ៉ាងណាឱ្យកុមាររៀនដោយធ្វើការពិសោធដោយខ្លួនឯង និងដោយឱ្យកុមារស្វែងយល់ពីពិភពលោកដែលនៅជុំវិញខ្លួនគេ។ ឥទ្ធិពលជាវិជ្ជមាន និងមានន័យអាចបរិយាយតែនៅពេលណាកុមារ(អ្នកសិក្សា) អាចទទួលយកឥទ្ធិពលនោះ ទៅប្រើប្រាស់ដោយហេតុផលផ្ទាល់ខ្លួន។

លោក Rousseau ប្រឆាំងនឹងការបង្កើតឱ្យមានសម្ពាធទៅលើកុមារ ឬក៏ការបង្ខំឱ្យកុមារធ្វើអ្វីមួយ។ ក្នុងគោលបំណងការពារធម្មជាតិ និងសេរីភាពមនុស្ស Rousseau ទទួលយកទម្រង់តែមួយគត់ពាក់ព័ន្ធនឹងការត្រួតត្រាមនុស្សនោះ គឺមនុស្សជាម្ចាស់លើខ្លួនឯង។ ទោះជាបែបនេះក្តី កុមារមិនទាន់ដឹងក្តីដើម្បីអាចធ្វើជាម្ចាស់លើខ្លួនឯងតាមរយៈការគិត និងចេតនានោះទេ។

ការអភិវឌ្ឍវិចារណញ្ញាណធ្វើឡើងនៅអំឡុងកុមារភាព ដោយចេញពីដំណាក់កាលកំណត់ជាក់លាក់នានា ពីវិចារណញ្ញាណផ្សារភ្ជាប់នឹងវិញ្ញាណអារម្មណ៍ទៅនឹងវិចារណញ្ញាណអរូបិយ។ ពេលណាដែលវិចារណញ្ញាណអរូបិយត្រូវបានអភិវឌ្ឍទៅលើក្មេងជំទង់ហើយនោះ ពេលនោះហើយដែលគេអាចចាប់ផ្តើមការអប់រំវិជ្ជមាន នេះបើតាមទស្សនរបស់ Rousseau។

លក្ខខណ្ឌជោគជ័យរបស់ការអប់រំគឺការគោរពភាពថ្លៃថ្នូរបស់មនុស្ស ហើយប្រការនេះគឺត្រូវធ្វើតាំងពីការចាប់ផ្តើមនៃជីវិត។ ទ្រឹស្តីនៃការអប់រំរបស់ Rousseau ស្វែងរកមធ្យោបាយក្នុងការចៀសវាងបង្កើតឱ្យមានហិង្សាចំពោះធម្មជាតិមនុស្ស។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៦. Wilhelm von HUMBOLDT (1767- 1835) ទ្រឹស្តីនៃការអប់រំ និងការបណ្តុះបណ្តាល

ទ្រឹស្តី Bildung («ការអប់រំ» «ការបណ្តុះបណ្តាល»)៖ បើតាម Bildung មនុស្ស ពេលគ្មានគោលបំណងប្រកបដោយទិសដៅជាក់លាក់ទេ គិតចង់តែពង្រឹង និងតម្កើងអំណាចខ្លួនឯងប៉ុណ្ណោះ។ ទីតិវិធីនៃការ «បណ្តុះបណ្តាល» អាចចាត់ទុកដូចជាការកែលម្អ និងការធ្វើឱ្យមានភាពចាស់ទុំ «នៃកម្លាំងធម្មជាតិ» ដែលមានដូចជាកាយសម្បទា បញ្ញា និងចិត្តដែលមនុស្សបានទទួល។«មនុស្សត្រូវការពិភពមួយដែលជាអ្វីនៅក្រៅខ្លួន» គឺជាអ្វីដែលយើងឱ្យឈ្មោះថា Bildung ឬទីតិវិធីនៃការបណ្តុះបណ្តាល (មនុស្សគ្រប់ជ្រុងជ្រោយ)។

មនុស្សជាចំណុចប្រសព្វនៃកិច្ចការទាំងអស់ និងពិភពលោកនេះ ដែលសម្រេចទៅតាមបីដំណាក់កាល ហើយក្នុងនោះ «មនុស្សប្រែក្លាយខ្លួនឯងទៅជាវត្ថុដែលជារបស់ក្រៅខ្លួន»។ មនុស្សមានអន្តរកម្មជាមួយទីង «សភាវៈក្រៅខ្លួន» មានន័យថា ពិភពខាងក្រៅ។ មនុស្សអាចប្រមូលផ្តុំកម្លាំងល្អិកណាតែបានបញ្ជ្រាបខ្លួនទៅក្នុងពិភពលោក តាមលទ្ធភាពដែលខ្លួនអាចធ្វើបានដោយខ្លួនឯង។ ជាកិច្ចតបស្នង មនុស្សទទួលបានមកវិញនូវសមត្ថភាពក្នុងការរៀបចំ «ពិភព» របស់ខ្លួន៖ «[...] តែក្នុងចេតនានេះ មនុស្សត្រូវបង្ខិតខ្លួនឱ្យកៀកនឹងវត្ថុនានាឱ្យបានច្រើន ផ្តិតផ្តាមទៅលើវត្ថុទាំងនោះនូវទម្រង់ស្មារតីរបស់ខ្លួន និងដាក់ចិត្តដាក់កាយឱ្យមានលក្ខណៈស្រដៀងគ្នា [...]»។

តាមរយៈការប្រៀបធៀបបន្តិចម្តងៗរវាងពិភពអតីតកាល និងអនាគតកាល មនុស្សយល់ច្បាស់ពីគ្រប់រូបភាព និងទម្រង់របស់មនុស្សជាតិ ក៏ដូចជាចំណែករបស់ខ្លួននៃភាពជាមនុស្សជាតិ។ កាលណាមនុស្សដឹងខ្លួនច្បាស់នូវភាពជាមនុស្សជាតិថាកសាងឡើងតាមរបៀបនេះ គតិបណ្ឌិត និងគុណធម៌នឹងមានឥទ្ធិពលទៅលើមនុស្សនោះ នេះជាគំនិតរបស់ Humboldt-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Bildung។ អំឡុងពេលស្វែងយល់ពិភពលោក មនុស្សអាចនឹងនៅជាប់គាំង នៅកណ្តាលផ្លូវ ហើយគេអាចជម្នះឧបសគ្គបានតែនៅជំហានទី ១ និងទី ២ តែប៉ុណ្ណោះក្នុងចំណោម ៣ ជំហានដែលត្រូវដើរ៖ មានន័យថាមនុស្សអាចកសាងចំណេះដឹងរបស់ខ្លួនបានច្រើន តែគឺមិនអាចទៅដល់ភាពឥតខ្ចោះនៃ bildung បាននោះទេ។

Humboldt គិតថាមនុស្សម្នាក់ៗមានសិទ្ធិក្នុងការទទួលបានការបណ្តុះបណ្តាលទូទៅរីងមាំមួយ។ គឺនៅសាកលវិទ្យាល័យដែលគេអាចទទួលបានការបណ្តុះបណ្តាលទូទៅដែលចាំបាច់មុននឹងបង្វឹកខ្លួនទៅជាអ្នកឯកទេស។ សាកលវិទ្យាល័យត្រូវជាទីកន្លែងនៃការស្វែងរកដោយសេរី។ គំនិតនេះបានបង្កើតនិយ័តភាពដល់ប្រព័ន្ធសាកលវិទ្យាល័យអាល្លឺម៉ង់រយៈពេល ២ សតវត្សរ៍។ ក្នុងគំនិតរបស់ Humboldt គ្រឹះស្ថានដែលអាចចាត់ទុកជាសាកលវិទ្យាល័យបានលុះណាតែគ្រឹះស្ថាននោះផ្តល់ការអប់រំស្តីពីវិទ្យាសាស្ត្រអប់រំផ្លូវចិត្ត អាចនិយាយបានថាបើមិនមានវិទ្យាសាស្ត្រអប់រំផ្លូវចិត្តនោះ គឺមិនមានសាកលវិទ្យាល័យឡើយ។

ដើម្បីឆ្លើយតបទៅនឹងគំនិតរបស់ Humboldt គេត្រូវរៀបចំការអប់រំជាបីដំណាក់កាល៖ (១) ការអប់រំបឋមសិក្សា (២) ការអប់រំមធ្យមសិក្សា (ការអប់រំកាយ អនុវិទ្យាល័យ វិទ្យាល័យ) និង (៣) ឧត្តមសិក្សា។ ប្រព័ន្ធអប់រំនេះផ្តោតទៅលើការបណ្តុះបណ្តាលទូទៅដល់មនុស្ស។ គឺនៅកម្រិតអប់រំបឋមសិក្សាដែលមានការបង្រៀនសញ្ញាណនៃចំណេះដឹងបឋម (អំណាន សំណេរ លេខសាស្ត្រ)។ ដោយឈរលើគោលការណ៍នេះ ការអប់រំ បឋមសិក្សាមានតួនាទីជាចាំបាច់ជាថ្នាក់ត្រៀម។ ដំណាក់កាលទី១នេះ គឺជាផ្នែកមួយនៃគម្រោងបណ្តុះបណ្តាលទូទៅពេញលក្ខណៈសម្រាប់មនុស្ស មុននឹងឈានដល់ដំណាក់កាលបន្តបន្ទាប់ទៀត ។

ការអប់រំអាចធ្វើបន្តសម្រាប់សិស្សតែមួយផ្នែកប៉ុណ្ណោះ។ គោលបំណងនៃការអប់រំនាដំណាក់កាលបន្ទាប់នេះ គឺដើម្បីត្រៀមសម្រាប់ឧត្តម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិក្សា។ ពេលដែលការអប់រំវប្បធម៌ និងការ បណ្តុះបណ្តាលទូទៅត្រូវបានបញ្ចប់ អាចនឹងមានការបន្តយកមុខជំនាញឯកទេស។ គឺនៅពេលនោះហើយដែលមានការផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើចំណង់ចំណូលចិត្ត និងទៅលើផ្នែកខ្លាំងពូកែរបស់សិស្ស នៅពេលដែលពួកគេចាប់ផ្តើមរើសវិជ្ជាជីវៈទៅអនាគត។ ការបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវនៅក្រោយការបណ្តុះបណ្តាលទូទៅ។ ការបញ្ចូលការបណ្តុះបណ្តាលវិជ្ជាជីវៈទៅក្នុងការបណ្តុះបណ្តាលទូទៅ ចំពោះ Humboldt គឺស្មើនឹងការបំបាត់ខ្លឹមសារចាំបាច់នៃការបណ្តុះបណ្តាលវប្បធម៌ទូទៅ។

មានទំនាក់ទំនងខាងក្នុងរវាងដំណាក់កាលទាំងបីនៃការអប់រំៈ តួនាទីរបស់គ្រូបង្រៀនថមថយបន្តិចម្តងៗ គ្រូបង្រៀនក្លាយទៅជាគ្មានប្រយោជន៍បន្តិចម្តងៗ ហើយនៅចុងបញ្ចប់ តួនាទីត្រូវបានផ្លាស់ប្តូរតែម្តង មានន័យថាសិស្សក្លាយទៅជាគ្រូលើខ្លួនឯង...។ ការអប់រំនៅឧត្តមសិក្សា តាមទស្សនៈរបស់ Humboldt គឺជាកន្លែងសម្រាប់ប្រកួតប្រជែងខាងផ្នែកវិទ្យាសាស្ត្រ។ លើសពីនោះទៅទៀត វិស័យវិទ្យាសាស្ត្រនេះនេះមិនមានព្រំដែន និងមិនមានទីបញ្ចប់។ ការប្រកួតប្រជែងជាមួយវិទ្យាសាស្ត្រគឺជានីតិវិធីបើកទូលាយ។

## ៧. Friedrich SCHLEIERMACHER (1768-1834)

### «ការបង្រៀនបែបឧទ្ទេស» នៃគរុកោសល្យនៅឆ្នាំ ១៨២៦

សកម្មភាពគរុកោសល្យបម្រើដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស ដោយវាជាសកម្មភាពមួយដែលមានគោលបំណងអភិវឌ្ឍបុគ្គលមនុស្សម្នាក់ៗ បើទោះបីជាបុគ្គលនោះនៅដាច់ឆ្ងាយពីគេ ឬក៏នៅដាច់ឆ្ងាយពីមនុស្សជាតិក៏ដោយ។ ការអប់រំមនុស្សជាតិទាំងមូល ដើម្បីឱ្យគេក្លាយទៅជាធនធានរបស់សង្គម និងមនុស្សជាតិ គឺជាគោលបំណងគរុកោសល្យ។ Schleiermacher ផ្តល់និយមន័យដល់ពាក្យគរុកោសល្យថាជា «វិទ្យាសាស្ត្រអនុវត្តមួយដែលផ្អែកតែទៅលើសីលធម៌មួយមុខគត់ ហើយដែលក្លាយ

ចេញពីសីលធម៌នេះតែម្តង»។ ឃ្លានេះមិនមានន័យពីរនោះទេ។ Schleier-macher មិនប្រកាន់យក «គរុកោសល្យបែបបទដ្ឋាន» នោះទេ។ លោកសង្កត់ធ្ងន់ជាការតម្រង់ទិសមូលដ្ឋាននៃសកម្មភាពគរុកោសល្យត្រូវតែជា «គំនិតល្អបរិសុទ្ធ»។ ជាទូទៅ គោលដៅរបស់ការអប់រំគឺរៀបចំជំនាន់បន្ទាប់ មិនត្រឹមតែសម្រាប់ការរស់នៅក្នុងសង្គមនោះទេ តែត្រូវរៀបចំពួកគេឱ្យមានលទ្ធភាពក្នុងការចូលរួមយ៉ាងសកម្មក្នុងការកែលម្អស្ថានភាពសង្គម។

## ទស្សនៈស្តីពីគរុកោសល្យ និងការអប់រំ

សំណួរដ៏ល្បីរបស់ «សូក្រាត» លោទស្សួរដោយ Schleiermacher នៅពេលចាប់ផ្តើមមេរៀនគរុកោសល្យរបស់គាត់គឺ៖ «តើអ្នកជំនាន់ចាស់ចង់បានអ្វីពីអ្នកជំនាន់ថ្មី?»។ នេះមានន័យថាត្រូវមានការសិក្សាទៅលើទំនាក់ទំនងជាមួយនឹងជំនាន់បន្ទាប់។ លក្ខខណ្ឌសង្គមមួយដែលមានការប្រែប្រួលជាប្រវត្តិសាស្ត្រទាមទារឱ្យមានការបញ្ចូលអ្នកជំនាន់ថ្មី ដែលនឹងស្នងខ្លួនក្នុងសង្គមដែលមានស្រាប់ តែក៏មិនកំណត់នៅត្រឹមមុខងារនឹងតួនាទីរបស់មនុស្សសម្រាប់តែសង្គមនោះឡើយ។

តាមគំនិតរបស់ Schleiermacher ការអប់រំមិនត្រូវនៅត្រឹមតែធ្វើឱ្យយុវជនមានសមត្ថភាពក្នុងការរស់នៅក្នុងសង្គមនោះទេ តែត្រូវឱ្យពួកគេចូលរួមក្នុងការរៀបចំ និងកែលម្អសង្គមជាថ្មី។ សមាសភាពទាំងពីរនេះគឺជាសមាសភាពចាំបាច់នៃគរុកោសល្យ សម្រាប់អប់រំបុគ្គលិកលក្ខណៈរបស់មនុស្ស។ Schleiermacher ជាអ្នកប្រាកដនិយម តាមរយៈទស្សនៈរបស់លោកដែលលើកឡើងថាមនុស្សម្នាក់មិនអាចទៅដល់គោលដៅដោយគ្មានមនុស្សម្នាក់ទៀតបាននោះទេ។ គឺមានតែនៅពេលដែលមនុស្សម្នាក់បំពេញគ្រប់លក្ខខណ្ឌដើម្បីរស់នៅក្នុងសង្គមបាននោះទេ ដែលគេអាចលះបង់កម្លាំងកាយចិត្តរបស់គេដើម្បីកែលម្អសង្គមនោះបាន។ មនុស្សណាដែលគ្រាន់តែចង់រស់នៅក្នុងសង្គម (គ្រាន់តែចង់រស់នៅក្នុងសង្គមទៅតាមអ្វីដែលខ្លួនអាច



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ធ្វើបាន) នឹងមិនអាចកែលម្អសង្គមនោះបានឡើយ។

## ទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្ត

Schleiermacher ផ្តល់អាទិភាពដល់ការអនុវត្តទៅតាមទ្រឹស្តី។ តាមរយៈការអនុវត្តតែប៉ុណ្ណោះដែលធ្វើឱ្យមានការផ្លាស់ប្តូរ និងការកែលម្អ។ ក្នុងបរិបទនេះ Schleiermacher និយាយពីភាពថ្លៃថ្នូរនៃការអនុវត្ត។ ឃ្លាល្បីល្បាញមួយក្នុងការបង្រៀនរបស់គាត់គឺ៖ «គុណតម្លៃនៃការអនុវត្ត គឺមិនពឹងផ្អែកតែទៅលើទ្រឹស្តីនោះទេ ផ្ទុយទៅវិញ ការអនុវត្តជាមួយនឹងទ្រឹស្តី វានឹងធ្វើឱ្យការអនុវត្តនោះកាន់តែមានការទទួលខុសត្រូវ»។ ទ្រឹស្តីមានតួនាទីក្នុងការយល់ពីការអនុវត្ត ផ្តល់នូវការតម្រង់ទិសចំពោះសកម្មភាព តែមិនមែនផ្តល់ការណែនាំដោយផ្ទាល់ចំពោះការអនុវត្តនោះទេ។

មានការប្រទាញប្រទង់រវាងសច្ចភាពនៃលក្ខខណ្ឌសង្គមក្នុងសកម្មភាពបង្រៀន និងទ្រឹស្តីនៃការអប់រំ នៅក្នុងទស្សនៈរបស់លោក Schleiermacher។ ជារៀងរាល់ថ្ងៃ អ្នកអប់រំ និងគ្រូបង្រៀនដែលនៅជាប់ជាមួយនឹងការអនុវត្ត ត្រូវទទួលការណែនាំពីសកម្មភាពជាក់ស្តែង បច្ចេកទេសនានាដែលអាចនាំពួកគាត់ទៅរកអ្វីដែលគេហៅថា «បង្រៀនបានល្អ»។ វិទ្យាសាស្ត្រគរុកោសល្យត្រូវសិក្សាផង និងបង្កើតច្បាប់អប់រំផងដើម្បីឱ្យអ្នកប្រតិបត្តិវិជ្ជាជីវៈនេះអាចអនុវត្តបាន។

## ទ្រឹស្តីគរុកោសល្យមានបញ្ហាប្រឈមចំនួនពីរ ៖

(១) បញ្ហាប្រឈមទីមួយ គឺស្ថានភាពគរុកោសល្យដែលមានលក្ខណៈចម្រុះច្រើនបែបច្រើនសណ្ឋានជាប្រចាំ។ ស្ថានភាពនីមួយៗខុសៗគ្នា ពីសិស្សម្នាក់ទៅម្នាក់ ពីថ្នាក់មួយទៅថ្នាក់មួយទៀត ពីគ្រួសារមួយទៅគ្រួសារមួយដូចគ្នានេះដែរ លក្ខខណ្ឌនៃការអប់រំក៏ខុសគ្នាពីមួយទៅមួយផងដែរ។ សម្រាប់លោក Schleiermacher ទាំងនេះមានន័យថាចាំបាច់ក្នុងការបង្កើនកម្រិតគិត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពិចារណាលើការអប់រំក្នុងកម្រិតខ្ពស់នៃអរូបិយ។ អ្នកអប់រំ ឬគ្រូបង្រៀនត្រូវមានសមត្ថភាពក្នុងការចាប់យកនូវការសម្រេចចិត្តប្រសើរបំផុតមួយដោយស្រូបទាញពីក្នុងចំណោះដឹងផ្នែកទ្រឹស្តីដ៏ធំទូលំទូលាយរួចរៀបចំកិច្ចប្រតិបត្តិសកម្មភាពឱ្យសមស្រប។

(២) តាមទស្សនវិជ្ជាជាក់ស្តែងរបស់ Kant បច្ចេកវិទ្យាអប់រំជួបប្រទះទៅនឹង «ឧបសគ្គ» ទី២ នៅពេលដែលមនុស្សលោកក្លាយទៅជាសការៈស្វ័យតដែលអភិវឌ្ឍ និងប្រែក្លាយខ្លួនឯងទៅតាមគោលបំណងផ្ទាល់ខ្លួន។

ទ្រឹស្តីអប់រំបានកំណត់នូវលក្ខខណ្ឌនានាដែលអ្នកអប់រំត្រូវយកចិត្តទុកដាក់ ប្រសិនបើគេចង់អប់រំពិតប្រាកដមែន។ គ្រូបង្រៀនត្រូវគោរពគោលការណ៍ដែលថាសិស្សរបស់ខ្លួន គឺជាបុគ្គលស្វ័យត។ គ្រូបង្រៀនត្រូវធ្វើយ៉ាងណាឱ្យសិស្សមានសេរីភាព ឬក៏ធ្វើឱ្យសិស្សចាប់យកបាននូវសេរីភាពនេះតាមរយៈគ្រូខ្លួនឯង។ ក្នុងន័យនេះ គេអាចនិយាយបានថាបញ្ញត្តិនៃការអប់រំគឺដឹកនាំគរុកោសល្យសម្រាប់ការអនុវត្ត គរុកោសល្យមានន័យថាមិនមែនជាបច្ចេកវិទ្យានៃការអប់រំនោះទេ តែជាការគិតពិចារណាលើការអប់រំវិញ។

## គោលការណ៍ចម្បងចំនួនបួននៃសកម្មភាពគរុកោសល្យ

Schleiermacher គាត់តែងសុភាសិតមួយចំនួនពាក់ព័ន្ធនឹងសកម្មភាពគរុកោសល្យដែលចេញពី «គំនិតល្អបរិសុទ្ធ» ក៏ដូចជាវិចារវិទ្យានៃ «ការសម្របសម្រួល» ព្រមទាំង «ការប្រែក្លាយសង្គម»។ គឺជាសុភាសិតមួយផ្តោតលើៈ ការពារ និងបណ្តោយឱ្យធ្វើ តាមទស្សនៈរបស់អ្នកអប់រំ គឺជាសុភាសិតដែលផ្តោតលើប្រតិកម្ម និងការគាំទ្រ។

គោលការណ៍ទីមួយនៃការអប់រំ គឺគោលការណ៍គាំទ្រៈ គឺជាអ្វីដែលការអប់រំត្រូវផ្តល់អាទិភាព គឺជាអ្វីដែលស្របទៅនឹងគោល«គំនិតល្អបរិសុទ្ធ»។ រាល់អ្វីៗដែលស្របជាមួយនឹងគំនិតល្អបរិសុទ្ធរបស់ក្មេងជំទង់ គឺជាអ្វីដែលត្រូវគាំទ្រ។ ដើម្បីគេចចេញពីឥទ្ធិពលខាងក្រៅ (ឥទ្ធិពលសង្គមក្នុងន័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទូលាយ) លោកបានផ្ដល់សារៈសំខាន់ដាច់ដោយឡែកចំពោះគោលការណ៍នៃការការពារក្នុងដំណាក់កាលដំបូងនៃជីវិត។ ប៉ុន្តែដោយព្រួយបារម្ភពីបុគ្គលិកលក្ខណៈសេរីផង ស្វ័យតផង និងសកម្មផងក្នុងសង្គម លោកបានឯកភាពក្នុងការបណ្ដោយឱ្យធ្វើ និងចុងក្រោយគឺមិនបណ្ដោយខ្លួនឱ្យរងនូវរាល់ឥទ្ធិពលគរុកោសល្យនោះទេ។

ការបណ្ដោយឱ្យធ្វើ ដែលជាការរំដោះខ្លួនចេញបន្តិចម្ដងៗពីឥទ្ធិពលនៃការអប់រំមិនត្រូវបំផ្លាញកិច្ចព្រមព្រៀងជាមួយនឹង «គំនិតល្អបរិសុទ្ធ» នោះទេ។ តែប្រសិនបើជីវិតក្មេងជំទង់មានជម្លោះជាមួយនឹងគោល «គំនិតល្អបរិសុទ្ធ» នោះចាំបាច់ត្រូវមានកិច្ចអន្តរាគមន៍គោលការណ៍ប្រតិកម្ម។ ប្រការនេះអាចកើតមានឡើង ល្គិកណាក្មេងជំទង់ត្រូវបានដាក់ឱ្យនៅក្រោមឥទ្ធិពលអាក្រក់ ឧទាហរណ៍ដូចជាការប្រើប្រាស់គ្រឿងញៀណជាដើម។

ក្នុងន័យនេះ គោលការណ៍សកម្មភាពក្លាយទៅជាចំណោទបញ្ហាចំនួនពីរ។ លោកបានទាញចេញជាសេចក្ដីសន្និដ្ឋានស្ដីពីទំនាក់ទំនងទំនុកចិត្តរវាងអ្នកអប់រំ និងអ្នកទទួលការអប់រំ។ ក្នុងស្ថានភាពប្រតិកម្ម អ្នកទទួលការអប់រំមិនត្រូវចាត់ទុកអ្នកអប់រំជាអ្នកដែលគាំទ្រពួកគេនោះទេ តែត្រូវចាត់ទុកថាជា «ដៃគូប្រឆាំង»។ មួយវិញទៀត ភាពចាំបាច់នៃប្រតិកម្មបង្ហាញពីទំនាក់ទំនងរវាងគោលការណ៍បីផ្សេងទៀតមិនមានសង្គតិភាពរវាងគ្នានឹងគ្នានោះទេ។ Schleiermacher បែងចែកភាពខុសគ្នារវាង ប្រតិកម្មរាងកាយ ប្រតិកម្មស្មារតី និងប្រតិកម្មបញ្ញា។ ប្រតិកម្មរាងកាយត្រូវផ្ដល់អាទិភាពដល់ប្រតិកម្មស្មារតីនៅពេលណាប្រតិកម្មរាងកាយនេះបង្ហាញចេញលើកុមារ ឬក្មេងជំទង់នូវចេតនាមួយដែលត្រូវតែបន្ទច់បង្អាក់ដោយបង្ហាញចេញជាអារម្មណ៍ខ្មាសអៀន មានន័យថាត្រូវបង្រៀនមនុស្សឱ្យចេះគិត មុននឹងធ្វើសកម្មភាព។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៨. Johann Friedrich HERBART (1776-1841) ការតំណាងសោភ័ណនៃពិភពលោកជាគោលដៅចម្បងនៃការអប់រំ (1804)

ចរិយាធម៌ គឺជាគោលដៅចម្បងនៃការអប់រំ។ គោលបំណងនៃការអប់រំ គឺការធ្វើឱ្យកើតមានឡើង និងធ្វើឱ្យក្លាយទៅជាធម្មចរិយា និងទៅជាកម្លាំងនៃចរិយា។ រាល់បេសកកម្មនៃការអប់រំត្រូវចំណុះឱ្យគោលដៅមួយនេះ។ ទោះជាបែបណា បញ្ហាសំខាន់នៃគរុកោសល្យ គឺការដែលមិនអាចធ្វើឱ្យផ្នែកខាងក្រៅនៃមនុស្សក្លាយទៅជាសភាវៈប្រកបដោយសីលធម៌។ គេអាចគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីប្រែក្លាយ «ផ្នែកខាងក្នុង» ជាមនុស្សប្រកបដោយសីលធម៌។ តាមឃ្លាគន្លឹះនៃស្នាដៃដែលមានចំណងជើងថា «La Représentation esthétique du monde» (ការតំណាងសោភ័ណនៃពិភពលោក)៖ «ធ្វើយ៉ាងណាឱ្យសិស្សដឹងដោយខ្លួនឯងដោយជ្រើសយកនូវអ្វីដែលល្អ ដោយបដិសេធនូវអ្វីដែលអាក្រក់៖ ការកសាងចរិតឬកពារ គឺធ្វើបែបនោះហើយ មិនមានវិធីផ្សេងពីនេះនោះទេ»។

គរុកោសល្យទូទៅរបស់ Herbart ឈរលើមូលដ្ឋានគោលការណ៍ «មេរៀនដែលបង្រៀន»។ មេរៀននេះមានមានខ្លឹមសារទាំងស្រុងពាក់ព័ន្ធនឹងបេសកកម្មអប់រំ នៅពេលណាមេរៀននេះគោរពទៅតាមការទាមទារនានានៃពិភពផ្នែកអារម្មណ៍ និងផ្លូវចិត្តរបស់កុមារ។ គេត្រូវបង្កើតឱ្យមានជម្រើសមួយក្នុងចំណោមជម្រើសផ្សេងៗ។ ក្នុងករណីដែលបុគ្គលម្នាក់ស្ថិតក្នុងស្ថានការណ៍បែបនោះ គេអាចនឹងជ្រើសយកជម្រើសដែលសុភវិនិច្ឆ័យរបស់គេយល់ថាជាជម្រើសដ៏ប្រសើរបំផុត។

គេត្រូវមានសុភវិនិច្ឆ័យ។ តែការកសាងពិភពអារម្មណ៍ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសម្បទាក្នុងការវិនិច្ឆ័យ។ ពិភពអារម្មណ៍នេះកសាងបានតាមរយៈបទពិសោធន៍ និងការសេពគប់របស់មនុស្សជុំវិញ។ ពិភពអារម្មណ៍នេះអភិវឌ្ឍ និងកាន់តែរឹងមាំជាលក្ខណៈប្រព័ន្ធតាមរយៈ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការអប់រំ។ សម្រាប់លោក Herbart សូម្បីតែគោលបំណងនៃការអប់រំក៏ត្រូវអភិវឌ្ឍចេញពីបទពិសោធន៍ និងការសេពគប់ដែរ។ «ចំណេះដឹង» និង «មេត្តាធម៌» ចូលរួមក្នុងការពង្រីងពិភពអារម្មណ៍។ ការតំណាងរបស់មនុស្សមានពីរសមាសភាគ៖ សមាសភាគទីមួយមានលក្ខណៈសច្ចភាព រួមមានចំណេះដឹង និងទីពីរគឺមនោសញ្ចេតនា ហើយសមាសភាពទីពីរនេះមាននៅក្នុងពិភពទំនាក់ទំនងរបស់យើង។

## ទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្តន៍ «Le tact pédagogique»

Herbart បានបង្កើតគោលគំនិត «កាយវិញ្ញាណគរុកោសល្យ» ដែលជាចំណុចស្នូលនៃទំនាក់ទំនងរវាងទ្រឹស្តី និងការអនុវត្ត។ ទ្រឹស្តីអាចទាញចេញពីបទពិសោធន៍តែមួយគត់បាន(ការអនុវត្ត)៖ទ្រឹស្តីប្រើប្រាស់សម្រាប់បញ្ជាក់ឱ្យការអនុវត្តសកម្មភាពរបស់ខ្លួន។ ចេញពីស្ថានភាពដូចរៀបរាប់នេះហើយ ដែលបញ្ជាក់ពីភាពចាំបាច់នៃអន្តរកម្មរវាងទ្រឹស្តី និងការអនុវត្ត ដែល Herbart ឱ្យឈ្មោះថា «Le tact pédagogique »។ បញ្ញត្តិនៃ «កាយវិញ្ញាណគរុកោសល្យ» គឺជាទំនាក់ទំនងចាំបាច់រវាងទ្រឹស្តីគរុកោសល្យ និងការអនុវត្តគរុកោសល្យ។ Herbart បង្ហាញដូច្នេះពីសមត្ថភាពផ្លូវចិត្ត និងសុភវិនិច្ឆ័យចាំបាច់សម្រាប់គ្រូបង្រៀន ប្រសិនណាជាគាត់ចង់ធ្វើសកម្មភាព និងសម្រេចចិត្តឱ្យបានត្រឹមត្រូវជាមួយនឹងកុមារ និងយុវជន និងធ្វើសកម្មភាពទាំងនេះក្នុងស្ថានភាពគរុកោសល្យថ្មីៗជាប្រចាំ។

ចំពោះអ្នកអប់រំវិញ ទំនាក់ទំនងគរុកោសល្យត្រូវបានគេសម្គាល់តាមរយៈសេចក្តីស្រលាញ់ដែលផ្តល់ដល់យុវជន/ កុមារដែលរៀនជាមួយខ្លួនតាមរយៈការប្រឹងប្រែងស្វែងយល់ថា ពួកគេកំពុងតែស្ថិតនៅក្នុងដំណើរការនៃការអភិវឌ្ឍខ្លួនឯងទៅតាមគ្រប់លទ្ធភាព កម្លាំង និងចំណុចខ្សោយដែលពួកគេមាន។ គឺមានតែតាមរយៈបទពិសោធន៍អនុវត្តនានារបស់សិស្សក្នុងការសេពគប់ក្រុមក្មេងជំទង់តែប៉ុណ្ណោះ ដែលគ្រូអាចអភិវឌ្ឍកាយវិញ្ញាណ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បញ្ជាក់ពីកាលវេលាដែលសិស្សនឹងមានភាពចាស់ទុំ ដើម្បីប្រតិបត្តិសមាសភាពសំខាន់ណាមួយរបស់ទ្រឹស្តី។

ក្នុងអត្ថបទរិះគន់សាលារៀន និងការបង្រៀន លោក Herbart បានបង្ហាញថា បុគ្គលភាពនៃពិភពអារម្មណ៍ពន្យល់ពីហេតុផលថាតើហេតុអ្វីបានជាសិស្សចំនួន ៣០ នាក់រៀនពីអ្វីមួយដូចគ្នា តាមរបៀបខុសៗគ្នា នៅក្នុងម៉ោងតែមួយនៅក្នុងថ្នាក់រៀន។ លោកបានទាញចេញជាហេតុផល ឬជាសេចក្តីសន្និដ្ឋានថា៖ សិស្សរៀន គឺមិនមែនរៀនពីអ្វីដែលកើតមាននៅក្នុងថ្នាក់ពេលបង្រៀននោះទេ តែរៀនពីអ្វីដែលត្រូវទៅតាមចំណង់ចំណូលចិត្តរបស់គេ ទៅតាមជីវប្រវត្តិនៃការសិក្សារបស់គេ និងពីអ្វីដែលគេត្រៀមក្នុងការបញ្ចូលមនោរម្យរបស់ពួកគេទៅក្នុងនោះ។

គរុកោសល្យរបស់ Herbart ចាត់ទុកសិស្សជាបុគ្គលដែលមាននីតិវិធីក្នុងការសិក្សារៀនសូត្ររបស់ខ្លួនដោយខ្លួនឯង ហើយលោកប្រកាន់យកទស្សនៈនេះដោយម៉ឺងម៉ាត់។ គ្រូបង្រៀនច្រើនតែបំពេញតួនាទីទេវវិទ្យារបស់ខ្លួន តួនាទីដែលធ្វើឱ្យពួកគាត់យល់បាននូវសតិបញ្ញា និងអារម្មណ៍របស់សិស្ស ព្រមទាំងធ្វើឱ្យគ្រូបង្រៀនអាចធ្វើសកម្មភាពឆ្លើយតបសមស្របបាន។

## ៩. John DEWEY (1859-1952)

លោក John Dewey ជាអ្នកគរុកោសល្យ និងទស្សនវិទូអាមេរិចកាំងដ៏ល្បីម្នាក់ និងជានិមិត្តរូបយ៉ាងលេចធ្លោជាងគេផ្នែកអប់រំបែបថ្មី។ លោកត្រូវបានគេចាត់ទុកជាអ្នកទ្រឹស្តីអប់រំល្បីៗតាមបែបផ្ទាតុង និង Rousseau។ ទស្សនៈរបស់លោកមានឥទ្ធិពលទៅលើទស្សនវិជ្ជាអប់រំ និងសាលារៀននៅអាមេរិចខាងជើងពេញមួយសតវត្សរ៍ទី ២០ ព្រមទាំងប្រព័ន្ធអប់រំនៃបណ្តាប្រទេសនានាក្នុងពិភពលោកផង។ Dewey ជ្រើសយកទស្សនវិជ្ជាបែបសង្គម ហើយបានតស៊ូមតិដើម្បីបង្កើតឱ្យមានកំណែទម្រង់សង្គម។ នៅឆ្នាំ ១៨៩៤ លោកត្រូវបានតែងតាំងជាសាស្ត្រាចារ្យទស្សនវិជ្ជា និងជានាយក ដេប៉ាតឺម៉ង់ទស្សន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិជ្ជា ចិត្តវិទ្យា និងអប់រំ នៅសាកលវិទ្យាល័យ Chicago។

នៅឆ្នាំ១៨៩៦ លោក Dewey បានបង្កើតសាលាពិសោធន៍មួយ (ដែលគេច្រើនតែស្គាល់ក្រោមឈ្មោះ សាលា Dewey ឬ សាលាពិសោធន៍ (អនុវត្តន៍)) ដែលជាសាលាអនុវត្តន៍របស់ដេប៉ាតឺម៉ង់គរុកោសល្យ។ លោកបានធ្វើការពិសោធន៍ក្នុងសាលានេះនូវគោលគំនិត និងបានចំណាយពេល ៤ទសវត្សរ៍ ដើម្បីកែលម្អទស្សនវិជ្ជាអប់រំរបស់លោក ដែលមានលក្ខណៈជាប្រជាធិបតេយ្យខ្នាតតូច។ គាត់ចាត់ទុកគ្រូៗដូចជាអ្នករួមការងារ។ ការប្រជុំប្រចាំសប្តាហ៍ត្រូវបានរៀបចំឡើងដើម្បីជជែកលើកម្មវិធី។ គ្រូបង្រៀនមានពេលវេលាទំនេរសម្រាប់និយាយគ្នាពីរឿងការងារ។ការបង្រៀនច្រើនតែចាប់ផ្តើមដំបូងតាមរយៈការជជែកពិភាក្សាគ្នារវាងសិស្សនិងសិស្ស សិស្សនិងគ្រូពីកិច្ចការដែលបានធ្វើ និងដែលត្រូវធ្វើ។ ការបង្រៀនត្រូវបានផ្តោតសំខាន់ ទៅលើការបង្រៀនតាមបែបការចូលរួមជាលក្ខណៈប្រជាធិបតេយ្យ។

Dewey បង្រៀននៅសាលាគរុកោសល្យនៃសាកលវិទ្យាល័យកូឡុមប៊ីយ៉ាចន្លោះឆ្នាំ ១៩០៥ ដល់១៩៣០។ គាត់បង្រៀនផ្នែកទស្សនវិជ្ជាច្រើនជាងផ្នែកអប់រំ។ លើសពីនោះ គាត់បានសរសេរសៀវភៅមួយក្បាលដែលមានចំណងជើងថា Schools of Tomorrow ជាមួយកូនស្រីរបស់គាត់ Evelyn ហើយត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩១៥។

ទ្រឹស្តីការអប់រំរបស់ Dewey គឺផ្តោតសំខាន់ទៅលើទស្សនវិជ្ជាអប់រំ។ ដូចគ្រូរបស់គាត់មានលោក Rousseau, Pestalozzi, Herbart និង Frobel ដែរ លោក Dewey គាំទ្រគំនិតដែលថាការអប់រំត្រូវផ្តោតទៅលើការអភិវឌ្ឍធម្មជាតិរបស់មនុស្ស។ វាពិតជាចាំបាច់ណាស់ក្នុងការសម្របសម្រួលលទ្ធិទ្វេភាពនិយមបែបបុរាណបញ្ចូលគ្នា៖ ហេតុផលនិងកិលេស រាងកាយនិងព្រលឹង អារម្មណ៍និងសកម្មភាព ចិត្តនិងសង្គម បុគ្គលភាពនិងសង្គម សិស្សនិង កម្មវិធីសិក្សា គោលដៅនិងមធ្យោបាយ សកម្មភាពអនុវត្តនិងសកម្មភាព បញ្ញាញាណមនុស្សនិងធម្មជាតិ។ ការអភិវឌ្ឍមនុស្ស ត្រូវធ្វើតាមរយៈការ អភិវឌ្ឍសង្គម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ហើយមនុស្ស និងសង្គមត្រូវមានទំនាក់ទំនងជាប្រចាំជាមួយគ្នា។

វគ្គមួយក្នុងសៀវភៅរបស់លោក Dewey ដែលមានចំណងជើងថា Democracy and Education (ប្រជាធិបតេយ្យ និងការអប់រំ) បានបរិយាយថា៖ «ដោយសារការអប់រំជាដំណើរការដែលត្រូវសម្រេចឱ្យបាននូវការផ្លាស់ប្ដូរចាំបាច់ និងមិននៅត្រឹមតែសម្មតិកម្មចំពោះអ្វីដែលគេចង់បាននោះ យើងអាចអះអាងបានថាទស្សនវិជ្ជាគឺជាទ្រឹស្ដីអប់រំដែលចាត់ទុកដូចជាវិធីសាស្ត្រតាមដានតាមបែបគិតទុកជាមុន។» ដូច្នេះ ការអប់រំគឺជាការកសាងឡើងវិញ ឬការរៀបចំឡើងវិញដោយផ្សារភ្ជាប់ជាមួយនឹងបទពិសោធន៍។ កុមារយុវជន ជីវិតពេញវ័យ-មនុស្សគ្រប់អាយុទាំងអស់មានភាពស្មើគ្នាចំពោះការអប់រំ ក៏ព្រោះថាអ្វីដែលបានរៀនពិតប្រាកដនៅតាមដំណាក់កាលនៃបទពិសោធន៍បង្កើតបានជាគុណតម្លៃនៃបទពិសោធន៍នោះ ហើយទង្វើនៃការរស់នៅមានបេសកកម្មសំខាន់មួយ គឺការចូលរួមនៅគ្រប់ពេលវេលាទាំងអស់ទៅដល់ការបង្កើនអត្ថន័យនៃជីវិត»។ ដោយមូលហេតុនេះហើយ បានជាការអប់រំគឺជាកត្តាចាំបាច់នៃប្រជាធិបតេយ្យ។

## បទពិសោធន៍ និងការអប់រំ

នៅក្នុងសៀវភៅ «Experience and Education (1938)» លោក Dewey បានលើកឡើងថា បទពិសោធន៍ គឺជាលក្ខណៈវិនិច្ឆ័យនៃការអប់រំ។ បទពិសោធន៍ដែលបង្រៀនមិនមែនជាអ្វីដែល «កើតឡើងចំពោះអ្នកនោះទេ» គឺជាទង្វើរំពឹងទុកមួយ។ មានគោលការណ៍ចំនួនពីរកំណត់លក្ខណៈរបស់បទពិសោធន៍ «អប់រំ» (ឬការបណ្តុះបណ្តាល)៖ (១) គោលការណ៍អនន្តរភាព (Continuity) ដែលក្នុងនោះគេឃើញ មានចរិតជានីតិវិធីក្នុងការត្រិះរិះពិចារណារបស់ Dewey និង(២) គោលការណ៍នៃអន្តរកម្មរវាងមនុស្ស និងពិភពដែលនៅជុំវិញខ្លួនគេ (Interaction)។

អនន្តរភាពនៃបទពិសោធន៍មានន័យថា «បទពិសោធន៍មួយទទួល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឥទ្ធិពលពីបទពិសោធន៍មុនៗ ហើយបទពិសោធន៍មួយនោះនឹងផ្លាស់ប្ដូរគុណភាពនៃបទពិសោធន៍មួយបន្ទាប់ទៀត» (Dewey, 1938, 1974)។ បទពិសោធន៍មួយក្លាយជាគំរូ នៅពេលដែលបទពិសោធន៍នោះជំរុញឱ្យមានគំនិតផ្ដួចផ្ដើម បំណងប្រាថ្នា និងគោលបំណងដែលនឹងត្រូវអនុវត្តសម្រាប់រយៈពេលវែង។ ក្នុងន័យនេះ បទពិសោធន៍គឺជា «ការលើកទឹកចិត្ត»។ ការអប់រំឈរលើមូលដ្ឋានបទពិសោធន៍ត្រូវធ្វើយ៉ាងណាឱ្យ «ការជ្រើសរើសប្រភេទបទពិសោធន៍ដែលស្ថិតស្ថេរប្រកបដោយនិរន្តរភាព និងភាពប៉ិនប្រសប់ក្នុងបទពិសោធន៍ជាបន្តបន្ទាប់ទៅទៀត» (Dewey, 1974)។

គោលការណ៍ទី២ នៃបទពិសោធន៍ដែលត្រូវបានចាត់ទៅក្រោមផ្នែកមួយនៃមុខងារគរុកោសល្យគឺជា «គោលការណ៍នៃអន្តរកម្ម» (Dewey, 1974) ដែលក្នុងនោះបុគ្គលម្នាក់ៗគឺជាសមាសភាពមួយនៃប៉ូលអន្តរកម្មនោះ ហើយប៉ូលមួយទៀតនៃអន្តរកម្មគឺជាលក្ខខណ្ឌនៃបរិស្ថានជុំវិញបុគ្គលនោះ។ រៀងរាល់ពេលដែលកើតមានអន្តរកម្មរវាងបុគ្គលនិងពិភពដែលនៅជុំវិញខ្លួនគេ ឬបរិស្ថានជុំវិញខ្លួនគេ គឺនៅពេលនោះហើយដែលបទពិសោធន៍មួយកើតឡើង។ «បរិស្ថានជុំវិញគឺជា [...] លក្ខខណ្ឌរួមដែលចូលទៅក្នុងអន្តរកម្មជាមួយនឹងតម្រូវការផ្ទាល់ខ្លួន បំណង គោលបំណង និងសមត្ថភាពដើម្បីធ្វើឱ្យបទពិសោធន៍មួយកើតឡើង» (Dewey, 1974)។

ក្នុងករណីដំណើរការសមាហរណកម្មមួយជោគជ័យ ពេលនោះនឹងកើតមាននូវអ្វីដែល Dewey ចាត់ទុកថាជា «មនុស្សសមាហរណកម្មពេញបុគ្គលិកលក្ខណៈ (personnalité intégrée)»។ ដូច្នេះនឹងមិនមានទីជម្រៅនោះទេរវាងពិភពសុបិន និងពិភពពិត។ ពិភពសុបិនអាច «ជាការពិត» ពិភពសុបិនលែងគ្រាន់តែជាគំនិត និងជានិមិត្តរូបទៀតហើយ ពិភពសុបិនក្លាយជា «មធ្យោបាយក្នុងការអនុវត្ត» (Dewey, 1990)។ ទស្សនៈ និងគោលដៅមិនត្រូវបានចាត់ទុកដូចជាគោលការណ៍និយ័តភាព ឬក៏ជានិមិត្តរូបនោះទេ តែត្រូវចាត់ថាជាអ្វីដែលយើងត្រូវធ្វើ អ្វីដែលយើងត្រូវសម្រេចឱ្យបាន។ បន្ទឹ

រវាងនិមិត្តរូប និងការគិតតាមទស្សនៈរបស់លោក Dewey គឺជា «បញ្ហាអចិន្ត្រៃយ៍នៅក្នុងជីវិតគ្រប់ៗគ្នា» (Dewey, 1990)។

## ការអប់រំ និងការបង្រៀន

លោក Dewey ផ្ដោតការចាប់អារម្មណ៍លើការអប់រំ និងប្រព័ន្ធសាលារៀន នៅពេលណាការអនុវត្តការអប់រំ និងប្រព័ន្ធសាលារៀននេះធ្វើឱ្យមានការអនុវត្តដំណើរការពិសោធ ដែលនាំឱ្យមានការកែលម្អជាប្រចាំផ្នែកសីលធម៌ និងសង្គមទៅលើមនុស្សជាតិ។ ប្រសិនណាជាអន្តរកាព និងអន្តរកម្មជាគោលការណ៍ដែលនៅមានសុពលភាពក្នុងបទពិសោធន៍ និងការសិក្សា នោះនៅមានលក្ខណៈវិនិច្ឆ័យសំខាន់ពីរទៀត ក្នុងក្របខ័ណ្ឌនៃដំណើរការអប់រំ និងការបង្រៀននៅសាលារៀន៖ តក្កវិទ្យា (logic) និងចិត្តវិទ្យា(psychology)។«ទស្សនៈនៃការអប់រំ[...]អាចទាញជារួមពីទស្សនៈនៃការកសាងឡើងវិញជាប្រចាំនៃបទពិសោធន៍»។

ដោយស្របទៅតាមគោលគំនិតនៃការអប់រំបែបថ្មី និងការអប់រំតាមបែបជឿនលឿន (Progressive education) លោក Dewey រិះគន់ចំពោះទ្រឹស្ដីបុរាណដែលមានចក្ខុវិស័យផ្ដោតខ្លាំងទៅលើអនាគត ដោយចាត់ទុកកុមារ-ភាព ជាដំណាក់កាលមុនតរុណវ័យ ហើយដែលយល់ឃើញថាការចាប់បាននូវចំណេះដឹង និងវិជ្ជា គឺជាការរៀបចំដ៏សាមញ្ញសម្រាប់ជីវិត និងមុខរបរទៅអនាគត។

## បង្រៀន គិត និងធ្វើ

ទង្វើនៃការ «គិតពិចារណា» (Thinking) និងសមត្ថភាពនៃការគិតពិចារណាជាប្រចាំគឺជាមធ្យោបាយផង និងជាគោលបំណង(ផ្នែកព្រលឹង)ផងនៃការអប់រំ។ គិតពិចារណា មិនត្រឹមតែជាទង្វើសត្យានុម័តនោះទេ «តែគឺជាទង្វើក្នុងការបង្កើតទំនាក់ទំនងរវាងអ្វីដែលត្រូវធ្វើ និងផលដែលចេញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីទង្វើនោះ ដោយច្បាស់លាស់ និងគិតទុកជាមុន» (Dewey, 1990) តាមទីតិវិធីដែលធ្វើឱ្យការអប់រំ បទពិសោធន៍ និងវឌ្ឍនភាពកតព្រួសព្វគ្នា។

ចំពោះអ្វីដែលទាក់ទងនឹងការបណ្តុះបណ្តាលស្មារតីរបស់សិស្ស កាតព្វកិច្ចរបស់សាលារៀនគឺ [...] អភិវឌ្ឍសមត្ថភាពក្នុងការគិតពិចារណា (Democrazy and Education)។ Dewey ប៉ាន់ប្រមាណថា «ត្រូវផ្តល់ការងារឱ្យសិស្សធ្វើមានន័យថា មិនត្រូវផ្តល់ការងារឱ្យសិស្សរៀននោះទេ ព្រោះថា «ធ្វើអ្វីមួយ» ទាមទារឱ្យមានការគិតពិចារណា និងការសាងនូវទំនាក់ទំនងរវាងវត្ថុនិងវត្ថុ ហើយទង្វើនេះនឹងធ្វើឱ្យកើតមានជាការសិក្សាតាមរបៀបធម្មជាតិ» (Dewey, 1990)។

នៅក្នុងស្នាដៃមួយដែលមានចំណងជើងថា How We Think លោក Dewey បែងចែកដំណាក់កាលនៃទង្វើគិតពិចារណាជាប្រាំបន្តបន្ទាប់គ្នា ៖ ទីមួយ ការលេចចេញនូវបញ្ហា ការលំបាក ឬបាតុភាពគួរឱ្យព្រួយបារម្ភ ទីពីរ ការសង្កេត និងការវិភាគព្រឹត្តិការណ៍ដើម្បី កំណត់បញ្ហា ឬដើម្បីពន្យល់ ទី៣ ការទាញយកនូវសម្មតិកម្ម ឬដំណោះស្រាយដែលអាចមាន និងការរកឱ្យឃើញនូវដំណោះស្រាយតាមរយៈគំនិតទី៤ ការវិភាគគំនិតតាមរយៈការឱ្យហេតុផលចំពោះដំណោះស្រាយ និងទី៥ គឺការសង្កេត និងការពិសោធបន្ថែមទៀតដើម្បីឈានទៅរកការទទួលយក ឬបដិសេធចោលដំណោះស្រាយ។ ការសង្កេត ឬការយល់ពីបញ្ហាមួយ ទាញចេញពីការគិតពិចារណា និងជំរុញឱ្យកើតមានដំណើរការនៃការគិតពិចារណាដែលនឹងមានតួនាទីក្នុងការបង្កើតឱ្យមានការស្រាវជ្រាវថ្មី។ គឺតាមវិធីសាស្ត្រនោះហើយដែលអាចទាញចេញជាគំរូបាននៅក្នុងការអប់រំ មានន័យថាការអប់រំមានតួនាទីក្នុងការបណ្តុះមនុស្សឱ្យមានសមត្ថភាពក្នុងការ គិតពិចារណា៖ «ពង្រីក និងរៀបចំឱ្យកាន់តែមានប្រសិទ្ធភាពសកម្មភាព បញ្ញា លើកទឹកចិត្តការសិក្សាស្រាវជ្រាវ និងការវិភាគ ព្រមទាំងអភិវឌ្ឍបញ្ញាចង់ដឹង។ វត្ថុទាំងអស់ជាវិញ្ញាណល្អិតណាដែលវា [...] បង្កើតចេញជា ដំណើរការនៃការរីកលូត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ណាស់» (Dewey, 1951)។

ចំណុចសំខាន់ គឺត្រូវចៀសវាងការផ្តល់ឱ្យនូវ «ដំណោះស្រាយរៀបចំរួចរាល់» ដែលបង្កើតឱ្យមានជាឧបសគ្គក្នុងការពិចារណា៖«ដូច្នេះ សមាសភាពគោលនៃវិធីសាស្ត្រនេះ គឺដូចទៅនឹងសមាសភាពគោលនៃការគិតពិចារណា ដែលទាមទារឱ្យ៖ ទី១ ឱ្យសិស្សស្ថិតក្នុងស្ថានភាពពិសោធន៍សាមញ្ញ ធ្វើយ៉ាងណាឱ្យសកម្មភាពដែលសិស្សចាប់អារម្មណ៍មានជាប្រចាំ ទី២ ឱ្យប្រើប្រាស់បញ្ហាជាក់ស្តែងនៅក្នុងស្ថានភាពនេះដើម្បីជំរុញឱ្យមានការគិតពិចារណា ទី៣ ឱ្យសិស្សមានចំណេះដឹង និងធ្វើការសង្កេតចាំបាច់នានាដើម្បីយល់ពីបញ្ហា ទី៤ ឱ្យសិស្សលើកចេញនូវដំណោះស្រាយដែលចេញពីការគិតពិចារណា ទី៥ ឱ្យសិស្សមានឱកាសក្នុងការយកគំនិតរបស់ខ្លួនមកអនុវត្តដើម្បីឱ្យគេអាចបញ្ជាក់ពីអត្ថន័យ និងស្វែងយល់ដោយខ្លួនឯងនូវសុពលភាពរបស់គំនិតនោះ (Dewey, 1990)។

ក្នុងគោលគំនិតនៃការអប់រំរបស់ Dewey មានសម្មតិកម្មចម្បងមួយ៖ ការគិតពិចារណាដូចជាការសិក្សាដែរ គឺមានចរិតលក្ខណៈដោយ «ឯកឯង» ឬដោយធម្មជាតិ។ ក្មេងម្នាក់ៗ សិស្សម្នាក់ៗធ្វើការពិសោធគុណវិស័យរបស់ខ្លួនមានន័យថាសិស្សមិនរៀនដោយគ្រាន់យកគោលបំណងយក «ជោគជ័យ» លើអ្វីជាលក្ខណៈបរិមាណនោះទេ។ ផ្ទុយទៅវិញ ដើម្បីអនុវត្តសកម្មភាពបង្រៀន វាចាំបាច់ណាស់ដែលត្រូវយល់ពី «ការកើតឡើងដោយឯកឯងនៃបញ្ញាស្មារតី» និង «ប្រឌិតញាណនៃបញ្ញាស្មារតីផ្ទាល់ខ្លួន» ទាំងនេះ។

## ប្រជាធិបតេយ្យ និងការអប់រំ

Dewey គិតថាប្រជាធិបតេយ្យគឺជាទម្រង់ត្រូវអនុវត្តតែមួយគត់នៃជីវិតក្នុងសង្គម។ គួរកត់សម្គាល់ថា មានការយល់ស្របលើអត្ថន័យនៃពាក្យប្រជាធិបតេយ្យគឺមានន័យលើសពីទម្រង់សាមញ្ញរបស់រដ្ឋាភិបាល» (Dewey, 1990)។ តាមទស្សនៈរបស់លោក Dewey ប្រជាធិបតេយ្យ គឺជាទម្រង់សមស្របមួយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*សម្រាប់ជីវិតក្នុងសង្គមសេរី និងសង្គមនិយម ដែលមនុស្សយល់ពីទម្រង់ពិតប្រាកដរបស់បុគ្គលខ្លួនឯងមួយផ្នែក និងមួយផ្នែកទៀត ធ្វើឱ្យគេអាចចូលរួមក្នុងការរៀបចំរបៀបរស់នៅតាមបែបប្រជាធិបតេយ្យ តាមរយៈទម្រង់ពិតប្រាកដរបស់ខ្លួននោះ។*

*សង្គមឧត្តុង្គឧត្តមដែលត្រូវប្រើប្រាស់ជាក្រឹត្យក្រមសម្រាប់ការអប់រំ គឺសង្គមប្រជាធិបតេយ្យ ដែលធានាដល់គ្រប់សមាជិកក្នុងនោះពីការបែងចែកទ្រព្យធនដោយស្មើភាព និងពីការកែតម្រូវស្ថាប័ននានារបស់ខ្លួនតាមរយៈអន្តរកម្មជាមួយនឹងទម្រង់ខុសៗគ្នានៃជីវិតក្នុងសង្គម។ សង្គមបែបនេះត្រូវមានការអប់រំមួយដែលមានសមត្ថភាពក្នុងការជំរុញឱ្យមានចំណាប់អារម្មណ៍ផ្ទាល់ខ្លួនចំពោះទំនាក់ទំនងសង្គម និងការគ្រប់គ្រងវត្ថុសាធារណៈ ព្រមទាំងអភិវឌ្ឍតម្រិះសម្បទាដែលធ្វើឱ្យមានការប្រែប្រួលក្នុងសង្គមដោយការគេចចេញរាល់ភាពអាណាធិបតេយ្យ។ ការអប់រំត្រឹមត្រូវសម្រាប់សង្គមប្រជាធិបតេយ្យ គឺឈរលើមូលដ្ឋានឧត្តមភាពនៃការកសាងឡើងវិញជាប្រចាំនូវបទពិសោធន៍ដែលមានការកែលម្អខ្លឹមសារសង្គម និងផ្តោតលើសមត្ថភាពរបស់បុគ្គលក្នុងការធ្វើអន្តរាគមន៍ក្នុងការកសាងឡើងវិញ នៃសង្គមនេះ។*

*សង្គមមួយរស់រវើងបានតាមរយៈសមត្ថភាពរបស់ស្ថាប័ននយោបាយ និងសេដ្ឋកិច្ចពាក់ព័ន្ធនឹងការចូលរួមក្នុង«ការរីកចម្រើនឱ្យបានពេញលេញតាមដែលអាចធ្វើបានរបស់សមាជិកនៃសង្គមនោះ។ គ្រប់ស្ថាប័នទាំងអស់ត្រូវចូលរួមក្នុងការអប់រំ»។ «រដ្ឋាភិបាល ធុរកិច្ច សិល្បៈ សាសនា» មានគោលដៅក្នុងការ «រំដោះ និងអភិវឌ្ឍសម្បទានានារបស់មនុស្សជាលក្ខណៈបុគ្គល ដោយមិនគិតពីជាតិសាសន៍ ភេទ វណ្ណៈ ឬស្ថានភាពសេដ្ឋកិច្ច»* (Dewey, 1990)។ *ជីវិតសម័យទំនើបមានន័យថាជាលទ្ធិប្រជាធិបតេយ្យ ហើយលទ្ធិប្រជាធិបតេយ្យមានន័យថាជាការរំដោះប្រាជ្ញាដើម្បីទទួលបានប្រសិទ្ធភាពឯករាជ្យ គឺការរំដោះចិត្តក្នុងនាមជាបុគ្គល ដើម្បីធ្វើកិច្ចការផ្ទាល់ខ្លួន»*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

(Dewey, 1990)។ ការអប់រំមិនត្រឹមតែជាឧបករណ៍ក្នុងការសម្រេចបានប្រជាធិបតេយ្យ ក្នុងន័យ ឬក្នុងទស្សនៈរបស់ Dewey នោះទេ តែការអប់រំនេះមានន័យដូចគ្នាជាមួយនឹងពាក្យប្រជាធិបតេយ្យ។ «ការអប់រំមិនមែនជាការរៀបចំសម្រាប់ជីវិតនោះទេ តែការអប់រំជាជីវិតតែម្តង។» អត្ថន័យចម្បងនៃសីលធម៌គឺការធ្វើឱ្យមនុស្សអាចទទួលបានជាប្រចាំការអប់រំសីលធម៌នេះ។ ព្រោះជីវិតដែលប្រកបដោយសម្បជញ្ញៈ គឺជាជីវិតមួយដែលមានការចាប់ផ្តើមឡើងវិញដោយគ្មានទីបញ្ចប់ (Dewey, 1990)។

## សាលារៀន និងប្រជាធិបតេយ្យ

ប្រសិនបើការអប់រំបង្កើតឧបករណ៍វឌ្ឍនភាពប្រជាធិបតេយ្យនីយកម្មនៃសង្គម សាលារៀនក្នុងទម្រង់ជាស្ថាប័ន គឺជា «មធ្យោបាយសន្សំសំចៃ និងមានប្រសិទ្ធភាពបំផុតសម្រាប់វឌ្ឍនភាពសង្គម» (Dewey, 1990)។ សាលារៀនគឺជាស្ថាប័នសង្គមដ៏ប្រសើរបំផុត តាមទស្សនៈរបស់ Dewey សាលារៀនគឺជាសហគមន៍តូចមួយ «a miniature community » ឬក៏ជាកោសិកាសង្គមមួយ «an embryonic society» (Dewey, 1956)។

លោក Dewey កំណត់និយមន័យការអប់រំថាជាដំណើរការសង្គម ហើយក្នុងបរិបទនេះ សាលារៀនគឺជាទម្រង់ជីវិតសហគមន៍ដែលនៅក្នុងនោះមានសេវាដ៏មានប្រសិទ្ធភាពដើម្បីឱ្យកុមារទទួលបានមរតកមនុស្សជាតិ និងការបណ្តុះបណ្តាលសមត្ថភាពផ្ទាល់ខ្លួនសម្រាប់គោលបំណងសង្គម។ លោកបានបញ្ជាក់ថាការអប់រំគឺជាដំណើរការជីវិត ហើយមិនមែនជាការរៀបចំសម្រាប់ជីវិតទៅអនាគតនោះទេ។ តាមទស្សនៈរបស់ Dewey ក្នុងនាមជាស្ថាប័នសង្គម និងសហគមន៍ជីវិត សាលារៀនត្រូវធ្វើឱ្យសាមញ្ញនូវជីវិតក្នុងសង្គមសម្រាប់កុមារ ធៀបជាមួយនឹងទិដ្ឋភាពស្មុគស្មាញរបស់ពិភពមនុស្សពេញវ័យ និងចំនួនដ៏ច្រើនលើសលប់នៃចំណេះដឹងលើលោក។ វាចាំបាច់ណាស់ក្នុងការបង្កើតបរិយាកាសនៅក្នុងសាលារៀនដែលធ្វើឱ្យកុមារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងក្មេងជំទង់អាចយល់ពីភាពចាំបាច់នៃការចូលរួម និងចំណែកនៃការទទួលខុសត្រូវរបស់គេ។

គោលដៅបញ្ញាញាណ មនោ និងនយោបាយនៃការអប់រំគឺត្រូវធ្វើយ៉ាងណាឱ្យមនុស្សមានសមត្ថភាពបន្តការគិតពិចារណា បន្តការហាត់រៀន បន្តការដោះស្រាយបញ្ហា ក្នុងចេតនានៃការអនុវត្តសកម្មភាពទាំងនោះ៖ «គោលដៅសំខាន់បំផុតនៃការអប់រំនៅសាលារៀនគឺធានាអនន្តរភាពនៃការអប់រំដោយកសាងសមត្ថភាពដែលជាទានូវការរីកចម្រើនជំពាក់របស់មនុស្ស (Growth)។ ចំណង់ចំណូលចិត្តក្នុងការសិក្សារៀនសូត្រកើតចេញពីជីវិតរស់នៅ និងធ្វើឱ្យលក្ខខណ្ឌជីវិតបានប្រសើរទៅតាមអ្វីដែលគ្រប់គ្នារៀនសូត្រតាមរយៈការរស់នៅគឺជាលទ្ធផលដ៏ជោគជ័យនៃសាលារៀន» (Dewey, 1990)។

## ១០. Ellen KEY (1849-1926)

យុគសម័យនៃយើងទាមទារយ៉ាងខ្លាំងនូវបុគ្គលិកលក្ខណៈជាមនុស្សពេញលេញ តែយុគសម័យនៃយើងនេះនឹងទទួលបរាជ័យប្រសិនបើយើងមិនផ្ដល់ដល់សិស្សនូវលទ្ធភាពក្នុងការទទួលបាននូវអ្វីដែលជាចេតនារបស់គេ មិនផ្ដល់លទ្ធភាពដល់គេក្នុងការគិតពិចារណាសម្រាប់ខ្លួនឯង មិនផ្ដល់លទ្ធភាពទៅដល់គេក្នុងការកសាងដោយខ្លួនឯងនូវចំណេះដឹងរបស់គេ មិនផ្ដល់លទ្ធភាពដល់គេក្នុងការបណ្ដុះនូវការវិនិច្ឆ័យផ្ទាល់ខ្លួន និយាយឱ្យខ្លីកាលណាយើងមិនរាំងមុខវិជ្ជាធម្មតាស្ដីពីបុគ្គលិកលក្ខណៈមនុស្សដោយសង្ឃឹមទាំងគ្មានប្រយោជន៍ថាចំណេះដឹងដែលទទួលបានពីមុខវិជ្ជានេះនឹងមានផលជះនាពេលខាងមុខ នៅក្នុងសាលារៀននោះទេ (Le siècle de l'enfant)។

ទស្សនៈបុគ្គលនិយមរបស់លោកស្រីមានភាពមុតស្រួចជាមួយនឹងការអានស្នាដៃរបស់ Goethe។ លោកស្រីស្ញប់ស្ញែងចំពោះសេចក្ដីស្រឡាញ់របស់ Goethe ពាក់ព័ន្ធនឹងការរីកលូតលាស់របស់មនុស្ស។ តាមទស្សនៈ Goethe



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សហគមន៍មនុស្សជាតិពិតប្រាកដមួយ គឺជាសហគមន៍ដែលទទួលស្គាល់គុណតម្លៃកំពូលរបស់មនុស្ស និងរិះរកវិធីក្នុងការផ្តល់នូវតម្លៃទៅដល់សក្តានុពលរបស់មនុស្សម្នាក់ៗដោយសុខដុមរមនាសម្រាប់ទាំងអស់គ្នា។ ការយកចិត្តទុកដាក់ចំពោះបរទត្ថនិយម (selflessness) ក្នុងធម្មជាតិរបស់មនុស្សនឹងធ្វើឱ្យមានតុល្យភាពភាពអាត្មានិយម ដើម្បីឱ្យមនុស្សមានភាពសុខដុមជាមួយខ្លួនឯង និងអ្នកនៅជុំវិញខ្លួន។ «សេរីភាពមួយដែលស្វែងរកប្រយោជន៍សម្រាប់ខ្លួនឯងដោយដកហូតប្រយោជន៍ពីអ្នកដទៃ គឺមិនមែនជាសេរីភាពនោះទេ»។

## ទ្រឹស្តីនៃបុគ្គលិកលក្ខណៈ

លោកស្រី Ellen បានធ្វើឱ្យអ្នកអប់រំយល់ពីកុមារ និងចិត្តវិជ្ជាកុមារ។ សៀវភៅ The Century of the Children បានធ្វើឱ្យលោកស្រីមានភាពល្បីល្បាញក្នុងនាមជាអ្នកទស្សនៈវិជ្ជាអប់រំតាមបែប Quintilien, Rousseau, Schleiermacher, Tolstoï និងអ្នកនិពន្ធល្បីៗជាច្រើនទៀត។ ដោយយកតាមទ្រឹស្តីរបស់ Rousseau ស្នាដៃនោះបានចាត់ទុកកុមាររួចចាកពីការដាក់កម្រិត ការដាក់ពិន័យ និងទម្រង់គរុកោសល្យអវិជ្ជមានផ្សេងទៀតរបស់មនុស្សពេញវ័យ នឹងធ្វើឱ្យគេមានចិត្តសប្បុរសដែលប្រការនេះនឹងធ្វើឱ្យគេក្លាយជាមនុស្សពេញលក្ខណៈ ទទួលខុសត្រូវ និងមានបរទត្ថភាព (Selflessness)។

គំនិតរួមនៃការអប់រំមានបីចំណុចសំខាន់ៗ៖ (១) តួនាទីអប់រំរបស់ក្រុមគ្រួសារ ជាពិសេសគឺម្តាយ (២) ការគោរព និងការតាមដានការអភិវឌ្ឍធម្មជាតិរបស់កុមារ និង (៣) ការកែប្រែជាថ្មីរបស់សាលារៀន និងគោលដៅរបស់សាលារៀន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## តួនាទីអប់រំរបស់ក្រុមគ្រួសារ

ចំពោះ Ellen អ្នកអប់រំធម្មជាតិដំបូងគេបំផុតរបស់កុមារគឺគេហដ្ឋាន។ «ការផ្លាស់ប្តូរសង្គមចាប់ផ្តើមជាមួយកុមារដែលត្រូវចាប់បដិសន្ធិពីផ្ទៃមាតាជាមួយនឹងលក្ខខណ្ឌនានាពាក់ព័ន្ធនឹងវត្តមាន ពាក់ព័ន្ធនឹងការអប់រំកាយសម្បទា និងការអប់រំផ្នែកស្មារតីរបស់គេ ក៏ដូចជាសភាវគតិថ្មីៗ មនោរម្មណ៍ថ្មីៗ គំនិតថ្មីៗចម្លងពីមាតាបិតា នៅក្នុងសាច់ និងឈាមរបស់កុមារទាំងអស់នេះនឹងប្រែក្លាយអត្តិភាពរបស់កុមារ។ មាតាបិតាបង្កើតបរិយាកាសល្អដល់សកម្មភាពដោយឯកឯង (spontaneity) របស់កុមារដើម្បីឱ្យគេក្លាយទៅជាមនុស្សពេញលក្ខណៈទៅថ្ងៃអនាគត។ ចំពោះ Ellen កុមារត្រូវរៀនគោរពមាតា បិតា និងអ្នកនៅជុំវិញខ្លួន។ កុមារមិនអាចទទួលបានការអប់រំបុគ្គលិកលក្ខណៈនោះទេ ប្រសិនបើគេមិនត្រូវបានគោរពតាមរយៈសិទ្ធិរបស់គេហើយ ប្រសិនបើគេមិនបំពេញបាននូវកាតព្វកិច្ចរបស់គេដោយខ្លួនឯងទេនោះ។

លោកស្រីគិតថាការធ្វើឱ្យកុមាររស់ក្នុងសាមញ្ញភាពមានសារៈសំខាន់ជាង ក៏ព្រោះថាកុមាររៀនស្គាល់គុណតម្លៃរបស់វត្ថុនានា និងមជ្ឈត្តិកភាព (ការចេះប្រមាណ moderation)។ ដូចលោក Rousseau ដែរ លោកស្រី Ellen បានផ្តល់តួនាទីយ៉ាងសំខាន់ដល់មាតាក្នុងការអប់រំបុគ្គលិកលក្ខណៈរបស់កុមារ។ លោកស្រី Ellen តស៊ូដើម្បីឱ្យមាតាមានតួនាទីនៅក្នុងគ្រួសារឡើងវិញ។ លោកស្រីចង់ឱ្យគុណតម្លៃរបស់ស្ត្រីត្រូវបានទទួលស្គាល់ដោយស្ត្រី និងបុរស។ លោកស្រីមិនប្រឆាំងនឹងការងារនៅក្រៅផ្ទះសម្រាប់នារីនោះទេ។ លោកស្រីជឿជាក់ថាសេចក្តីស្រលាញ់របស់មាតា ការថ្នាក់ថ្នមបមបីដែលមាតាមានចំពោះបុត្រាបុត្រីគឺចាំបាច់បំផុតសម្រាប់ការរីកលូតលាស់ធំធាត់របស់បុគ្គលទៅតាមទស្សនៈរបស់ Goethe។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ការគោរព និងការតាមដានការអភិវឌ្ឍដោយធម្មជាតិរបស់កុមារ

ក្នុងជំពូកនិយាយពីការអប់រំ លោកស្រីEllen បានដាក់ចេញជាគោលការណ៍សំខាន់ៗរបស់លោកស្រីគាត់ច្រើន ដោយផ្អែកលើមូលដ្ឋានចេញពីអំណានស្នាដៃរបស់ Rousseau និង Goethe។ តាមទស្សនៈរបស់ Rousseau និង Goethe មានអំណោយផលធម្មជាតិវិជ្ជមាននៅក្នុងខ្លួនរបស់កុមាររួចទៅហើយ។ តួនាទីរបស់មនុស្សពេញវ័យគឺបង្កើតឱ្យមានបរិយាកាសល្អសម្រាប់ឱ្យអំណោយផលធម្មជាតិនោះលេចចេញមកខាងក្រៅតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ការបង្កើតពិភពស្រស់ត្រកាលមួយដែលផ្ដល់ឱកាសដល់កុមារក្នុងការអភិវឌ្ឍខ្លួនគេ និងអាចឱ្យគេធ្វើចលនាដោយសេរីរហូតដល់ពេលមួយដែលគេទៅប៉ះនឹងព្រំដែន ដែលមិនអាចបំពាន់បាននៃសិទ្ធិរបស់អ្នកដទៃនឹងក្លាយជាគោលដៅនៃការអប់រំនាពេលអនាគត។ លោកស្រី Ellen ប្រឆាំងនឹងគ្រប់អំពើហិង្សាលើផ្លូវចិត្ត និងផ្លូវកាយលើកុមារ។ លោកស្រីទាមទារឱ្យមានការរំលាយចោលគ្រប់ទម្រង់ទណ្ឌកម្មផ្នែករាងកាយនៅសាលារៀនក៏ដូចជានៅគេហដ្ឋាន។

ការអប់រំមានគោលដៅក្នុងការធ្វើឱ្យមនុស្សមានបុគ្គលិកលក្ខណៈរឹងមាំ ការអប់រំតម្រូវឱ្យកុមារយល់ដឹងពីក្រឹត្យក្រមផ្សេងៗក៏ដូចជាក្រឹត្យក្រមពាក់ព័ន្ធនឹងសេរីភាពអ្នកដទៃ។ មុនការលើកឡើងរបស់ Sartre ទៅទៀត លោកស្រី Ellen បានកំណត់ព្រំដែនសេរីភាពមួយក្នុងគោលបំណងពង្រីកទស្សនៈរបស់លោកស្រីដោយគ្មានទីបញ្ចប់។ អ្នកអប់រំមានតួនាទីក្នុងការតាមដានកុមារដោយសុទ្ធចិត្ត និងដោយម៉ឺងម៉ាត់ គឺជាអ្នកដែលផ្ដល់នូវតុល្យភាពត្រឹមត្រូវរវាងចេតនានៃអំណាចដូចដែលលើកតម្កើងដោយ Nietzsche និងការសម្របខ្លួនទៅនឹងលក្ខខណ្ឌខាងក្រៅនានាដូចជាអ្វីដែលបានលើកឡើងដោយ Spencer។ ដូច្នេះការអប់រំបុគ្គលិកលក្ខណៈត្រូវបំពេញតួនាទីក្នុងការរក្សាបានតុល្យភាពដ៏សុខដុមគ្រប់សមាសភាពដូចបានរៀបរាប់ខាងដើម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ការកែប្រែជាថ្មីគោលដៅរបស់សាលារៀននិងការអនុវត្តគរុកោសល្យ

តាមទស្សនៈរបស់លោកស្រី Ellen «L'école de l'avenir (សាលារៀននាពេលអនាគត)» មានគោលបំណងក្នុងការតាមដានដោយប្រុងប្រយ័ត្នចំពោះកុមារ ក្នុងការប្រែក្លាយខ្លួនឱ្យទៅជាមនុស្សពេញវ័យដោយសេរី និងរីកលូតលាស់ ប្រកបដោយស្មារតីគិតគូពីអ្នកដទៃតាមរយៈការអភិវឌ្ឍ និងការបញ្ចេញអាកប្បកិរិយា និងបញ្ញាញាណដោយលក្ខណៈធម្មជាតិ។ សាលារៀនអនាគត គឺជាសាលារៀននៃយុត្តិធម៌សង្គម និង ជាសាលារៀនមួយដែលបើកទ្វារសម្រាប់ទាំងក្មេងប្រុស និងក្មេងស្រី សម្រាប់កុមារត្រកូលអភិជន និងសម្រាប់កុមារកូនកម្មករ។

ចំពោះ Ellen មាតាមួយរូបមានសមត្ថភាពក្នុងការបង្រៀនតាមបែបសាមញ្ញ តាមបែបហ្មត់ចត់ និងដោយយកចិត្តទុកដាក់រាល់ចង្វាក់នៃការវិវឌ្ឍរបស់កុមារ។ កុមារអាចចូលរៀននៅសាលារៀននៅអាយុត្រឹមត្រូវសម្រាប់គេ។ មិនមានកម្មវិធីជាប្រព័ន្ធ (systematic) រហូតដល់កុមារអាយុ ១៥ ឆ្នាំនោះទេ គឺជាថ្នាក់រៀនដែលមានក្មេងប្រុស និងក្មេងស្រីលាយគ្នា ហើយដែលបង្រៀនផ្នែកទ្រឹស្តី និងការអនុវត្ត។ គឺចាប់ពីអាយុ ១៥ ឆ្នាំនោះហើយ ដែលសិស្សលែងរៀននៅក្នុងថ្នាក់ធម្មតាដែលមានច្រើនកម្រិតថ្នាក់ តែពួកគេត្រូវរៀននៅក្នុងថ្នាក់ដែលមានបង្រៀនមុខវិជ្ជានៅក្នុងកម្មវិធីផ្សេងៗពីគ្នា។ លោកស្រីឱ្យឈ្មោះថ្នាក់ទាំងនេះថា ជាថ្នាក់អនុវត្ត។ ក្នុងសាលារៀននេះ លោកស្រីក៏បានត្រៀមទីកន្លែងផ្ទាល់ខ្លួនក្នុងថ្នាក់រៀន ដើម្បីឱ្យសិស្សម្នាក់ៗអាចរៀនដោយខ្លួនឯង។ សាលារៀនក្នុងថ្ងៃអនាគតមានគោលបំណងផ្តល់ការអប់រំសម្រាប់បុគ្គលម្នាក់ៗ (individualisation) ទៅតាមគុណសម្បត្តិរបស់ខ្លួន។

## ១១. Heinrich PESTALOZZI (1746-1827)

សម្រាប់ខ្ញុំ គឺជាបទពិសោធន៍មួយដែលថាកុមារដែលបានបាត់បង់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សុខភាព កម្លាំងកាយ និងសេចក្តីក្លាហានក្នុងជីវិតខ្ពស់ខ្ពង់ និងឥតបានការស្រាប់តែនៅពេលដែលពួកគេត្រូវបានដាក់ក្នុងស្ថានភាពឱ្យធ្វើការងារជាប្រចាំ ពួកគេក៏មានភាពសប្បាយរីករាយ គំនិតក៏ថ្លា ទឹកមុខស្រស់ស្រាយឡើងវិញ ហើយមានការអភិវឌ្ឍខ្លួនឯងតាមរបៀបគួរឱ្យភ្ញាក់ផ្អើល ដោយគ្រាន់តែតាមរយៈការប្តូរផ្លាស់នៃស្ថានភាពរបស់ពួកគេតែប៉ុណ្ណោះ៖ កុំឱ្យគេស្ថិតនៅក្នុងលក្ខខណ្ឌដែលនាំឱ្យពួកគេដើរលើផ្លូវខុស(ខូច)។ សម្រាប់ខ្ញុំគឺជាបទពិសោធន៍មួយដែលថាកុមារផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវអារម្មណ៍ជាមនុស្សជាតិ ជឿជាក់ និងប្រុងប្រយ័ត្ន ថាភាពស្និទ្ធស្នាលបង្ហាញចេញជាបន្ទាល់ទៅកាន់សការៈដែលបាក់ទឹកចិត្តខ្លាំងបំផុតនោះនឹងធ្វើឱ្យជីវិតរបស់គេមានការប្រសើរឡើង ហើយថាភ្នែករបស់កុមារដែលត្រូវបានគេបោះបង់នឹងបញ្ចេញពន្លឺភ្ញាក់ផ្អើលយ៉ាងរីករាយ និងកត្តញ្ញូតាធម៌ នៅពេលដែលមានដៃដ៏ស្រទន់ និងភាតរភាពមួយហុចទៅឱ្យគេដើម្បីដឹកនាំពួកគេ បន្ទាប់ពីការរស់នៅក្នុងជីវិតទុរគតអស់ជាច្រើនឆ្នាំ (Prière aux amis et bienfaiteurs de l'humanité)។

ប៉ែសតាឡូហ្ស៊ី (Pestalozzi) គិតលើសពីនេះថាការអប់រំគឺជាមុខងារពលរដ្ឋមួយ ដែលអាចគំនត់ពីការពិតនៃគំនិតរបស់រដ្ឋមួយ (Dewey, ២០០៤: ៨៩)។ ដូចនេះ យើងអាចបង្កើតក្រមខ័ណ្ឌគំនិតមួយដែលផ្សារភ្ជាប់ការអប់រំទៅនឹងប្រជាពលរដ្ឋ។

ក្នុងស្នាដៃដ៏ល្បីរបស់លោកដែលមានឈ្មោះថា Lettre de Stans, 1799 លោក Pestalozzi បានបង្ហាញដល់ភ្ញៀវលោកម្នាក់នូវការពិសោធន៍ធ្វើឡើងជាមួយក្មេងកំព្រាក្នុងមជ្ឈមណ្ឌល Stans។ ស្នាដៃនោះគឺជាស្នាដៃមូលដ្ឋានស្តីពីការអប់រំផ្លូវចិត្តរបស់កុមារ។

លោកបានអនុវត្តក្នុងការតាក់តែងគោលការណ៍នៃ «ការអប់រំច្បាស់លាស់ និងតាមកម្រិត» គោលការណ៍នៃការបណ្តុះបណ្តាល និងអប់រំ «ធម្មជាតិ» ដោយផ្សារភ្ជាប់ និងអភិវឌ្ឍប្រកបដោយសុខដុមរមនានូវអំណោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផលពីធម្មជាតិនៃខួរក្បាល និងបេះដូង (សមាសភាពបញ្ញាញាណ សាសនា និងផ្លូវចិត្ត) ព្រមទាំងអំណោយផលពីធម្មជាតិនៃដៃ (ដៃសម្បទា)។ គឺតាមរយៈស្ថានភាពទាំងនេះហើយដែលចេញជារូបមន្តក្នុងការធ្វើសាលារៀនៈ រៀនជាមួយក្បាល បេះដូង និងដៃ។

## ពីនរវិទ្យាទៅទ្រឹស្តីគរុកោសល្យ

ចំណុចស្នូលនៃស្នាដៃរបស់លោកស្ថិតនៅត្រង់ការស្វែងរកខ្លឹម និងធម្មជាតិរបស់មនុស្ស។ លោក Pestalozzi បានចាត់ទុកសញ្ញាណនៃធម្មជាតិជាចំណុចស្នូលនៃការផ្តល់និយមន័យមនុស្សរបស់គាត់។ លោក Pestalozzi គឺជាអ្នកគាំទ្រទស្សនៈ និងចក្ខុវិស័យក្លីស្វាងស្តីពី «ធម្មជាតិបរិសុទ្ធ» នៃមនុស្សរបស់ Rousseau»។ ដោយផ្អែកលើចក្ខុវិស័យបន្តបន្ទាប់គ្នាទាំងបីរបស់មនុស្ស «ស្នាដៃធម្មជាតិ» «ស្នាដៃសង្គម» និង«ស្នាដៃខ្លួនឯងផ្ទាល់» គេអាចបែងចែកទស្សនៈខុសគ្នាស្តីពីសាលារៀន និងការអប់រំ។

## «ធម្មជាតិបរិសុទ្ធ» នៃមនុស្ស និងការអប់រំ«ធម្មជាតិ»

នៅតាមគេហដ្ឋាននៅក្នុងស្នាដៃរបស់លោក Crépuscule d’un solitaire នៅឆ្នាំ ១៧៨០ លោក Pestalozzi បានចោទសំណួរស្តីពីខ្លឹមនៃមនុស្ស។ ចំពោះលោកខ្លឹមទេវ នៃមនុស្ស គឺនៅជាប់នឹងមនុស្ស ធម្មជាតិទេវ គឺមាននៅលើមនុស្សរួចស្រេចទៅហើយ។ តែប្រសិនបើ «មូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាល (Bildung) មនុស្សជាចំណុចស្នូលនៃធម្មជាតិរបស់យើង» នោះ វាពិតជាចាំបាច់ណាស់ ក្នុងការមានការអប់រំ «ធម្មជាតិ» ដែលត្រូវមានទម្រង់ស្ថាប័នសមស្របមួយដើម្បីធ្វើកិច្ចការនេះ ដូចជាគ្រួសារ ដែលជា «ឋានសួគ៌គ្រួសារ» តែមួយគត់នៅលើផែនដី ដែល «ទេវៈ» អាចបញ្ចេញមតិយោបល់របស់ខ្លួនទៅតាមអ្វីដែលខ្លួនចង់ ហើយប្រការនេះធ្វើឱ្យកុមារទទួលបាននូវសមត្ថភាពទាំងនោះ ប្រកបដោយប្រសិទ្ធភាព។ ចំពោះ Pestalozzi «ទេវៈ»



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លែងមាននៅក្នុងវិហារទៀតហើយ ប៉ុន្តែមាននៅក្នុងធម្មជាតិរបស់មនុស្ស។ គឺមានតែគេហដ្ឋានប៉ុណ្ណោះ ដែលអាចធានាភាពចាំបាច់ «តុល្យភាពនៃសមត្ថភាពរបស់មនុស្ស» និងផ្តល់«វិន័យនៃពិភពខាងក្នុងខ្លួនយើង» បាន ក៏ព្រោះថា «កម្មវត្ថុនៃការងារ ដែលមាននៅឯគេហដ្ឋានអាចបង្ហាត់បង្រៀនមនុស្សនៅពេលតែមួយលើ ផ្នែកក្បាល បេះដូង និងដៃ»បាន។

តាមទស្សនៈ Pestalozzi គ្រូបាអាចារ្យទទួលខុសត្រូវលើការកសាងបេះដូង ការកសាងបេះដូងនេះមានប្រភពនៅក្នុងទំនាក់ទំនងរបស់កុមារទៅម្តាយ និងឪពុក ក្នុងការរស់នៅដោយផ្ទាល់ក្នុងជីវភាពគ្រួសារ។ ការបណ្តុះបណ្តាលឱ្យយល់ ដែលជាដំណាក់កាលទី ២ មានប្រភពក្នុងការពិសោធន៍វេទយិត (sensitivity) នៃវត្ថុដែលនៅជុំវិញខ្លួន។ សាលារៀនដែលជាស្ថាប័នសាធារណៈគឺជាអ្វីដែលប្រឆាំងទៅនឹងធម្មជាតិមនុស្ស។ សាលារៀនប្រឈមនឹងកង្វះមាត៌ាដែលធម្មជាតិបានកំណត់។

## ស្ថានភាពដើមរបស់មនុស្សនិងភាពចាំបាច់នៃសាលារៀន

តើអំណាចនៃការៈអាក្រក់មកពីណានៅលើផែនដី ជាសំណួរដែលត្រូវបានចោទសួរនៅពេលមានហិង្សា និងភាពសាហាវយង់ឃ្នងជាច្រើនដែលកើតចេញពីបដិវត្តន៍បារាំង ហេតុអ្វីទំនៀមទម្លាប់ព្រៃផ្សៃសាហាវយង់ឃ្នងកើតមានក្នុងសម័យកាលរបស់លោក? ការទទួលយកគំនិតដែលថាសភាវគតិរបស់មនុស្សប្រាកដជាអាចដាក់ស្របបាន លោកបានកែប្រែទស្សនវិស័យរបស់លោកពាក់ព័ន្ធនឹងការកំណត់និយមន័យនៃការអប់រំ។ លោក Pestalozzi មើលឃើញកាន់តែច្បាស់ពីភាពចាំបាច់នៃស្ថាប័នសាធារណៈទទួលបន្ទុកការងារអប់រំ។

នៅដំបូងទី លោកមិនទាន់គិតទៅដល់សាលារៀននោះទេ តែគ្រាន់តែគិតទៅដល់ស្ថាប័នសាធារណៈ គិតទៅដល់«ស្ថាប័នដែលមានផ្តល់ជំនួយនិងជំបូន្មានដល់មនុស្ស ដើម្បីស្តារសន្តិសុខសាធារណៈឡើងវិញ»។ ក្នុងន័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះ លោក Pestalozzi បានលើកចេញសមាសភាពចំនួនពីរដែលប្រឆាំងគ្នាក្នុងធម្មជាតិមនុស្ស។ ជាមួយនឹងទស្សនៈបុគ្គល «ទេវ» នៅក្នុងស្នូលលោកបានបែងចែកកាន់តែច្បាស់ចំណែកខាងសភាវគតិ និងចំណែកខាងភាពព្រៃផ្សៃ នៅក្នុងខ្លួនមនុស្ស។ ឥទ្ធិពលអវិជ្ជមាននៃកំហុសរបស់សង្គមបានបង្កឱ្យមានផ្នែកមួយបន្ថែមនៅក្នុងធម្មជាតិរបស់មនុស្សដែលរីងរូចទៅហើយ ដោយប្រការនេះ បានធ្វើឱ្យសារជាតិល្អរបស់មនុស្សត្រូវគ្របដណ្ដប់បាត់ ហើយលេចចេញមកខាងក្រៅនូវសារជាតិអាក្រក់វិញ។

លោក យ ល់ថាការស្ដារឡើងវិញនូវក្រឹត្យក្រមសីលធម៌អាចធ្វើបានតាម រ យៈការអនុវត្តវិធានម៉ឺងម៉ាត់នានាក្នុងការអប់រំនិងក្នុងការសិក្សា។ ដោយសារតែមនុស្សប្រព្រឹត្តខ្លួនទៅតាមទង្វើអាក្រក់ពីធម្មជាតិរបស់ខ្លួន ដូច្នេះ សង្គមត្រូវធ្វើអន្តរាគមន៍លើបញ្ហានេះ។ ត្រូវបង្កើតសាលារៀនដើម្បីធ្វើឱ្យមនុស្សដើរលើផ្លូវត្រូវ «ធម្មជាតិត្រឹមត្រូវ»។ តែក៏មានហេតុផលបន្ថែមក្នុ ង តម្រូវការសាលារៀនជាបន្ទាន់ដែលត្រូវរៀបចំដោយរដ្ឋ។ ប្រឈមមុខនឹងសង្គមមួយដែលមានសសរស្តម្ភរង្គោះរង្គើ សាលារៀនមានភារកិច្ចបន្ថែមដែលត្រូវបំពេញ៖ សាលារៀនត្រូវអនុវត្តតួនាទីកែលម្អសង្គម។ ចាប់ពីពេលនោះមក លោក Pestalozzi បោះបង់ចោលគំនិតដែលថាការអប់រំត្រូវធ្វើតាមរយៈគ្រួសារ ហើយផ្ដល់អាទិភាពការអប់រំដោយសាលារៀនវិញ។ លោក Pestalozzi ផ្ដល់តួនាទីដល់សាលារៀនក្នុងការផ្សាំងមនុស្ស ។

## បុគ្គលជាប្រធានបទនៃការបណ្ដុះបណ្ដាល

ស្នាដៃរបស់លោក Pes talozzi ដែលមានចំណងជើងថា Recherches sur la marche de la nature dans le développement du genre humain នាឆ្នាំ ១៧៩៧ បញ្ជាក់ពីរបត់ថ្មីនៃទស្សនៈរបស់លោក។ គឺជាទស្សនៈចាស់ទុំរបស់ Pestalozzi។ ស្នាដៃនេះធ្វើឱ្យលោកចាកចេញពីទស្សនៈប្រឆាំងគ្នាពីមុន«ធម្មជាតិបរិសុទ្ធ» និង «ធម្មជាតិព្រៃផ្សៃ» របស់មនុស្ស ព្រមទាំងធ្វើឱ្យលោកអាចបង្កើតនូវ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទស្សនៈទេវនិយមនៃមនុស្ស។ ចាប់ពីពេលនោះមក លោក Pes talozzi បាន បញ្ចូលទៅក្នុងទស្សនៈស្តីពីធម្មជាតិរបស់លោកនូវទស្សនអភិវឌ្ឍ។

នៅក្នុងស្នាដៃនោះ គេអាចមើលឃើញផែនការចំនួន ៣៖ ទីមួយ ការអភិវឌ្ឍមនុស្សទាំងមូលទីពីរការអភិវឌ្ឍបុគ្គលទីបីដំណើរវិវឌ្ឍន៍នៃការគិតពិចារណារបស់អ្នកនិពន្ធខ្លួនឯង។តាមរយៈស្នាដៃនេះគេសង្កេតឃើញមានទិដ្ឋភាពចំនួន៣៖ ទិដ្ឋភាពធម្មជាតិ ទិដ្ឋភាពសង្គម និងទិដ្ឋភាព សីលធម៌។

ក្នុងករណីទី១ លោក Pestalozzi ជឿជាទីងឃើញវឌ្ឍនភាពមនុស្សជាតិចាប់តាំងពីដំណាក់កាលទាបអន់រហូតដល់ដំណាក់កាលខ្ពស់រឹងមាំ កើតមានសារចុះសារឡើងក្នុងវឌ្ឍនភាពនៃមនុស្ស។ លោក Pestalozzi បកស្រាយដំណាក់កាលខុសៗគ្នា ចាប់ពីទិដ្ឋភាពធម្មជាតិរហូតដល់ទិដ្ឋភាព សីលធម៌របស់មនុស្ស ដោយឆ្លងតាមទិដ្ឋភាពសង្គម។ លោកបានចាត់ទុកកុមារគ្រប់អាយុត្រៀមចូលសាលារៀនជានៅក្នុងទិដ្ឋភាពធម្មជាតិ ចាត់ទុកកុមារចូលរៀននៅក្នុងសាលាជានៅក្នុងទិដ្ឋភាពសង្គមនិងចុងក្រោយចាត់ទុកមនុស្សពេញវ័យជានៅក្នុងទិដ្ឋភាពសីលធម៌ (Recherche)។

គោលគំនិតទី២ ទទួលស្គាល់សត្វលោកដែលចូលរួមក្នុងទិដ្ឋភាពទាំងបីនៅក្នុងខ្លួនមនុស្ស។ ក្នុងទិដ្ឋភាពសីលធម៌ មនុស្សនៅជិតដាមក្នុងសារជាតិធម្មជាតិ និងសារជាតិសង្គមរបស់ខ្លួន តែក៏លែងត្រូវបានកំណត់ដោយភាពជិតដាមនោះទៀតហើយដែរ៖ តាមរយៈការអនុវត្តនៃឆន្ទៈរបស់គេ មនុស្សមានសមត្ថភាពទទួលខុសត្រូវក្នុងការគ្រប់គ្រងទិដ្ឋភាពទាំងពីរនៃសារជាតិរបស់ខ្លួន។

តាមរយៈគោលគំនិតនវវិទ្យានៃមនុស្សរបស់លោក លោក Pestalozzi ដាក់មនុស្សឱ្យឯករាជ្យពីក្រឹត្យក្រមលើធម្មជាតិ ហើយទទួលស្គាល់ញាណសតិក្នុងការអភិវឌ្ឍខ្លួនដោយខ្លួនឯង។

## វិធីសាស្ត្របឋម

លោក Pestalozzi មានការចាប់អារម្មណ៍ខ្លាំងទៅលើបញ្ហាវិធីសាស្ត្រដែលត្រូវប្រើប្រាស់ក្នុងការអប់រំ និងការណែនាំ។ លោកចម្លងទស្សនៈវិទ្យាសាស្ត្រក្នុងសម័យកាលនោះ ដែលយល់ថាភាពសាំញ៉ាំអាចដោះស្រាយបានដោយប្រមូលផ្តុំសមាសធាតុបឋម។

### ១. ការបណ្តុះបណ្តាលបឋមផ្នែកបញ្ញា

លោក Pestalozzi បានផ្តោតការចាប់អារម្មណ៍ជាពិសេសទៅលើទិដ្ឋភាពសីលធម៌ ដែលត្រូវបានចាត់ជាទម្រង់ខ្ពស់បំផុតដែលត្រូវសម្រេចឱ្យបានក្នុងការអប់រំមនុស្ស។ ការអប់រំ និងការណែនាំត្រូវគោរពទៅតាមធម្មជាតិ មានន័យថាដំបូងបង្អស់ មិនត្រូវធ្វើអន្តរាគមន៍ដោយដាច់ណាត់នោះទេ។ ដូច្នេះ អ្វីដែលត្រូវធ្វើនោះ គឺការចេះទទួលស្គាល់គ្រប់ឧបនិស្ស័យពីកំណើតគ្រប់សម្បទាដែលបង្ហាញចេញដោយកុមារ និងក្មេងជំទង់ ដើម្បីជួយគាំទ្រ និងជួយជំរុញពួកគេ។ ការអប់រំមិនត្រូវបញ្ចូលនូវអ្វីដែលចម្លែកសម្រាប់មនុស្សនោះឡើយ។

### ២. វិធីសាស្ត្របឋមក្នុងផ្នែកសីលធម៌

ក្នុងស្នាដៃដ៏ល្បីរបស់លោកក្រោមចំណងជើងថា Lettre de Stans សរសេរទៅកាន់មិត្តម្នាក់របស់លោកបន្ទាប់ពីបានដកពិសោធន៍នៅមជ្ឈមណ្ឌលកុមារកំព្រា Stans លោកបានបង្ហាញដោយលម្អិតទ្រឹស្តី និងវិធីសាស្ត្ររបស់លោកក្នុងការអប់រំផ្នែកសីលធម៌។

មុននឹងដល់វិធានអប់រំផ្សេងៗទៀត លោកគិតថាវាចាំបាច់ណាស់ក្នុងការឆ្លើយតបទៅនឹងតម្រូវការចាំបាច់បំផុតរបស់កុមារ ដោយក្នុងនោះត្រូវចាត់ជាអាទិភាពនូវសមាសភាពក្នុងការផ្តល់អាហារ ផ្តល់សម្លៀកបំពាក់ និងផ្តល់ភាពកក់ក្តៅដល់ពួកគេ (រស់នៅដោយមានភ្លើងកម្តៅនៅពេលរងារ)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាជាងការផ្តល់មេរៀនផ្នែកសីលធម៌ជាពាក្យសម្តីដល់សិស្ស ដូចជាការស្តីបន្ទោសពីការដែលពួកគេប្រព្រឹត្តខុសមិនល្អ លោករិះរកជាដំបូងនូវវិធីក្នុងការយកបេះដូងសិស្សៗ បន្ទាប់មក ក្រោយពីបានកសាងទំនាក់ទំនងទំនុកចិត្តរវាងគ្នានឹងគ្នា លោក Pestalozzi ទុកមួយឡែកវិធីសាស្ត្របច្ចេកទេសណែនាំ«សើរៗ» លោកមិនប្រើសៀវភៅហើយក៏មិនប្រើសម្ភារឧបទេសផ្សេងទៀតនោះដែរ។ លោកយកឱកាសនៃភាពចាំបាច់ប្រចាំថ្ងៃនៃជីវិតដើម្បីផ្សារភ្ជាប់ជាមួយគុណតម្លៃនៃការអប់រំវិញ។ លោកបានបែងចែកកិច្ចការដែលត្រូវធ្វើនៅផ្ទះ និងនៅក្រៅផ្ទះរវាងសិស្សនិងសិស្ស ដោយចូលរួមគ្រប់ធម្មជាតិដែលមានជុំវិញខ្លួនរបស់ពួកគេ។

គឺតាមរយៈការងាររបស់សិស្សនេះហើយ ដែលធ្វើឱ្យពួកគេទទួលស្គាល់ភាពចាំបាច់នៃក្បួនច្បាប់ និងការទុកចិត្តគ្នាទៅវិញទៅមក។ ពួកគេសាកល្បងអនុវត្តកាតព្វកិច្ចចំពោះមុខក្បួនច្បាប់ខាងក្រៅ និងច្បាប់សារជាតុ (Substantive rule) ដែលចាត់ជាមូលដ្ឋានគ្រឹះនៃក្បួនច្បាប់សីលធម៌។ គឺនៅពេលដែលកុមារបានពិនិត្យពិច័យលើគុណប្រយោជន៍ទំនាក់ទំនងទៅវិញទៅមក ការជួយគ្នាទៅវិញទៅមក ការប្រកាន់សម្តីដើម្បីរស់នៅជាមួយគ្នាទាំងនោះហើយ ដែលលោក Pestalozzi សន្និដ្ឋានថាមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីឱ្យគេអាចគិតពិចារណាទៅលើគុណតម្លៃ និងអាចជជែកពិភាក្សាពីគុណតម្លៃនេះជាមួយកុមារបាន។

ដោយយកចេញពីការពិសោធនៅមជ្ឈមណ្ឌលកុមារកំព្រា Stans លោក Pestalozzi ពិពណ៌នាអភិក្រមរបស់លោកក្នុងការអប់រំសីលធម៌ តាមរបៀបមួយដែលអាចយកជាគំរូបាន។ លោកបានបែងចែកការអប់រំសីលធម៌ជាបីដំណាក់កាល៖ ដំណាក់កាលទី ១ គឺជាដំណាក់កាលដែលត្រូវយកចិត្តទុកដាក់ទៅលើគ្រប់តម្រូវការសម្ភារ និងជាដំណាក់កាលក្នុងការកសាងទំនុកចិត្ត បន្ទាប់មកឈានដល់ដំណាក់កាលទី ២ ដែលជាដំណាក់កាលក្នុងការពិសោធផ្លូវចិត្តតាមរយៈតថភាព ដែលកុមារត្រូវពិនិត្យពិច័យទៅលើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផលដែលកើតចេញពីសកម្មភាពផ្ទាល់របស់ខ្លួន និងការប្រព្រឹត្តខ្លួនរបស់គេ។ បន្ទាប់មកដំណាក់កាលទី ៣ ចូលមកដល់ គឺជាដំណាក់កាលក្នុងការគិតពិចារណាទៅលើបទពិសោធន៍ដែលបានធ្វើតាមរយៈសកម្មភាពនានា។

លោក Pestalozzi យល់ឃើញថាការអប់រំ និងការណែនាំគឺជាវិធីសាស្ត្រមួយ។ សម្រាប់លោក ការអប់រំ និងការណែនាំគឺជាផ្លូវមួយឆ្ពោះទៅការបណ្តុះបណ្តាលមនុស្ស គឺផ្លូវមួយដែលមនុស្សត្រូវមានមនសិការលើសម្បទារបស់ខ្លួនផ្ទាល់ ព្រមទាំងអាចអភិវឌ្ឍសម្បទាទាំងនោះទៅតាមមាត់នៃពលរដ្ឋសាកល។ ការអប់រំ និងការណែនាំគាំទ្រការបណ្តុះបណ្តាល ការអប់រំ និងការណែនាំផ្តល់ឱកាសដល់បុគ្គលគ្រប់រូបក្នុងការសម្រប និងបញ្ចូលខ្លួនទៅក្នុងពិភពជុំវិញ និងពិភពដ៏ធំទូលាយមួយ។ ចំពោះលោក Pestalozzi មនុស្សជាតិ និងការបណ្តុះបណ្តាលគឺជាវត្ថុដែលមិនអាចដកហូតចេញពីគ្នាបាន មនុស្សជាតិ និងការបណ្តុះបណ្តាលគឺជាក់ច្បាស់ណាស់ថាជា «ស្នាដៃរបស់ខ្លួនឯង»។

## ១២. Pauline KERGOMARD (1838-1925)

កុមារា កុមារីនៅមត្តេយ្យសិក្សាទទួលបាននូវការបង្រៀនមួយតាមបែបអរូបិយ។ ដូចជាប់ផុងនៅក្នុងសំណាញ់នៅអាយុពីរឆ្នាំ ពួកគេមិនមានឱកាសក្នុងការស្វែងយល់ពីខ្លួនឯងនោះទេ ហើយប្រសិនបើគេគិតពីអ្វីមួយ គឺប្រហែលជាគិតរឿងនេះ៖ «យើងនៅសាលារៀនដើម្បីឮអ្វីដែលយើងមិនយល់»។ផ្ទុយទៅវិញគេព្យាយាមដើម្បីយល់ពេលណាដែលគេចាប់អារម្មណ៍អ្វីមួយតាំងពីដើមទីមក ហើយថាការលំបាកនានានឹងលេចចេញមក៖ តែប្រសិនបើតាំងពីដើមទីមកមិនមានអ្វីដែលអាចយល់បានទេនោះ តើត្រូវធ្វើដូចម្តេច? ផ្ទុយទៅវិញ គេធ្វើដូចជាត្រង់ត្រាប់ស្តាប់ដោយអសកម្ម។ ខ្ញុំបារម្ភខ្លាចតែត្រូវទទួលរងការចោទប្រកាន់ទៀតពីភាពរឹងត្អឹង តែខណៈនេះ ខ្ញុំព្យាយាមធ្វើឱ្យមានប្រសិទ្ធភាពដូចជាគិលានុបដ្ឋាយិកា ដែលបានដាក់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របាយការណ៍នៃការសង្កេតរបស់ខ្លួនទៅគ្រូពេទ្យស្តីពីស្ថានភាពអ្នកជំងឺដែលគាត់ត្រូវព្យាបាល។ តើគិលានុបដ្ឋាយិកានេះចង់ឱ្យអ្នកជំងឺជាទេ? បើសិនជាចង់នាងត្រូវកត់ត្រាយ៉ាងផ្ចិតផ្ចង់រាល់ស្ថានភាពប្រែប្រួលទាំងអស់របស់អ្នកជំងឺ។ ខ្ញុំសូមគោរពអះអាងជូនលោករដ្ឋមន្ត្រីថាខ្ញុំមានក្តីសោមនស្សរីករាយជាខ្លាំងក្នុងការធ្វើការសង្កេតផ្សេងៗទៀត។(របាយការណ៍ស្តីពីសាលាមត្តេយ្យរបស់អគ្គនាយកដ្ឋានអប់រំក្រុង de Toulouse, de Clermont et de Bordeaux ខែធ្នូ ឆ្នាំ១៨៨១)។

បើទោះបីជាលោកស្រី Pauline Kergomard ត្រូវបានចាត់ទុកជាអ្នកបង្កើតសាលាមត្តេយ្យបារាំងទំនើប តាមរយៈឯកសារគតិយុត្តនានា ដូចជាក្រឹត្យដែលត្រូវបានចុះហត្ថលេខាតាមរយៈការជំរុញរបស់លោកស្រីខ្លួនឯងផ្ទាល់ និងត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៨២៨ ដោយ Jules Ferry ក៏ពិតមែន តែគឺលោកស្រី Marie Pape-Carpantier ដែលជាអ្នកទីមួយក្នុងការទាមទារឱ្យមានការផ្លាស់ប្តូរពីឈ្មោះ «salle d'asile (បន្ទប់ជ្រកកោន)» មកជា «école maternelle (សាលាមត្តេយ្យ)»។ លោកស្រី Pape-Carpantier ពិចារណាលើវិធីសាស្រ្តធម្មជាតិ ជាមួយនឹងគរុកោសល្យដែលធ្វើឱ្យកុមារក្លាយជាតួអង្គក្នុងការសិក្សារៀនសូត្ររបស់គេ គឺមិនមែនគ្រាន់តែជាអ្នកប្រើប្រាស់នូវសេវានេះនោះទេ។ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ១៨៨១ Jules Ferry បានចុះហត្ថលេខាលើក្រឹត្យកែប្រែឈ្មោះរបស់ «បន្ទប់ជ្រកកោន» ទៅជា «សាលាមត្តេយ្យ»វិញ។ នៅក្នុងក្រឹត្យដដែលនេះ លោកបានរៀបចំឡើងវិញនូវប្រព័ន្ធអធិការកិច្ចទូទៅសម្រាប់សាលាមត្តេយ្យ និងបានចាត់តាំងលោកស្រី Pauline Kergomard ជាអគ្គាធិការ។

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៨៧០ Jules Ferry ពេលមកកាន់តំណែងនៅក្រសួងអប់រំសាធារណៈ ក៏បានក្លាយទៅជាបិតាស្ថាបនិកសាលាបារាំងទំនើបដោយអនុវត្តជាពិសេសនូវអ្វីដែលអ្នកជំនាន់មុនរបស់លោកបានគិត។ លោកបានគូសវាសនូវគន្លងនាទីដាច់ដោយឡែករបស់សាលារៀនធៀបនឹង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្ថាប័នផ្សេងទៀត ជាមួយនឹងពាក្យគន្លឹះចំនួនបី «អាន សរសេរ រាប់លេខ»។ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៨៨១ លោកបានដាក់ឱ្យអនុវត្តនូវក្រឹត្យស្ដីពីសាលារៀនមិនបង់ថ្លៃ នៅថ្ងៃទី២៨ ខែមិនា ឆ្នាំ១៨៨២ សាលារៀនបែបអាណាចក្រក្លាយទៅជាកាតព្វកិច្ចសិក្សាសម្រាប់កុមារពីអាយុ ៦ ដល់ ១៣ ឆ្នាំ។ បន្ទាប់ពីនោះមក លោកបានធ្វើចលនាយ៉ាងធំមួយដើម្បីកសាងសាលារៀន។ Jules Ferry គិតគូពីបេសកកម្មរបស់គ្រូបង្រៀន និងពីលក្ខណសម្បត្តិរបស់គ្រូបង្រៀន។ នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៨៨០ លោកបានលើកឡើងក្នុងសមាជនាយកសាលាគរុវិជ្ជាថា៖ «យើងចង់ឱ្យអ្នកទាំងអស់គ្នាមិនត្រឹមគ្រាន់តែបំពេញតួនាទីជាគ្រូបង្រៀននោះទេ តែត្រូវបំពេញតួនាទីជាអ្នកអប់រំផង»។

## ពីការអប់រំបែបម្ដាយ ទៅជាការអប់រំបែបមត្តេយ្យ

លោកស្រី Pauline Kergomard បានសង្កត់ធ្ងន់ទៅលើវិធីសាស្ត្រអប់រំបារាំង ធៀបជាមួយនឹងវិធីសាស្ត្រអប់រំអាល្លឺម៉ង់របស់សាលា Fröbel។ Friedrich Fröbel (១៧៨២-១៨៥២) ត្រូវបានចាត់ទុកជាស្ថាបនិកសួនកុមារជាមួយនឹងឧបករណ៍ល្បែងពិសេសរបស់គាត់ ដែលទទួលបានជោគជ័យយ៉ាងត្រចះត្រចង់តាមរយៈការចេញនូវទស្សនវិជ្ជាបង្កើតសួនកុមារ និងវិធីសាស្ត្រដែលមានរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នាបានយ៉ាងល្អ។ ក្រោមឥទ្ធិពលរបស់លោក Pestalozzi លោក Fröbel បានបង្កើតសាលាឯកជនដោយឈរលើគំរូលក្ខណៈគ្រួសារ។ សាលា Keilhau គឺជាគ្រួសារធំមួយដែលការបង្រៀនរួមមានការណែនាំ និងការអប់រំ តាមទស្សនវិជ្ជាសាកលរបស់ Fröbel។ ទស្សនវិជ្ជានេះបង្រៀនសិស្សឱ្យដឹងពីអត្ថិភាពនៃសម្បទារបស់គេ និងពីពិភពវត្ថុព្រមទាំងបាតុភូតនានាដែលបង្កើតឡើងដោយច្បាប់ធម្មជាតិជាទូទៅ និងចាំបាច់នានា។ មានន័យថា ជាការអប់រំសាកល និងវិទ្យាសាស្ត្រដែល Fröbel ស្នើឡើងសម្រាប់ការសិក្សារៀនសូត្ររបស់សិស្ស។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំពោះ Kergomard ឯណោះវិញ គរុកោសល្យបែបនេះមិនអាចអនុវត្តបាននៅក្នុងវប្បធម៌បារាំងទេ។ លោកស្រីបានសរសេរនៅក្នុងរបាយការណ៍ថា៖ «ខ្ញុំបានឃើញកុមារអាយុប្រាំឆ្នាំដ៏កំសត់រៀនធរណីមាត្រជាច្រើនម៉ោង ខ្ញុំមិនឃើញកុមារណាម្នាក់អាចបញ្ចេញគំនិតដោយឯកឯងបាននោះឡើយ ខ្ញុំក៏មិនបានឃើញពន្លឺបញ្ញាញាណអ្វីសោះនៅក្នុងកែវភ្នែករបស់ពួកគេ»។ លោកស្រីបានធ្វើការកត់សម្គាល់ថាម្តាយជនជាតិអាល្លឺម៉ង់ម្នាក់មិនបង្រៀនកូនខ្លួន ដោយប្រើប្រាស់វិធីសាស្ត្រដូចគ្នាជាមួយម្តាយជនជាតិបារាំងនោះទេ ក្នុងន័យនេះហើយ ដែលសាលាមត្តេយ្យ ដែលយកគំរូតាមវិធីសាស្ត្រអប់រំរបស់ម្តាយត្រូវមានលក្ខណៈដាច់ដោយឡែកសម្រាប់វប្បធម៌នីមួយៗ។

សម្រាប់លោកស្រី គេត្រូវអភិវឌ្ឍសុខភាពរាងកាយតាមរយៈល្បែង ក៏ព្រោះថាសុខភាពរាងកាយនេះធានានូវសុខភាពផ្លូវចិត្ត ហើយជាពិសេសត្រូវប្រើប្រាស់ភាសាកុមារដើម្បីឱ្យពួកគេចេះធ្វល់ចង់ដឹងចង់ឮ តាមរយៈមេរៀនខ្លីៗ ច្បាស់លាស់ រស់រវើក និងរូបិយ ដោយចៀសវាងគ្រប់អ្វីៗដែលជាអរូបិយ។ លោកស្រីក៏បានផ្សារភ្ជាប់មេរៀនប្រវត្តិវិទ្យា ភូមិវិទ្យា ឬប្រវត្តិធម្មជាតិខ្លីៗ ទៅនឹងល្បែងកម្សាន្តដែលលោកស្រីយកគំរូពី Fröbel។ លោកស្រីនាយិកាទុកពេលឱ្យកុមារក្នុងការសង្កេត និងទាញចេញជាអនុមាន ក្នុងការសិក្សារបស់កុមារ ដោយមិនប្រញាប់ប្រញាល់ពេកក្នុងការបង្រៀនមេរៀនបែបចងចាំច្រើនដែលនាំឱ្យបាត់បង់ភាពសោមនស្សរីករាយក្នុងការលេងផងរៀនផងរបស់កុមារ។ សរុបមក «ទុកឱ្យកុមារធ្វើអ្វីដែលជាការងាររបស់គេ ដើម្បីឱ្យពួកគេក្លាយជាមនុស្សពេញលេញ គេអាចធ្វើអ្វីដែលមនុស្សពេញលេញត្រូវធ្វើ»។ លោកស្រីតស៊ូដើម្បីឱ្យនាយិកាទទួលបានការបណ្តុះបណ្តាលទៅលើចំណេះដឹងចិត្តសាស្ត្ររបស់កុមារ និងចំណេះដឹងពាក់ព័ន្ធនឹងការអភិវឌ្ឍកុមារ។ ទស្សនៈគំរូរបស់លោកស្រីស្តីពីអ្នកអប់រំ គឺជាទស្សនៈដែលផ្តោតលើ«ម្តាយធ្វាតវៃ និងមានកក្តីភាព»។ គឺជាអ្នកអប់រំដែលយកចិត្តទុកដាក់លើការថែទាំដែលគេត្រូវផ្តល់ដល់កុមារមុនអ្វីៗទាំងអស់។ សម្រាប់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោកស្រីស្រលាញ់កុមារឱ្យដូចម្តាយស្រលាញ់កូន គឺមានន័យថាត្រូវមើលថែកុមារដោយប្រុងប្រយ័ត្ន និងដោយល្អិតល្អន់ផ្នែកការអភិវឌ្ឍរាងកាយ ចិត្តគំនិត និងបញ្ញារបស់កុមារ ដោយត្រូវបង្កើតបរិយាកាសសមស្រប សម្រាប់គេ និងដោយការពារពួកគេផង។

## ១៣. Maria MONTESSORI (1870-1952)

ដំណាក់កាលសំខាន់បំផុតក្នុងជីវិតស្ថិតនៅចន្លោះការប្រសូតចេញពីផ្ទៃម្តាយទៅដល់អាយុ ៦ ឆ្នាំ ហើយគឺមិនស្ថិតនៅក្នុងពេលរៀននៅសាកលវិទ្យាល័យនោះទេ។ ដូច្នេះ ដំណាក់កាលនេះគឺជាឱកាសដែលសមាសធាតុសំខាន់របស់មនុស្ស និងបញ្ញាស្មារតីកំពុងរីកចម្រើនល្អតលាស់។ មិនត្រឹមតែបញ្ញាស្មារតីរបស់គេនោះទេ កំប៉ុន្តែគឺគ្រប់សមត្ថភាពរាងកាយថែមទៀតផង។ មិនមានអាយុណាផ្សេង ដែលកុមារត្រូវការជំនួយផ្នែកបញ្ញាស្មារតីខ្លាំងដូចនៅដំណាក់កាលនេះទេ ហើយប្រសិនបើមានឧបសគ្គអ្វីមួយរារាំងការងារច្នៃប្រឌិតរបស់គេហើយនោះ នោះនឹងធ្វើឱ្យឱកាសក្នុងការកសាងខ្លួនឱ្យបានប្រសើរបំផុតរបស់គេនឹងត្រូវថមថយ (L'Esprit absorbant de l'enfant)។

លោកស្រី Maria Montessori គឺនិមិត្តរូបនៃគរុកោសល្យដ៏ល្បីដែលនៅតែមានឥទ្ធិពលយ៉ាងខ្លាំងក្នុងពិភពអប់រំ និងជាពិសេសនៅតាមសាលាមត្តេយ្យ និងសាលាបឋមសិក្សា។ ស្នាដៃទីមួយរបស់លោកស្រី ក្រោមចំណងជើងថា«វិធីសាស្ត្រគរុកោសល្យ» ផ្តោតលើនរវិទ្យាគរុកោសល្យ។ លោកស្រីយល់ថា គរុកោសល្យត្រូវពឹងផ្អែកទៅលើចិត្តវិទ្យាដើម្បីឱ្យគរុកោសល្យនេះមានប្រសិទ្ធភាព។

ត្រូវយល់ពី«ទស្សនវិជ្ជាMontessori» ទៅតាមរបៀបដែលមានសរសេរក្នុងស្នាដៃ Philosophy of Education មានន័យថា ទៅតាមអត្ថន័យនៃទ្រឹស្តីគរុកោសល្យជាមូលដ្ឋានគ្រឹះដែលវិធីសាស្ត្រអប់រំ Montessori ឈរលើ។ ទ្រឹស្តី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អប់រំ Montessori ជាមូលដ្ឋាននៃវិធីសាស្ត្រអប់រំ Montessori គឺជាខ្ទឹមក្នុងការបង្កើតសាលារៀន Montessori។

នៅក្នុងផ្នែកមួយនៃអត្ថបទក្រោមចំណងជើងថា The Child ដែលលោកស្រីចេញផ្សាយនៅឆ្នាំ ១៩៤១ នាឱកាសនៃការស្នាក់នៅរបស់លោកស្រីនៅប្រទេសឥណ្ឌា លោកស្រីបានរៀបរាប់ពីរឿងរបស់កុមារីអាយុ៣ឆ្នាំម្នាក់ កំពុងលេងនៅក្នុងគេហដ្ឋានដំបូងគេសម្រាប់កុមារនៅក្រុងរ៉ូមប្រទេសអ៊ីតាលី៖ សម្លឹងមើលសារចុះសារឡើងស៊ីឡាំងឈើជាច្រើនដាក់នៅលើបន្ទះឈើសម្រាប់ដាក់ស៊ីឡាំងដោយយកចិត្តទុកដាក់ចំនួន-៤០ដង ឬលើសពីនោះ។ រឿងនេះជ្រៀតចូលទៅក្នុងអក្សរសិល្ប៍ប្រៀបដូចជារបកគំហើញពីអ្វីដែលគេឱ្យឈ្មោះថា «មហស្ចារ្យ Montessori»។ លោកស្រីបានពិពណ៌នាពីក្មេងស្រីនេះដែលផ្ដោតអារម្មណ៍លើការងារមួយដែលទាមទារឱ្យមានការផ្ចង់ស្មារតី តែនាងមានភាពរីករាយ អារម្មណ៍ធូរស្រាល ចាកចេញពីភាពស៊ោកដុយ និងរឹងមាំផ្នែកផ្លូវចិត្ត។ មើលទៅហាក់ដូចជាក្នុងវិញ្ញាណរបស់នាងមានទ្វារមួយ ដែលបើកទៅរកថាមពលភ្លឺស្វាងបង្ហាញផ្នែកដ៏ស្រស់ល្អបំផុតនៃចរិតរបស់នាង។ លោកស្រីMontessori ចាត់ទុកក្មេងស្រីនេះជាក្មេង «ល្អ»«ធម្មតា» ហើយលើសពីនោះ គឺលោកស្រីរហូតដល់ឱ្យឈ្មោះថាជា«ក្មេងថ្មី»។«ក្បួនច្បាប់ ការអភិវឌ្ឍស្មារតី បញ្ញា និងមនោសញ្ចេតនាត្រូវមើលដើមកំណើតក្នុងប្រភពអាថ៌កំបាំងនេះបន្ទាប់ពីនោះមកខ្ញុំបានប្រឹងប្រែងអស់ពីកម្លាំងកាយ និងចិត្តដើម្បីយល់ដឹងឱ្យបានច្បាស់ពីកត្តាដែលធ្វើឱ្យមានការផ្ចង់ស្មារតីបែបនេះ។ ហើយខ្ញុំបានសិក្សាដោយយកចិត្តទុកដាក់ តើយើងត្រូវបង្កើតបរិយាកាសដែលរួមមានលក្ខខណ្ឌខាងក្រៅសមស្របដែលអាចធ្វើឱ្យការផ្ចង់ស្មារតីដូច្នេះកើតឡើងដូចម្ដេច? (The Child, in W. Böhm, 1985, p. 58)»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**គោលការណ៍គ្រឹះអប់រំគោលលទ្ធិ Montessori ៖ ផែនការកសាង**

បញ្ញត្តិមូលដ្ឋាន Montessori គឺជាបញ្ញត្តិនៃ «ផែនការកសាងដោយមិតមេ»។ សម្រាប់លោកស្រី បុគ្គលម្នាក់ត្រូវបាន «កំណត់ជាមុនជាក់លាក់រួចទៅហើយក្នុងបុគ្គលិកលក្ខណៈនៃការបង្កកំណើតពីអំប្រ៊ីយ៉ុង តូចៗមិនអាចមើលឃើញនឹងភ្នែក អំប្រ៊ីយ៉ុងដែលកំណត់រួចទៅហើយទៅលើគ្រប់បុគ្គល» (១៩០៦)។ លោកស្រី Montessori គិតថាការអប់រំអាចអភិវឌ្ឍ និងដឹកនាំមនុស្សឱ្យប្រសើរឡើង «តែការអប់រំនេះមិនអាចផ្លាស់ប្តូរជម្រៅធម្មជាតិរបស់មនុស្សបានឡើយ»។

កត្តាជីវសាស្ត្រ៖ លោកស្រី Montessori សិក្សាដោយស៊ីជម្រៅកត្តានានាដែលជាលក្ខខណ្ឌនៃការអភិវឌ្ឍរបស់កុមារ ហើយលោកស្រីបានទាញចេញជាសេចក្តីសន្និដ្ឋានថា៖ «មានកត្តាជីវសាស្ត្រ ដែលកំណត់យ៉ាងអាថ៌កំបាំងនូវវាសនាណាមួយនោះសម្រាប់មនុស្សម្នាក់ៗ។ បរិយាកាសជុំវិញអាចប្រឆាំង ជំនួស និងបង្កជាឧបសគ្គចំពោះអ្វីដែលធម្មជាតិបានកំណត់ក្នុងអំប្រ៊ីយ៉ុងបង្កកំណើត តែយើងក៏មិនអាចបំភ្លេចចោលនូវអ្វីដែលបានកំណត់រួចស្រេចទៅហើយដោយច្បាប់ធម្មជាតិនៃជីវិត ហើយដែលជាអ្វីតែមួយគត់កំណត់ចរិតលក្ខណៈរបស់មនុស្ស (L'enfant, 2004) ។

បរិយាកាសជុំវិញ៖ បរិយាកាសជុំវិញអាចមានឥទ្ធិពលសមស្រប ឬមិនសមស្រប តែបរិយាកាសជុំវិញនេះមិនមានលក្ខណៈអំណោយផលសម្រាប់ឱ្យមានការផ្តួចផ្តើម ឬឱ្យមានការបង្កើតនោះទេ។ លោកស្រីបន្ថែមលើការពន្យល់ដូច្នេះថា៖ «ប្រភពកំណើតនៃការអភិវឌ្ឍគឺនៅក្នុងវិញ្ញាណ។ កុមារមិនលូតលាស់ដោយសារគេបរិភោគ ដោយសារគេដកដង្ហើម ដោយសារគេរស់នៅក្នុងលក្ខខណ្ឌសីតុណ្ហភាពត្រឹមត្រូវនោះទេ តែគេលូតលាស់ដោយសារជីវិតប្រកបដោយសក្តានុពលនៅក្នុងខ្លួនគេបានរីកលូតលាស់ធំធាត់ ក្លាយជាការពិត ព្រោះអំប្រ៊ីយ៉ុងបានបង្កកំណើត ដែលជាប្រភពកំណើតនៃជីវិតរបស់គេ គេបន្តការវិវឌ្ឍខ្លួនស្របតាមកម្មវិធីជីវសាស្ត្រពីដូនតារបស់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គេ (1996)»។

លោកស្រីបានផ្តល់ដល់ពាក្យ «សេរីភាព» នូវអត្ថន័យស៊ីជម្រៅ អត្ថ-ន័យនៃការរំដោះជីវិតរបស់កុមារពីឧបសគ្គដែលរាំងដល់ការអភិវឌ្ឍជាធម្មតារបស់ពួកគេ។ កុមារម្នាក់ៗមានជាលក្ខណៈធម្មជាតិនៃសមត្ថភាពក្នុងការអភិវឌ្ឍសរីរាង្គកាយដោយឯកឯង ក៏ដូចជាមានកម្លាំងថាមពលជំរុញតាំងពីកំណើតក្នុងការរីកលូតលាស់ធំធាត់នៃកម្លាំងខាងក្នុង ដែលលោកស្រីពណ៌នាយ៉ាងជាក់លាក់ថាជាចេតនាក្នុងការចាប់យកនូវមធ្យោបាយអភិ-វឌ្ឍន៍សុខដុមនានាតាំងពីកំណើតមក។ កម្លាំងថាមពលនេះ ដែលបង្ហាញចេញតាមរយៈតម្រូវការ ចេតនា និងចំណាប់អារម្មណ៍របស់កុមារ ដែលសម្រាប់លោកស្រី វាហាក់ដូចជា «សម្រែកពីខាងក្នុងនៃជីវិតដែលចង់រីកលូតលាស់ធំធាត់ទៅតាមក្បួនច្បាប់ដ៏អាថ៌កំបាំង»។ តាមគំនិតរបស់លោកស្រី Montessori មនុស្សខុសពីសត្វ មនុស្សមិនមែនជាកម្មវត្ថុសម្រាប់អាកប្ប-កិរិយាមួយចំនួនណានោះទេ ក៏ព្រោះថាមនុស្សមានភាពស៊ាំសីុងតែជាគ្មានដែនកំណត់ ហើយមនុស្សបើកចិត្តបើកគំនិតសម្រាប់ពិភពលោក។ កុមារមានសក្តានុពលសម្រាប់ភាសា។

## ដំណាក់កាលអភិវឌ្ឍកុមារ

លោកស្រី Montessori បែងចែកគ្រប់វ័យណ្ឌទូទៅនៃវឌ្ឍនភាព និងការអភិវឌ្ឍនៃគ្រប់វ័យណ្ឌនោះទៅតាមបុគ្គលិកលក្ខណៈរបស់កុមារ។ កុមារគ្រប់រូបស្មើភាពគ្នាតាំងពីកំណើត។ ពួកគេរីកចម្រើនធំធាត់ដូចៗគ្នា ហើយពួកគេអនុវត្តតាមច្បាប់ដូចៗគ្នា។ ការអភិវឌ្ឍកុមារត្រូវធ្វើឡើងតាមដំណាក់បន្តបន្ទាប់គ្នា ហើយដែលអាចកំណត់បានតាមរយៈទិន្នន័យអាយុ។ លោកស្រី Montessori បរិយាយពី «ដំណាក់កាលវេទយិត Sensible phase»។ កុមារមានអាយុក្រោមបីឆ្នាំមានទម្រង់វិញ្ញាណពិសេស «វិញ្ញាណស្រូបទាញ»។ លោកស្រីចាត់ទុកកុមារនៅអាយុនេះមានសមត្ថភាពអាចចាប់យកនូវចំណាប់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អារម្មណ៍សង្គម ដែលមនុស្សធម្មតាអាចមានសមត្ថភាពបែបនេះតែនៅពេលធំតែប៉ុណ្ណោះ។

ចំពោះអ្វីដែលពាក់ព័ន្ធនឹងការវិវឌ្ឍផ្លូវចិត្តរបស់មនុស្ស លោកស្រី Montessori ក៏បានប្រើប្រាស់រូបភាពអំប្រ៊ីយ៉ុងផ្លូវចិត្ត និងរាងកាយ ហើយបរិយាយពី«ផែនការកសាងផ្លូវក្នុងនៃមនុស្ស» ដែលដឹកនាំការអភិវឌ្ឍនេះ។

មនុស្សអភិវឌ្ឍមិនដូចជារុក្ខជាតិ ឬផ្កានោះទេ ព្រោះមនុស្សមានធម្មជាតិជាសត្វលោកនៃវប្បធម៌។ មនុស្សជាសត្វលោកពឹងផ្អែកលើវប្បធម៌ និងបង្កើតវប្បធម៌។ សត្វលោកនេះកើតមកលើផែនដីដោយមានលក្ខណៈមិនទាន់គ្រប់គ្រាន់ ហើយត្រូវកសាងខ្លួនបន្ថែមទៀតតាមរយៈការផ្តោតការយកចិត្តទុកដាក់យ៉ាងសកម្មទៅលើបរិយាកាសធម្មជាតិ សង្គម និងវប្បធម៌នៅជុំវិញខ្លួន។ កុមារគឺជា «ស្ថាបត្យករនៃមនុស្សជាតិ»។ លោកស្រី Montessori អះអាងថា មនុស្សជាតិនេះគឺជាស្នាដៃរបស់ធម្មជាតិ ស្នាដៃរបស់មនុស្ស (សង្គម) និងស្នាដៃរបស់បុគ្គលម្នាក់ៗ។

គោលគំនិតនៃអត្ថិភាពកប់ខាងក្នុងបុគ្គលិកលក្ខណៈផ្ទាល់នៅក្នុងវិញ្ញាណរបស់កុមារ ដែលត្រូវរិះរកវិធីក្នុងការធ្វើយ៉ាងណារំដោះអត្ថិភាពនេះចេញមកក្រៅតាមរយៈការអភិវឌ្ឍសមស្របមួយ និងតាមរយៈការបង្កើតឱ្យមានបរិយាកាសសមស្របមួយ។ ក្តីមេត្តា គឺជាសមាសធាតុដែលមាននៅក្នុងមូលដ្ឋានគ្រឹះនៃស្នាដៃរបស់ Montessori។

## គោលការណ៍គ្រឹះផ្នែកសាសនានៃគរុកោសល្យរបស់ Montessori

វិញ្ញាណរបស់ព្រះមិនត្រឹមតែមាននៅក្នុងខ្លួនរបស់កុមារម្នាក់ៗ តាមរយៈផែនការប្រទាក់ក្រឡាច្បាស់លាស់នៃការអភិវឌ្ឍបុគ្គលនីមួយៗនោះទេ តែព្រះជាម្ចាស់បានផ្តល់សកម្មភាពនៃផែនការរចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ជាលក្ខណៈបុគ្គល។ នៅក្នុងស្នាដៃរបស់លោកស្រីក្រោមចំណងជើងថា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

L'Inconscient dans l'histoire លោកស្រីសង្កត់ធ្ងន់ទៅលើផែនការសាកលមួយស្ដីពីភាពសុខដុមរៀបចំទុកជាមុននៃពិភពលោក ហើយលោកស្រីបានធ្វើការបែងចែករវាងការតព្វកិច្ចមូលដ្ឋានចំនួនពីរ ឬអាចនិយាយបានថាសមាសភាពមូលដ្ឋានចំនួនពីរនៅក្នុងអាកប្បកិរិយារបស់គ្រប់បុគ្គលទាំងអស់៖ សមាសភាពទី ១ ផ្ដោតលើការរីកលូតលាស់ធំធាត់ និងការអភិរក្សផ្លូវចិត្តរបស់បុគ្គលនោះ មួយទៀតគឺការអភិរក្សនៃក្រឹត្យក្រមពិភពលោក» និងបង្កើតឱ្យមានការរួមចំណែករបស់បុគ្គលម្នាក់ៗក្នុងការបង្កើតពិភពលោកនេះ។ «សរុបមក បញ្ហាការអប់រំត្រូវរកដំណោះស្រាយចំពោះបញ្ហាទាំងនោះ ដោយសារតែអត្ថិភាពនៃច្បាប់របស់ក្រឹត្យក្រមសាកលលោក» (1996)។ ចង់ថាថា៖ ច្បាប់អភិវឌ្ឍកុមារគឺមានប្រភពដើមមកពីព្រះជាម្ចាស់។

## ការអប់រំកុមារជាប្រក្រតីភាព-សារៈសំខាន់នៃការផ្ចង់ស្មារតី

អ្នកអប់រំមិនអាចមានចំណេះដឹងលើគ្រប់ខ័ណ្ឌដែលក្នុងនោះបញ្ជាក់ពីការអភិវឌ្ឍសមត្ថភាពរបស់មនុស្សនោះទេ។ ដោយហេតុផលនេះហើយបានជាចាំបាច់ក្នុងការផ្ដល់ដល់កុមារនូវកិច្ចគាំពាររឹងមាំមួយក្នុងអំឡុងពេលនៃការរីកលូតលាស់អភិវឌ្ឍរបស់គេ ដើម្បីឱ្យគេអាចអភិវឌ្ឍខ្លួនឯងទៅតាមកម្លាំងជំរុញផ្ទាល់ខ្លួនដែលគេមាននៅក្នុងខ្លួនរបស់ពួកគេ ហើយដែលគេមិនបានដឹងថាខ្លួនរបស់គេមានកម្លាំងជំរុញនោះ។ ប្រក្រតីកម្ម គឺជាពាក្យគន្លឹះសម្រាប់គ្រប់គរុកោសល្យទាំងអស់របស់ Montessori។ ចំពោះលោកស្រី Montessori ចរិតលក្ខណៈរួមសម្រាប់គ្រប់ការដើរខុសផ្លូវអាចពន្យល់បានតាមសភាពអ្វីដែលកើតមានលើកុមារដែលងាកចេញពីគន្លងធម្មតានៃការរីកលូតលាស់របស់គេ មានន័យថា កម្លាំងថាមពលខុសៗគ្នាត្រូវរាយប៉ាយ ហើយកម្លាំងចលកររបស់គេបែកចេញពីគ្នាដោយមិនមានការសម្របសម្រួល ចំណែកឯប្រក្រតីកម្មគ្រាន់តែទាមទារក្នុងការដាក់ឱ្យប្រតិបត្តិដោយសុខដុមនៃអន្តរសកម្មភាព ដែលមានការសម្របសម្រួលនៃកម្លាំងកាយ និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចិត្ត សាច់ដុំ បញ្ញា ឆន្ទៈដូចដែលធម្មជាតិចង់បាន។

ត្រូវបង្កើតបរិយាកាសមួយសម្រាប់កុមារ ហើយផ្តល់ដល់ដៃពួកគេនូវឧបករណ៍ដែលពួកគេធ្វើការងារដោយផ្ទង់អារម្មណ៍ជាមួយនឹងឧបករណ៍ទាំងនោះ ព្រមទាំងអាចផ្តោតការយកចិត្តទុកដាក់របស់គេផងទៅលើការងារនោះ។

ក្នុងមេរៀននៅឆ្នាំ១៩២១ លោកស្រី Montessori បរិយាយពីបរិយាកាសនេះតាមរបៀបរូបិយ «បរិយាកាសត្រូវផ្តល់ទៅដល់កុមារគ្រប់លទ្ធភាពក្នុងការផ្ទង់ស្មារតី និងលទ្ធភាពនៃការជ្រើសរើស...។ វាចាំបាច់ដែលថាកុមារត្រូវអាចទឹកឃើញទីតាំងដែលវត្ថុណាមួយស្ថិតនៅ...។ បរិយាកាសបែបនេះដែលរហូតដល់គេជឿថាវាចូលស៊ីបទៅក្នុងវិញ្ញាណរបស់កុមារ តាមរបៀបដែលថានៅពេលកុមារជ្រើសយកសកម្មភាពមួយ ការជ្រើសរើសនោះ គឺជាវិចារណញ្ញាណ ហើយការផ្ទង់អារម្មណ៍ហាក់មានភាពងាយស្រួលសម្រាប់គេ»។

លំហាត់ដែលមានឈ្មោះថាលំហាត់ជីវិតប្រចាំថ្ងៃគឺជាការងារចាំបាច់ប្រចាំថ្ងៃសម្រាប់ថែទាំរូបរាងកាយខ្លួនឯងផ្ទាល់ (ឧទាហរណ៍ លាងសម្អាតដៃ) សម្រាប់បរិស្ថានជុំវិញ (មើលថែទាំផ្កា) សម្រាប់ជីវិតក្នុងសង្គម (ទទួលភ្ញៀវ) និងសម្រាប់លំហាត់រូបរាងកាយ (ឧទាហរណ៍ ការដើរលើខ្សែបន្ទាត់) លំហាត់ ដែលលោកស្រី Montessori លើកឡើងថាជាលំហាត់ដែលធ្វើឱ្យកុមារចាប់ផ្តើមមានប្រក្រតីកម្មជាមួយនឹងជីវិតរស់នៅ ហើយលំហាត់ដូចបានរៀបរាប់ខាងដើម ធ្វើឱ្យកុមារទទួលបាននូវប្រក្រតីភាពទាំងនោះ។ «គឺជាសកម្មភាពហត្ថកម្ម ជាមួយនឹងគោលបំណងអនុវត្ត ដែលជួយធ្វើឱ្យរៀបរយផ្នែកផ្លូវចិត្ត»។ ចំពោះលោកស្រី Montessori ការផ្ទង់ស្មារតីបំពេញតួនាទីចំនួនពីរនៅក្នុងជីវិត៖ មួយស្ថិតនៅក្នុងខណៈ និងមួយទៀតស្ថិតនៅក្នុងពេលវេលា។ តួនាទីទី១ គឺដើម្បីជំរុញឱ្យការមានកំណើតកុមារក្នុងនាមជាបុគ្គល។ សម្រាប់រយៈពេលវែង ចំណុចសំខាន់ទី១ នៃការផ្តោតអារម្មណ៍នេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្កើតបានជាចំណុចចាប់ផ្តើមនៃស្វ័យអប់រំដោយឯកឯង និងដោយសេរីរបស់កុមារ។ ប្រក្រតីកម្មពឹងផ្អែកលើសម្ភារឧបទេស ដែលលោកស្រី Montessori ចាត់ទុកនៅពេលនោះថាជាឧបករណ៍ «គន្លងនៃប្រក្រតីកម្ម និងកូនសោរសម្រាប់ការអប់រំបុគ្គល»។

## វិធីសាស្ត្រ Montessori-ការគាំទ្រផ្នែកគរុកោសល្យ

សម្ភារគរុកោសល្យច្រើនតែត្រូវបានចាត់ទុកជាសមាសភាពចាំបាច់ក្នុងគរុកោសល្យរបស់ Montessori ដែលគេឱ្យឈ្មោះថា វិធីសាស្ត្របង្រៀន Montessori។ ឯកសារគរុកោសល្យដែលត្រូវបានចាត់ជាឯកសារអភិវឌ្ឍន៍ និងចាត់ទុកជាគន្លងនៃការអភិវឌ្ឍឱ្យមានប្រក្រតីភាព គឺជាការផ្តល់អត្ថន័យកាន់តែប្រសើរសម្រាប់គោលបំណងនៃសម្ភារគរុកោសល្យ។

សម្ភារគរុកោសល្យនេះរួមមាន ៥ ក្រុម។ ក្រុមទី១ លំហាត់ជីវិតប្រចាំថ្ងៃ និងក្រុមទី២ ចាត់ជាឧបករណ៍បម្រើដល់រំញោចវិញ្ញាណ ត្រូវបានប្រើប្រាស់យ៉ាងពិសេសក្នុងបុរីសម្រាប់កុមារ។ សម្ភារសម្រាប់វិញ្ញាណ មិនត្រឹមតែប្រើសម្រាប់អភិវឌ្ឍវិញ្ញាណទាំងប្រាំនោះទេ តែក៏រួមបញ្ចូលវិញ្ញាណរំញោចកម្តៅ (ថង់ច្រកទឹកក្តៅសម្រាប់ស្ទំ) ទម្ងន់ (របារលើកសាច់ដុំ) និងវិញ្ញាណសម្រាប់សម្គាល់ទម្រង់ធរណីមាត្រផ្សេង (ការយល់ពីលំហ)។ សម្ភារសម្រាប់អភិវឌ្ឍវិញ្ញាណប្រើប្រាស់ក្នុងការបង្ហាត់បង្រៀនផ្នែកវិញ្ញាណខុសៗគ្នារបស់កុមារ៖ ដុំឈើរាងមូលទ្រវែង (ស៊ីឡាំង) សម្រាប់ចក្ខុវិញ្ញាណ បន្ទះគូល័រទឹក សម្រាប់វិញ្ញាណពាក់ព័ន្ធនឹងពណ៌ ប្រអប់ភ្លេង/សំឡេង និងជួងច្រើនខ្នាតសម្រាប់សោតវិញ្ញាណ បន្ទះក្តារសម្រាប់ស្ទាប ប្រើប្រាស់សម្រាប់អភិវឌ្ឍកាយវិញ្ញាណជាដើម។ ឧបករណ៍សម្រាប់អភិវឌ្ឍវិញ្ញាណទាំងនេះផ្តល់នូវការយល់ជាវត្ថុ ជាខណ្ឌនៃបរិស្ថានជុំវិញ និងភាពមុតស្រួចកាន់តែខ្លាំងផ្នែកញាណសតិក្នុងការវិនិច្ឆ័យ។

សម្ភារឧបទេសបង្ហាញពីចរិតលក្ខណៈរួមនៃក្រុមទាំងប្រាំ។ ការប្រើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាស់ដោយស្វ័យភាពរបស់កុមារ ធ្វើឱ្យគេមានលទ្ធភាពក្នុងការអភិវឌ្ឍវិញ្ញាណរបស់គេទៅតាមសន្ទុះនៃការងាររបស់ខ្លួន ព្រមទាំងអភិវឌ្ឍល្បឿននៃការសិក្សាផ្ទាល់ខ្លួនឯងផងៗ កុមារអាចបញ្ចេញគំនិតនៅដំណាក់កាលវឌ្ឍនភាព និងទទួលជោគជ័យក្នុងអំឡុងពេលសិក្សារៀនសូត្ររបស់គេ ធ្វើបែបនេះនឹងធ្វើឱ្យពួកគេទទួលបានឯករាជ្យភាព ជៀសនឹងការវិនិច្ឆ័យរបស់គ្រូបង្រៀនៗ

តាមរយៈការបង្កើតនូវនីតិវិធីផ្សេងៗដើម្បីចាប់យកចំណេះដឹង ដោយផ្អែកទៅលើសម្ភារឧបទេសស្រដៀងៗគ្នាព្រមទាំងកម្រិតនៃការលំបាកផ្សេងៗគ្នា ធ្វើឱ្យគេអាចបង្កើតមិនត្រឹមតែសកម្មភាពដោយឯកឯងនោះទេ តែវាព្រមទាំងបង្កើតឱ្យមានការប្រឈមផ្ទៃក្នុង និងស៊ីជម្រៅជាមួយនឹងមុខវិជ្ជាបង្រៀន ដើម្បីធ្វើយ៉ាងណាឱ្យការប្រឈមនេះដក់ជាប់ជាប្រចាំនៅក្នុងការចងចាំរបស់កុមារៗ សកម្មភាពកុមារអភិវឌ្ឍទៅបានក្នុងលក្ខខណ្ឌនៃទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងសម្ភារៗ គឺលក្ខណៈពិសេសបែបនេះហើយដែលធ្វើឱ្យដោះស្រាយបាននូវបញ្ហានៃការទទួលយកនូវវប្បធម៌ៗ ដំណោះស្រាយនេះទាមទារជាដំបូងក្នុងការកំណត់ព្រំដែននៃកិច្ចអន្តរាគមន៍របស់មនុស្សពេញវ័យៗ កុមារម្នាក់ៗដែលមានសេរីភាពក្នុងការជ្រើសរើសសកម្មភាពរបស់ខ្លួននឹងអភិវឌ្ឍខ្លួនឯងតាមតម្រូវការចេញពីជម្រៅចិត្តដាច់ដោយឡែករបស់ខ្លួនដែលមានពីកំណើត ហើយប្រការនេះ ធ្វើឱ្យកុមារវិវត្តទៅមុខតាមរយៈការរៀនដោយខ្លួនឯងៗ បន្តិចម្តងៗ និងតាមរយៈខ្លួនឯងផង កុមារត្រូវអភិវឌ្ឍអាកប្បកិរិយាចាំបាច់នានាសម្រាប់ការរស់នៅក្នុងសហគមន៍ ឬការរស់នៅជាមួយគ្នា នេះបើតាមលោកស្រី Montessoriៗ

[...] វិន័យ របៀបរៀបរយ ការស្ងាត់ស្ងៀម ការស្តាប់ដំបូន្មាន វិញ្ញាណផ្នែកសីលធម៌ និយាយដោយខ្លី រាល់អ្វីៗបញ្ជាក់ពីថាមពលក្នុងការសម្រួបខ្លួនៗ ហើយកុមារមួយនេះក៏បង្ហាញពីភាពរស់រវើក ពីទំនុកចិត្តលើខ្លួនឯងពីសេចក្តីក្លាហាន ពីសាមគ្គីភាព និយាយដោយខ្លីពីកម្លាំងចិត្តដែលត្រូវបាន



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ចាត់ជាផ្នែកសីលធម៌។ ខណៈជាមួយគ្នានោះ គុណវិបត្តិនានាក៏ត្រូវបាន បាត់បង់ ឬអាចនិយាយបានថាលែងកើតមាននោះ គឺជាអ្វីដែលគេស្វែងរក ក្នុងការលុបបំបាត់វាតាមរយៈការអប់រំ៖ ចិត្តក្អើតក្អើន មនោហិង្សា មុសា ភាពអៀនខ្មាស ភាពភ័យខ្លាច ហើយជាទូទៅវាល់ចរិតឬកពាដែលមាន ទំនាក់ទំនងទៅនឹងស្ថានភាពនៃការការពារខ្លួន (2000)។

## «គ្រូបង្រៀនសម័យថ្មី» និងបរិយាកាសជុំវិញ

គ្រូបង្រៀនមានន័យថាគឺជាទីកន្លែងមួយ បូកផ្សំជាមួយនឹងសមាស ធាតុផ្សេងៗរបស់ទីកន្លែងនោះ វាច្បាស់ណាស់ដែល Montessori ត្រូវកំណត់ នូវភិនភាគរបស់គ្រូសម័យថ្មី។ ជាដំបូង គ្រូសម័យថ្មីនេះត្រូវមានការកិច្ចក្នុង ការបញ្ចប់ជម្លោះជាប្រចាំរវាងកុមារ និងមនុស្សពេញវ័យដោយត្រូវបដិសេធ ចំពោះសិទ្ធិអំណាចបែបបុរាណរបស់មនុស្សពេញវ័យទៅលើកុមារ ហើយ ត្រូវធ្វើយ៉ាងណាឱ្យសកម្មភាព ដែលគេត្រូវធ្វើជាមួយកុមារក្លាយជាសកម្ម ភាពគាំទ្រពីក្រោយរាល់សកម្មភាពនានារបស់កុមារវិញ។

នៅក្នុងគ្រឹះស្ថាន Montessori មិនមានគ្រូបង្រៀនដែលបង្រៀននោះ ទេ មានតែមនុស្សពេញវ័យដែលជួយដល់កុមារឱ្យធ្វើកិច្ចការរបស់គេ ដោយ ប្រើប្រាស់ឧបករណ៍ និងបរិយាកាសសមស្រប ជួយដល់កុមារឱ្យផ្ចង់ស្មារតី និងឱ្យរៀនសូត្រ។ ការអប់រំផ្អែកទៅលើគ្រូបង្រៀន និងបរិយាកាសជុំវិញ។ គ្រូបង្រៀនសម័យថ្មីមិនមែនជាអ្នកដឹកនាំដោយទាញដៃនោះទេ តែជាអ្នក ជួយដល់កុមារដែលស្គាល់គេច្បាស់ ហើយដែលបង្ហាញដល់កុមារនូវសម្ភារ ឧបទេសនៅពេលណាដែលកុមារត្រូវការ ដើម្បីធ្វើយ៉ាងណាឱ្យគេអាច ទទួលបាននូវចំណេះដឹងដោយស្វ័យតបំផុត។

គ្រូបង្រៀនសម័យថ្មីមិនត្រូវកែកំហុសរបស់កុមារទេ តែផ្ទុយទៅវិញ គាត់ត្រូវយកចិត្តទុកដាក់ទៅលើកំហុសឆ្គងរបស់ខ្លួនឯងផ្ទាល់។ តួនាទីផ្នែក គរុកោសល្យរបស់គាត់គឺទាមទារឱ្យគាត់ផ្តល់ឱកាសតាមរយៈការជួយអម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និងចង្អុលបង្ហាញដល់កុមារ ដើម្បីឱ្យគេអាចអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់ខ្លួន គឺមានន័យថាត្រូវត្រៀមខ្លួនជាស្រេចក្នុងការសហការជាមួយកុមារ នៅពេលណាដែលកុមារស្នើសុំ៖ «ជួយខ្ញុំដើម្បីឱ្យខ្ញុំអាចធ្វើដោយខ្លួនឯងបានផង»។

## ១៤. Janusz KORCZAK (1878-1942)

បដិវត្តទំនាក់ទំនង៖ «តើត្រូវធ្វើដូចម្តេចដើម្បីរស់នៅក្រោមដំបូលតែមួយជាមួយគ្នា?»

**«កុមារបរិសុទ្ធ La sainte enfance »**

កន្សោមពាក្យ «កុមារបរិសុទ្ធ» គឺជាការអំពាវនាវឱ្យមានបដិវត្តន៍នៃការរួមរស់ជាមួយគ្នា ធៀបទៅនឹងបញ្ហាទំនាក់ទំនងជាមួយនឹងអ្នកដទៃ។ ព្រះយេស៊ូបានមានបន្ទូលថា «ទុកឱ្យកុមារដើរមករកយើងមក»។ បដិវត្តន៍ទីពីរគឺជាបដិវត្តរបស់លោក Jean-Jacques Rousseau ដែលលោកបានប្រកាសថា៖ «មនុស្សកើតមកស្អាតស្អំ ហើយថាគឺសង្គមដែលធ្វើឱ្យគេប្រឡាក់ប្រឡូស»។

បដិវត្តន៍ទីបីកើតឡើងជាមួយនឹង Korczak។ វាមិនគ្រាន់តែសម្លឹងមើលកុមារ និងស្គាល់កុមារនោះទេ តែក៏ត្រូវផ្តល់ក្តីស្រលាញ់ដល់គេដោយស្មើភាព។

កុមារនឹងមិនអាចក្លាយជាមនុស្សពេញលេញម្នាក់បានទេ ប្រសិនបើគេមិនត្រូវបានគោរព និងមានសិទ្ធិដូចគ្នាទៅនឹងសិទ្ធិដែលមនុស្សពេញវ័យមាន។ លោកបានបញ្ចេញនូវគំនិតបែបនេះនៅក្នុងសៀវភៅរបស់លោកដែលមានលក្ខណៈបដិវត្តន៍ក្រោមចំណងជើងថា របៀបស្រឡាញ់កុមារ (Comment aimer un enfant)។

## សិទ្ធិកុមារ

KORCZAK អំពាវនាវដល់«សិទ្ធិកុមារ» (magna charta libertatis) នូវអ្វីដែលជាសិទ្ធិរបស់កុមារ៖

1. សិទ្ធិរបស់កុមារក្នុងការរស់ជាជីវិតរបស់ខ្លួននាពេលបច្ចុប្បន្ន។
2. សិទ្ធិរបស់កុមារក្នុងការក្លាយជាអ្វីដែលគេមានពីកំណើត ៖ ការស្រឡាញ់ គោរព លួតលាស់ ធ្វើឱ្យមានកំហុស មានបំណង មានទ្រព្យសម្បត្តិ ជំនឿសាសនា ការពារតាមផ្លូវតុលាការ។
3. សិទ្ធិរបស់កុមារក្នុងការស្លាប់ ៖ ប្រសិនបើកុមារនោះគ្មានលក្ខណៈគ្រប់គ្រាន់ដើម្បីរស់នៅ ទោះបីឪពុកម្ដាយស្រឡាញ់កូនយ៉ាងណាក៏ដោយ។

## ស្វ័យគ្រប់គ្រងគរុកោសល្យ

គរុកោសល្យ Korczak ផ្ដោតទៅលើគម្រូវការចំនួនពីរ៖ កុមារជាមនុស្សពេញលក្ខណៈ និងមិនមែនជាអនាគតមនុស្សពេញវ័យដែលវិវត្តពីកុមារនោះទេ។

អភិក្រមអប់រំដែលអនុវត្តក្នុងមណ្ឌលកុមារកំព្រាទាំងពីររបស់ Korczak គឺត្រូវធ្វើទៅតាមគរុកោសល្យសេរីរបស់ Niell។ អភិក្រមនេះជឿជាក់ថា «អ្វីៗត្រូវផ្ដើមចេញពីកុមារ»។ ការធ្វើបែបនេះនឹងនាំឱ្យមានការបដិសេធរាល់គោលគំនិតដែលថារដ្ឋ ឬសាសនាមានសិទ្ធិអំណាចក្នុងការសម្រេចលើអ្វីដែលកុមារត្រូវរៀន។

វត្តមានសាលារៀនមិនមែនសម្រាប់រៀបចំសិស្សក្នុងការរស់នៅនោះទេ តែគឺជាទីកន្លែងនៃជីវិតផ្ទាល់តែម្ដងដែលត្រូវបង្រៀនកុមារឱ្យរស់នៅក្នុងពេលបច្ចុប្បន្ន។

ខ្លឹមសារនៃការសិក្សាអាស្រ័យលើចំណង់ចំណូលចិត្តរបស់កុមារ។ កុមារចូលរួមក្នុងការជ្រើសយកមុខវិជ្ជាដែលត្រូវបង្រៀនពួកគេ។ វិធាននា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នាដែលត្រូវបានដាក់ឱ្យអនុវត្ត៖

1. ប្រអប់សំបុត្រ La boîte aux lettres ៖ វិធាននេះគឺជាកិច្ចទំនាក់ទំនងជាលក្ខណៈបុគ្គល។ ការធ្វើបែបនេះធ្វើឱ្យកុមារទទួលបានចំណេះដឹងផ្នែកសរសេរ។ ការធ្វើបែបនេះក៏ទាមទារឱ្យកុមារធ្វើការគិត និងការបំផុសឱ្យមានការធ្វើសកម្មភាព និងសេចក្តីសម្រេចចិត្តផ្សេងៗ។

2. ទូកញ្ចក់សម្រាប់របស់រកឃើញវិញ La vitrine aux objets trouvés ៖ អ្នកអប់រំត្រូវជួយកុមារក្នុងការស្វែងរកទ្រព្យសម្បត្តិរបស់ខ្លួន។ នេះគឺជាការទទួលខុសត្រូវលើកាតព្វកិច្ចជាពលរដ្ឋល្អចំពោះអ្នកដទៃ។

3. ក្តារខៀននៅជញ្ជាំងស្របតាមកម្ពស់របស់កុមារ៖ ក្តារខៀននេះប្រើប្រាស់សម្រាប់បិទសេចក្តីប្រកាស និងព័ត៌មានផ្សេងៗ។

4. កាសែត La gazette ៖ ប្រៀបដូចជាកន្លែងសម្រាប់សរសេរដែលកុមារអាចទទួលព័ត៌មាន ផ្លាស់ប្តូរព័ត៌មាននៅក្នុងប្រទេសប៉ូឡូញ និងនៅទូទាំងពិភពលោក។

5. កិច្ចប្រជុំពិភាក្សាប្រចាំសប្តាហ៍៖ បើកទទួលសម្រាប់គ្រប់គ្នាដែលចង់ចូលប្រជុំទៅលើប្រធានបទដែលគេជ្រើសរើស។
កុមារម្នាក់ៗបញ្ចេញមតិ យោបល់ដោយសេរី។

6. កិច្ចប្រជុំស្ថាប័ន La réunion institutionnelle ៖ និយាយពីជីវិត និងក្បួនច្បាប់ជីវិតក្នុងស្ថាប័ន។ គោលដៅនៃកិច្ចប្រជុំនេះគឺដើម្បីរៀនរស់នៅជាមួយគ្នាតាមរយៈការគោរពក្បួនច្បាប់ជីវិតរបស់មនុស្សពេញវ័យ និងកុមារនៅក្នុងស្ថាប័នមួយ។

7. តុលាការ Le tribunal ៖ ធ្វើឱ្យកុមារក្លាយជាពលរដ្ឋសាកលក្នុងប្រជាធិបតេយ្យ។ តុលាការនេះប្រព្រឹត្តទៅតាមក្រឹត្យក្រមសីលធម៌ដែលកំណត់ដោយច្បាប់ និងដោយកាតព្វកិច្ចរបស់មនុស្សគ្រប់រូបដែលរស់នៅក្នុងសហគមន៍។ ក្រឹត្យក្រមនេះរួមមាន ១០០០ មាត្រា។ ក្នុងផ្នែកពាក់ព័ន្ធនឹងការវិនិច្ឆ័យ ការអត់ឱនគឺជាគោលការណ៍គ្រឹះ។ ការដាក់ទណ្ឌកម្ម គឺគ្រាន់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តែជានិមិត្តរូបតែប៉ុណ្ណោះសម្រាប់កំហុសធ្ងន់ដែលត្រូវបានទទួលស្គាល់។ តុលាការរួមមានហៅក្រុមចំនួន ៥រូប(ពី ១២ ទៅ ១៤ឆ្នាំ) ដែលត្រូវបានជ្រើសតាំងតាមរយៈការចាប់ឆ្នោតក្នុងចំណោមកុមារ។

## កំណត់ហេតុគរុកោសល្យ

កំណត់ហេតុគរុកោសល្យសម្រាប់គ្រូបង្រៀនគឺជាឧបករណ៍វិធីសាស្ត្រមួយដែលប្រាប់ពីពេលវេលានៃការបង្រៀន ហើយវាក៏ប្រាប់ពីខណៈផ្សេងៗ (វែង ឬខ្លី) ដូចជាការបង្រៀន ការសម្រាក គ្រួសារ ការស្រាវជ្រាវ កិច្ចប្រជុំពិភាក្សា តុលាការ និងការសង្កេតជាច្រើនប្រភេទទៀត។

តាមគំនិតរបស់Korczak គ្មានអ្វីដែលមានតម្លៃជាងការសង្កេតសិស្សនោះទេ។ កំណត់ហេតុធ្វើឱ្យគេអាចកត់ត្រាបានភ្លាមៗ និងប្រើប្រាស់ជាទុនសម្រាប់រាល់ការសង្កេតរបស់ខ្លួន។

កំណត់ហេតុធ្វើឱ្យគេអាចពណ៌នាពីទង្វើ ការវិភាគពីស្ថានការណ៍ និងស្វ័យទិតៀនខ្លួនឯងក្នុងស្ថានភាពនៃការសង្កេត។ កំណត់ហេតុនេះធ្វើឱ្យអ្នកកត់ត្រារឿងរ៉ាវផ្ទាល់ខ្លួនអាចគ្រប់គ្រងស្ថានការដែលខ្លួនបានកត់ត្រាក៏ដូចជាការដោះស្រាយបញ្ហារបស់ខ្លួននៅក្នុងស្ថានការណ៍ណាមួយ។

## គំនិតឆ្លុះពិចារណា

គរុកោសល្យរបស់ Korczak បម្រើដល់ការសិក្សាប្រជាធិបតេយ្យក្នុងការរួមរស់ជាមួយគ្នា។ សង្គតិភាពផ្នែកទ្រឹស្តីមានតិចតួចប៉ុណ្ណោះនៅក្នុងគរុកោសល្យរបស់លោក។

មរតកដែលបន្សល់ទុកដោយគរុវិទូដ៏ល្បីល្បាញនេះគឺការគិតគូររបស់គាត់ចំពោះកុមារ។ ការលែងចាត់ទុកកុមារភាពជាគ្រាន់តែជាខណៈស្ពានចម្លងឆ្ពោះទៅស្ថានភាពមនុស្សពេញវ័យ តែត្រូវចាត់ទុកកុមារភាពជាខណៈដែលត្រូវស្វែងយល់ និងដែលត្រូវគោរព។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ១៥. Alexander Sutherland NEILL (1883-1973) ជំណើរផ្សេងក្រៅដែលមានឈ្មោះថា «សេរីនិយម» នៃ SUMMERHILL

*សាលារៀន SUMMERHILL គឺជាជំនួញគ្រួសាររបស់លោក Alexander។ លោក Neill បានបង្កើតសាលារៀន ជាមួយនឹងភរិយាទី ១ របស់លោក នៅឆ្នាំ ១៩២៤។ លោកបានគ្រប់គ្រងសាលារៀននេះរហូតដល់អស់ជីវិត ហើយភរិយារបស់លោកក៏បានបន្តគ្រប់គ្រងសាលានេះរហូតដល់ឆ្នាំ ១៩៨៥ ទើបប្រគល់ការកិច្ចបន្តដល់កូនស្រីរបស់គាត់ជាអ្នកបន្តវេន។*

Neill *ពន្យល់ក្នុងស្នាដៃរបស់លោកដែលមានចំណងជើងថា កុមារមានសេរីភាពនៃ* Summerhill *៖ «ភរិយាខ្ញុំ និងខ្ញុំបានសម្រេចដូច្នេះថា គឺត្រូវបង្កើតសាលារៀនមួយដែលផ្ដល់សេរីភាពទៅដល់សិស្សក្នុងការបញ្ចេញមតិយោបល់។ ដើម្បីធ្វើបានដូច្នេះ ទាមទារឱ្យយើងត្រូវបដិសេធរាល់វិន័យ រាល់ការកំណត់រាល់ខ្នឹមសារសីលធម៌ដែលរៀបចំមុន រាល់ក្រឹត្យវិន័យផ្នែកសាសនាទោះក្នុងទម្រង់បែបណាក៏ដោយ»។*

*បើទោះបីជាចលនាហួសវិស័យ* (utopistes) *និងសេរីនិយមនេះត្រូវបានសាទរតាមរយៈការរកឃើញនេះក៏ដោយចុះ ក៏សង្គមទាំងមូលមានការភ្ញាក់ផ្អើលជាខ្លាំងដោយសារការរៀនសូត្រដែលគ្មានសណ្ដាប់ធ្នាប់ គ្មានការគោរពសម្ភារសាលារៀន និងតក់ស្លុតពីសេរីភាពផ្លូវភេទ (មានដៃគូច្រើន) ដែលតស៊ូទាមទារដោយនាយកសាលាមួយនេះ។*

*នេះគឺជាអ្វីដែលលោកបានសរសេរប៉ុន្មានឆ្នាំមុនក្នុងកំណត់ហេតុរបស់លោក ពាក់ព័ន្ធនឹងសេជាតិនៃសេរីនិយម៖ «ខ្ញុំមិនចូលចិត្តវិន័យតឹងតែងនោះទេ ព្រោះខ្ញុំគិតថាកុមារម្នាក់ត្រូវមានសេរីភាពឱ្យបានច្រើនតាមការដែលអាចធ្វើបាន។ ខ្ញុំចង់ឱ្យកុមារម្នាក់ជាមនុស្សម្នាក់...ប្រសិនបើខ្ញុំមានភរិយាខ្ញុំនឹងឱបថើបនាងនៅក្នុងថ្នាក់រៀនតែម្ដង តែខ្ញុំមិនមានភរិយានោះទេ»។*

*មេរៀនបង្រៀនគឺជារឿងបន្ទាប់បន្សំសម្រាប់* Summerhill*។ កុមារមាន*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិទ្ធិសម្រេចថាខ្លួនត្រូវលេងពេញមួយថ្ងៃ ឬក៏ធ្វើសកម្មភាពផ្សេងៗដោយប្រើកម្លាំងក្នុងម៉ោងបង្រៀនជាដើម។ ពេលល្ងាច កុមារមានសិទ្ធិសម្រេចក្នុងការយក ពិធីជប់លៀងជួបជុំ របាំ ឬក៏ល្ខោន ឬក៏មិនធ្វើអ្វីតែម្ដង។

រៀងរាល់ល្ងាចថ្ងៃសុក្រ មានកិច្ចប្រជុំទូទៅមួយដែលដឹកនាំដោយសិស្សម្នាក់។ ក្នុងជំនួបនេះ មានសំណួរជាច្រើនត្រូវបានលើកមកធ្វើជាប្រធានបទនៃកិច្ចពិភាក្សាពាក់ព័ន្ធទាំងជីវិតនៅក្នុងសាលា និងនៅក្រៅសាលារៀន។ សេចក្ដីសម្រេចត្រូវបានធ្វើជារួមដោយមិនបានចាត់ទុកជំហររបស់មនុស្សពេញវ័យគ្របដណ្ដប់លើមនុស្សក្មេងជាងនោះទេ។ តាមការជាក់ស្ដែងមនុស្សពេញវ័យមិនអាចតម្រូវឱ្យគេធ្វើតាមខ្លួននោះទេ នេះគឺជាក្រឹត្យក្រមសាលា Summerhill។

គឺក្នុងនាមជាអ្នកវិភាគចិត្តសាស្ត្រ អ្នកអានទ្រឹស្ដី Freud និង Reich ដែលលោក Neill រកឃើញអំណះអំណាងការពារជំហររបស់ខ្លួនពាក់ព័ន្ធនឹងការប្រឆាំងនឹងវិន័យ និងសេរីនិយមរបស់ខ្លួន។ ចំពោះលោក គឺដោយសារតែភាពជឿស៊ប់ និងការបង្រ្កាប់នានាដែលកើតចេញពីសីលធម៌តឹងតែងនោះហើយដែលបង្កជាបញ្ហាជំងឺបាក់ស្មារតីចំពោះយុវជន និងអំពើហិង្សានៅក្នុងពិភពលោក។

លោកយល់ឃើញដូចជាលោកRousseauដែរថាកុមារកើតមកជាមួយនឹងធម្មជាតិបរិសុទ្ធ ហើយថា ដោយសារតំនាបសង្គមនោះឯងហើយដែលធ្វើឱ្យពួកគេក្លាយជាអសកម្ម ឬហិង្សានិយម។ ដូចអ្វីដែលលោកបានសរសេរក្នុងកុមារមានសេរីភាពតាមបែប Summerhill «ប្រសិនបើមាតាបិតាបំផ្លាញកម្លាំងជីវិតរបស់កូនខ្លួនតាមរយៈភាពផ្ដាច់ការ អត្តនោម័តិ ឧក្រិដ្ឋកម្ម ហើយសង្គ្រាមនឹងនៅតែបន្តកើតមាន»។

សេរីភាពផ្នែកផ្លូវភេទដែលទាមទារដោយ Neill មិនមានទំនាក់ទំនងអ្វីជាមួយភាពស្រើបស្រាល អាសអាភាស ឬក៏ទ្រឹស្ដីស្រើបស្រាលផ្នែកផ្លូវភេទនោះទេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រតិកម្មរបស់ក្រុមលោកចំពោះមុខសេរីភាពកើតយ៉ាងឆាប់រហ័ស និងរីករាលដាលយ៉ាងលឿន [...] ក្រុមគាត់ធ្វើគ្រប់យ៉ាងនូវអ្វីដែលគេហាមឃាត់កាលពីអតីតកាល៖ ពួកគាត់ជេរ ជក់បារី វាយបំផ្លាញវត្ថុផ្សេងៗ។ ហើយនាពេលនោះ ពួកគេមានពាក្យពេចន៍គួរសម និងពាក្យពេចន៍ផ្តាំផ្តែងបង្កប់ក្នុងកែវភ្នែក និងនៅក្នុងសម្រែករបស់ពួកគេ។ គេត្រូវប្រើពេលរហូតដល់ ១០ ខែដើម្បីបំបាត់នូវពាក្យលែបខាយ បញ្ឆិតបញ្ឆៀងរបស់ពួកគេ។ បន្ទាប់ពីនោះមក ក្រុមគេបាត់បង់នូវសេចក្តីគោរពចំពោះអ្វីដែលពួកគេមើលឃើញកាលពីមុនថាជាការផ្តាច់ការ។ នៅប្រហែលជា១០ ខែក្រោយមក កុមារក៏ប្រែជាមានលក្ខណៈបែបធម្មជាតិ និងបរិសុទ្ធដែលនិយាយពីអ្វីដែលខ្លួនគិត ដោយមិនអៀនខ្មាស ហើយក៏ដោយមិនស្អប់ខ្ពើម។

គឺមិនមែនស្រមោលមនុស្សអនាធិបតេយ្យស្លូនតួនោះទេ តែគឺជាស្រមោលមនុស្សដែលជឿទៅលើអំពើល្អ និងរបៀបរបបយ៉ាងមានសណ្តាប់ធ្នាប់ណាមួយនោះដែលចេញមកពីក្នុងចិត្ត។

តាមគំនិតរបស់លោក ការគោរពប្រតិបត្តិមិនត្រូវតម្រូវពីខាងក្រៅនោះទេ តែត្រូវចេញមកពីក្នុងចិត្តរបស់កុមារដែលចេញផុតពីសេចក្តីថប់បារម្ភដើម្បីជ្រើសរើសជម្រើសណាមួយដោយសេរី។ ក្នុងន័យនេះ លោកក៏ប្រឆាំងយ៉ាងខ្លាំងចំពោះការដាក់ទណ្ឌកម្ម ក៏ដូចជាការលើកសរសើរជាដើម។

សុចរិតភាពកើតឡើងដោយការភ័យខ្លាចនរក ខ្លាចនគរបាលឬអាវុធហត្ថ ឬខ្លាចទណ្ឌកម្មគឺមិនមែនជាសុចរិតភាពនោះឡើយ គឺគ្រាន់តែជាភាពកំសាកតែប៉ុណ្ណោះ។ សុចរិតភាពកើតឡើងដោយក្តីសង្ឃឹមថាបានរង្វាន់ ការលើកសរសើរ ឬក៏ឋានសួគ៌ គឺជាទម្រង់នៃការបោកប្រាស់។

នៅសាលារៀន Summerhill កុមារអាចពាល់ត្រូវក្នុងទីជម្រៅរបស់ខ្លួនពីហេតុផលនៃការលះបង់ផ្នែកសង្គម និងការចូលរួមចំណែកក្នុងការកែលម្អសង្គមរបស់គេនៅក្នុងសហគមន៍។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*នេះគឺជាគោលដៅដែលនៅជាប់នឹងរូបលោកពេញមួយជីវិត៖ ផ្ដល់ដល់កុមារនូវអ្វីដែលប្រសើរបំផុត!*

## «គ្រូគង្វាល»នៃសេចក្ដីស្រលាញ់

*កំណត់ហេតុបង្ហាញចេញពីអំណាចអវិជ្ជមាននៃគោលនយោបាយអប់រំនាសម័យកាលរបស់លោក៖ «ការងាររបស់ខ្ញុំអសារបង់ ព្រោះការអប់រំត្រូវផ្ដោតទៅលើការបង្កើតជំនាន់ថ្មីមួយមានលក្ខណៈប្រសើរជាងជំនាន់មុន។ ប្រព័ន្ធអប់រំបច្ចុប្បន្នផលិតតែប្រភេទមនុស្សដែលយើងជួបនាពេលបច្ចុប្បន្នតែប៉ុណ្ណោះ។ ហើយប្រព័ន្ធអប់រំបែបនេះគឺជាប្រព័ន្ធអប់រំដ៏គួរឱ្យអាសូរ។»*

*«ខ្ញុំអះអាងនូវគំនិតដែលថាគោលដៅនៃជីវិត គឺការបន្តនូវសុភមង្គល មានន័យថាការស្វែងរកផលប្រយោជន៍។ ការអប់រំត្រូវតែជាអ្វីដែលរៀបចំសម្រាប់ជីវិត។ ក្នុងវិស័យនេះ វប្បធម៌ ទំនៀមទម្លាប់ប្រពៃណី និងជំនឿរបស់យើង គឺជាអ្វីដែលបានបរាជ័យបាត់ទៅហើយ។ ការអប់រំរបស់យើង នយោបាយរបស់យើង និងសេដ្ឋកិច្ចរបស់យើងនាំយើងទៅរកតែសង្គ្រាមប៉ុណ្ណោះ។»*

*ជាគូសត្រូវស៊ីសាច់ហុតឈាមរបស់* Maria Montessori *លោកតែងតែចំអកឱ្យគរុកោសល្យថ្មីៗ។ តាមរយៈភាពប៉ិនប្រសប់ក្នុងការប្រើប្រាស់បញ្ញត្តិការវិភាគចិត្តសាស្ត្រ លោកមានភាពប៉ិនប្រសប់ក្នុងការចំអកចំពោះគំនិតនិងការអនុវត្តនានាដែលមានលក្ខណៈផ្ទុយពីអ្វីដែលលោកចង់បាន។*

## គរុកោសល្យច្នៃប្រឌិតបាននឹងសិល្បៈនៃការប្រឈមមុខ

*សាលា* Summerhill *ជាសក្ខីភាពនៃការបន្តឥស្សរភាពរបស់ស្ថាបនិក។ អ្វីដែលសំខាន់ដែលយកចេញពីគោលគំនិតរបស់លោក* A. S. Neill *គឺវត្តមានរបស់ គ្រូ-មិត្តរួមថ្នាក់ ដែលអាចជួយដល់កុមារក្នុងការស្វែងរកនូវអ្វី*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលគេចូលចិត្ត អ្វីដែលជាប្រយោជន៍សម្រាប់គេ។ គ្រូបង្រៀនត្រូវប្រុងប្រយ័ត្នដើម្បីចៀសវាងបង្កើតឱ្យមានឡើងវិញនូវស្នាមរបួសផ្លូវចិត្តចំពោះកុមារ តាមរយៈការទាមទារឱ្យកុមាររៀននូវអ្វីដែលមិនមានប្រយោជន៍សម្រាប់គេ។

«មុខវិជ្ជាដែលខ្ញុំទាមទារឱ្យបង្រៀនជាទូទៅ គឺមុខវិជ្ជាណាដែលផ្តល់ប្រយោជន៍»។ លោកត្រូវបានគេរិះគន់ពីបញ្ហាដែលលោកមិនបានគិតពីទំនាស់ផលប្រយោជន៍របស់សិស្សពេលនៅក្នុងថ្នាក់រៀន។

អ្វីដែលសំខាន់នោះគឺការបញ្ជាក់ពីវត្តមានដ៏សកម្មរបស់គ្រូ។ នៅសាលា Summerhill ការធ្វើរបៀបនេះក្លាយទៅជាការសិក្សាដោយសេរី

លោកធ្វើតាមវិធីសាស្ត្របង្រួម(Approche régressive) របស់ Lane ដែលទាមទារឱ្យគ្រូចូលរួមក្នុងក្រុមសិស្សខូច ហើយចូលរួមក្នុងសកម្មភាពផ្តេសផ្តាស់ទាំងនោះ ឬរហូតទាល់តែធ្វើឱ្យសម្ភារសាលារៀនបែកបាក់ជាមួយនឹងពួកគេតែម្តង។ វត្តមានគរុកោសល្យសកម្មធៀបនឹងផលប្រយោជន៍ដែលជិតដាមក្នុងជំនឿជឿជាក់ទៅលើសមត្ថភាពកុមារក្នុងការរកឃើញដោយខ្លួនឯងនូវសណ្តាប់ធ្នាប់ និងវិន័យ។ នៅពេលដែលកុមារបញ្ចប់អារម្មណ៍ក្រេវក្រោធរបស់ខ្លួន កុមារនោះនឹងត្រឡប់មកប្រឹងប្រែងរៀនសូត្រ និងជោគជ័យក្នុងការសិក្សាឡើងវិញ។

គម្រោងតែមួយគត់របស់សាលារៀនគឺធ្វើយ៉ាងណាឱ្យកុមារទាំងអស់ដើរផ្លូវត្រូវ និងមានចិត្តសណ្តោសប្រណីតាមរយៈការអនុវត្តសេរីភាព។

## គំនិតសួរពិចារណា

គឺក្រុមគ្រួសារអ្នកធូរធារដែលមានការគិតប្រកបដោយវិចារណញ្ញាណថាសាលារៀននេះអាចពន្ធត់វិបត្តិកូនរបស់ពួកគេ។

សេរីភាពក្នុងការជ្រើសរើសដែលប្រើប្រាស់នៅក្នុងសាលារៀនតាមបែប Summerhill ផ្តល់ផលប្រយោជន៍ចំពោះកុមារមកពីគ្រួសារធូរធារជាង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កុមារមកពីគ្រួសារក្រីក្រ ក៏ព្រោះថាអ្វីដែលវណ្ណៈកម្មករមិនអាចធ្វើបានគឺជាអ្វីដែលវណ្ណៈអភិជនអាចធ្វើបាន។ មាតាបិតារបស់ក្រុមអភិជនមានវត្តមាននៅក្នុងសាលារៀន។ ពួកគេជំរុញឱ្យកូនរបស់ពួកគេធ្វើការជ្រើសរើស។

ប្រៀបបាននឹងកោះសុកមង្គល Summerhill ពិចារណាពីសន្តិភាពដោយផ្តោតលើសន្តិភាពផ្លូវចិត្តជាជាងសន្តិភាពវចនាសម្ព័ន្ធ។ ពេលខ្លះ កុមារត្រូវការការជួយដោយផ្ទាល់ ត្រូវការឈើច្រត់មុនគេអាចដើរដោយខ្លួនឯងបាន ត្រូវការគំរូនៃភាពជោគជ័យ ហើយក៏មិនអាចស្ងប់ចិត្តនឹងស្ថានភាពរបស់ខ្លួនបានដែរ។

## ១៦. Celestin FREINET (1896-1966)

សាលារៀនប្រពៃណីផ្តោតទៅលើមុខវិជ្ជាដែលត្រូវបង្រៀន និងលើកម្មវិធីដែលកំណត់មុខវិជ្ជាទាំងនេះ។ ក្នុងការរៀបចំសាលារៀន គ្រូក៏ដោយសិស្សក៏ដោយត្រូវបន្ទន់ខ្លួនទៅតាមការទាមទាររបស់សាលារៀន។

សាលារៀនពេលអនាគតនឹងផ្តោតទៅលើកុមារដែលជាសមាជិករបស់សហគមន៍។ គឺធ្វើទៅតាមតម្រូវការចាំបាច់របស់កុមារ ដែលត្រូវកំណត់ពីបច្ចេកទេសក្នុងការគ្រប់គ្រងកុមារ មុខវិជ្ជាដែលត្រូវបង្រៀន ប្រព័ន្ធក្នុងការចាប់យកចំណេះដឹង របៀបក្នុងការអប់រំ ដោយផ្អែកទៅលើតម្រូវការរបស់សង្គមដែលកុមារនោះរស់នៅ ។

លោក Freinet រៀបចំវិធានថ្នាក់រៀនបែបពនេចរ។ ក្រោយពីបានអនុវត្តការបង្រៀនតាមបែបថ្នាក់ពនេចរ លោកបន្តស្វែងរកនវានុវត្តន៍ផ្សេងៗទៀតនៅក្នុងថ្នាក់រៀន។

មួយឆ្នាំក្រោយមក លោកផ្តួចផ្តើមក្នុងការបង្កើតសហករនៃការបង្រៀនបែបអាណាចក្រ (coopérative de l’enseignement laïc (CEL)) ដែលការបោះពុម្ពនៅសាលារៀនក្លាយទៅជាការបោះពុម្ពទស្សនាវដ្តី។ នៅឆ្នាំ១៩៤៧ វិទ្យាស្ថានសហករនៃសាលាទំនើប (Institut coopératif de l’école modern) ដែល

ជាចលនារបស់ Freinet នាពេលបច្ចុប្បន្នត្រូវបានបង្កើត។

## គរុកោសល្យនយោបាយរបស់ Freinet

មានស្មារតីមួយបែប Freinet នៅក្នុងវិធីសាស្ត្រគរុកោសល្យរបស់លោក ដែលមានបង្កប់ពីក្រោយនូវគោលបំណងផ្នែកទស្សនវិជ្ជា និងនយោបាយ។

គ្រូបង្រៀននៃសាលា Freinet ផ្តល់ដល់កុមារនូវសាលារៀនស្តង់ដារខ្ពស់ និងសកម្មមួយ។ ក្នុងន័យនេះ លោកត្រូវបានចាត់ទុកជានៅក្នុងចលនានៃការអប់រំបែបថ្មីដែលតស៊ូឱ្យមានការយកចិត្តទុកដាក់ចំពោះកុមារនៅក្នុងសាលារៀន។ គ្រូបង្រៀនត្រូវយកចិត្តទុកដាក់ចំពោះចំណង់ចំណូលចិត្ត និងបទពិសោធន៍របស់កុមារ ធ្វើបែបនេះនាំឱ្យកុមារអាចសម្របខ្លួនទៅតាមចំណង់ចំណូលចិត្តរបស់គេ ប្រយោជន៍ដើម្បីឱ្យគេរកឃើញនូវអត្ថន័យ និងភាពរីករាយក្នុងការសិក្សា។ តួនាទីរបស់គ្រូបង្រៀនក៏ត្រូវថែមនុស្សឱ្យមានសមត្ថភាព គំនិតបង្កើតថ្មី មានសេរីភាព និងមានទំនួលខុសត្រូវសម្រាប់ជីវិតក្នុងសង្គម។

លោក Freinet ប្រឆាំងនឹងការបង្រៀននៅសម័យរបស់គាត់ដែលគាត់ចាត់ទុកថាគឺជាការបង្រៀនមួយដែលផ្តោតខ្លាំងពេកទៅលើចំណេះដឹងអរូបិយ និងទៅគុណផលផ្នែកបញ្ញា។

តាមគំនិតរបស់លោក Freinet «សាលារៀនត្រូវអប់រំកុមារទៅតាមអ្វីដែលគេមានពីធម្មជាតិ ទៅតាមតម្រូវការរបស់គេ ទៅតាមចំណង់ចំណូលចិត្តពិតប្រាកដរបស់គេ បើទោះបីជាពេលខ្លះពួកគេមានលក្ខណៈផ្ទុយពីទម្លាប់សង្គម ឬក៏ផ្ទុយពីគំនិតរបស់អ្នកអប់រំក៏ដោយចុះ។ សាលារៀនត្រូវផ្តល់ដល់ពួកគេនូវបច្ចេកទេសសមស្រប និងឧបករណ៍សមរម្យទៅនឹងបច្ចេកទេសទាំងនោះ ដើម្បីផ្តល់សេរីភាពពេញលេញឱ្យពួកគេអភិវឌ្ឍពង្រីកចំណេះដឹង សម្រេចសមត្ថភាពរបស់ខ្លួន និងធ្វើខ្លួនឱ្យកាន់តែប្រាកដសម្រាប់ជីវិតក្នុងគ្រប់ទម្រង់ទាំងក្នុង ទាំងក្រៅនៃតួអង្គខ្លួនឯង»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោក Freinet ទាមទារពីគ្រប់អ្នកអប់រំទាំងអស់ក្នុងការរៀនស្គាល់សិស្សរបស់ខ្លួន។ លោកស្នើធ្វើយ៉ាងណាឱ្យគេអាចបង្កើតសម្រាប់សិស្សម្នាក់ៗនូវកម្មវិធីមួយដើម្បីសម្របការបង្រៀនឱ្យកាន់តែប្រសើរទៅតាមការវិវឌ្ឍ និងទៅតាមវេទយិតភាព (sensibilité) ផ្ទាល់ខ្លួនរបស់សិស្ស។ ក្នុងន័យនេះ កុមារត្រូវចាត់ទុកដូចជារុក្ខជាតិដែលត្រូវត្រូវជួយឱ្យគេរីកលូតលាស់ដោយសុខដុម និងប្រកបដោយប្រសិទ្ធភាព។

គរុកោសល្យ Freinet រួមមានគោលការណ៍មួយចំនួនដែលមិនត្រូវបំពាននាំឱ្យប្រឈមទៅនឹងការពិន័យដល់កុមារគឺ«គោលការណ៍មិនផ្លាស់ប្តូរ invariants» ៖

គោលការណ៍មិនផ្លាស់ប្តូរទី ១៖ កុមារមានធម្មជាតិដូចយើងដែរ។

គោលការណ៍មិនផ្លាស់ប្តូរទី២៧៖ យើងរៀបចំប្រជាធិបតេយ្យសម្រាប់អនាគត តាមរយៈប្រជាធិបតេយ្យនៅសាលារៀន។ បើនៅក្នុងសាលារៀនមានលក្ខណៈផ្តាច់ការ នោះសាលារៀននឹងមិនអាចអប់រំពលរដ្ឋឱ្យក្លាយទៅជាអ្នកប្រជាធិបតេយ្យបាននោះទេ។

គេក្មេចថាលោកគឺជាអ្នកអានដ៏ស្មោះស្ម័គ្រនៃស្នាដៃនិពន្ធរបស់ Rousseau និង Voltaire ហើយក្មេចថាលោកទទួលនូវឥទ្ធិពលពីស្នាដៃរបស់Dewey និងជាលោកស្គាល់ Nadejda Kroupskaïa ឬមិត្តសម្លាញ់ជាគរុវិទូជនជាតិស្វីស និងជាគ្រិស្តសាសនិក Adolphe Ferrièreរបស់លោក។

លោកគឺជាអ្នកតស៊ូកុម្មុយនីសជាមួយនឹងចក្ខុវិស័យអប់រំបម្រើដល់គោលនយោបាយប្រយុទ្ធដើម្បីការផ្លាស់ប្តូរសង្គមបច្ចុប្បន្ន។

ចំពោះ Freinet សាលារៀន Vence នឹងក្លាយជាឧបករណ៍ជាក់ស្តែងពិតប្រាកដបម្រើដល់ការប្រយុទ្ធផ្នែកសង្គមមួយ។ សាលារៀនបណ្តុះបណ្តាលកម្មករសកម្មជន ហើយមិនមែនបណ្តុះបណ្តាលបញ្ញាវន្តបានតែនិយាយនោះទេ។

សាលារៀន Freinet ចង់បណ្តុះបណ្តាលពលករថ្មីដែលស្គាល់ពីគុណ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តម្លៃរបស់ខ្លួន និងចេះប្រយុទ្ធប្រឆាំងរាល់ភាពអយុត្តិធម៌សង្គម។ គឺជាក្រុមបដិវត្តដែលតាមរយៈចំណេះដឹងបច្ចេកទេស និងតាមរយៈការបណ្តុះបណ្តាលផ្នែកស្មារតី អាចកម្ទេចគុណតម្លៃចាស់គំរិលដែលកើតឡើងពីភាពអាត្មានិយម ការកេងចំណេញ និងការធ្វើទាសភាពកម្មចំពោះអ្នកដទៃ។ នេះជាដំណាក់កាលអនុវត្តគុណតម្លៃមនុស្សជាតិ ដែលរួមមាន សេរីភាព សមភាព សាមគ្គីភាព ការគោរពសិទ្ធិ និងការគោរពមនុស្ស...។

គរុកោសល្យតស៊ូនេះមានគោលដៅក្នុងការបណ្តុះបណ្តាលមនុស្សពេញវ័យជំនាន់ថ្មីឱ្យមានសមត្ថភាពក្នុងការប្រយុទ្ធតស៊ូរាល់ទម្រង់ទាសភាព និងការកេងប្រវ័ញ្ចគ្រប់ប្រភេទ និងកសាងសង្គមមួយដែលមានការគោរពដោយគ្រប់គ្នាតាមរយៈការងារ។ គឺមនុស្សពេញវ័យដែលដឹងពីការអភិវឌ្ឍគ្រប់សក្តានុពលរបស់គេដោយមានសិទ្ធិក្នុងការជ្រើសរើសផ្លូវដើរដោយសេរី មានសមត្ថភាពក្នុងការសម្របខ្លួនទៅនឹងមជ្ឈដ្ឋានរបស់ខ្លួន និងធ្វើជាម្ចាស់នូវរាល់មរតកវប្បធម៌។

## សារៈសំខាន់នៃបច្ចេកទេសក្នុងគរុកោសល្យ Freinet

ដើមដំបូងនៃការកកើតគរុកោសល្យបែបនេះ គឺដោយសារពិការភាពដែលធ្វើឱ្យ Freinet មិនអាចនិយាយឮខ្លាំងៗពេញមួយថ្ងៃបាននៅក្នុងថ្នាក់រៀនរបស់លោក។

បើទោះបីជាបែបនោះក្តី ចំណង់ចំណូលចិត្តជាគ្រូបង្រៀនបានបង្ខំរូបគាត់ឱ្យបង្កើតគរុកោសល្យមួយបែបដែលអភិវឌ្ឍទៅតាមនីតិវិធីខុសពី «គរុកោសល្យជួរមុខ (គ្រូជាធំ) (pédagogie frontale)»។ ក្នុងន័យនេះ គំនិតនៃ «ពនេចរ» ចាត់ជាចំណុចចាប់ផ្តើមនៃការសង្កេតដែលធ្វើឱ្យគេអាចស្ថាបនានូវចំណេះដឹង ដែលគំនិតនេះត្រូវបានលើកឡើងរួចមកហើយដោយលោក Marc-Antoine Jullien (Essai sur une methode ..., 1808)។

ក្នុងស្នាដៃដដែលរបស់ M.A. Jullien យើងក៏ឃើញមានមូលដ្ឋានគ្រឹះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃការសរសេរកំណត់ហេតុដែលចាត់ជាមធ្យោបាយសន្សំបន្តិចម្តងៗនូវការសង្កេតរបស់ខ្លួន។ ដោយសារលោក Freinet មិនអាចនិយាយបានយូរ លោកជំរុញឱ្យមានការងារជាក្រុមសិស្សវិញ។ សិស្សរៀបចំជាក្រុមតូចៗដើម្បីសិក្សា។ មួយវិញទៀត លោក Freinet បានសង្កេតដោយយកចិត្តទុកដាក់នូវគរុកោសល្យបែប «គ្រូ-មិត្តរួមថ្នាក់» របស់លោក Hambourg។

ក្នុង «ចលនា Freinet» ម្នាក់ៗត្រូវបានអញ្ជើញឱ្យសាកល្បងបច្ចេកទេសថ្មី និងបង្ហាញបច្ចេកទេសនោះទៅកាន់មិត្តរួមថ្នាក់នៃចលនាគរុកោសល្យ។

ក្នុងគរុកោសល្យ Freinet កិច្ចប្រជុំប្រឹក្សាយោបល់គឺជាខណៈចាំបាច់បំផុត។ កិច្ចប្រជុំប្រឹក្សាយោបល់គឺជាកិច្ចប្រជុំថ្នាក់រៀនទាំងមូលដែលធ្វើឡើងម្តងក្នុងមួយសប្តាហ៍ដើម្បីគ្រប់គ្រងការរៀបចំពេលវេលានិងរៀបចំការងារ។ តួនាទីរបស់ប្រធានអង្គប្រជុំ និងលេខាត្រូវបានបែងចែកទៅដល់កុមារ។ គេកត់ត្រារាល់សេចក្តីសម្រេចនានា។ កិច្ចប្រជុំប្រឹក្សាយោបល់មានតួនាទីក្នុងការគ្រប់គ្រង (រៀបចំ) តែក៏មានតួនាទីក្នុងការវិភាគ។ ប្រសិនបើមានជម្លោះរវាងកុមារ និងកុមារ ឬរវាងគំនិតផ្តួចផ្តើមរបស់គ្រូ និងសិស្ស បញ្ហានេះនឹងត្រូវលើកមកពិភាក្សានៅក្នុងកិច្ចប្រជុំ។ កុមារពិនិត្យពិច័យ មុននឹងសម្រេចលើអ្វីមួយ។ ម្នាក់ៗទទួលគោរពតាមសេចក្តីសម្រេចរបស់អង្គប្រជុំ។

ទម្រង់របស់អង្គប្រជុំប្រឹក្សាយោបល់មាននៅក្នុងការគ្រប់គ្រងកំណត់ហេតុថ្នាក់រៀន។ នៅពេលមានករណីពិសេសដែលកើតមានឡើងនៅពេលសិក្សា (ទស្សនកិច្ចនៅកសិដ្ឋាន ឬក្រុមហ៊ុនជាដើម) កុមារត្រូវបានស្នើឱ្យសរសេរកំណត់ហេតុនៃការសង្កេត។ បន្ទាប់មក កុមារត្រូវធ្វើបទបង្ហាញដល់មិត្តរួមថ្នាក់ទាំងអស់ រួចមានការបោះឆ្នោតដើម្បីសម្រេចថាកំណត់ហេតុណាត្រូវជាប់លេខដើម្បីចុះក្នុងទស្សនាវដ្តីសាលារៀន។ ក្នុងន័យនេះ នៅក្នុង ការគ្រប់គ្រងទស្សនាវដ្តីថ្នាក់រៀនដែលនឹងត្រូវបោះពុម្ពផ្សាយ គេសង្កេតឃើញមានខណៈនៃកិច្ចប្រជុំរួម និងខណៈនៃកិច្ចប្រជុំពិគ្រោះយោបល់។

កិច្ចប្រជុំពិគ្រោះយោបល់ក៏គ្រប់គ្រងសមាសធាតុថវិការបស់សហករ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថ្នាក់រៀនមានថវិការបស់ខ្លួន។ កុមារធ្វើការចំណាយ តែគេក៏ត្រូវមានប្រកពធនធានដែរ។ ទស្សនាវដ្ដីដែលផលិតនៅក្នុងថ្នាក់រៀនហើយដែលត្រូវបានបោះពុម្ពត្រូវបានលក់នៅក្នុងភូមិ។ ហើយគេសម្រេចជារួមក្នុងការប្រើប្រាស់ថវិកាដែលទទួលបានពីការលក់ទស្សនាវដ្ដីនេះ។ គរុកោសល្យ Freinet ស្វែងរកមធ្យោបាយធ្វើយ៉ាងណាឱ្យកុមារចេះដឹងពីបញ្ហាសេដ្ឋកិច្ច គណនីហិរញ្ញវត្ថុ។ រាល់អ្វីៗដែលពាក់ព័ន្ធនឹង «មូលដ្ឋានសម្ភារៈ» សម្រាប់ថ្នាក់រៀនគឺជាប្រធានបទក្នុងការពិចារណាជារួម។

អ្វីដែលគេចង់បង្រៀនដល់កុមារ គឺមិនត្រឹមតែ«មុខវិជ្ជានានា»នោះទេ តែរបៀបដែលវត្ថុ ឬអ្វីៗទាំងនោះកើតឡើង និងដំណើរការបាន។ ការដើរកម្សាន្តអាចជាពេលវេលាមួយសម្រាប់ពិចារណាដែលរួមមានសមាសធាតុនានាពាក់ព័ន្ធនឹងមុខវិជ្ជាច្រើនមុខ (ភាសា គណិតវិទ្យា ប្រវត្តិសាស្ត្រ ភូមិវិទ្យាជាដើម)

ថ្នាក់រៀនជនបទច្រើនតែទទួលសិស្សមានអាយុខុសៗគ្នា។ ថ្នាក់រៀនបែបនេះ «មានច្រើនកម្រិត» គឺជាក្របខ័ណ្ឌអំណោយផលមួយសម្រាប់ការអនុវត្តការងារដែលសិស្សមានអាយុច្រើនអាចជួយដល់សិស្សមានអាយុតិចក្នុងការចូលរួមសកម្មភាពសិក្សារៀនសូត្រ។ គរុកោសល្យ Freinet ទទួលបានជោគជ័យជាខ្លាំងនៅប្រទេសបារាំងតាមទីជនបទនៅក្នុងចន្លោះឆ្នាំ ១៩៣០ ដល់១៩៦៨។

## គំនិតគួរពិចារណា

សាវ័កចាស់ៗរបស់លោក ដូចជា Fernand Oury ឬ Raymond Fonvieille ព្រមទាំងមិត្តរួមថ្នាក់កុម្មុយនីស ដូចជា Georges Snyders ជាដើមនោះរិះគន់ Freinet ចំពោះការមាក់ងាយរបស់លោកទៅដល់ក្រុមអ្នកទ្រឹស្ដីវិទូ មានន័យថា ក្រុមបញ្ញាជននានា និងជំនឿងប់ងល់របស់លោកលើ«វិធីសាស្ត្រធម្មជាតិ» ដែលលោកចាត់ទុកថា ជាប្រកពគរុកោសល្យតែមួយគត់ដែលមានតម្លៃនោះ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គោលគំនិតចិត្តសាស្ត្ររបស់លោកត្រូវបានអភិវឌ្ឍលើការសិក្សារៀនសូត្រតាមរយៈការរាវរកតាមបែបពិសោធន៍ ក៏ដូចជាវិធីសាស្ត្រតាមបែបធម្មជាតិដែលមិនគិតពីអសម្បជញ្ញៈ ហើយក៏មិនគិតពីកុមារដែលងាយរងគ្រោះផ្នែកសង្គម និងផ្នែកចិត្តសាស្ត្រធ្ងន់ធ្ងរនោះដែរ។ គឺជាចិត្តសាស្ត្រដែលគិតថាកុមាររស់នៅក្នុងបរិដ្ឋានល្អនៃភូមិតូចមួយ ដែលអមដោយព្រៃព្រឹក្សា ហើយដែលមានមាតាបិតាយល់ចិត្តគ្នា និងគ្រួសារប្រកបដោយសុភមង្គល។ «គរុកោសល្យជោគជ័យ» របស់លោកមិនបានគិតពីកុមារក្នុងមជ្ឈដ្ឋានសង្គមយ៉ាប់យ៉ឺន ឬក្នុងក្រុមជនអន្តោប្រវេសន៍នោះទេ។ មួយវិញទៀត វិធីសាស្ត្រធម្មជាតិរបស់លោកក៏មិនបានគិតពីកុមារដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរបណ្តាលមកពីការប្រឈមក្នុងជីវិតដ៏ឈឺចាប់ និងជូរចត់នោះទេ។

ឥទ្ធិពលសាលារៀនសកម្មរបស់ Freinet គឺនៅតែជាបច្ចុប្បន្នភាពតាមរយៈស្មារតី និងវិធីសាស្ត្រអនុវត្តតាមលក្ខណៈតិចឬច្រើនបែបព្រៃ (Sauvage) របស់លោក។ គរុកោសល្យនេះនៅអាចបម្រើដល់កម្រិតសិក្សាមួយចំនួននៅតាមសាលារៀន ឬក្នុងផ្នែកឯកទេសនានា នៅប្រទេសបារាំងក៏ដូចជានៅក្នុងពិភពលោក។

## ១៧. Pierre FAURE (1904-1988)

ត្រូវមានជំនឿជឿជាក់លើកុមារដោយបើកផ្លូវឱ្យគេ ដោយផ្តល់ឱ្យគេនូវសកម្មភាពនានាដែលគេអាចមានឱកាសក្នុងការទទួលបានជោគជ័យពេញលេញតាំងពីចាប់ផ្តើមដំបូង ឬក៏យ៉ាងហោចណាស់ក៏ធ្វើឱ្យគេអាចរីកចម្រើនជំជាត់ និងទទួលបានជោគជ័យមួយចំនួនណានោះ។ [...] អ្វីដែលយុវជនបានធ្វើ និងបានរកឃើញ បើទោះបីជាមិនល្អឥតខ្ចោះ ហើយមើលទៅហាក់មានន័យខ្លឹមសារត្រឹមត្រូវនឹងជំរុញឱ្យគេមានចំណង់ចំណូលចិត្ត និងមោទនភាពក្នុងការផ្សព្វផ្សាយពីទង្វើទាំងនោះ បង្ហាញពីទង្វើទាំងនោះ និងចែករំលែកទង្វើទាំងនោះ។ គឺនោះហើយដែលធ្វើឱ្យមានការផ្លាស់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឬរមតិយោបល់ និងការជួយគ្នាទៅវិញទៅមក។

កន្សោមពាក្យ «Societas Iesu » ត្រូវបានស្គាល់នៅប្រទេសបារាំងក្រោមពាក្យសម្រាយថា «ក្រុមជំនុំព្រះយេស៊ូ» ត្រូវបានបង្កើតឡើងជាផ្លូវការនៅឆ្នាំ ១៥៤០ ដោយអាចារ្យសាសនាគ្រិស្តជាតិអេស្ប៉ាញម្នាក់ គឺលោក Ignace de Loyola (១៤៩១-១៥៥៦)។ សមាជិករបស់ក្រុមជំនុំត្រូវបានកំណត់ដោយការប្ដេជ្ញាចិត្តតស៊ូ និងដោយមិនរួញរាក្នុងការបម្រើដល់ព្រះគ្រិស្ត និងការគោរពតាមដោយគ្មានតវ៉ាចំពោះសម្ដេចប៉ាប។

តែក្រុមជំនុំព្រះយេស៊ូបន្ថែមដល់សកម្មភាពរបស់ខ្លួនដែលផ្ដោតជាពិសេសក្នុងបេសកកម្មផ្សព្វផ្សាយសាសនារបស់ខ្លួននូវសកម្មភាពអប់រំ។ សកម្មភាពនេះក៏បានក្លាយទៅជាសកម្មភាពចម្បងទៀតផង។ នៅឆ្នាំ១៥៥១ ក្រុមជំនុំបានបើកអនុវិទ្យាល័យទី១ របស់ខ្លួននៅក្រុងរ៉ូម។ នៅឆ្នាំ១៧៦៣ ក្រុមជំនុំព្រះយេស៊ូមានអនុវិទ្យាល័យប្រមាណជាជាង ២០០ គ្រាន់តែនៅប្រទេសបារាំង។

ក្នុងវិស័យអប់រំ អនុវិទ្យាល័យក្រុមជំនុំទទួលបាននូវកិត្តិនាមល្បីសុះសាយ។ សិស្សមួយចំនួន បានក្លាយទៅជាមនុស្សល្បីល្បាញ ដូចជាលោក Montaigne លោក Erasmus ឬក៏លោក Voltaire ជាដើមនោះ តែពួកគេមិនបានរក្សាទុកនូវស្នាកស្នាមអនុស្សាវរីយ៍ល្អរបស់សាលារៀនរបស់ពួកគាត់ដែលមានវិន័យតឹងរ៉ឹងបំផុតនោះទេ។

នៅឆ្នាំ១៩៣៥លោក Pierre Faure ត្រូវបានកោះអញ្ជើញដោយអាចារ្យសាសនាគ្រិស្ត Desbusquois ដើម្បីទទួលបន្ទុកក្នុងក្របខ័ណ្ឌនៃសកម្មភាពប្រជាជន Action Populaire ស្ដីពីបញ្ហាអប់រំ។

លោកបានបង្កើតទស្សនាវដ្ដីចំនួនពីរ គឺ Pour les parents និង Trait d'union។ ទស្សនាវដ្ដីទាំងពីរនេះមានគោលបំណងក្នុងការផ្ដល់ព័ត៌មាន និងកៀរគរគ្រួសារ និងគ្រូបង្រៀន។ លោកបានដាក់ឱ្យប្រើប្រាស់ឧបករណ៍មួយទៀតគឺ៖ សំណុំឯកសារសាលារៀន Le Fichier scolaire ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅឆ្នាំ ១៩៣៨ ក្រោមការដឹកនាំរបស់លោក «លេខាធិការដ្ឋានអនុវិទ្យាល័យ le secrétariat des collèges» បានក្លាយទៅជា «មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវគរុកោសល្យ Le centre d'Etudes Pédagogiques» ហើយមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀននៅប្រទេសបារាំង និងនៅបរទេសក៏ត្រូវបានបង្កើតឡើង។ នៅឆ្នាំ១៩៤៥ លោកបានបង្កើតនិងដឹកនាំគ្រប់គ្រងទស្សនាវដ្តី «គរុកោសល្យ Pédagogie» ដែលទទួលបានការពេញនិយមក្នុងការអានយ៉ាងឆាប់រហ័សពីសំណាក់គ្រូបង្រៀន។

## ឥទ្ធិពលសង្គមអប់រំ

ក្រោយសង្គ្រាម លោក Pierre Faure ផ្តល់បេសកកម្មដល់សាលារៀនក្នុងការចូលរួម «ការអប់រំមនុស្សជាតិឡើងវិញ»។ លោកអាចារ្យ Faure អះអាងថាបញ្ហាសាលារៀនមានជាប់ពាក់ព័ន្ធនឹងបញ្ហាសង្គម។ សាលារៀនត្រូវគិតពីវឌ្ឍនភាព និងភាពរំជើបរំជួលសង្គម មានន័យថាបញ្ហាសេដ្ឋកិច្ច នយោបាយ និងសាសនាជាដើម។ល។

ពេលចប់សង្គ្រាមភ្លាម លោក Pierre Faure បានប្រកាសចេញទស្សនាវដ្តីមួយមានគោលដៅក្នុងការរិះរកដោះស្រាយបញ្ហានានាដែលកើតមានចំពោះសាលារៀន និងនៅក្នុងសាលារៀន។ លោកបានសរសេរសៀវភៅដ៏ក្រាស់មួយមានចំណងជើងថា សាលារៀន និងបុរី (L'École et la Cité) ដែលបង្ហាញថាគោលនយោបាយអប់រំគឺជាចម្លើយរបស់សង្គម តែនៅក្នុងនោះលោកក៏ចង់បង្ហាញជាពិសេសនូវទំនាក់ទំនងមិនអាចកាត់ផ្តាច់បានរវាងសាលារៀន និងបុរី។

ក្នុងគ្រប់សាខាផលិត ក្នុងគ្រប់វិស័យ គេត្រូវការមនុស្សមានគុណភាព ដូច្នេះគេក៏ត្រូវការសាលារៀនមានលក្ខណៈបត់បែនត្រូវទៅតាមមជ្ឈដ្ឋានផ្សេងៗគ្នានៃសង្គម។

អនាគតរបស់សង្គមផ្អែកទៅលើសាលារៀន ហើយអនាគតនោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ទៀតសោត គឺពឹងផ្អែកទាំងលើផ្នែកសេដ្ឋកិច្ច និងមនុស្ស។ ដូច្នេះ ដើម្បីឱ្យមនុស្សមានគុណភាព គេត្រូវយកចិត្តទុកដាក់ពីអ្វីដែលនឹងកើតឡើង និងឆ្លើយតបទៅនឹងសង្គមរាល់បញ្ហាប្រឈមនានាដែលកើតមានឡើង។ សាលារៀនត្រូវតែជាចម្លើយច្បាស់លាស់មួយសម្រាប់បញ្ហាប្រឈមដែលកើតមានក្នុងសង្គម។

សាលារៀនជាស្ថាប័នសង្គមមួយ។ សាលារៀនត្រូវបញ្ចេញសកម្មភាពនានាដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់សង្គម ឬក៏ជំរុញក្នុងនាមជាតួអង្គសំខាន់មួយ ដោយមិនត្រូវឃុំខ្លួនឯងក្នុងអគារប្រណីត(Ivory tower) នៃបញ្ញាជនដែលមានលក្ខណៈដាច់តែឯងដោយប្រាស់ចាកពីកាតព្វកិច្ចសង្គមក្នុងការអប់រំយុវជននោះទេ។

លោក Pierre Faure ជាសមាជិករបស់ក្រុមមួយដែលកៀរគរក្រុមសហជីព និងជាពិសេសមាតាបិតាសិស្សក្នុងការអំពាវនាវឱ្យមានគោលនយោបាយដើម្បីការរស់រានសាលារៀនបែបសេរី។ លោកបានដាក់បញ្ចូលក្រុមមាតាបិតាសិស្សដែលកាលពីដើមឡើយនៅក្រៅជីវភាពរបស់សាលារៀនចូលរួមក្នុងជីវភាពសាលារៀន ក៏ដូចជាកិច្ចពិភាក្សាផ្សេងៗពាក់ព័ន្ធនឹងការសិក្សារៀនសូត្រ។ ក្នុងន័យនេះ មាតាបិតាសិស្សយល់ដឹងច្បាស់ពីភាពចាំបាច់នៃសេរីភាពពិតប្រាកដនៃការបង្រៀន។ តាមទស្សនៈលោកសេរីភាពក្នុងការគិតត្រូវឆ្លងតាមជម្រើសរបស់គ្រួសារក្នុងការជ្រើសយកសម្រាប់សាលារៀនដែលគេសង្ឃឹមថានឹងផ្តល់សេរីភាពនោះដល់កូនរបស់គេ។ មិនត្រឹមតែគ្រួសារនោះទេដែលត្រូវជ្រើសរើស តែសាលារៀនក៏ត្រូវផ្តល់ដល់គ្រួសារសិស្សវិញនូវខ្លឹមសារ និងរបៀបដែលគេប្រើប្រាស់ក្នុងការអប់រំកុមារផងដែរ។

ការប្រកាន់ជំហរដែលទាមទារឱ្យបញ្ចូលគ្រួសារទៅក្នុងជីវភាពសាលារៀន នេះបង្កើតជាថ្មីនូវសំណួរដែលសួរពីការបង្រៀន និងការអប់រំ។ មាតាបិតាយល់ដឹងច្បាស់ពីរបៀបក្នុងការចាប់យកចំណេះដឹង ក៏ដូចជាការវាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តម្លៃ ផ្នែកសីលធម៌ក្នុនៗរបស់ពួកគេ។

ក្នុងកិច្ចពិភាក្សា «បង្រៀន ឬអប់រំ?» លោក Pierre Faure ជ្រើសយកទម្រង់សាលារៀនអប់រំបង្រៀន មានន័យថាសាលារៀនដែលអប់រំផង និងបង្រៀនផង។

លោក Ferdinand Buisson ដែលជាសហការីដ៏ជិតស្និទ្ធរបស់លោកបានបកស្រាយយ៉ាងល្អនូវគំនិតនេះដោយលើកឡើងថា៖

បើតាមការអប់រំបែបអាណាចក្រនៅកម្រិតបឋមសិក្សា គេអាចមើលឃើញយ៉ាងច្បាស់ពីការបន្ទាបគោលការណ៍នៃការបង្រៀននៅត្រឹមការសិក្សាពីអំណាននិងសំណេរ ពីអក្ខរាវិរុទ្ធនិងការគិតលេខគណិត ការបន្ទាបគោលការណ៍នៃការបង្រៀននៅត្រឹមមេរៀនស្តីពីវត្ថុ និងមេរៀនស្តីពីពាក្យ[...] យើងមិនស្ទាក់ស្ទើរក្នុងការនិយាយថានោះគឺជាអ្វីដែលធ្វើរួចមកហើយនៅក្នុងការបង្រៀនកម្រិតជាតិ។ គឺការនាំគ្រូបង្រៀនទៅរកតួនាទីដែលស្ទើរតែដូចគ្រឿងម៉ាស៊ីននៃគ្រូបង្រៀនសម័យបុរាណ [...]។ ត្រូវឱ្យគ្រូមានសិទ្ធិនិងកាតព្វកិច្ចក្នុងការនិយាយទៅកាន់បេះដូងក៏ដូចជាទៅកាន់ព្រលឹងរបស់សិស្ស ត្រូវឱ្យគ្រូមានសិទ្ធិក្នុងការតាមដានការអប់រំមនសិការសម្រាប់សិស្សម្នាក់ៗ ឬយ៉ាងហោចណាស់ក៏ពេលវេលាដែលប្រើប្រាស់សម្រាប់សកម្មភាពទាំងនោះ ស្មើនឹងផ្នែកផ្សេងៗទៀតក្នុងការបង្រៀនរបស់គាត់ដែរ ។

គឺក្នុងស្មារតីនេះហើយដែលលោក Pierre Faure មានចំណាប់អារម្មណ៍ និងអនុវត្តក្នុងការពិសោធស្តីពីការអប់រំបែបថ្មីរបស់លោក។ ចំពោះរូបលោក ការកសាងសង្គមថ្មីដែលជាតថភាពក្រោយពីការរំដោះ ទាមទារឱ្យមានការកសាងតរុកោសល្យថ្មី។ សាលារៀនមិនត្រូវហ៊ុំព័ទ្ធតែនៅក្នុងគំនិតបង្រៀនសិស្សត្រឹមអាននិងគិតលេខនោះទេ តែត្រូវគិតជាខ្លួនប្រៀបដូចជា «ចំណុចប្រសព្វដែលមានសមាជិករបស់បុរីត្រូវជួបជុំគ្នា» ជាទីកន្លែងសម្រាប់ជួបជុំផ្នែកសង្គមជុំវិញបញ្ហាការសិក្សារៀនសូត្រនូវចំណេះដឹងដែលនឹងត្រូវប្រើប្រាស់ជាចាំបាច់នៅក្នុងបុរី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កាត់ផ្តាច់សាលារៀនចេញពីបញ្ហាប្រឈមរបស់សង្គម ព្រមទាំងប្រាស់ចាកពីវង្វេងនភាពគរុកោសល្យគឺជាអ្វីដែលហួសនិស្ស័យ ហើយអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់សាលារៀន ក៏ដូចជាដល់សង្គមទាំងមូលតែម្តង។

## គរុកោសល្យបែបថ្មីតាមគំនិតរបស់លោក Pierre Faure

លោក Pierre Faure បារម្ភក្នុងការអនុវត្តគរុកោសល្យបែបរស់រវើក និងជាក់ស្តែង។ គឺជាគរុកោសល្យដែលឈរលើមូលដ្ឋាននៃជំនឿពាក់ព័ន្ធនឹងភាពដែលអាចអប់រំបាន និងទៅលើសមត្ថភាពនវានុវត្តន៍និងការសិក្សារៀនសូត្ររបស់សិស្ស ដោយផ្តោតលើដំណាក់កាលនីមួយៗនៃការរីកលូតលាស់របស់កុមារ។

លោក Pierre Faure មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយលោកស្រី Hélène Lubienska។ តាមរយៈការជំរុញរបស់លោកស្រី លោកបានផ្តួចផ្តើមគំនិតក្នុងការដាក់ចេញជាវិធីសាស្ត្រ និងគោលគំនិតស្តីពី «មនុស្សមានមនសិការ» ដែលមានចេតនាក្នុងការធ្វើឱ្យកុមារមានការប្រយ័ត្នប្រយែងចំពោះកាយវិការប្រចាំថ្ងៃរបស់ខ្លួន ដែលក្លាយទៅជាប្រភពនៃការសិក្សារៀនសូត្រ និងការវាយតម្លៃផ្នែកសីលធម៌។

ចំពោះរូបលោក លោកបានទទូចលើសារៈសំខាន់នៃភាពស្ងប់ស្ងៀមសកម្មក្នុងការសិក្សារៀនសូត្រ។ ឧបករណ៍ការងារនេះមានការរីកលូតលាស់ជាខ្លាំងនៅក្នុងទស្សនវិជ្ជាសាសនាគ្រិស្តស្តីពីបុគ្គលនិយមសហគមន៍។

លើសពីនោះ លោកបានរំលេចគរុកោសល្យរបស់លោកក្នុងធម្មនុញ្ញគរុកោសល្យរបស់ក្រុមជំនុំដែលមានកាលបរិច្ឆេទនៅឆ្នាំ ១៥៩៩៖ Le «ratio studiorum »។

ប្រភពដើមរបស់ធម្មនុញ្ញនេះ គណៈកម្មការអាចារ្យសាសនាគ្រិស្តចំនួន ១២ រូប មានបេសកកម្មក្នុងការដាក់ឱ្យអនុវត្តសម្រាប់អនុវិទ្យាល័យ និងសាកលវិទ្យាល័យក្រុមជំនុំ ដែលរីកលូតលាស់យ៉ាងខ្លាំងក្នុងពិភពគ្រិស្ត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាសនានោះ នូវកម្មវិធី និងវិធីសាស្ត្របណ្តុះបណ្តាលជាសាកលមួយដែលផ្តោតទៅលើតថភាពជាក់ស្តែងក្នុងមូលដ្ឋាន។

ផលប្រយោជន៍របស់Le«ratiostudiorum» ដែលមានន័យជាភាសាខ្មែរថា «កម្មវិធីសិក្សា» គឺការបង្ហាញនូវគោលគំនិតដែលគរុកោសល្យ ឬក៏អាចនិយាយម្យ៉ាងទៀតថាការបណ្តុះបណ្តាលតាមបែបគរុកោលសល្យ Pierre Faure ត្រូវបានរំលេចនៅក្នុងលទ្ធិគ្រិស្តសាសនា។

សមាជិកក្រុមជំនុំបានជំនួសយ៉ាងឆាប់រហ័សស្ថាប័នអប់រំចាស់ៗដែលប្រើប្រាស់វិធីសាស្ត្រឈរលើមូលដ្ឋាននៃការចងចាំ និងវិន័យ ហើយដែលវិធីសាស្ត្រទាំងនោះគឺគ្រាន់តែសម្រាប់និស្សិតផ្នែកសាសនារៀនតែប៉ុណ្ណោះ។

ជាមួយនឹងកម្មវិធីសិក្សា ក្រុមជំនុំទទួលបានការបណ្តុះបណ្តាលតាមបែបមនុស្សនិយមពេញលេញដោយបើកទូលាយចំពោះគ្រប់មនុស្សទាំងអស់តាមរយៈវិធីសាស្ត្រសកម្ម។

គរុកោសល្យក្រុមជំនុំផ្តល់អាទិភាពចំពោះការយល់ជាជាងការទន្ទេញចាំ។ ឧទាហរណ៍ មេរៀនស្តីពីអត្ថបទរបស់អារីស្តូត ត្រូវបានចាប់ផ្តើមបង្រៀនតាមរយៈទំនាក់ទំនងរបស់គ្រូទៅសិស្សជាមុន។ បន្ទាប់មក គ្រូស្នើទៅសិស្សម្នាក់ៗឱ្យចាប់ផ្តើមរៀនមេរៀនឡើងវិញពីដើមរហូតដល់ចប់ដើម្បីធានាថាសិស្សយល់មេរៀន ហើយការរៀន និងបង្រៀនត្រូវបានធ្វើតាមបែបនេះជាច្រើនដង។ ក្រុមជំនុំហៅរបៀបនៃការធ្វើបែបនេះថា «repetitio»។

វាមិនគ្រប់គ្រាន់នោះទេក្នុងការយល់តែម្យ៉ាង តែក៏ត្រូវចេះទំនាក់ទំនងពីអ្វីដែលខ្លួនយល់ និងត្រូវអាចការពារជំហររបស់ខ្លួនក្នុងជម្លោះ ឬក្នុងការជជែកវែកញែកជាដើម (les disputationes)។ ការជជែកវែកញែកទាំងនោះអាចធ្វើឡើងរវាងបុគ្គលនឹងបុគ្គល ឬរវាងក្រុមនឹងក្រុម ។

ការរៀនសកម្មតាមរយៈការរៀនសាចុះសាឡើង និងតាមរយៈការជជែកវែកញែកនេះ ប្រសិនក្នុងករណីចាំបាច់ ត្រូវជំរុញដោយគ្រូបង្រៀនដែលនៅខាងក្រៅសង្វៀន និងដែលនាំសិស្សឱ្យអនុវត្តដោយខ្លួនឯងនូវវិធី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាស្ត្រទាំងពីរខាងដើម។ សិស្សហ្វឹកហាត់ដើម្បីឱ្យមានភាពរហ័សរហួនផ្នែកស្មារតី ការផ្ចង់ស្មារតី តាំងចិត្តស្ងប់ស្ងាត់ រកពាក្យត្រឹមត្រូវជាដើម។ល។ គឺតាមរយៈការធ្វើបែបនេះហើយ ដែលសិស្សអាចកសាងខ្លួនដោយខ្លួនឯងបាន។ សិស្សអនុវត្តដោយខ្លួនឯង ហើយនាំអ្នកផ្សេងឱ្យអនុវត្ត។ បែបនេះគឺស្របទៅនឹងវិធីសាស្ត្ររបស់ Ignace de Loyola ក្នុងនោះ ដើម្បីឱ្យម្នាក់ៗអាចទៅដល់គោលដៅចម្បងផ្នែកមនុស្សជាតិ និងសាសនាគ្រិស្តរបស់ខ្លួន ក៏ដូចជាជំនឿស៊ប់ក្នុងសាសនាបាន ចាំបាច់ណាស់ត្រូវដកពិសោធន៍លំហាត់ផ្នែកស្មារតី។

ការបង្រៀនតាមបែបក្រុមជំនុំផ្តោតទៅលើអ្វីដែលម្នាក់ៗអាចមានម្ចាស់ការលើចំណេះដឹងដើម្បីឱ្យគេស្រលាញ់ចូលចិត្តក្នុងការសិក្សា។ ចំណេះដឹង និងសេចក្តីស្រលាញ់គឺជាគោលដៅចុងក្រោយនៃការបណ្តុះបណ្តាលអប់រំនេះ។

គរុកោសល្យ Pierre Faure ផ្តល់សារៈសំខាន់ចំពោះការចូលរួមរបស់សហគមន៍។ កុមារមិននៅឯកាក្នុងលោកនោះទេ។ ក្នុងស្ថានភាពសិក្សារៀនសូត្រ កុមារត្រូវរៀនក្នុងការផ្តល់ និងការទាញយកប្រយោជន៍ពីវត្តមានរបស់អ្នកដទៃ។ តាមគំនិតរបស់ Pierre Faure ទំនាក់ទំនងគឺជាភាពចាំបាច់របស់មនុស្សជាតិក្នុងការកសាងភាពជាមនុស្ស។ គរុកោសល្យត្រូវមានលក្ខណៈមួយដែលអាចគិតគូរពីការអភិវឌ្ឍផ្នែកសង្គមរបស់កុមារ។ ឧទាហរណ៍ លោកបានដាក់ឱ្យអនុវត្តនូវវិធាន «ការកែជារួម» កិច្ចការ និង «séance d'animation» ជាពេលវេលាមួយដែលសិស្សម្នាក់ៗអាចធ្វើបទបង្ហាញពីចំណេះដឹងដែលខ្លួនទទួលបាន។ សិស្សហាត់រៀនដោយខ្លួនឯងជាមួយនឹងគ្រូម្នាក់តែគ្រូនោះត្រូវនៅក្រៅពីសង្វៀននៃការហាត់រៀនរបស់សិស្ស។ ការចាប់យកចំណេះដឹងបែបនេះមិនផ្អែកលើការទន្ទេញចាំនោះទេ តែទៅលើទង្វើនៃការរៀនសាចុះសាឡើងនៃមេរៀនដោយខ្លួនឯង។

«យល់មិនទាមទារឱ្យប្រមូលយកមកដាក់ក្នុងខួរក្បាលនូវចំណេះដឹង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រៀបចំរួចរាល់នោះទេ តែទាមទារឱ្យចេះស្វែងយល់ពីចំណេះដឹងទាំងនោះ ដើម្បីក្នុងករណីចាំបាច់មានសមត្ថភាពក្នុងការបង្កើតអ្វីថ្មី ឬបង្កើតរបស់ទាំងនោះឡើងវិញ»។

សិស្សបែងចែកជាក្រុម ១០នាក់ ស្ថិតក្រោមការទទួលខុសត្រូវរបស់សិស្សម្នាក់ក្នុងចំណោមនោះទៅតាមការជ្រើសរើសរបស់សិស្សក្នុងក្រុមៗ គឺជាគរុកោសល្យមួយដែលជំរុញឱ្យមានការទទួលខុសត្រូវ និងការប្រណាំងប្រជែងគ្នា។

## គំនិតគួរពិចារណា

លោក Pierre Faure ត្រូវបានទទួលការរិះគន់ពីទំនាក់ទំនងដ៏គ្រោះថ្នាក់របស់លោកជាមួយនឹងគរុកោសល្យបែបថ្មីៗ ដូចលោក Rousseau ដែរ លោកហាក់មានជំនឿជឿជាក់ខ្លាំងទៅលើកុមារ និងទៅលើរបៀបក្នុងការអប់រំពួកគេ។

ជាសាវ័ករបស់លោកអាចារ្យ Desbuquois លោកបានកសាងនូវមនោគមវិជ្ជាអប់រំមួយដែលត្រូវបានបញ្ចូលក្នុងបុរី ដែលមនោគមវិជ្ជានោះគិតគូរពីអ្វីដែលត្រូវធ្វើក្នុងកាលវេលានោះ និងគិតពីសង្គមដែលលោកចង់ជួយជ្រោមជ្រែង។

## ១៨. Françoise DOLTO (1908-1988)

«មនុស្សជាតិគឺជាការរស់នៃចំណង់តាំងពីកំណើត និងដែលវិវត្តដោយសារចំណង់ក្នុងយកតម្រាប់តាមឪពុកម្ដាយដែលមានចិត្តរីករាយដោយត្រូវបានយកតម្រាប់តាម» (La Cause des Enfants)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ចំណង់ក្នុងការអប់រំ និងការអប់រំតាមចំណង់

មានទស្សនៈចម្បងចំនួនពីរនៅក្នុងគោលគំនិតរបស់លោកស្រី Françoise Dolto នោះគឺចំណង់ និងមនុស្ស ដែលត្រូវបានសម្របសម្រួលទៅតាមវិធីសាស្ត្រផ្សេងៗក្នុងពាក្យសម្ដី កាយវិការ ហើយដែលជាសមាសធាតុចម្បងនៃវិធានក្នុងកិច្ចទំនាក់ទំនងអប់រំ។ ប្រធានបទនៃចំណង់គឺជាផ្នែកសំខាន់ពាក់ព័ន្ធនឹងកុមារភាព និងកុមារដោយផ្ទាល់តែម្ដង។

ចំពោះ François Dolto គឺការរីកធំធាត់នៃចំណង់ដែលធ្វើឱ្យលេចចេញនូវមនុស្សដែលមានស្ថានភាពនីងនរ មានន័យថាមនុស្សសេរី ច្នៃប្រឌិត និងទទួលខុសត្រូវដែលជាគោលដៅនៃគ្រប់ការអប់រំតាមបែប Dolto។ សម្រាប់ Dolto មនុស្សគឺជាប្រធាននៃចំណង់របស់ខ្លួន ឬក៏ប្រវត្តិរបស់ខ្លួន។ លោកស្រី Françoise កំណត់ព្រំដែនក្នុងការទទួលស្គាល់កុមារក្នុងនាមជាមនុស្សម្នាក់។

## សីលធម៌នៃចំណង់

គឺជាអ្វីដែលមិនត្រូវច្រឡំគ្នារវាងអភិសមាចារ និងសីលធម៌។ សីលធម៌គឺងនឹតងងុលចំពោះអ្វីដែលផ្ទុយពីការគិតរបស់ខ្លួន និងសម្រាប់មនុស្សដែលកំណត់ថាមានមនសិការ ហើយមានវត្តមានគ្រប់ពេលវេលា សីលធម៌មិនស្គាល់ ឬមិនខ្វល់ពីអ្វីដែលមនុស្សមិនដឹងនោះទេ មានន័យថាមនុស្សត្រូវគោរពវា បើទោះបីជាមិនយល់ពីហេតុផលនៃការគោរពរបស់ខ្លួនក៏ដោយ។ ផ្ទុយទៅវិញ ភាពមិនដឹងខ្លួន មិនខ្វល់ ឬមិនអើពើពីអ្វីល្អនិងអាក្រក់នោះទេ អ្វីដែលមានខែងគឺត្រូវធ្វើ ហើយប្រការនេះបានផ្ដល់បទដ្ឋានដែលជាអាទិភាពដល់អ្វីដែលគេចាត់ថាជាសីលធម៌។

លោកស្រី Françoise ធំធាត់នៅក្នុងមជ្ឈមណ្ឌលក្រុងក្លាយពាក់ព័ន្ធនឹងច្បាប់សីលធម៌ដែលមិនបង្ហាត់បង្រៀនមនុស្សឱ្យក្លាយទៅជាមនុស្សពេញលេញ។ ច្បាប់សីលធម៌នេះកំណត់នៅត្រឹមការគិតពីប្រយោជន៍ផ្ទាល់ខ្លួន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលគេឃើញមានក្បួនច្បាប់វិន័យជាច្រើនពាក់ព័ន្ធនឹងទំនៀមទម្លាប់ជាមួយនឹងទំនោរក្នុងការអនុវត្តជាលក្ខណៈសាកល និងជាលក្ខណៈបង្ខំ ដោយមិនគិតពីហេតុផលត្រឹមត្រូវនិងថាមវន្តថ្លៃប្រឌិតនោះឡើយ។ អភិសមាចារផ្តល់ជាគំនិតក្នុងការតាក់តែងឃ្លាប្រយោគសម្រាប់ដាក់ចេញជាច្បាប់ដែលផ្ទុយទាំងស្រុងពីអ្វីដែលលោកស្រីគិត។ ព្រោះថា អ្វីដែលគេកំពុងធ្វើ គឺជាផ្តោតការយកចិត្តទុកដាក់ក្នុងការផ្តល់តម្លៃដល់ការយល់ឃើញ និងដល់កថាដែលផ្ទុយពីអ្វីដែលលោកស្រីគិត ជាមួយនឹងការយល់ និងកថាដែលចេញពីអ្នកមានអំណាចទាំងនោះគេអាចបង្កើតកិច្ចទំនាក់ទំនងជាមួយនឹងដៃគូដែលគ្រាន់តែឮនិងមិនមានការគិតពិចារណា ក្នុងគោលបំណងដើម្បីធ្វើឱ្យកើតឡើងនូវពាក្យ «អញ» ចំពោះម្នាក់ៗ។

ដោយជ្រើសយកខាងទម្រង់អភិសមាចារ លោកស្រី Françoise ចាប់ផ្តើមតាមរយៈការបំផ្លាញរាល់ក្បួនច្បាប់ប្រតិបត្តិដែលកុមារត្រូវទទួលយកដោយបង្ខំ។ លោកស្រី Françoise បែងចែកតម្រូវការ ពីចំណង់តាមរយៈខ្លឹមសាររបស់វា។ តម្រូវការបំពេញឱ្យផ្នែកផ្លូវចិត្តដែលខ្វះចន្លោះៗ គឺជាឥរិយាបថ «របស់សត្វ» ដែលមនុស្សពេញវ័យ ក៏ដូចជាការអប់រំត្រូវបំពេញឱ្យ។ សម្រាប់អ្នកអប់រំ កុមារខុសពីសត្វតែត្រង់លើពេលចាប់ពីកំណើតមកត្រូវផ្តល់ឈ្មោះ អត្តសញ្ញាណមួយប្រសើរបំផុតសម្រាប់គេក្នុងនាមជាសមាជិករបស់សង្គម ជាសមាសធាតុមួយរបស់សង្គមដែលត្រូវការពារ ត្រូវអប់រំដើម្បីឱ្យគេចាកចេញផុតពីភាពជាសត្វជាតុដែលគេមាន។

ដើម្បីចេញឱ្យផុតពីក្របខ័ណ្ឌសីលធម៌នៃចំណង់ទៅដល់អភិសមាចារនៃចំណង់ វាចាំបាច់ណាស់សម្រាប់មនុស្សពេញវ័យក្នុងការគិតគូរដល់កុមារដែលនៅពីមុខគេតាំងពីកុមារនៅតូច ដោយមិនត្រូវចាត់ទុកគេដូចជាសត្វដែលត្រូវផ្សាំង និងត្រូវបញ្ចូលគេទៅក្នុងសង្គមនោះទេ តែត្រូវចាត់ទុកគេជាសមាសធាតុដែលមានចំណង់ មានន័យថាមានសមត្ថភាពក្នុងការទាក់ទង។ គឺមានតែនៅពេលដែលមនុស្សពេញវ័យទទួលយកបដិវត្តន៍ផ្នត់គំនិត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះទេដែលគេអាចយល់ពីចំណង់របស់កុមារ។

អភិសមាចារនៃចំណង់ជាការទទួលស្គាល់កុមារថា ជាការៈរស់នៃចំណង់ និងផ្តល់សេចក្តីមេត្តាករុណា និងសុវត្ថិភាពដល់គេដើម្បីឱ្យគេអាចអភិវឌ្ឍខ្លួនឯងដោយសេរី។

## ការអប់រំសម្រាប់ចំណង់

ការអប់រំសម្រាប់ចំណង់ គឺមិនមែនជាការដាក់ក្បួនច្បាប់ចំពោះចំណង់ ការឃុំគ្រងចំណង់ក្នុងក្របខ័ណ្ឌសីលធម៌នោះទេ។ ហើយវាក៏មិនមែនការផ្តល់បណ្តោយដល់កុមារដើម្បីឱ្យគេធ្វើអ្វីតាមចិត្តចង់របស់គេនោះដែរ។ មានន័យថា យើងមិនប្រែក្លាយពីអ្វីដែលជាភាពផ្តាច់ការរបស់មនុស្សពេញវ័យ ទៅជាឱ្យកុមារក្លាយជាស្តេចនោះក៏ទេដែរ។ លោកស្រី Françoise ប្រឆាំងជាប់ជានិច្ចទៅនឹងការអប់រំបែបសេរីដោយយកចំណង់របស់មនុស្សពេញវ័យទៅដាក់ជាចំណង់របស់កុមារ។ បើទោះជាលោកស្រី Françoise ព្យាយាមដើម្បីឱ្យមានវត្តមាននៃប្រធានបទដែលយើងគោរព គឺមិនមែនដើម្បីធ្វើឱ្យកុមារមានភាពទំនើងនោះទេ តែគឺដើម្បីកុំឱ្យមានការរាំងខាមវត្តនៃចំណង់ក្នុងក្របខ័ណ្ឌសង្គមដែលរាំងកុមារក្នុងការចាប់ផ្តើមបង្កើតឱ្យមានចំណង់ដោយឃុំពួកគេនៅក្នុងគំនាប និងការបង្ខំ។

បើទោះជាយ៉ាងនេះក្តី លោកស្រី Françoise យល់ស្របចំពោះ «ការកាត់ផ្តាច់មនោសញ្ចេតនា» កុមារដើម្បីកុំឱ្យគេរស់នៅឃុំគ្រងក្នុងតម្រេក។

ដូចអ្វីដែលលោកស្រីអះអាងក្នុងសៀវភៅ បុព្វហេតុរបស់កុមារ (Cause des enfants) ៖ «វាមិនល្អនោះទេក្រោមការយកលេសថាទុកឱ្យកុមាររីកលូតលាស់ដោយសេរី ដែលកុមារមិនដែលជួបនឹងអ្វីដែលជាការព្យាយាមសោះត្រូវឱ្យគេជួបសកម្មភាពផ្សេងៗនៃចំណង់របស់អ្នកដទៃ និងដែលស្របទៅនឹងអាយុផ្សេងពីខ្លួនឯង។ ប្រសិនបើ គេលះបង់គ្រប់យ៉ាងទៅឱ្យកុមារ គេនឹងលុបចោលតែម្តងនូវអំណាចច្នៃប្រឌិតរបស់ខ្លួនដែលជាការស្វែងរកមួយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដ៏លំបាកក្នុងការបំពេញចំណង់ដែលមិនចេះគ្រប់គ្រាន់ ហើយអ្វីដែលគេពេញចិត្តពេលនេះ បែរជាក្លាយទៅជាមិនចាប់អារម្មណ៍នៅពេលណាមួយវិញនោះ»។

និយាយថា «ទេ» មិនចាំបាច់ប្រើប្រាស់តវិយាបថផ្តាច់ការនោះទេ គឺបង្រៀនកុមារឱ្យចេះនិយាយបង្ហាញពីចំណង់របស់ខ្លួន និងចេះស្តាប់ពីចំណង់របស់អ្នកដទៃ។ ចំណង់របស់ខ្លួនអាចបង្កើតជាជម្លោះជាមួយនឹងចំណង់អ្នកដទៃ។

មនុស្សពេញវ័យត្រូវរំឭកកុមារថាគេហ្វឹកហាត់ភាពទទួលខុសត្រូវក្នុងនាមជាមនុស្សពេញវ័យ គឺមិនមែនប្រមាថដល់ចំណង់របស់ខ្លួននោះទេ តែគឺត្រូវដាក់ចំណង់របស់ខ្លួននៅកម្រិតគុណតម្លៃណាមួយដើម្បីឱ្យម្នាក់ៗអាចបង្ហាញនិងប្រើប្រាស់ចំណង់របស់ខ្លួនឱ្យបានសមស្រប។

តើត្រូវធ្វើយ៉ាងណាដើម្បីបង្រួមបង្រួមរវាងសេរីភាព និងការកាត់ផ្តាច់មនោសញ្ចេតនាតាមទស្សនៈរបស់ Françoise Dolto? មនុស្សពេញវ័យត្រូវធ្វើតួនាទីជា «អ្នកការពារ» ដែលកុមារត្រូវការដើម្បីឱ្យគេមានលទ្ធភាពក្នុងការរស់នៅក្នុងលោកមុនពេលកំណត់។ គំនិតនៃពាក្យថាមុនពេលកំណត់ (prématuration) តាមទស្សនៈរបស់ Françoise Dolto ស្រដៀងនឹងគំនិតនៃពាក្យថាមិនទាន់សម្រេច (Inachèvement) ក្នុងទស្សនៈរបស់លោក Georges Lapassade ដែរ។

មនុស្សពេញវ័យត្រូវជាអ្នកបម្រើដល់សិទ្ធិកុមារ ដែលត្រូវធ្វើឱ្យកុមារមានការរីកលូតលាស់ទៅតាមថាមវន្តនៃចំណង់។ ចំពោះលោកស្រី មនុស្សមានសមត្ថភាពក្លាយជាមាតាបិតានៅពេលណាដែល «គេអាចមានទំនួលខុសត្រូវលើការរស់ដែលខុសពីខ្លួន និងដែលមិនមែនជាកម្មសិទ្ធិផ្ទាល់របស់ខ្លួនម្តងណាឡើយ»។

តាមគំនិតរបស់ Françoise Dolto ការអប់រំផ្នែកចំណង់ត្រូវធ្វើនៅក្នុងក្របខ័ណ្ឌមិនមែនសីលធម៌ល្អស្អាតក្នុងគ្រប់ទម្រង់នៃការរំលោភអំណាច និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សេចក្តីស្រលាញ់ដោយមានការដោះដូរ។ មាតាបិតាត្រូវចេញឱ្យឆ្ងាយពីភាពភ័យបារម្ភថាកុមារដើរខុសក្របខ័ណ្ឌសង្គមនេះ ដោយបង្ខំគេឱ្យអនុវត្តរាល់បំរាមសង្គមដែលច្រើនតែជាអ្វីសម្រាប់ភាពអាត្មានិយមរបស់ក្រុមមនុស្សពេញវ័យក្នុងការស្វែងរកនូវភាពសុខស្រួលសម្រាប់ខ្លួនឯងតែប៉ុណ្ណោះ។ ក្របខ័ណ្ឌទាំងនេះសម្ងាប់«ទេពកោសល្យ» នៅខាងក្នុងរបស់កុមារតែម្តង។

លោកស្រីស្របតាមលោកស្រីEllen Key ពេលដែលលោកស្រីសរសេរក្នុងសៀវភៅចំណងជើងថា វិថីនៃការអប់រំ Les chemins de l'éducation «ត្រូវឱ្យកុមារមានអារម្មណ៍ថាអ្វីដែលត្រូវការពារគឺត្រូវការពារដោយហេតុផល គឺមិនមែនសេចក្តីពន្យល់ពីអស់លោកអ្នកនោះឡើយ តែតាមរយៈការពិសោធដែលកុមារនឹងទទួលបានចំណេះដឹងនោះលឿន ហើយថានៅពេលដែលពួកគេមិនស្តាប់បង្គាប់ គេនឹងបង្កើតឱ្យមានឧប្បត្តិហេតុនានាដែលអាចបំផ្លាញដល់គេ»។ ដោយដាក់ក្របខ័ណ្ឌមាតាបិតាក្នុងស្នាដៃដ៏ល្បីរបស់លោកស្រីដែលមានចំណងជើងថា Au jeu du désir «វាមានសារៈប្រយោជន៍ណាស់ដែលកុមារអាចបញ្ចុះបញ្ចូលខ្លួនឯង ក្នុងលក្ខខណ្ឌដែលជាបញ្ហាអាចគ្រប់គ្រងបាន ក្រោមការត្រួតពិនិត្យរបស់មនុស្សពេញវ័យដែលនៅអមគេក្នុងដំណើរការនៃកថាពន្យល់ រហូតដល់ពេលដែលកុមារទទួលបាននូវការជឿជាក់ពីការពិតនៃសម្តីរបស់មនុស្សពេញវ័យ»។

គ្រប់ទម្រង់នៃការហាមប្រាម ត្រូវមានអមដោយកថាដែលមិនត្រូវគ្រាន់តែជាការបង្គាប់បញ្ជានោះទេ តែត្រូវបើកឆ្ពោះទៅរកលទ្ធភាពក្នុងការពិភាក្សា មានន័យថាការប្រើប្រាស់ពាក្យនៃចំណង់។

មនុស្សជាតិ! គេនិយាយចេញមកនូវពាក្យនោះៗ ហើយគឺដោយសារពាក្យទាំងនេះ និងដោយសារតែភាពសាំញ៉ាំរបស់វានេះហើយដែលធ្វើឱ្យកុមារយល់បានថាមនុស្សពេញវ័យម្នាក់នេះ គេអាចជឿជាក់បាន ក៏ដោយសារតែកុមារទទួលស្គាល់ពីភាពខុសឆ្គងដែលគេចង់បំពានលើសេចក្តីហាមឃាត់ក្នុងការធ្វើអ្វីមួយទៅតាមក្តីស្រមៃរបស់គេ ហើយនៅពេលនោះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គេយល់បានថាការហាមឃាត់នោះគឺមានហេតុផល [...]។

លោកស្រី Françoise Dolto ស្នើយ៉ាងច្បាស់លាស់ទៅកាន់មនុស្សពេញវ័យក្នុងការផ្តល់ជាឧទាហរណ៍តាមរយៈការគោរពច្បាប់ដែលខ្លួនឯងធ្វើនោះសិន ក៏ព្រោះថាកុមារត្រូវការគំរូដូចគ្នាសម្រាប់គេដើម្បីទទួលយកនូវអ្វីដែលខុសពីចិត្តរបស់គេដោយស្ងប់ចិត្ត។

ចំពោះលោកស្រី Françoise Dolto ការយកតម្រាប់តាមជាការចាំបាច់ប្រៀបបាននឹងមធ្យោបាយធ្វើឱ្យកុមារដែលនៅមិនទាន់មានសមត្ថភាពពេញលេញនៅឡើយក្នុងការសម្រួលខ្លួនទៅក្នុងគោលការណ៍មួយចំនួនដែលមានស្រាប់ដោយយកមនុស្សពេញវ័យជាគំរូ។

ប្រការនេះ គឺជាទំនួលខុសត្រូវរបស់មនុស្សពេញវ័យក្នុងការមិនអប់រំកុមារឱ្យកាន់ច្រឡំក្នុងការយកតម្រាប់តាម។ គ្រប់អ្នកអប់រំទាំងអស់ក៏ត្រូវចៀសវាងក្នុងការប្រៀបធៀបកុមារទៅនឹងមនុស្សទីបី និងជាពិសេសទៅនឹងកុមារម្នាក់ទៀត។

## នីតិសោធន៍នៃការពិចារណាលើការអប់រំ

### សាលា Neuville

នៅឆ្នាំ១៩៧៣ លោកស្រី Fabienne d'Ortoli លោក Michel Amram និងលោក Pascal Lemaître បានបើកសាលាមួយនៅ Neuville-du-Bose នៅតំបន់ Normandie ក្រោមការជួយឧបត្ថម្ភរបស់លោក Fernand Oury និងលោកស្រី Françoise Dolto។ នៅឆ្នាំ១៩៨៧ សាលារៀនត្រូវបានប្រសិទ្ធនាមថា «ក្រុមស្រាវជ្រាវគរុកោសល្យ Françoise Dolto»។

គឺជាសាលារៀនមួយដែលមានចាប់ពីបឋមសិក្សារហូតដល់ថ្នាក់ទីបី (ថ្នាក់ទី៩នៅកម្ពុជា)។ ស្ថាបនិករបស់សាលានេះប្រើប្រាស់នូវគំរូទ្រឹស្តីរបស់ A. S. Neill, A. Makarenko, C. Freinet, F. Oury ជាដើម និយាយឱ្យខ្លី គឺក្រុមអ្នកទ្រឹស្តី និងក្រុមអ្នកប្រតិបត្តិនៃចលនាគរុកោសល្យស្ថាប័ន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រុមនោះយកគំនិតតាមទំនាក់ទំនងអប់រំរបស់ Makarenko ដែលត្រូវបានទាញចេញជារូបមន្តនេះ៖ «គឺមិនមែនអ្នកអប់រំដែលត្រូវអប់រំកុមារនោះទេ តែគឺមជ្ឈដ្ឋានដែលកុមាររស់នៅ»។ ភារកិច្ចរបស់«អ្នកអប់រំ-គ្រូបង្រៀន» មិនត្រូវនៅកម្រិតត្រឹមការផ្ដល់ដំបូន្មាននោះទេ។ អ្នកអប់រំមិនមែនគ្រាន់តែត្រឹមតាមដានកុមារ ឬផ្ទេរចំណេះដឹងដល់កុមារនោះទេ តែត្រូវត្រៀមខ្លួនបម្រើសិស្សដើម្បីជួយពួកគេក្នុងករណីដែលមានការស្នើសុំជំនួយពីពួកគេ។

លោកស្រី Françoise Dolto បញ្ជូនកុមារដែលរៀនយឺតទៅកាន់សាលានោះ ហើយទទួលបន្ទុកទៅលើការងារមួយដែលក្រុមនោះឱ្យឈ្មោះថា «ការត្រួតពិនិត្យគរុកោសល្យ» ដែលជាទម្រង់ត្រួតពិនិត្យទៀងទាត់មួយដែលលោកស្រីធ្វើជាប្រចាំជាមួយនឹងស្ថាបនិករបស់សាលារៀន។

«សៀវភៅកំណត់ត្រាពីការមិនពេញចិត្ត Cahier de ralage» ត្រូវបានដាក់ឱ្យសិស្សដើម្បីបញ្ចេញមតិយោបល់ បង្ហាញនូវចំណង់ ក៏ដូចជាបង្ហាញពីភាពថប់បារម្ភរបស់គេ។ រាល់បញ្ហាកត់ត្រាក្នុងសៀវភៅ ត្រូវបានយកមកពិភាក្សាសួរដេញដោលនៅក្នុងអង្គប្រជុំ។ ត្រូវដឹងថាមានការប្រជុំបែបនេះរៀងរាល់ថ្ងៃលើកលែងតែថ្ងៃនៅចុងសប្ដាហ៍។

សាលារៀន Neuville មិនផ្ដោតជ្រុលតាមរយៈការកេងចំណេញពេលវេលា ក៏ដូចជាភាពបរាជ័យរបស់សិស្សក្នុងការសិក្សានោះទេ។ ភាពបរាជ័យ ក្នុងការសិក្សារបស់សិស្សមិនត្រូវបានជិតដាមជាប់ក្នុងអារម្មណ៍របស់សិស្ស ដោយបង្កើតឱ្យមានការផាត់ចេញសិស្សដែលរៀនយឺត ឬមិនយកចិត្តទុកដាក់ប្រៀបបានជាពេលវេលាដ៏សំខាន់មួយសម្រាប់ស្វែងរកផ្លូវសិក្សាដ៏ប្រសើរ សម្រាប់សិស្សដោយផ្ដោតទៅលើបុគ្គលភាពដាច់ដោយឡែករបស់គេ។ ស្ថាប័នសាលារៀនត្រូវបានណែនាំឱ្យស្ដាប់ពីទុក្ខសោក និងផលលំបាករបស់សិស្សដែលបង្ហាញចេញតាមរយៈភាពបរាជ័យក្នុងការសិក្សារបស់គេ។

ស្ថាប័ននេះក៏ផ្ដល់សារៈសំខាន់ទៅលើបទបញ្ជាដែលត្រូវបានតាក់តែង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឡើងដោយគ្រប់គ្នា ហើយការមិនគោរពបទបញ្ញាទាំងនោះនឹងនាំទៅដល់ការដាក់ទណ្ឌកម្មបែបផែនជាសំណងជានិមិត្តរូបបន្តិចបន្តួចដើម្បីជួសជុលការខូចខាត។ គោលបំណងគឺមិនមែនដើម្បីបង្គ្រប់ចំណង់ណាមួយនោះទេ តែគឺធ្វើឱ្យម្នាក់ៗមានការទទួលខុសត្រូវលើខ្លួនឯង និងលើអ្នកដទៃ។ សាលារៀននោះ គឺជាទីកន្លែងដែលបានផ្ដល់សារៈសំខាន់ខ្លាំងដល់កថារបស់មនុស្សគ្រប់គ្នាដែលប្រការនេះជាវិធានមួយសម្រាប់ឱ្យមានការផ្លាស់ប្ដូរមតិយោបល់រវាងគ្នានឹងគ្នា។

## គេហដ្ឋានបៃតង

«គេហដ្ឋានបៃតង Maison verte» ទីមួយ ត្រូវបានបើកទ្វារលើកដំបូងនៅឆ្នាំ ១៩៧៨។ គឺជាកន្លែងសម្រាប់ទទួលកុមារតូចៗអាយុចាប់ពី ០ ដល់ ៣ឆ្នាំ។ គោលបំណងនៃសាលានេះគឺផ្ដល់អាទិភាពដល់ការអប់រំចាប់តាំងពីឆ្នាំដំបូងនៃកុមារភាព។ គឺជាគម្រោងបង្ការបញ្ហាជំងឺផ្លូវចិត្តសង្គមរបស់កុមារតូចៗដែលអាចកើតឡើងដោយសារការបែកគ្នាម្ដងៗពីមាតាបិតានៅពេលពួកគេចូលទារកដ្ឋាន ឬចូលទៅសាលាមត្តេយ្យ។ សាលារៀននេះជួយដល់ឪពុកម្ដាយ និងកុមារក្នុងកិច្ចសហការគ្នាដើម្បីឃ្លាតពីគ្នាបន្តិចម្ដងៗ និងដើម្បីសិក្សារៀនសូត្រពីសេរីភាពរវាងគ្នានឹងគ្នា។

មាតាបិតារៀននៅក្នុងទីកន្លែងមួយមានលក្ខណៈសាមញ្ញ និងរៀនរំដោះខ្លួនចេញពីទំនោរជ្រុលនិយមក៏ដូចជាទំនោរក្នុងការប្រកាន់ថាកូនជារបស់ផ្ទាល់ខ្លួន ដែលខ្លួនត្រូវគ្រប់គ្រងនឹងដឹកមុខៗ គឺជាការរៀនដើម្បីសេរីភាព និងដើម្បីការទទួលស្គាល់គុណតម្លៃនៃចំណង់របស់អ្នកផ្សេង។

## គំនិតគួរពិចារណា

គេបានរិះគន់លោកស្រីទៅលើគំនិតប្រឆាំងគ្នារបស់លោកស្រី (ឧទាហរណ៍ លោកស្រីសរសេរថាកុមារមានត្រឹមតែសិទ្ធិ ហើយមនុស្សពេញវ័យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានកាតព្វកិច្ច បន្ទាប់មកទៀតនិយាយពីកាតព្វកិច្ចរបស់កុមារ ថាលោកស្រីជាចិត្តវិភាគវិទូបែបបន្ទរាប (psychanalyse édulcorée) និងបែប Rousseau ដែលបានលើកឡើងនូវទស្សនៈសុខវេទនានៃមនុស្សជាតិប្រកបដោយការពេញចិត្ត និងភ្ញីស្វាង ផ្ទុយទៅវិញការរកឃើញពីភាពមិនដឹងអី (ភាពអសម្បជញ្ញៈ) បានកែប្រែទិន្នន័យទាំងនោះ។ លើសពីនោះទៅទៀត លោកស្រីបានបញ្ចូលមនោរម្មណ៍នៃពិរុទ្ធភាពរបស់ឪពុកម្តាយដែលសព្វថ្ងៃនេះបង្កឱ្យមានបញ្ហានៃការដើរខុសផ្លូវរបស់កុមារដែលត្រូវបានឪពុកម្តាយទំយើ។ បញ្ហាចរចា និងសម្របសម្រួលរវាងចំណង់របស់មនុស្សពេញវ័យ និងចំណង់របស់កុមារនៅតែជាសំណួរបើកចំហ។

## ១៩. Paulo FREIRE (1921-1997)

លោកត្រូវបានចាត់ទុកជាជាស្ថាបនិកម្នាក់នៃ «មនោគមវិជ្ជាផ្នែកសាសនានៃការរំដោះ La théologie de libération» ដែលជាការទទួលខុសត្រូវមួយចំពោះក្រុមជនក្រីក្របំផុត និងដើម្បីការពារសេចក្តីថ្លៃថ្នូរមនុស្សជាតិដោយសាសនាវិទូ Leonardo Boff។ ដោយចេញពីប្រភពដើមដ៏សាមញ្ញ និងជាកាតូលិកផងនោះ ធ្វើឱ្យរូបលោកមានការជក់ជាប់យ៉ាងជ្រៅក្នុងបេះដូងពីរូបភាពអ្នកក្រីក្រ ហើយដែលធ្វើឱ្យអ្នកច្បាប់រូបនេះស្វែងរកគរុកោសល្យសមស្របណាមួយសម្រាប់សិស្សនៅក្នុងមជ្ឈដ្ឋានរបស់លោក។ លោកជាទ្រឹស្តីវិទូ និងជាប្រតិបត្តិករ ដែលបន្តការតែងនិពន្ធពាក់ព័ន្ធនឹងគរុកោសល្យនៃក្តីសង្ឃឹម (pédagogie de l'esperance)។

## ទស្សនវិជ្ជាប្រតិបត្តិនៃការរំដោះតាមរយៈការអប់រំ

ចំពោះលោក Paulo Reglus Neves Freire គោលដៅនៃការអប់រំគឺការផ្លាស់ប្តូរទាំងស្រុងនូវរចនាសម្ព័ន្ធសង្គមដោយរំដោះខ្លួនពីការកៀបសង្កត់តាមរយៈមនសិការកម្ម។ តាមគំនិតរបស់លោក Paulo Freire អ្នកកៀបសង្កត់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គេដាក់បន្ទុកលើអ្នកផ្សេងនូវទំនាក់ទំនងរវាងអ្នកត្រួតត្រាគេ និងអ្នកត្រូវគេត្រួតត្រាតាមរយៈឋានៈរបស់ខ្លួន តាមរយៈច្បាប់នយោបាយ ច្បាប់សង្គម ច្បាប់វប្បធម៌និងច្បាប់សេដ្ឋកិច្ច។ អ្នកត្រូវគេកៀបសង្កត់ចូលរួមចំណែកធ្វើឱ្យស្របច្បាប់នូវតួនាទីរបស់អ្នកកៀបសង្កត់ខ្លួនដោយសារតែអ្នកដែលត្រូវគេជិះជាន់ ក៏ចង់ក្លាយទៅជាអ្នកជិះជាន់គេដែរ។ តាមរយៈឥរិយាបថបែបនេះ អ្នកត្រូវគេជិះជាន់បង្កើនទំនាក់ទំនងនេះដោយផ្តល់ឱ្យអ្នកដែលជិះជាន់លើខ្លួននូវភាពស្របច្បាប់។

ចំពោះលោក ការប្រយុទ្ធប្រឆាំងដល់ស្នូលនៃភាពអយុត្តិធម៌ គឺត្រូវបែរត្រឡប់អំណាចអ្នកជិះជាន់គេ-អ្នកត្រូវគេជិះជាន់។តាមរយៈគោលការណ៍នេះ ធ្វើឱ្យគេអាចមើលឃើញពីភាពខុសគ្នាដាច់ស្រឡះរវាងការបះបោរ និងបដិវត្តន៍វេទនាសម្ព័ន្ធ។ ក្នុងការបះបោរ ប្រជាជនក្រោកឈរឡើងដោយគ្មានគម្រោងការច្បាស់លាស់ក្រៅពីស្រែកប្រឆាំងនឹងភាពអយុត្តិធម៌។ ប្រសិនណាបើប្រជាជនអាចផ្តួលរំលំអ្នកកៀបសង្កត់គេឬអ្នកជិះជាន់ខ្លួននោះ គឺគ្រាន់តែដើម្បីឡើងទៅធ្វើអ្នកកៀបសង្កត់គេដោយខ្លួនឯងវិញម្តងតែប៉ុណ្ណោះ។

ស្ថានភាពកៀបសង្កត់គឺជាភាពអមនុស្សធម៌សម្រាប់គ្រប់ៗគ្នា។ ការកៀបសង្កត់ គឺជាភាពអយុត្តិធម៌ដែលគ្រាន់តែអាចស្ថិតស្ថេរតាមរយៈភាពហិង្សាអកម្ម ឬសកម្មតែប៉ុណ្ណោះ។ គឺជាស្ថានភាពហិង្សាដែលត្រៀមឆ្ពោះទៅរកការបះបោរ ក៏ព្រោះថាស្ថានភាពនោះមិនមែនធ្វើឡើងក្នុងគោលគំនិតច្បាស់លាស់នោះទេ។

ចំពោះលោក Paulo Freire ចរិតនយោបាយនៃការអប់រំទាមទារក្នុងការរក្សាអនុត្តរភាពនៃក្រុមអ្នកត្រួតត្រាគេ។ ក្នុងន័យនេះ ការអប់រំក៏ត្រូវជាគោលនយោបាយដែរ មានន័យថា បង្កើតការប្រយុទ្ធប្រឆាំងនឹងវណ្ណៈសង្គមនានាដើម្បីរំដោះទាំងស្រុងនូវមនុស្សជាតិ។ គឺតាមរយៈទង្វើនោះហើយ ដែលគរុកោសល្យបដិវត្តនៅក្នុងក្រុមអ្នកដែលត្រូវគេជិះជាន់ដែលជាក្រុមភាគច្រើននោះត្រូវបានបង្កើតឡើងដើម្បីរំដោះពួកគេចេញពីគំនាប ហើយគោល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បំណងនៃគរុកោសល្យនោះ គឺជាសកម្មភាព និងជាការគិតពិចារណាដោយមានមនសិការ និងដោយនវានុវត្តន៍។

ប្រសិនបើគេអាចផ្លាស់ប្តូរលំដាប់នៃវត្ថុនានា គឺដើម្បីតែផ្លាស់ប្តូរពីអ្នកត្រូវគេជិះជាន់ទៅជាអ្នកជិះជាន់គេតែប៉ុណ្ណោះ មានន័យថាគេទទួលស្គាល់លំដាប់នៃការជិះជាន់ និងការត្រូវគេជិះជាន់! គឺព្រោះថាអ្នកត្រូវគេកៀបសង្កត់ និងអ្នកកៀបសង្កត់គេទទួលយកទម្រង់នៃទំនាក់ទំនងរវាងគ្នានឹងគ្នាដែលធ្វើឱ្យអំពើអាក្រក់បន្តកើតឡើងនៅក្នុងការបះបោរ ឬការប្រយុទ្ធកម្ចាត់អំពើអាក្រក់ដែលការពិតអំពើអាក្រក់នោះនៅជិតជាមយ៉ាងជ្រៅក្នុងខ្លួនមនុស្សម្នាក់ៗ។

## ចាកចេញពីភាពឆក់កំហែងដើម្បីធ្វើសមាហរណកម្មបែបមិត្តភាពក្នុងសមភាព

លោក Paulo Freire គិតថាស្ថាប័នអប់រំជាគ្រួសារ និងជាសាលារៀនត្រូវបានគ្រប់គ្រងដោយគុណតម្លៃនៃការជិះជាន់។ ក្នុងន័យនេះ តួនាទីនៃការអប់រំរបស់អ្នកដឹកនាំបដិវត្តន៍គឺការរំដោះ និងការចេញឱ្យឆ្ងាយពីស្ថានភាពនៃការជិះជាន់តាមរយៈសកម្មភាពសន្ទនា។ ដូច្នេះ កិច្ចសន្ទនាដែលមានទម្រង់ជាការបញ្ចេញមតិយោបល់មានសារៈសំខាន់បំផុតសម្រាប់មនុស្សក្នុងកិច្ចទំនាក់ទំនងរវាងគ្នានឹងគ្នា។ កិច្ចសន្ទនាធ្វើឱ្យគេអាចផ្លាស់ប្តូរកថាក្នុងអត្ថន័យច្នៃប្រឌិត និងផ្លាស់ប្តូរពិភពលោក។

ក្នុងជំពូកទីបីនៃសៀវភៅរបស់លោកក្រោមចំណងជើងថាគរុកោសល្យរបស់ក្រុមអ្នកត្រូវគេជិះជាន់ (La Pédagogie des opprimés) លោកបានសរសេររៀប រាប់យ៉ាងវែងនូវបញ្ញត្តិស្តីពីកិច្ចសន្ទនាដែលត្រូវបានចាត់ជាអ្វីដែលចាំបាច់បំផុតសម្រាប់គ្រប់កិច្ចទំនាក់ទំនងមនុស្សជាតិតាំងពីដើមរៀងមក។ ចេញឆ្ងាយពីអកិច្ចសន្ទនាដើម្បីចាប់យកកិច្ចសន្ទនាទាមទារពីម្នាក់ៗនូវឥរិយាបថ មូលដ្ឋានបែបសាមញ្ញ បែបគោរព បែបទុកចិត្ត បែបសង្ឃឹម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាដើម។ល។

ក្នុងន័យនេះ កិច្ចសន្ទនាដើរតួនាទីយ៉ាងសំខាន់ក្នុងគរុកោសល្យរបស់ Paolo Freire។ អ្នកបង្រៀនត្រូវគោរពអស់ពីចិត្តនូវកេរ្តិ៍របស់អ្នកផ្សេង មានន័យថាគោរពចំណេះដឹងរបស់គេ។ ចំពោះ Paolo Freire «គរុកោសល្យបម្រើដល់ការរំដោះសក្ដានុពលរបស់មនុស្ស» ត្រូវមានថែងនៅក្នុងតថភាពជាក់ស្ដែងរបស់អ្នកត្រូវគេអប់រំ (សិស្ស) មុននឹងគិតពីខ្លឹមសារដែលត្រូវបង្រៀន ឬមុននឹងគិតពីតថភាពដែលត្រូវប្រែក្លាយគេ (សិស្ស)ទៅទៀតផង។

គ្រូនរទេសត្រូវរក្សានូវទម្រង់មូលដ្ឋាននៃកិច្ចសន្ទនានេះតាំងពីចាប់ផ្ដើមរហូតដល់ចប់ការបណ្ដុះបណ្ដាល ដើម្បីឱ្យម្នាក់ៗអាចវិភាគស្ថានភាពជាក់ស្ដែងដែលខ្លួនរស់នៅ ហើយយកស្ថានភាពនោះជាបញ្ហាសម្រាប់ដោះស្រាយដើម្បីមនុស្សជាតិថ្មី។

## សម្រាប់គរុកោសល្យនៃការរំដោះ

ជោគជ័យគរុកោសល្យរបស់ Paolo Freire មានភាពល្បីល្បាញតាមរយៈបទពិសោធន៍ស្ដីពីអក្ខរកម្មរបស់លោក។ គរុកោសល្យរបស់ Paolo Freire គឺជានយោបាយ។ គឺជាទស្សនវិជ្ជាគរុកោសល្យដែលផ្ដោតលើការប្រែក្លាយមនុស្ស និងសង្គមតាមរយៈការផ្សារភ្ជាប់ទៅនឹងគោលគំនិតអភិសមាចារ និងគោលនយោបាយនៃការរួមរស់ជាមួយគ្នា។

លោក Paolo Freire ចូលចិត្តនិយាយថា «គ្មានកិច្ចប្រតិបត្តិអប់រំណាដែលគ្មានគោលបំណង គ្មានក្ដីសុបិន្ត គ្មានភាពហួសនិស្ស័យនោះទេ។ ក្ដីសុបិន្ត គោលបំណង ភាពហួសនិស្ស័យ ដែលអ្នកអប់រំ ទាំងស្រីទាំងប្រុសមាន និងប្រើប្រាស់នោះ គឺជាគោលនយោបាយ។ ពេលដែលគេដាក់ចិត្តដាក់កាយទៅក្នុងសកម្មភាពមួយ គេភ្ជាប់ខ្លួនគេទៅនឹងគំនិតដែលតួអង្គទាំងនោះបង្កើតចេញមកពីបញ្ហាក្នុងសង្គម ក្នុងគោលបំណងដើម្បីតស៊ូកែប្រែក្នុងបុព្វហេតុសង្គមនោះ»។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការងារគរុកោសល្យរបស់លោកបង្ហាញចេញជាអ័ក្សចំនួនពីរ នៅអង្គការ Service Social de l'Industrie (SESI) ក៏ដូចជានៅក្នុងចលនា «ក្លឹបកម្មករ Les Clubs ouvriers»។ នៅក្នុងស្ថាប័នទាំងនេះ លោកបានព្យាយាមនាំកុមារ និងឪពុកម្ដាយរបស់ពួកគេឱ្យផ្លាស់ប្ដូរមតិយោបល់លើបញ្ហានានាពាក់ព័ន្ធការអប់រំ និងសង្គម។ ចំពោះលោក អ្នកអប់រំមិនអាចធ្វើការជាមួយកុមារម្នាក់បានទេ ប្រសិនបើគេមិនចាប់អារម្មណ៍ពីការរស់នៅប្រចាំថ្ងៃរបស់គេ ហើយប្រសិនបើគេមិនស្វែងរកកិច្ចសហប្រតិបត្តិការពីឪពុកម្ដាយកុមារម្នាក់នោះទេ។

ចំពោះកិច្ចការបន្ទាប់ លោកផ្ដួចផ្ដើមឱ្យក្រុមកម្មករនៃសាលារៀនសេវាសង្គមនៃឧស្សាហកម្មទាំងអស់ឱ្យមានកិច្ចសន្ទនា។ ពួកគេត្រូវរៀនក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហានានា ជាជាងរង់ចាំអ្វីៗទាំងអស់មកពីនិយោជក។

គឺក្នុងរចនាសម្ព័ន្ធ និងស្របតាមសកម្មភាពអប់រំរបស់លោកធ្វើក្នុងក្របខ័ណ្ឌដែលលោកបានតាត់តែងគោលវិធីកិច្ចសហប្រតិបត្តិការនៃគ្រប់ភាគីទាំងអស់ក្នុងការអនុវត្តការរៀបចំ និងខ្លឹមសារសម្រាប់បង្រៀន។ លោកបានប្រសិទ្ធនាមទម្រង់សហប្រតិបត្តិការនេះថា «សភានីយកម្មនៃក្រុមអ្នកចូលរួម (parlementarisation des participants)»។

គឺតាមរយៈទង្វើនោះហើយ ដែលកកើតប្រព័ន្ធ Paulo Freire ដែលប្រមូលផ្ដុំបច្ចេកទេសអប់រំដូចជា វិធីសាស្ត្រតុមូល (tables rondes) វិធីសាស្ត្រការបែងចែកបណ្ណជំនួសស្មារតីសម្រាប់ប្រធានបទ (distribution de cartes mnémoniques à themes) វិធីសាស្ត្រក្រុមសិក្សា (groupes d'étude) និងវិធីសាស្ត្រក្រុមសកម្មភាព (groupes d'action)។

លោកតស៊ូទាមទារឱ្យមានកម្មវិធីសិក្សាតាក់តែងដោយក្រុមអនក្ខរជនពេញវ័យ។ ក្នុងន័យនេះ លោកបានសម្រិតសម្រាំងគោលគំនិតស្ដីពីអក្ខរកម្ម និងការដកពិសោធន៍របស់លោកក្នុងនាមជាអ្នកដឹកនាំ- សម្របសម្រួល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

animateur-coordinateur ក្នុងផ្នែកវប្បធម៌។

គឺនៅពេលនោះហើយដែលលោកដឹងពីប្រសិទ្ធភាពនៃវិធីសាស្ត្ររបស់លោក។ អ្នករៀនម្នាក់ក្នុងចំណោមអ្នករៀនផ្សេងៗទៀតចេះអានអត្ថបទព័ត៌មានសាមញ្ញយ៉ាងច្បាស់ ក៏ដូចជាចេះសរសេរឃ្លាខ្លីៗបន្ទាប់ពីរៀនអក្ខរកម្មត្រឹមតែរយៈពេល២១ម៉ោង។

**ដំណាក់កាលនានានៃវិធីសាស្ត្រមនសិការកម្មនេះរួមមាន៖**

-ដំណាក់កាលសង្កេតសកម្ម ដែលអ្នកអប់រំស្វែងយល់ពីពិភពរស់នៅប្រចាំថ្ងៃរបស់សិស្សដែលជាគោលក្នុងការប្រើប្រាស់វាក្យស័ព្ទរបស់ពួកគេតាមរយៈទំនាក់ទំនងផ្លូវការ និងក្រៅផ្លូវការ។

បញ្ជៀន ចំពោះលោក Paulo Freire មិនទាមទារក្នុងការ«ផ្ទេរចំណេះដឹងនោះទេ តែបង្កើតលទ្ធភាពឱ្យមានការផលិត និងការកសាងខ្លួនដោយខ្លួនឯង»។

-ដំណាក់កាលសម្គាល់ពាក្យ និងប្រធានបទនាំមុខ និងការរៀបចំអត្ថន័យនៃពាក្យ និងប្រធានបទទាំងនោះទៅជារូបភាពតំណាង។ ពាក្យទាំងនោះត្រូវបានជ្រើសរើសព្រោះតែវាជាផ្នែកមួយនៃវាក្យស័ព្ទ។ «ការត្រួតពិនិត្យពាក្យដែលគេឃើញត្រូវធ្វើដោយក្រុម ក្រោមជំនួយរបស់អ្នកអប់រំ។ លោក Paulo ផ្អែកលើការសង្កេតដែលបង្ហាញថាក្រុមកម្មករចាប់អារម្មណ៍ទៅនឹងបញ្ហានយោបាយ»។

-ដំណាក់កាលនៃការបកស្រាយពាក្យ និងប្រធានបទនាំមុខ។ កិច្ចសន្ទនា និងការជជែកវែកញែកធ្វើឡើងតាមរយៈពាក្យដែលមានអត្ថន័យផ្នែកសង្គម និងវប្បធម៌សម្រាប់ក្រុមដែលមានឈ្មោះថា «រង្វង់វប្បធម៌ (Cercle culturel)»។

-ដំណាក់កាលរៀបចំពាក្យ និងប្រធានបទឡើងវិញនាំទៅរកការធ្វើសកម្មភាព។ យើងនៅចុងបញ្ចប់នៃនីតិវិធីដែលតាមរយៈបំណកស្រាយក៏



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រេចបានដូចគ្នាអក្ខរកម្មក៏ដូចជាការចាប់យកនូវមនសិការវិភាគពីគុណតម្លៃរបស់ខ្លួនក្នុងនាមកោសិកានៃសង្គម។

## គំនិតឆ្លុះពិចារណា

ការរិះគន់មួយចំនួនបង្ហាញថាវិធីសាស្ត្ររបស់ Paulo Freire មិនទទួលជោគជ័យទៅតាមការរំពឹងទុកគ្រប់ពេលនោះទេ។

គឺជាគរុកោសល្យដែលធ្វើវិចារណកម្មកិច្ចសន្ទនាប្រៀបដូចជាការផ្សារភ្ជាប់រវាងទ្រឹស្តីនិងការអនុវត្ត មានន័យថាទំនាក់ទំនងរវាងការគិតពិចារណានិងការអនុវត្ត។ ការអនុវត្តពិតប្រាកដត្រូវឈរលើមូលដ្ឋាននៃការគិតពិចារណាលើបញ្ហាប្រឈមដែលអាចឱ្យធ្លាក់ចូលទៅក្នុងសកម្មភាពជ្រុលនិយម ឬរហូតដល់គេរវកម្មនិយម ក៏ព្រោះថាការគិតពិចារណាពិតប្រាកដត្រូវចេញជាសកម្មភាពមិនដូច្នេះទេវានឹងក្លាយទៅជា «ការគិតឥតប្រយោជន៍» នេះជាអ្វីដែលលោក Paolo Freire បានលើកឡើង។

រាល់គរុកោសល្យរបស់ Paulo Freire គឺសម្រាប់បម្រើដល់ការអភិវឌ្ឍស្មារតីវិភាគ។ អក្ខរកម្មគឺជាមធ្យោបាយក្នុងការ «ផ្តល់កថាឡើងវិញដល់អ្នកដែលត្រូវបានគេដកហូត»។ គឺក្នុងន័យនៃយុត្តិធម៌សង្គមធ្លងតាមសេរីភាពនិងសមត្ថភាពនេះហើយ ដែលគេអាចធ្វើសមាហរណកម្មខ្លួនឯងទៅក្នុងពិភពលោកបាន។

# ២០. Raymond FONVIEILLE (1923-2000)

លោក Reymond Fonvieille ក៏ត្រូវបានស្គាល់តាមរយៈបច្ចេកទេសនៃកំណត់ហេតុប្រចាំថ្នាក់រៀន។ ជារៀងរាល់ឆ្នាំ លោកតែងតែសរសេរកំណត់ហេតុសង្កេតថ្នាក់រៀនដោយផ្តោតលើប្រធានបទផ្សេងៗគ្នា ដូចជាក្រុមកុមារការផ្ទេរចំណេះដឹង ការសិក្សារៀនសូត្រអំណាន ការប្រឹក្សាយោបល់ទំនាក់ទំនងជាមួយមាតាបិតាសិស្ស ឬក៏ការសិក្សាស្រាវជ្រាវរបស់សិស្ស ព្រមទាំង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បទពិសោធន៍ស្ម័យគ្រប់គ្រងខុសៗគ្នាផ្សេងៗ។ កំណាត់ហេតុប្រចាំថ្នាក់រៀនក៏ក្លាយទៅជាឧបករណ៍នាំដល់ការគិតពិចារណាស្តីពីការប្រតិបត្តិវិជ្ជាជីវៈ និងជាឧបករណ៍វិនិច្ឆ័យជាក់ស្តែង (outil clinique) សម្រាប់យល់កាន់តែច្បាស់ពីអាកប្បកិរិយា ឬក៏ផលលំបាករបស់សិស្ស។

លោកបានចូលទៅក្នុងសាលារៀនក្នុងនាមជាសិស្ស «បន្ទាប់ពីនោះភ្លាម លោកបានរកឃើញនូវភាពល្ងង់ខ្លៅ បន្ទាប់មករកឃើញនូវភាពអយុត្តិធម៌ភាពផ្តាច់ការពុតត្បុតរបស់មនុស្សពេញវ័យ ហើយចម្លើយតែមួយគត់ដែលមានសម្រាប់កុមារនោះគឺ៖ ការបន្លំ (Tricherie)» (R. Fonvieille, 1996)។ ហើយចុងក្រោយ លោករស់នៅឆ្លងកាត់ភ្លើងសង្គ្រាមប្រកបដោយភាពឈឺចាប់ដោយសង្គ្រាមផង និង ដោយសារឪពុករបស់លោកដែលចង់ធ្វើឱ្យលោកក្លាយជាអ្នកសន្តិភាពនិយម។

សំណេរក៏បានធ្វើឱ្យលោកជម្នះភាពអៀនប្រៀន និងទុយមុយរបស់លោកដែលបានធ្វើឱ្យលោកជាប់គាំងក្នុងស្ថានភាពទំនាក់ទំនងមួយចំនួន។

លោករកឃើញដោយឆាប់រហ័សនូវតួនាទីសំខាន់ចំនួនបីសម្រាប់សំណេរ៖ «ចំណង់ក្នុងការសរសេរ បន្ទាប់មកគឺមានបន្ថែមពីរមុខងាររងទៀត៖ ឥន្ទ្រីយជំនួយដល់ការរំឭកនឹកឃើញ និងមុខងារកាន់តែសំខាន់មួយទៀតនោះ គឺលទ្ធភាពក្នុងកិច្ចអន្តរាគមន៍ដើម្បីផ្លាស់ប្តូរស្ថានភាពព្រឹត្តិការណ៍នានាបើទោះជាមានលក្ខណៈតូចតាច ឬធំទូលាយក៏ដោយ» (R. Fonvieille, 1996)។

លោកបានបន្ថែមសមាសធាតុចំនួនពីរទៀតសម្រាប់បុព្វហេតុរបស់កុមារ៖ «ភាពរន្ធត់នៃសង្គ្រាម និងអយុត្តិធម៌សង្គមទៅលើក្រុមជនក្រីក្រជាងគេ» (R. Fonvieille, 1998)។ លោក R. Fonvieille ក្លាយទៅជាគ្រូឧទ្ទេសគ្រូបង្រៀនពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ នៅ Montlignon ក្នុងក្រុង Val d’Oise រហូតដល់ឆ្នាំ១៩៧៩ បន្ទាប់មកនៅសាលាគរុវិទ្យា Auteuil ជំនួសមិត្តរបស់លោកឈ្មោះ Fernand Oury ដែលចូលនិវត្តន៍។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សៀវភៅរបស់លោកគឺភាគច្រើនជាសំណេរប្រវត្តិសាស្ត្រ ព្រោះថា លោក Fonvieille មានព្រលឹងជាប្រវត្តិវិទូយកចិត្តទុកដាក់ និងព្រួយបារម្ភចំពោះពិភពដែលលោករស់នៅ។ លោកកត់ត្រា រៀបចំតាមលំដាប់លំដោយ និងរក្សាទុកពល់ស្នាកស្នាម អ្វីដែលមានប្រយោជន៍ក្នុងការរកឃើញយ៉ាងត្រឹមត្រូវនូវកាលបរិច្ឆេទ ទីកន្លែង និងព្រឹត្តិការណ៍ជាក់លាក់នានា។ តាមពិតទៅ ប្រភពដើមនៃគោលវិធីរបស់លោកគឺកើតចេញពីខ្សែជីវិតរបស់លោកក្នុងចលនារបស់លោកFreinet។ លោក Raymond Fonvieille ក៏មានទំនោរទៅរកការវិភាគស្ថាប័ននៃទំនាក់ទំនងដែលលោកមានជាមួយនឹងចលនានោះផងដែរ។

## សក្ខីជន

ក្នុងសៀវភៅរបស់លោក លោក Raymond Fonvieille លើកឡើងយ៉ាងទៀងទាត់ពីទំនាក់ទំនងរបស់លោកជាមួយនឹងចលនាលោក Freinet ជាពិសេសជាមួយនឹងស្ថាបនិកនៃចលនានោះតែម្តង។

លោក Raymond Fonvieille ពើបប្រទះបច្ចេកទេស Freinet តាំងពីឆ្នាំ ១៩៤៧។ លោកក៏បានជាប់ចិត្តភ្លាម ហើយចង់សាកល្បងបច្ចេកទេសទាំងនោះនៅក្នុងថ្នាក់រៀនរបស់លោក «ព្រោះបច្ចេកទេសទាំងនោះត្រូវនឹងថាមវន្តរបស់ខ្ញុំ និងត្រូវនឹងទំនោររបស់ខ្ញុំ ជាបច្ចេកទេសធ្វើឱ្យមានភាពប៉ិនប្រសប់ផ្នែករាងកាយ និងនវានុវត្តន៍ ជាបុប្ផាដែលមានដាំបន្តិចបន្តួចប៉ុណ្ណោះនៅក្នុងមជ្ឈដ្ឋានសាលារៀន ហើយជាទូទៅច្រើនតែមិនសូវទទួលបានការផ្តល់តម្លៃ» (R. Fonvieille, 1998)។ លោកព្យាយាមច្នៃប្រឌិត បង្កើត និងកែសម្រួលប្រព័ន្ធអប់រំដែលជាប់ស្គក។ លោក Raymond Fonvieille ចង់អភិវឌ្ឍគរុកោសល្យមួយសម្រាប់សាធារណៈមានលក្ខណៈជនពិសេសនៅក្នុងថ្នាក់រៀនរបស់លោក៖ សិស្សនៅជាយក្រុងដែលជួបការលំបាក។ ក្នុងអំឡុងពេលជាច្រើនឆ្នាំ លោក Raymond Fonvieille បន្តភាតព្វកិច្ចរបស់លោកក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្លូវចលនា Freinet។

## ជម្លោះជាមួយ Freinet

លោកគត់សម្គាល់ឃើញថា Freinet ភាគច្រើនជាមនុស្សតែម្នាក់គត់ដែលជាអ្នកធ្វើសេចក្ដីសម្រេច ដោយគ្មានសុំយោបល់ពីអ្នកទទួលខុសត្រូវ ឬមតិប្រឆាំងរបស់ក្រុមបន្ថិចណាឡើយ។ លោក Raymond Fonvieille បានបង្ហាញយើងនូវលិខិតមួយចំនួនដែលលោកសរសេរឆ្លងឆ្លើយជាមួយ Freinet ដែលក្នុងលិខិតទាំងនោះគេឃើញជាក់ច្បាស់នូវទំនាក់ទំនងតឹងតែងសមគួរ ហើយពេលខ្លះរហូតដល់មានទម្រង់ជាជម្លោះទៀតផងរវាងរូបលោកទាំងពីរតាំងពីដើមទីមក។

ការបំបែករដ្ឋធានី/ខេត្តបានធ្វើឱ្យគរុកោសល្យជនបទរបស់ Freinet មិនអាចអនុវត្តទៅបានក្នុងតំបន់ជាយក្រុងប៉ារីស ដែលនៅទីនោះទីជនបទនៅចម្ងាយប្រមាណជា ២០ គីឡូម៉ែត្រពីសាលារៀនឯណោះ។ ក្នុងសាលារៀន-បន្ទាយ écoles-casernes អ្វីជាអាទិភាព គឺវិធីក្នុងការរក្សាជីវិតដែលគ្រូត្រូវបង្ហាត់បង្រៀនទៅដល់សិស្ស។

ក្នុងសន្និបាតនៅប៉ារីសនាឆ្នាំ១៩៥៨ ការចូលរួមពីបរទេសគឺជាការចាំបាច់បំផុត។ សមាជិកទីក្រុងប៉ារីសព្យាយាមក្នុងការបើកទូលាយ ក្នុងការពង្រីកឥទ្ធិពលរបស់ចលនា ផ្ទុយទៅវិញលោក Freinet ព្យាយាមក្នុងការដកថយអត្តិភាពរបស់លោកជ្រុលបន្តិចនាពេលនោះ ។

ទីបំផុត លោក Raymond Fonvieille យល់ពីមូលហេតុធំបំផុត និងសំខាន់បំផុតថាតើហេតុអ្វីបានជាលោក Freinet បារម្ភក្នុងការបើកទូលាយចលនារបស់លោកចំពោះចរន្តមនុស្សសាស្ត្រផ្សេងៗទៀត ដូចជាចិត្តវិភាគវិទ្យា និងចិត្តវិទ្យាជាដើម ក៏ព្រោះថាមុខវិជ្ជាទាំងនេះអាចទៅហួសនូវអ្វីដែលគ្រាន់តែជាការប្រតិបត្តិបច្ចេកទេសរបស់លោក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## កំណើតនៃគរុកោសល្យស្ថាប័ន

លោក Raymond Fonvieille បន្តការងារកិច្ចគរុកោសល្យរបស់លោក ជាមួយនឹង Fernand Oury និងសមាជិកផ្សេងទៀតដែលមានចំណាប់អារម្មណ៍លើគរុកោសល្យស្ថាប័ន តាមរយៈក្រុមថ្មី (ក្រុមបច្ចេកទេសអប់រំ Groupe Technique Éducative) និងទស្សនាវដ្ដីថ្មីឈ្មោះថា ការអប់រំ និងបច្ចេកទេស (Education et techniques)។ ចលនាគរុកោសល្យស្ថាប័នលេចរូបរាងឡើងនៅឆ្នាំ១៩៥៨ ចេញពីជំនួយគាំទ្ររបស់ចិត្តតិកិច្ចាស្ថាប័ន។

វត្តមានរបស់ Georges Lapassade ព្រមទាំងលោក Michel Lobrot បន្ទាប់មកទៀតមានលោក René Lourau ជាកត្តាសម្រេចជោគវាសនាលើការតម្រង់ទិសនាពេលអនាគតសម្រាប់ក្រុមបច្ចេកទេសអប់រំ។ នាពេលនោះ មានការលេចចេញយ៉ាងឆាប់រហ័សនៅក្នុងក្រុមនូវការតម្រង់ទិសចំនួនពីរនៃគរុ-កោសល្យស្ថាប័ន ដែលតំណាងដោយស្ថាបនិករៀងៗខ្លួន ដោយក្នុងនោះក៏មានការប្រសិទ្ធនាមក្រុមនោះជាជាក្រុមក្បាលពីរ។ វិធីសាស្ត្រទី១ ជាវិធីសាស្ត្រវាងចំណាស់ ជារបស់Fernand Oury ដែលជាវិធីសាស្ត្រចិត្តគរុកោសល្យ ឬចិត្តតិកិច្ចា។ លោកមានបំណងអនុវត្តខ្លឹមសារនៃចិត្តវិកាគវិជ្ជានៅក្នុងថ្នាក់រៀនកម្រិតខ្ពស់។ វិធីសាស្ត្រទី២ ជាវិធីសាស្ត្រសម័យថ្មីរបស់លោក Raymond Fonvieille ដែលជាវិធីសាស្ត្រសង្គមគរុកោសល្យ។

## ពីគរុកោសល្យស្ថាប័នទៅស្វ័យគ្រប់គ្រងគរុកោសល្យ

លោក Raymond Fonvieille កំណត់កំណកំណើតពិតប្រាកដរបស់ស្វ័យគ្រប់គ្រងគរុកោសល្យនៅចន្លោះឆ្នាំ ១៩៦២-១៩៦៣។ នៅសម័យនោះលោកបង្រៀនថ្នាក់បញ្ចប់៖ សិស្សអាយុ ១៣ឆ្នាំ បរាជ័យក្នុងការសិក្សា និងដែលត្រូវប្រឡងយកវិញ្ញាបនបត្រសិក្សា។ «ហើយពិតណាស់ថាសមត្ថភាពសិក្សារបស់គេគឺនៅបាតាលតែម្ដង គឺថាអ្វីក៏ពួកគេខ្វះដែរ។ តែបញ្ហាទាំងនោះ មើលទៅហាក់ដូចជាមកពីឧបសគ្គនានាដែលគេជួបប្រទះ ជាជាងភាព



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អសមត្ថភាពផ្នែកបញ្ហារបស់ពួកគេ» (R. Fonvieille, 1998)។

លោក Georges Lapassade ដែលជាអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រឯណោះវិញ បានមកធ្វើការសង្កេតរយៈពេលវែងនៅ Gennevilliers ក្នុងឆ្នាំ១៩៦៤ ក្នុងថ្នាក់រៀនរបស់លោក Raymond Fonvieille។ គឺតាមរយៈការសង្កេតរបស់លោកនោះហើយដែលលោកបានចងក្រងជាគោលគំនិតក្នុងការអនុវត្តនូវអ្វីដែលលោកបានឃើញដោយដាក់ឈ្មោះថា ស្វ័យគ្រប់គ្រងគរុកោសល្យ autogestion pédagogique ។

ពាក្យស្វ័យគ្រប់គ្រងមិនមែនជាពាក្យបាក់ងទេ។ លោកទាញចេញពីប្រភពដើមនៃពាក្យនេះតាំងពី១០ឆ្នាំមុនមកម្ល៉េះ នៅក្នុងបទពិសោធន៍យូហ្គូស្លាវី ក្រោមការគ្រប់គ្រងរបស់ Tito បន្ទាប់ពីចប់សង្គ្រាម។

ស្វ័យគ្រប់គ្រងអនុវត្តក្នុងវិស័យគរុកោសល្យគឺជាការទិតៀនគំរូអប់រំ និងការប្រយុទ្ធដើម្បីទំនាក់ទំនងផ្សេងៗគ្នារវាងអ្នកដែលត្រូវគេបង្រៀន និងអ្នកដែលបង្រៀនគេ។ គឺជាការប្រយុទ្ធប្រឆាំងនឹងភាពផ្តាច់ការ និងឋានានុក្រមដែលធ្វើឱ្យសិស្សមិនអាចនិយាយអ្វីបានសោះ។ អ្នកស្វ័យគ្រប់គ្រងផ្តោតលើការរំដោះខ្លួនដោយផ្តល់ឱ្យអ្នកត្រូវគេបង្រៀននូវតួនាទីកាន់តែសំខាន់ឡើងៗក្នុងសកម្មភាពរៀនសូត្ររបស់គេ។

លោក Georges Lapassade ផ្តល់និយមន័យស្វ័យគ្រប់គ្រងគរុកោសល្យថាជា «ប្រព័ន្ធអប់រំដែលក្នុងនោះទំនាក់ទំនងបណ្តុះបណ្តាលជាគោលការណ៍ត្រូវបានរំលាយចោល។ គឺអ្នកត្រូវគេបង្រៀនជាអ្នកសម្រេចពីអ្វីដែលត្រូវជាការបណ្តុះបណ្តាលពួកគេ ហើយដែលត្រូវគ្រប់គ្រងការបណ្តុះបណ្តាលនោះ»(G.Lapassade,1971)។ បន្ទាប់មក លោកក៏បានទាញចេញជាការតម្រង់ទិសចំនួន ៣ លើស្វ័យគ្រប់គ្រងគរុកោសល្យដែលគេអាចចាត់ជាបីកម្រិតក្នុងការអនុវត្តស្វ័យគ្រប់គ្រង។ «ចរន្តផ្តាច់ការដែលក្រុមគ្រូបង្រៀនប្រើប្រាស់គំរូស្ថាប័នសម្រាប់ដំណើរការការបង្រៀន ចរន្ត «Freinet» ដែលក្រុមគ្រូបង្រៀនក៏ប្រើប្រាស់គំរូស្ថាប័នដែរ តែមានទំនោរក្នុងការធ្វើបុគ្គលភាព និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការផ្តល់សេរីភាពដល់ស្វ័យបណ្តុះបណ្តាល និងចរន្តបែបសេរី ដែលក្រុមគ្រូបង្រៀនក្លាយជា «អ្នកពិគ្រោះយោបល់» របស់ក្រុមនៅពេលបណ្តុះបណ្តាលវិញ» (G. Lapassade, 1971)។ គេឃើញច្បាស់គ្រប់ឥទ្ធិពលនៃបរិយាកាសសង្គមដែលរួមមាន ផ្តាច់ការ ប្រជាធិបតេយ្យ និងការបណ្តោយឱ្យធ្វើតាមរយៈ Kurt Lewin។

ដើម្បីបែងចែកគរុកោសល្យបុរាណនិយម ដែលនៅតែមានការប្រើប្រាស់កាតច្រើននៅក្នុងថ្នាក់រៀន ពីគរុកោសល្យស្ថាប័ន Georges Lapassade បានប្រើប្រាស់ សញ្ញាណស្ថាប័ននៃចិត្តគិកិច្ចាស្ថាប័នឡើងវិញ។ លោកបញ្ចូលទៅក្នុងថ្នាក់រៀន ការបែងចែករវាងស្ថាប័នផ្ទៃក្រៅ «មានន័យថា កម្មវិធីនានា ការប្រឡងនានា ហានាទុក្រមរដ្ឋបាល ពិន្ទុនានាជាដើម។ល។» (G. Lapassade, 1971) និងស្ថាប័នផ្ទៃក្នុង «បច្ចេកទេសស្ថាប័នទាំងមូលដែលគេអាចប្រើប្រាស់នៅក្នុងថ្នាក់រៀន៖ ការងារជាក្រុមការប្រឹក្សាយោបល់ជាដើម។ល។» (G. Lapassade, 1965)។ ក្នុងគរុកោសល្យបុរាណនិយម «ស្ថាប័នផ្ទៃក្នុងនៅក្នុងថ្នាក់រៀនត្រូវបានសម្រេចដោយគ្រូបង្រៀនតែប៉ុណ្ណោះ»។

## ឥរុមិត្ត

លោក Raymond Fonvieille ជាគ្រូបង្រៀនបឋមសិក្សាជាប់ចិត្តនឹងមុខរបរបស់ខ្លួន ព្រួយបារម្ភពីសុខមាលភាពរបស់កុមារ យកចិត្តទុកដាក់រាល់តម្រូវការរបស់សិស្ស និងស្វែងរកនវានុវត្តន៍ជាប់ជាប្រចាំ។ លោកជាអ្នករដ្ឋបាលជំនួយដែលប្រមូលផ្តុំនូវបច្ចេកទេសរបស់ Freinet តែលោកក៏យល់បានយ៉ាងច្បាស់ហើយថាបច្ចេកទេសទាំងនោះហាក់មានព្រំដែនកំណត់។ «ត្រូវទទួលស្គាល់ថាយើងមិនបានដោះស្រាយគ្រប់បញ្ហាអប់រំ និងការបង្រៀនដោយប្រើប្រាស់ត្រឹមរោងពុម្ពលិខិតឆ្លើយឆ្លង និងកិច្ចសហប្រតិបត្តិការនោះទេ បើទោះបីជានៅក្នុងទម្រង់មានប្រយោជន៍ផ្សេងដែលសមាសធាតុទាំងនោះផ្តល់ឱ្យ ក៏ដូចជាពេលបច្ចេកទេសទាំងនោះត្រូវបានប្រើប្រាស់អស់លទ្ធ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ភាពក៏ដោយចុះ» (R. Fonvieille, 1998)។

មួយវិញទៀត នៅឆ្នាំ ១៩៦៦ លោក Michel Lobrot បានផ្ដល់និយមន័យដល់ពាក្យស្វ័យគ្រប់គ្រងមានលក្ខណៈពេញលេញសមគួរ៖

គោលការណ៍ខាមខារឱ្យផ្ដល់ក្នុងដៃរបស់សិស្សគ្រប់អ្វីៗដែលអាចផ្ដល់ទៅឱ្យពួកគេ មានន័យថា មិនមែនជាការរៀបចំកម្មវិធីសិក្សា ឬការសម្រេចក្នុងការប្រឡង ដែលមិនផ្អែកទៅលើគ្រូ និងសិស្សនោះទេ តែគឺជីវិតទាំងមូល សកម្មភាពទាំងអស់ និងការរៀបចំកិច្ចការទាំងស្រុង នៅខាងក្នុងក្របខ័ណ្ឌនោះតែម្ដង។ សិស្សមិនត្រឹមតែអាចធ្វើកិច្ចការ ឬមិនធ្វើកិច្ចការនោះទេ តែលើសពីនោះទៅទៀតពួកគេអាចសម្រេចចិត្តដោយខ្លួនឯងពីទំនាក់ទំនងរបស់ពួកគេ មានន័យថាទំនាក់ទំនងរបស់គេ «នៅទីនេះ នៅម៉ោងនេះ» សកម្មភាពរួមរបស់ពួកគេ ការរៀបចំការងាររបស់ពួកគេ គោលបំណងថ្នាក់រៀនរបស់ពួកគេដែលគេអាចរៀននៅក្នុងនោះ ទៅតាមកាលៈទេសៈ ទុកឱ្យធ្វល់ទុកឱ្យចង់តាមដាន ប្រមូលចងក្រងដោយផ្អែកលើគំរូថ្មីៗ ប្រមូលចងក្រងដោយផ្អែកលើគំរូបែបបុរាណជាដើម។ល។ (M. Lobrot, 1966,)។

ពីការដាក់ឱ្យប្រើប្រាស់នូវបន្ទប់ពិសោធន៍រូបថត ទៅការបញ្ចូលរថយន្តទៅក្នុងថ្នាក់រៀន ដោយឆ្លងតាមការដាក់ឱ្យអនុវត្តកម្មវិធីសិក្សា ឬការរៀបចំនិងហិរញ្ញប្បទានស្នាក់នៅ លោក Raymond Fonvieille ផ្ដួចផ្ដើមឱ្យសិស្សរបស់លោកទទួលបាននូវគរុកោសល្យប្រជាធិបតេយ្យ ដែលស្ថាប័នផ្ទៃក្នុងទាំងអស់ត្រូវសម្រេចយក និងត្រូវបានគ្រប់គ្រងជាសមូហភាព ដើម្បីបណ្ដុះបណ្ដាលមនុស្សជាតិដែលមានការទទួលខុសត្រូវ និងស្វ័យភាព។

«ចំណុចសំខាន់គឺការផ្ដល់សោរគន្ធិ៍ះនៃចំណេះដឹង ការរៀនពីរបៀបរៀនសូត្រ» (R. Fonvieille, 1989)។ រំដោះខ្លួន ស្វ័យបណ្ដុះបណ្ដាល មានស្វ័យភាព មានការទទួលខុសត្រូវបាត់បង់ភាពកោងកាច គឺជាអ្វីដែលត្រូវធ្វើជាមួយសិស្សទាំងនេះ គឺជាអ្វីដែលលោក Raymond Fonvieille ស្វែងរកតាមរយៈការអនុវត្តស្វ័យគ្រប់គ្រង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លោកក៏យល់ច្បាស់បញ្ញត្តិចម្បងចំនួនពីរ បន្ទាប់ពីការពិសោធលើគរុកោសល្យថ្មីបួនឆ្នាំក្រោយមក។ បញ្ញត្តិទីមួយពាក់ព័ន្ធនឹងពេលវេលា និងទីកន្លែងនៃសកម្មភាពរបស់លោក។ វាពិតជាចាំបាច់ណាស់ក្នុងការនៅជាប់ជាប្រចាំនៅក្នុងគ្រឹះស្ថានសិក្សាតែមួយក្នុងអំឡុងពេលច្រើនឆ្នាំ ជាពិសេសនៅក្នុងគ្រឹះស្ថានសិក្សាដែលស្ថិតនៅក្នុងតំបន់រសើប ឬកាន់តែប្រសើរថែមទៀតនោះ គឺតាមជានថ្នាក់រៀនដដែលរយៈពេលច្រើនឆ្នាំជាប់ៗគ្នា។ លោកមានលទ្ធភាពច្រើនក្នុងការរក្សាបានក្រុមសិស្សរយៈពេលពីរបីឆ្នាំបន្តបន្ទាប់គ្នា ព្រោះថាប្រភពសង្គមដើមរបស់សិស្សនៅក្រុង Gennevilliers មិនមានភាពទាក់ទាញគ្រូឱ្យនៅជាប់នឹងគ្រឹះស្ថានសិក្សានោះបន្តិចសោះ។

ក្នុងន័យនេះ លោកបានផ្តល់មេរៀនពិសេសៗបន្ទាប់ពីរៀននៅក្នុងថ្នាក់ នៅផ្ទះរបស់លោក ឬនៅក្នុងថ្នាក់រៀនតែម្តង។ បញ្ញត្តិទីពីរដែលលោកលើកឡើងគឺជាកាតព្វកិច្ច និងកិច្ចគាំទ្រពីមាតាបិតាចំពោះបដិវត្តន៍គរុកោសល្យនេះតែម្តង។ ភាពនឹងនររបស់គ្រូបង្រៀនធ្វើឱ្យមានការជឿទុកចិត្តពិតប្រាកដជាមួយនឹងក្រុមគ្រួសាររបស់សិស្ស។

លោក Raymond Fonvieille ព្យាយាមដាក់ឱ្យអនុវត្តគរុកោសល្យសុខដុមមួយដែលមនោគមវិជ្ជា និងសកម្មភាពមានភាពស៊ីចង្វាក់គ្នា។ លោកព្យាយាមក្នុងការជំរុញឱ្យមានបដិវត្តន៍ផ្ទៃក្នុង។ ក្នុងន័យនេះ លោក Raymond Fonvieille ចូលចិត្ត និងផ្តល់តម្លៃដល់គោលវិធី «សកម្មភាព-ស្រាវជ្រាវ» របស់លោក ជាជាងគោលវិធី «ស្រាវជ្រាវ-សកម្មភាព»។ ការស្វែងរកស្វ័យគ្រប់គ្រងរបស់លោកបានធ្វើឱ្យលោកចោទសួរខ្លួនឯងពីភាពចាំបាច់ និងតួនាទីរបស់គ្រូនៅក្នុងប្រភេទគរុកោសល្យនេះ ឬក៏ភាពចាំបាច់ និងតួនាទីរបស់ប្រធានអង្គប្រជុំនៅពេលមានកិច្ចប្រជុំប្រឹក្សាយោបល់នៅក្នុងថ្នាក់រៀន ពាក់ព័ន្ធនឹងទំនាក់ទំនងគ្រូ/សិស្ស និងសញ្ញាណនៃអំណាច។

ខុសពីមនោគមវិជ្ជាបែបសេរីក្រោមគំនាប ប្រភេទគរុកោសល្យស្វ័យគ្រប់គ្រងទាមទារឱ្យអនុវត្តទំនាក់ទំនងរវាងពេលវេលា និងទីកន្លែងខុសគ្នា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ព្រោះថាថ្នាក់ទាំងមូលមួយមិនប្រាកដថាដូចគ្នាទាំងស្រុងនៅពេលជាមួយគ្នានោះទេ។ «ត្រូវយល់ថាមានពេលខ្លះ សិស្សទាំងអស់ត្រូវបង្ខំឱ្យចូលរួមសកម្មភាពរួម (ការជជែកពិភាក្សា បទបង្ហាញជាដើម។ល។) មានពេលខ្លះសិស្សអាចចូលរួមសកម្មភាពបុគ្គល (ស្រាវជ្រាវ អំណាន ។ល។) ឬជាក្រុម (គណិតវិទ្យា ស្រាវជ្រាវ) សកម្មភាពស្ងប់ស្ងាត់ និងចុងក្រោយ គឺពេលវេលាសម្រាប់សកម្មភាពសេរី (ការពិសោធ សកម្មភាពហត្ថកម្ម ជាដើម។ល។)» (R. Fonvieille, 1996)។

សិស្សចាស់តែងតែត្រឡប់មករក«គ្រូល្អ»របស់ពួកគេ និងដើម្បីពិនិត្យមើលថាតើសិស្សជំនាន់ក្រោយមានឧត្តមភាពចំពោះខ្លួនឯងដែរឬយ៉ាងណា។ ពួកគេទាំងនោះមានរហូតដល់បង្កើតសមាគមអតីតសិស្សក្នុងសាលារៀន Gennevilliers ទៀតផង៖ ទីជ្រកកោន Le refuge។ សិស្សខ្លះក្លាយទៅជាមិត្តភក្តិនឹងគ្នា ហើយច្រើនតែទៅជួបរូបលោកនៅផ្ទះរបស់លោកជាប់ជាប្រចាំ។

## គំនិតឆ្លុះពិចារណា

ចំណុចកំពូលនៃខណៈស្វ័យគ្រប់គ្រងគឺនៅក្នុងទសវត្សរ៍ទី ៧០ នៅប្រទេសបារាំង។ ពាក្យដែលត្រូវបានយកមកនិយាយបែបមនោគមន៍វិជ្ជានេះត្រូវបានបាត់បង់ ដោយជំនួសវិញនូវពាក្យថាសុទិដ្ឋិនិយម ការជជែកពិភាក្សា និងសំណេរយ៉ាងឆាប់រហ័ស។

ចលនាស្វ័យគ្រប់គ្រងមិនទទួលបានជោគជ័យក្នុងការពង្រីកខ្លួនដូចអ្វីដែលខ្លួនប៉ងនោះទេ ផ្ទុយទៅវិញមនោគមន៍វិជ្ជាបែបនេះត្រូវបានបង្កើតឡើង។ បំណងប្រាថ្នាចំពោះពិភពលោកប្រកបភាពយុត្តិធម៌ ចំណេះដឹងប្រជាធិបតេយ្យកាន់តែប្រសើរ និងកាន់តែមានភាពមនុស្សជាតិនៅតែស្ថិតនៅក្នុងក្តីស្រមៃរួម ប្រសិនបើយើងមិនរួមគ្នាធ្វើឱ្យក្តីស្រមៃនោះក្លាយជាការពិតទេ។ សង្គមរបស់យើងនៅឆ្ងាយនៅឡើយក្នុងការធ្វើឱ្យមនុស្សក្លាយជាមនុស្សពេញលេញ ឬគ្រាន់តែប្រែក្លាយគេឱ្យទៅជាបុគ្គលសេរីក្នុងសង្គមសេរី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មួយនោះ។ ស្ថ័យគ្រប់គ្រងដែលលោក Rayomond Fonvieille ជាមេដឹកនាំនេះ គឺមានលក្ខណៈជាទស្សនវិស័យ ជាជាងភាពហួសវិស័យ ហើយគឺពេលវេលាជាអ្នកកំណត់ថាតើយើងអាចធ្វើបានឬយ៉ាងណា។

## ២១. Georges LAPASSADE (1924-2008)

«ដើម្បីប្រតិកម្មតប យើងលែងត្រូវការស្រមើស្រមៃពីអនាគតគ្មានជម្មោះ និងក្រុមមនុស្សត្រូវរ៉ូវគ្នានៅថ្ងៃអាទិត្យនៃជីវិតទៀតហើយ(ថ្ងៃអាទិត្យជាថ្ងៃជួបជុំនៅវិហារសម្រាប់គ្រិស្តសាសនិក)។ ផ្ទុយទៅវិញ សម្រាប់យើងក្រុមនីងនរគឺជាក្រុមដែលស្លាប់បាត់ទៅហើយ។ សង្គម «ដល់គោលដៅ» ជាសង្គមមួយដែលមានលក្ខណៈការិយាធិបតេយ្យ ឈរលើមូលដ្ឋានដាច់ណាត់ ហើយបដិសេធនូវរាល់ការផ្លាស់ប្តូរនានា។ សង្គមរស់រវើក និងសេរីអាចកសាងបានដោយផ្អែកលើការបង្កើតថ្មីជាប្រចាំនូវស្ថាប័នថ្មី។» G. LAPASSADE, L'Entrée dans la vie (ការចូលក្នុងជីវិត)។

តាមរយៈសៀវភៅប្រមាណជាជាង ៤០ ក្បាលរបស់លោក គេអាចនិយាយបានថាលោក Georges Lapassade មានជំនាញចម្រុះវិស័យដូចជាសាលារៀន ជាតិពន្ធុ ការចូលរួប ពិធីខាបព្រលឹង យុវជននៅជាយក្រុងវប្បធម៌ Rap សាកលវិទ្យាល័យ អន្តរវប្បធម៌ជាដើម។ គ្មានអ្វីដែលផុតពីក្រសែភ្នែក និងផុតពីការវិភាគរបស់លោកនោះទេ។ អ្នកប្រយុទ្ធមិនចេះហត់នេះបានធ្វើដំណើរពាសពេញពិភពលោក។

នៅឆ្នាំ១៩៤៥ លោកត្រូវបានតែងតាំងជាគ្រូបង្រៀនបឋមសិក្សា។ លោកក៏បន្តការសិក្សាផ្នែកទស្សនវិជ្ជានៅក្រុង Montpellier បន្ទាប់មកនៅក្រុងប៉ារីសនៅឆ្នាំ ១៩៤៨។ នៅទីនោះហើយ ដែលលោកបានប្រឡងជាប់អធិការបឋមសិក្សា បន្ទាប់មកទទួលបានតំណែងជាអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រ CNRS។

លោកចាប់ផ្តើមល្បីឈ្មោះនៅទសវត្សរ៍ឆ្នាំ ៦០។ នាពេលនោះ លោក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានចូលរួមបង្កើតចលនាគរុកោសល្យស្ថាប័ន បន្ទាប់មកចលនាស្វ័យគ្រប់គ្រងគរុកោសល្យ។ នៅឆ្នាំ១៩៦២ លោកការពារនិក្ខេបបទថ្នាក់បណ្ឌិតរបស់លោកមានចំណងជើងថា៖ ការចូលក្នុងជីវិត កម្រងបទពិសោធន៍ស្តីពីភាពមិនទាន់សម្រេចនៃមនុស្ស L'Entrée dans la vie, essai sur l'inachèvement de l'homme ដែលត្រូវបានបោះពុម្ពផ្សាយមួយឆ្នាំក្រោយមក។

## ការវិភាគស្ថាប័ន

វិបត្តិស្ថាប័នកើតមានជាទូទៅនៅប្រទេសបារាំង នៅក្នុងទសវត្សរ៍ទី៦០។ សាធារណៈជនចាប់ផ្តើមលែងទុកចិត្តអង្គការ មនោគមវិជ្ជា និងស្ថាប័នរដ្ឋ។ គឺក្នុងបរិការនេះហើយដែល Georges Lapassade បង្កើត និងដាក់ចេញនូវមូលដ្ឋានគ្រឹះស្តីពីទ្រឹស្តីចិត្តសង្គមវិជ្ជាថ្មី នៅឆ្នាំ១៩៦២៖ ការវិភាគស្ថាប័ន។ រូបរាង និងទ្រង់ទ្រាយនៃចលនានេះជាការជឿលើសមត្ថភាពរបស់មនុស្សក្នុងការទទួលខុសត្រូវក្នុងនាមជាប្រធាននៃជីវិតរបស់ខ្លួន និងក្នុងនាមជាប្រធាននៃប្រវត្តិរបស់ខ្លួន។ ដើម្បីធ្វើបែបនេះបាន មនុស្សត្រូវយល់តថភាពសង្គមដែលខ្លួនរស់នៅតាមរយៈការវិភាគស៊ីជម្រៅនៃស្ថាប័ននានាដែលខ្លួនពឹងផ្អែក។

សាលារៀនប្រៀបបានជាស្ថាប័នមួយ គឺជាមូលដ្ឋានអាទិភាពក្នុងការបង្កើតទ្រឹស្តី និងការអនុវត្តក្នុងចរន្តនៃចលនានោះ។ ការវិភាគស្ថាប័នអាចអនុវត្តបានដោយគ្រូបង្រៀន តែក៏អាចអនុវត្តបានដោយសិស្សផងដែរ។ ក្នុងសៀវភៅរបស់លោកក្រោមចំណងជើងថា ពីវ៉ាំងសែន ទៅសាំងដឺនីស (De Vincennes à Saint-Denis) លោក Lapassade បានលើកជាឧទាហរណ៍ជាក់ស្តែងមួយក្នុងការវិភាគស្ថាប័ននៃសាកលវិទ្យាល័យក្នុងអំឡុងពេលមានវិបត្តិ។

## ស្វ័យគ្រប់គ្រងគរុកោសល្យ

លោក Georges Lapassade ជាស្ថាបនិកបញ្ញត្តិស្តីពីស្វ័យគ្រប់គ្រង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គរុកោសល្យ។ ទេពកោសល្យរបស់លោក Lapassade គឺត្រូវបានផ្ទេរនៅពេលបន្ទាប់ទៅកាន់វិស័យអប់រំ នោះគឺគំរូនាំការបណ្ដុះបណ្ដាលតាមបែបការបណ្ដុះបណ្ដាលជាក្រុម (Training Group)។ «តើមានអ្វីកើតឡើងនៅពេលដែលគេបង្កើតស្វ័យគ្រប់គ្រងក្នុងថ្នាក់រៀន?» (G. Lapassade, 1971d)។ ដើម្បីឆ្លើយទៅនឹងសំណួរនេះលោកLapassadeបានផ្ដោតការសង្កេតរបស់លោកនៅឯ Gennevilliers លើដំណើរការនៃកិច្ចប្រជុំប្រឹក្សាយោបល់ក្នុងថ្នាក់រៀនរបស់លោក Bernard Bessière និង Raymond Fonvieille។ លោកបានឃើញនៅក្នុងកិច្ចប្រជុំប្រឹក្សាយោបល់នេះ នូវខណៈចម្បងនៃស្វ័យគ្រប់គ្រងនៅក្នុងថ្នាក់រៀន។ គឺជា «សោរគន្លឹះនៃប្រព័ន្ធអប់រំ ព្រោះថាកិច្ចប្រជុំនេះមានលទ្ធភាពក្នុងការបង្កើតស្ថាប័នថ្មីៗ ក្នុងការធ្វើស្ថាប័នីយកម្មនៃមជ្ឈដ្ឋានជីវិតរួម» (Oury et Vasquez, 1967)។

តើអ្វីទៅជាការប្រជុំពិគ្រោះយោបល់? គឺជាពេលវេលាដាច់ដោយឡែកមួយដែលអ្នកចូលរួមទាំងអស់នៅក្នុងថ្នាក់ មានសិស្ស និងគ្រូត្រូវប្រជុំគ្នា។ ជាទូទៅ គេរៀបចំតុជារង្វង់ ឬជារាងអក្សរ U ធ្វើយ៉ាងនេះដើម្បីឱ្យអ្នកចូលរួមទាំងអស់អាចមើលមុខគ្នាឃើញ និងផ្លាស់ប្ដូរមតិយោបល់។ ដោយដើមឡើយ ក្នុងគរុកោសល្យស្ថាប័នក្ដី ឬតាមទ្រឹស្ដីរបស់ Freinet ក្ដី ការប្រជុំប្រឹក្សាយោបល់ត្រូវធ្វើឡើងរៀងរាល់សប្ដាហ៍ លើកលែងតែការប្រជុំពិគ្រោះយោបល់វិសាមញ្ញក្នុងករណីមានការចាំបាច់។ «គឺជាកិច្ចប្រជុំពិភាក្សាពិសេសមួយស្ដីពីការរៀបចំ និងការគ្រប់គ្រង ដែលក្នុងកិច្ចប្រជុំនោះ គេឱ្យសិស្សរៀបចំកម្មវិធី និងរៀបចំសកម្មភាពផ្ទាល់ខ្លួនរបស់ខ្លួនឯង» (R. Fonvieille, 1998)។ កិច្ចប្រជុំប្រឹក្សាយោបល់ត្រូវដឹកនាំដោយសិស្សពីររូប។ សិស្សមួយរូបជាប្រធានអង្គប្រជុំ ហើយមួយរូបទៀតជាលេខាកត់ត្រាដែលត្រូវកត់រាល់ការសម្រេចចិត្តនានារបស់អង្គប្រជុំ។ សិស្សទាំងអស់ត្រូវដើរតួនាទីបែបនេះតាមវេន។ កិច្ចប្រជុំពិគ្រោះយោបល់គឺជាពេលវេលាជាក់ស្ដែងមួយនៃស្វ័យគ្រប់គ្រងដែលម្នាក់ៗអាចបញ្ចេញមតិយោបល់ និងក៏ជាពេលវេលាមួយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលច្បាប់ និងការសម្រេចចិត្តត្រូវបានធ្វើឡើងរួមគ្នាដោយលក្ខណៈប្រជាធិបតេយ្យ។ កិច្ចប្រជុំប្រឹក្សាយោបល់គឺជាការសិក្សារៀនសូត្ររូបិ និងជាក់ស្ដែងពីភាពជាពលរដ្ឋ។

តាមគំនិតរបស់ Freinet កិច្ចប្រជុំប្រឹក្សាយោបល់អាចរៀបចំឡើងនៅពេលច្បាស់លាស់ណាមួយក្នុងសប្ដាហ៍ដោយមានកត់ចូលក្នុងកាលវិភាគ។ ពេលណាដែលបញ្ហាមួយកើតឡើងត្រូវកត់បញ្ហានោះ ហើយបញ្ហានោះត្រូវយកទៅពិភាក្សានៅកិច្ចប្រជុំបន្ទាប់ មានន័យថាបញ្ហាកើតឡើងមិនត្រូវបានដោះស្រាយភ្លាមៗនោះទេ។

អ្វីៗទាំងអស់ត្រូវដោះស្រាយ ឧទាហរណ៍បណ្ដឹងរបស់សិស្សត្រូវយកមកដោះស្រាយពេលក្រោយ នៅពេលដែលសិស្សលែងស្ថិតនៅក្នុងសេចក្ដីក្រេវក្រោធ។ នៅពេលសិស្សសរសេរបណ្ដឹងនៅលើសៀវភៅសិស្សដឹងថាបណ្ដឹងរបស់ខ្លួននឹងត្រូវដោះស្រាយនៅពេលប្រជុំប្រឹក្សាយោបល់។ រាល់អារម្មណ៍ទាំងអស់មិនត្រូវបានបំភ្លេចនោះទេ តែអារម្មណ៍ទាំងនោះត្រូវប្រើប្រាស់ជាមធ្យោបាយសម្រាប់អប់រំវិញ។ ពាក្យសម្បីកកាំងបន្តិចម្ដងៗកុំឱ្យបញ្ចេញសកម្មភាពជំនួសសម្ដី នឹងបង្រៀនឱ្យសិស្សកសាងខ្លួនតាមរយៈការជជែកវែកញែក (M. P. Matthey,1998)។

ផ្ទុយទៅវិញ ក្រុមស្វ័យគ្រប់គ្រងមួយចំនួនចង់ដោះស្រាយបញ្ហាភ្លាមៗដោយមិនរង់ចាំកិច្ចប្រជុំពិគ្រោះយោបល់លើកក្រោយ។ ពួកគេចង់ឱ្យថ្នាក់រៀនរបស់ពួកគេក្លាយជាកន្លែងប្រជុំប្រឹក្សាយោបល់ជាប្រចាំ។ នៅគ្រប់ពេលទាំងអស់ សិស្សអាចស្នើសុំដល់គ្រូក្នុងការបញ្ឈប់មេរៀនដើម្បីជជែកពិភាក្សាបញ្ហាដាច់ដោយឡែក និងបន្ទាន់ណាមួយ។

កិច្ចប្រជុំប្រឹក្សាយោបល់រួមមានបួនដំណាក់កាលធំៗ៖ ស្នើ ពិភាក្សា សម្រេច និងអនុវត្ត ដែលក្នុងនោះរួមមានដំណាក់កាលគន្លឹះចំនួនបី៖ ខ្ញុំស្នើ ខ្ញុំរិះគន់ និងខ្ញុំសម្រួល។ កិច្ចប្រជុំប្រឹក្សាយោបល់គឺជាអង្គបញ្ញត្តិ ប្រតិបត្តិ និងសេដ្ឋកិច្ច។ ក្រៅពីតួនាទីទាំងបីនេះ កិច្ចប្រជុំប្រឹក្សាយោបល់ក៏ជាវិធាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិភាគមួយដែរ។ កិច្ចប្រជុំប្រឹក្សាយោបល់នាំឱ្យមានការយកចិត្តទុកដាក់ទៅលើបញ្ហាកំផស្ទះមួយចំនួន និងនាំទៅដល់ការរកឃើញរួមគ្នានូវវិធីសាស្ត្រសមស្របបំផុតសម្រាប់បញ្ហាទាំងនោះ។

លោក Georges Lapassade ពិនិត្យឃើញថាបញ្ហាអំណាចគឺជារឿងធំបំផុត។ ក្នុងគរុកោសល្យស្វ័យគ្រប់គ្រង ការអប់រំបែបផ្ដាច់ការដែលគ្រូ គឺជាអ្នកវិនិច្ឆ័យ និងជាអ្នកមានអំណាចជាងគេនៅក្នុងថ្នាក់តែម្នាក់គត់នោះ ត្រូវជំនួសដោយប្រព័ន្ធមួយមានលក្ខណៈប្រជាធិបតេយ្យដែលសិស្សមានសិទ្ធិក្នុងការតបតដោយសេរី។ ដោយសារតែរាល់សេចក្ដីស្នើ រាល់សេចក្ដីសម្រេច និងរាល់ក្បួនច្បាប់នានាត្រូវបានសម្រេចដោយមនុស្សពេញវ័យនិងកុមារជាសមូហភាព ការបែងចែកអំណាចមានលក្ខណៈតុល្យភាព និងសមធម៌ជាង។

គ្រូបង្រៀនលែងជាមនុស្សតែម្នាក់ដែលត្រួតពិនិត្យសិស្ស។ គ្រូបង្រៀនលែងជាអ្នកដែលមានសិទ្ធិក្នុងការឱ្យអ្នកផ្សេងបញ្ចេញមតិយោបល់ដូចមុនហើយ។

តួនាទីរបស់មនុស្សពេញវ័យមានលក្ខណៈមិនច្បាស់លាស់ ព្រោះថាតួនាទីនេះត្រូវបានបែងចែកចេញជាច្រើនសណ្ឋាន។ តាមជម្រើសនៃការតម្រង់ទិសស្វ័យគ្រប់គ្រង គ្រូបង្រៀនអាចជាកម្លាំងមួយនៃសំណើ ដូចសិស្សដែរ ឬក៏គ្រាន់តែជាអ្នកដែលឆ្លើយតបទៅនឹងការស្នើសុំរបស់សិស្សតែប៉ុណ្ណោះ។ដោយហេតុនេះហើយបានជាលោកLobrot មើលឃើញគ្រូបង្រៀនប្រៀបដូចជាមនុស្សម្នាក់ដែល «មិនត្រូវបានផាត់ចេញ ឬអវត្តមាន ដូចក្នុងគរុកោសល្យ «បណ្ដោយឱ្យធ្វើ» នោះទេ តែគ្រូបង្រៀនត្រូវធ្វើអន្តរាគមន៍ក្នុងក្របខ័ណ្ឌ និងទៅតាមវិធីសាស្ត្រកំណត់ដោយសិស្ស»។

លោក Lapassade មើលឃើញគ្រូប្រៀបដូចជា «អ្នកពិគ្រោះយោបល់សម្រាប់ក្រុម (លើបញ្ហាវិធីសាស្ត្រ ការរៀបចំ និងខ្លឹមសារ)។ គ្រូបង្រៀនមិនចូលរួមក្នុងការសម្រេចចិត្ត គ្រូបង្រៀនវិភាគដំណើរការនៃការសម្រេចចិត្តសកម្មភាពដែលលើកឡើង ក៏ដូចជាការងាររបស់ក្រុមក្នុងកម្រិតនៃការបែង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចែកការកិច្ច (កម្មវិធី)» (G. Lapassade, 1971 b)។

លោក Lapassade ប្រើប្រាស់ការសង្កេតរបស់លោកនៅ Gennevilliers ដើម្បីផ្ទេរគំរូស្វ័យគ្រប់គ្រងទៅក្នុងសាកលវិទ្យាល័យ Vincennes។ ក្នុងន័យនេះ កិច្ចប្រជុំប្រឹក្សាយោបល់ប្រចាំសប្តាហ៍ធ្វើឡើងដើម្បីប្រជុំរួមគ្រូទាំងអស់ក្នុងដេប៉ាតឺម៉ង់វិទ្យាសាស្ត្រអប់រំ នៅចន្លោះឆ្នាំ១៩៧០ និង១៩៨៣។ កិច្ចប្រជុំនេះក៏បើកទូលាយចំពោះនិស្សិតគ្រប់រូបដែរ។

## ជាតិពន្ធុសាស្ត្រសាលារៀន

លោក Lapassade យកតាមគំរូការងាររបស់ពន្ធុវិទូជាតិអង់គ្លេស Peter Woods និងសាលាសង្គមវិទ្យាឈីកាហ្គោដើម្បីអនុវត្តជាគំរូសង្គមខ្នាតតូចក្នុងពិភពសាលារៀន។

តាមរយៈជាតិពន្ធុសាស្ត្រនៃស្ថាប័នសាលារៀន លោក Lapassade សិក្សាពីការប្រជុំប្រឹក្សាយោបល់ដែលយើងបានឃើញនៅខាងដើម តែលោកក៏សិក្សាទៅលើវប្បធម៌យុវជន អវត្តមាន ការបោះបង់ការសិក្សា ឬក៏បាតុភូតផ្សេងៗដែលអាចកើតមានក្នុងថ្នាក់រៀនដូចជាភាពអនាធិបតេយ្យជាដើម។

ការសង្កេតដែលមានការចូលរួមគឺជាឧបករណ៍ពិសេសសម្រាប់វិធាននៃការស្រាវជ្រាវផ្នែកជាតិពន្ធុវិជ្ជា។

ពាក្យការសង្កេតដែលមានការចូលរួមមានន័យដូច្នេះថា «ការស្រាវជ្រាវមួយកំណត់ដោយខណៈនៃអន្តរកម្មសង្គមខ្លាំងក្លារវាងអ្នកស្រាវជ្រាវ និងក្រុមមុខសញ្ញាក្នុងមជ្ឈដ្ឋានរបស់ក្រុមមុខសញ្ញា។ នាអំឡុងពេលនោះទិន្នន័យត្រូវបានប្រមូលជាលក្ខណៈប្រព័ន្ធ[...]។ ការសង្កេតធ្វើឡើងជាលក្ខណៈបុគ្គលក្នុងជីវិតរបស់ក្រុមមុខសញ្ញា។ ក្រុមអ្នកស្រាវជ្រាវ និងក្រុមមុខសញ្ញាចែករំលែកបទពិសោធន៍រវាងគ្នានឹងគ្នា» (BOGDAN et TAYLOR, 1975) ។

គេច្រើនតែបែងចែកចេញជាបីទម្រង់នៃការសង្កេតដែលមានការចូល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រួមគឺ៖

ស្រមោល Péripherique ៖ ក្រុមអ្នកស្រាវជ្រាវមានបំណងស្ថិតនៅឆ្ងាយពីក្រុមមុខសញ្ញានៅជុំវិញ ដើម្បីអង្កេតមុខសញ្ញាដែលត្រូវអង្កេត។

សកម្ម៖ អ្នកស្រាវជ្រាវចូលរួមក្នុងការដើរតួនាទីអ្វីមួយ និងទទួលយកនូវមុខងារ ឬតួនាទីមួយនៅក្នុងក្រុម ឬក្នុងស្ថាប័នដែលគេសិក្សាស្រាវជ្រាវ។

ពេញលេញ៖ តាមរយៈលក្ខន្តិកៈរបស់ខ្លួន អ្នកស្រាវជ្រាវអាចនៅក្នុងស្ថានភាពសិក្សាស្រាវជ្រាវតែម្តង។

ក្នុងសៀវភៅរបស់លោកក្រោមចំណងជើងថា«សង្គ្រាម និងសន្តិភាពក្នុងថ្នាក់... ការប្រាសចាកវិន័យសាលា» (Guerre et paix dans la classe ... la déviance scolaire) លោក Lapassade ប្រើប្រាស់ជាតិពន្ធុសាស្ត្រដើម្បីសិក្សាអាកប្បកិរិយាផ្សេងៗគ្នានៅក្នុងសង្គមរបស់សិស្ស។ លោកកត់សម្គាល់ឃើញថាការមិនគោរពវិន័យសាលារៀនមានការកើនឡើង និងមានការប្រែប្រួល។ ការមិនគោរពវិន័យនេះគឺផ្សារភ្ជាប់ទៅនឹងការកើនឡើងនៃអាយុសម្រាប់ការអប់រំកាតព្វកិច្ចពី ១៤ឆ្នាំ ទៅ ១៦ឆ្នាំ។

ប្រឈមនឹងកំណើនហិង្សានេះ គ្រូបង្រៀនច្រើនតែស្ថិតនៅក្នុងយុទ្ធសាស្ត្រក្នុងការទ្រាំទ្រនឹងស្ថានការណ៍ជាជាងការបង្រៀន។ ការសង្កេតដោយមានការចូលរួមរបស់លោកធ្វើឱ្យគាត់អាចកំណត់ភាពអនាធិបតេយ្យចេញជាបីប្រភេទ៖

ភាពអនាធិបតេយ្យប្រពៃណី៖ កើតទៅលើគ្រូវង់ព្រោះដោយសារខ្វះបទពិសោធន៍ ដោយសារលក្ខន្តិកៈ ឬដោយអត្តសញ្ញាណរបស់ពួកគាត់។

ភាពអនាធិបតេយ្យបែបកាច់កុង (polémique ou anomique) ៖ មិនបដិសេធបទបញ្ជារបស់ស្ថាប័ននោះទេ តែព្យាយាមទាញយកប្រយោជន៍ពីភាពខ្វះចន្លោះ។

ភាពអនាធិបតេយ្យរ៉ាំរ៉ៃ Le chahut endémique ៖ ត្រូវបានកំណត់ដោយវត្តមាននៃការវាយប្រហារសំដៅគ្រូបង្រៀន។ ភាពអនាធិបតេយ្យដែលកើត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*មានសឹងតែគ្រប់ពេលនេះកើតឡើងនៅត្រឹះស្ថានសិក្សាជារួមតែម្តង។ «ខ្ញុំឱ្យឈ្មោះថាភាពអនាធិបតេយ្យកុំរើផល់ទម្រង់នៃភាពគ្មានសណ្តាប់ធ្នាប់ដែលមានលក្ខណៈជាការរកាំងសឹងតែគ្រប់ពេល គ្រប់វេលាកិច្ចសន្ទនានៅក្នុងថ្នាក់រៀន»។*

## គំនិតគួរពិចារណា

*ស្វ័យគ្រប់គ្រងគឺជាគរុកោសល្យមានសារៈប្រយោជន៍មួយសម្រាប់សិស្សគ្រប់រូប មានន័យថាមិនត្រឹមតែសម្រាប់សិស្សដែលរៀនយឺតនោះទេ បើទោះបីជាស្ថាបនិកនៃគរុកោសល្យនេះបានធ្វើការជកពិសោធន៍ជាមួយតែសិស្សរៀនយឺតនៅក្នុងសាលាបឋមសិក្សាក៏ដោយចុះ។*

*តាមរយៈគ្រូបឋមសិក្សាផ្ទៃក្នុង សិស្សអាចបញ្ចេញមតិយោបល់ប្រកាន់យកនូវសិទ្ធិ អំណាចមួយចំនួន សង្កេត វិភាគ ជជែកពិភាក្សា ឬក៏ផ្តល់នូវអំណះអំណាងផ្សេងៗដើម្បីការពារគំនិតរបស់ខ្លួន។ តែ តើគ្រប់គ្រាន់ទេ ដែលត្រឹមតែផ្តល់ដល់កុមារនូវគំនិតផ្តួចផ្តើមក្នុងការសិក្សារៀនសូត្រដើម្បីឱ្យគេអាចអនុវត្តដោយខ្លួនឯងនោះ? ពិតជាមិនគ្រប់គ្រាន់នោះទេ ហើយក៏មិនអាចបានដែរក្នុងការផ្តល់ឱ្យពួកគេនូវបច្ចេកវិទ្យាថ្មីៗដើម្បីជំនួយដល់ការរៀនសូត្រនោះ។ ក្នុងន័យនេះ វាចាំបាច់ណាស់ដែលត្រូវមានកិច្ចអន្តរាគមន៍របស់គ្រូបង្រៀនដើម្បីអភិវឌ្ឍឥរិយាបថ«ក្នុងក្រុម»។«គោលដៅចម្បងគឺមិនមែនឱ្យសិស្សទទួលចំណេះដឹងបែបនេះ ឬបែបនោះ នោះទេ តែគឺធ្វើឱ្យគេមានភាពចាប់អារម្មណ៍ពិតប្រាកដផ្នែកបញ្ហា និងស្មារតីតាមរយៈចំណាប់អារម្មណ៍ដែលមានស្រាប់របស់ពួកគេ ដើម្បីឱ្យបញ្ញាស្មារតីទាំងនោះអាចផ្តល់ឱ្យគេនៅពេលក្រោយនូវគោលវិធីសមស្របសម្រាប់គេក្នុងការទទួលយកចំណេះដឹងទាំងនោះវិញ»* (M. Lobrot, 1966)។ *ក្នុងន័យនេះ គ្រូបង្រៀនមានតួនាទីប្រែប្រួល ហើយស្វ័យគ្រប់គ្រងតម្រូវឱ្យសិស្សក្នុងការអភិវឌ្ឍគុណតម្លៃមនុស្សជាតិមួយចំនួន ដូចជាការយល់ចិត្តដើម្បីបង្កើតទំនាក់ទំនង*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គរុកោសល្យ។

ការអនុវត្តស្វ័យគ្រប់គ្រងគឺជាគរុកោសល្យនៃសេរីភាព។ មានន័យថា មិនមែនជាសេរីភាពក្នុងការធ្វើអ្វីស្រេចតែចិត្ត គរុកោសល្យធូរលុង ការបណ្តោយឱ្យធ្វើ ឬក៏ធ្វើអ្វីធ្វើទៅនោះទេ តែជាគរុកោសល្យដែលម្នាក់ៗអាចអភិវឌ្ឍ និងរៀនសូត្រនូវអ្វីដែលខ្លួនចង់រៀន ក្នុងអំឡុងពេលស្វ័យគ្រប់គ្រង។ ក្នុងគរុកោសល្យនៃជម្រើសសេរី និងអាជ្ញាកណ្តាលសេរី libre-arbitre កុមារក៏អាចអភិវឌ្ឍចំណង់ចំណូលចិត្តរបស់គេពិតប្រាកដដើម្បីធ្វើជកពិសោធន៍ផងដែរ។ រៀនក៏ក្លាយទៅជាភាពរីករាយពិតប្រាកដនៅពេលកុមារចូលរួមក្នុងសកម្មភាពជ្រើសរើសដោយសេរី។

លោក Georges Lapassade ជឿជាក់ទៅលើលទ្ធភាពក្នុងការផ្លាស់ប្តូរសង្គមទាំងមូល។ ស្វ័យគ្រប់គ្រងគរុកោសល្យគឺជាសមាសធាតុដែលអាចនាំទៅរកការផ្លាស់ប្តូរ។ គឺជាគរុកោសល្យដែលបង្រៀនសិស្សដោយផ្តោតលើធម្មជាតិរបស់កុមារ ដើម្បីនាំគេទៅឱ្យបានឆ្ងាយដោយគោរពតាមចង្វាក់នៃការសិក្សារបស់គេ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ២

# ទ្រឹស្តីនៃការអប់រំ

## ២.១. តួនាទីនៃការអប់រំក្នុងការអភិវឌ្ឍជាតិ

*ការអប់រំត្រូវតែឆ្លើយតបនឹងតម្រូវការនៃការផ្លាស់ប្តូរសេដ្ឋកិច្ច* (Fägerlind និង Saha, ១៩៨៩)។ *ប្រព័ន្ធអប់រំជាតិរួមមានធាតុគន្លឹះចំនួន៣៖ មគ្គុទ្ទេសក៍នយោបាយ សន្ទិទានសេដ្ឋកិច្ច និងយន្តការអប់រំ* (Adamson et al.,២០១៦)។

Adamson et al., (២០១៦) *បានចង្អុលបង្ហាញជម្រើសគោលនយោបាយចំនួន ២ ដល់អ្នកសម្រេចចិត្តផ្នែកគោលនយោបាយ៖*

(១) *គោលនយោបាយវិនិយោគសាធារណៈ៖ ផ្តោតលើកម្មសិទ្ធិសាធារណៈ ការទទួលខុសត្រូវសាធារណៈ សមធម៌ និងការសម្រេចចិត្តប្រជាធិបតេយ្យ និង*

(២) *គោលនយោបាយសេរីនិយមថ្មី៖ ផ្តោតលើឯកជនភាវូបនីយកម្ម អនិយតកម្ម វិមជ្ឈការ និងសេរីភាវូបនីយកម្ម។*

*ការអប់រំត្រូវឆ្លើយតបទៅនឹងគោលដៅរបស់ប្រទេស នៅពេលដែលប្រព័ន្ធអប់រំត្រូវឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ច ហើយកំណត់គោលដៅជាមគ្គុទ្ទេសក៍នៃការអភិវឌ្ឍ។ ការវិនិយោគសាធារណៈដែលឆ្លើយតបនឹងសន្ទិទានសេដ្ឋកិច្ចផ្តោតលើភាពទទួលបានជាសកលនៃការអប់រំ ដោយរៀបចំប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការធានាសមធម៌។ ផ្ទុយទៅវិញ គោលនយោបាយសេរីនិយមថ្មីមានគោល*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បំណាស់ផ្តោះទៅរកប្រសិទ្ធភាព ការប្រកួតប្រជែង និងគុណភាព។

ការប៉ុនប៉ងកែទម្រង់ប្រព័ន្ធអប់រំបានធ្វើឡើងទាំងក្នុងសង្គមឧស្សាហកម្មកំពុងអភិវឌ្ឍ និងសង្គមឧស្សាហកម្មអភិវឌ្ឍជឿនលឿន។ ក្នុងអំឡុងទសវត្ស ១៩៦០ គេបានបង្កើតទ្រឹស្តីធនធានមនុស្សដែលជាក្របខ័ណ្ឌទ្រឹស្តីដែលភ្ជាប់ការអប់រំទៅនឹងការអភិវឌ្ឍ (Schultz, ១៩៦១, Becker,១៩៦០, យោងតាម Fägerlind និង Saha, ១៩៨៩)។ លក្ខខណ្ឌពីរដែលមិនអាចខ្វះបានសម្រាប់គ្រប់ប្រទេសទាំងអស់ ក្នុងការអភិវឌ្ឍជាតិ គឺ៖ (១) ធ្វើឱ្យប្រសើរ និងប្រសិទ្ធភាពនៃបច្ចេកវិទ្យា និង(២) ការប្រើប្រាស់បច្ចេកវិទ្យា។ ការអប់រំផ្លូវការផ្តល់ជំនាញ និងលើកទឹកចិត្តសម្រាប់ផលិតភាព (Fägerlind and Saha, ១៩៨៩)។ កំណែទម្រង់គោលនយោបាយធនធានមនុស្សត្រូវផ្តោតលើ៖ (១) ការបង្កើនផលិតភាពពលកម្មតាមរយៈការផ្តល់ការអប់រំ (២)ការពង្រឹងគុណភាពចំនួនឆ្នាំសិក្សាក្នុងសាលា និង (៣) ការបង្កើនការទទួលបានពីសង្គមតាមរយៈឥទ្ធិពលជាវិជ្ជមាននៃការអប់រំ។

ក្នុងអំឡុងទសវត្ស ១៩៧០ ក្រមខ័ណ្ឌទ្រឹស្តីមួយទៀត ដែលស្គាល់ថាជាទ្រឹស្តីនៃកំណើនសេដ្ឋកិច្ច បានក្លាយជាមនោគមវិជ្ជាដ៏សំខាន់មួយ។ លោក Rostow (១៩៧១ យោងដោយ Fägerlind និង Saha, ១៩៨៩) គិតថាការអប់រំជាកត្តាដ៏សំខាន់ក្នុងការទទួលបាន និងទាញយកផលប្រយោជន៍ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ មានយន្តការយ៉ាងហោចណាស់ចំនួន៣ដែលធ្វើឱ្យការអប់រំអាចមានឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ច (Hanushek និង Woessmann ២០០៧)៖ (១) ការអប់រំបង្កើនធនធានមនុស្សដែលជាកម្លាំងពលកម្ម ដែលនឹងបង្កើនផលិតភាពកម្លាំងពលកម្ម សម្រាប់រក្សាកម្រិតលំនឹងកម្រិតខ្ពស់នៃទិន្នផល (ដូចនឹងទ្រឹស្តីកំណើនបុរាណថ្មី ដែលលើកឡើងដោយ Mankiv, Romer និង Weil, ១៩៩២), (២) ការអប់រំអាចបង្កើនសមត្ថភាពច្នៃប្រឌិតសេដ្ឋកិច្ច ព្រមទាំងចំណេះដឹងថ្មីស្តីពីបច្ចេកវិទ្យា ផលិតផល និងដំណើរការថ្មី ដែលជំរុញកំណើន (ដូចនឹងទ្រឹស្តីកំណើនពីខាងក្នុងរបស់

Lucas (១៩៨៨) និង Romer (១៩៩០)), និង (៣) ការអប់រំអាចនឹងជួយសម្រួលដល់ការផ្លាស់ប្តូរចំណេះដឹងដែលត្រូវការដើម្បីយល់ និងដាក់ឱ្យដំណើរការព័ត៌មានថ្មី និងអនុវត្តបច្ចេកវិទ្យាថ្មីឱ្យទទួលបានជោគជ័យ ដែលខុសពីបច្ចេកវិទ្យាផ្សេងទៀត ដែលជំរុញកំណើនសេដ្ឋកិច្ច (Benhabib និង Spiegel, ១៩៩៤)។

នៅអំឡុងទសវត្ស១៩៦០និង១៩៧០មនោគមវិជ្ជាល្បីល្បាញនៃរដ្ឋមានប្រព័ន្ធសុខមាលភាព (Welfare State) បានផ្លាស់ប្តូររបៀបវារៈកំណែទម្រង់ការអប់រំក្នុងអឺរ៉ុបឆ្ពោះទៅរកគោលដៅនៃការបង្កើតរដ្ឋដែលមានប្រព័ន្ធសុខមាលភាព។ យុទ្ធសាស្ត្រកំណែទម្រង់ផ្តោតលើការកសាងគុណភាពកម្រិតខ្ពស់ និងស្មើភាពក្នុងការអប់រំ ដោយកសាងប្រព័ន្ធសាលាគ្រប់ជ្រុងជ្រោយដែលទទួលមូនិធិរដ្ឋ ដោយគ្មានការរើសអើង ឬការបែងចែកសមត្ថភាពសិស្សអំឡុងពេលអប់រំមូលដ្ឋាន រហូតដល់អាយុ ១៦ឆ្នាំ។ មជ្ឈការត្រូវបានចាត់ទុកជាមធ្យោបាយ ក្នុងការអនុវត្តកំណែទម្រង់សាលាគ្រប់ជ្រុងជ្រោយដើម្បីជំរុញការទទួលបានសមធម៌ (Antikainen និង Pitkanen, ២០១៤)។ ប្រព័ន្ធអប់រំមជ្ឈការអាចឱ្យរដ្ឋគ្រប់គ្រងគ្រងការអប់រំគ្រប់រូបភាពចាប់ពីមុខវិជ្ជាដែលត្រូវសិក្សា រហូតដល់ធនធានសម្រាប់គ្រឹះស្ថានសិក្សា។ គំនិតសមធម៌មិនមានន័យថាសាលារៀនគួរទទួលបានធនធានស្មើគ្នានោះទេ។ ជាងនេះទៅទៀត គំនិតនេះមានន័យថាសិស្សគ្រប់រូបត្រូវទទួលបានឱកាសអប់រំស្មើគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ ឱកាសស្មើគ្នាមិនអាចធានាស្តង់ដាអប់រំស្មើគ្នានោះទេ ហើយភាពខុសគ្នានៃគុណភាពអប់រំនឹងលេចចេញមក ដោយជំរុញឱ្យគណបក្សនយោបាយ ចាប់ផ្តើមកំណែទម្រង់ការអប់រំសេរីនិយមថ្មីក្នុងទសវត្ស ១៩៨០ (Francia, ២០១៤)។

ការកើនឡើងនៃវិសមភាព និងការចាប់ផ្តើមនៃសកលភាវូបនីយកម្មជំរុញឱ្យមានកំណែទម្រង់អប់រំក្នុងអំឡុងទសវត្ស ១៩៨០ ដែលមានគោលបំណងអនុវត្តគោលនយោបាយសេរីនិយមថ្មី យោងទៅតាមទីផ្សារអប់រំ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណែទម្រង់ការអប់រំសេរីនិយមថ្មីមានគោលបំណងឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។ កំណែទម្រង់ការអប់រំសេរីនិយមថ្មី ផ្តោតទៅលើគុណភាពប្រសិទ្ធភាព ឯកទេស និងការវាយតម្លៃស្តង់ដា ការជ្រើសរើសត្រឹមត្រូវ ពិពិធកម្មស្ថាប័នវិមជ្ឈការ និងឯកជននីយកម្ម។ សកលភាវូបនីយកម្មមានឥទ្ធិពលយ៉ាងសំខាន់លើការអប់រំក្នុងប្រទេសជាច្រើន ដូចជាការកាត់បន្ថយ សេវាដែល ផ្តល់ដោយរដ្ឋមានសុខមាលភាព (Hill, ២០០៣)។ ទោះបីជាផលប្រយោជន៍ជាតិក្នុងការអប់រំនៅតែមានក៏ដោយ រដ្ឋដើរតួនាទីតិចតួចណាស់ក្នុងផ្តល់សេវាអប់រំតាមគោលនយោបាយនេះ។

គោលនយោបាយសេរីនិយមថ្មីរួមមានវិមជ្ឈការ និងការអន្តរាគមន៍តិចតួចរបស់រដ្ឋ។ ក្នុងបរិបទនៃវត្តមានធនធានមិនស្មើគ្នា វិមជ្ឈការបានកាត់បន្ថយភាពស៊ីចង្វាក់គ្នានៃការអប់រំ ដែលបណ្តាលឱ្យមានភាពខុសគ្នាតាមតំបន់ ដូចជាការឧបត្ថម្ភសៀវភៅសិក្សា ការផ្តល់អាហារូបករណ៍ និងការផ្តល់ហិរញ្ញវត្ថុដល់សាលារៀន។ ក្រុមសេរីនិយមថ្មី បានគិតថាការអប់រំគឺគ្រាន់តែគិតក្នុងន័យចង្អៀត នៅពេលវាប្រើប្រាស់ជាយន្តការសម្រាប់ផ្សព្វផ្សាយ «ជំនាញ» និង«ឱកាសរកការងារ» ហើយសាលារៀនដើរតួជារោងចក្រដែលផ្សារភ្ជាប់ជាមួយ "ចំណេះដឹងសេដ្ឋកិច្ច" ជាមួយធនធានមនុស្ស (Beltran, ២០១៤)។ គោលនយោបាយសេរីនិយមថ្មីនេះ ឈានទៅរកវិសមភាព ជាពិសេសបង្កើតកម្រិតខុសគ្នានៃគុណភាពអប់រំ។

ការអប់រំត្រូវបានចាត់ទុកជាការវិនិយោគមួយ។ការស្រាវជ្រាវដោយ Psacharopoulos (១៩៨៥)ផ្តោតទៅលើការទទួលបានមកវិញពីការអប់រំ និងបានបញ្ជាក់ពីមធ្យោបាយទទួលផលចំណេញពីធនធានមនុស្ស៖ (១) ផលចំណេញទទួលជាឯកជន និងសង្គមគឺមានកម្រិតខ្ពស់សម្រាប់ការអប់កម្រិតបឋមសិក្សា (២) ផលចំណេញជាឯកជនលើសពីផលចំណេញសង្គម ជាពិសេសនៅកម្រិតឧត្តមសិក្សា (៣) ផលចំណេញរួមចំពោះការវិនិយោគក្នុងការអប់រំគឺលើសពី ១០% នៃការចំណាយឱកាសមូលធន និង (៤) ផល

ចំណេញពីការអប់រំនៅក្នុងប្រទេសកំពុងអភិវឌ្ឍមានកម្រិតខ្ពស់ជាងផល ចំណេញពីការអប់រំនៅក្នុងប្រទេសអភិវឌ្ឍជឿនលឿន។ ផ្នែកមួយដ៏ធំនៃអក្សរសិល្ប៍ក្នុងការអប់រំបានបង្ហាញជាកស្តុតាងថា ការអប់រំបង្កើនផលិតភាពរបស់កម្មករ (ឧ. Mincer, ១៩៧៤; Psacharopoulos និង Ratrinos, ២០០៤; Hanushek និង Zhang, ២០០៩; Glewwe, Hanushek, Humpage និង Ravina, ២០១១)។ យើងអាចធ្វើសំយោគទ្រឹស្តីកំណែទម្រង់គោលនយោបាយធនធាន មនុស្សរបស់ Schultz (១៩៦១), Becker (១៩៦០), Psacharopoulos (១៩៨៥), Mincer (១៩៧៤), Psacharopoulos និង Patrinos (២០០៤), Hanushek និង Zhang (២០០៩) Glewwe, Hanushek, Humpage និង Ravina (២០១១) ដើម្បីសន្និដ្ឋានថាការអប់រំធ្វើឱ្យប្រសើរការជ្រើសរើសរបស់បុគ្គល និងប្រជាជនដែលមានការអប់រំបានផ្តល់នូវប្រភេទកម្លាំងពលកម្មចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍ។

ដើម្បីដោះស្រាយភាពខុសគ្នា នៃគុណភាពនិងភាពមិនស្មើគ្នានៃការអប់រំ ចលនានៃការអប់រំផ្អែកលើស្តង់ដាមួយបានលេចចេញក្នុងទសវត្ស ១៩៩០ ក្នុងសហរដ្ឋអាមេរិក។ ក្នុងអំឡុងទសវត្ស ២០០០ តំបន់ជាច្រើនក្នុងសហរដ្ឋអាមេរិក បានចាប់ផ្តើមកំណែទម្រង់ការអប់រំផ្អែកលើស្តង់ដា។ Nelso, Palonsky និង McCarthy (២០១២) បានផ្តល់ការវិភាគទូលំទូលាយនៃចលនាកំណែទម្រង់ការអប់រំផ្អែកលើស្តង់ដាសហរដ្ឋអាមេរិក។ ការបោះពុម្ពរបាយការណ៍ឆ្នាំ ១៩៨៣ A Nation at Risk ក្នុងហានិភ័យ គឺជាកត្តាលីករសម្រាប់ការអនុម័តច្បាប់ No Child Left Behind (NCLB)។ ការសិក្សានេះបង្ហាញថា ស្ថានភាពរបស់សហរដ្ឋអាមេរិកដែលខ្លាំងជាងប្រទេសឯទៀតក្នុងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម វិទ្យាសាស្ត្រ និងការច្នៃប្រឌិតបច្ចេកវិជ្ជាកំពុងដើរតាមក្រោយអ្នកប្រកួតប្រជែងជាច្រើន ពេញពិភពលោក (គណៈកម្មការជាតិស្តីពីឧត្តមភាពនៃការអប់រំ, ១៩៨៣)។ បញ្ហាជាច្រើនបានរកឃើញក្នុងសាលារួមមានការទទួលបានពិន្ទុទាបចំពោះស្តង់ដាតេស្ត និង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការប្រៀបធៀបជាអន្តរជាតិមានកម្រិតទាប។

អនុសាសន៍របស់របាយការណ៍សម្រាប់ការអប់រំជាតិ គឺមានដូចខាងក្រោម៖(១)ការអប់រំសម្រាប់សិស្សគ្រប់គ្នា និង(២)បង្កើនស្តង់ដាកាន់តែខ្ពស់ (Nelso et al, ២០១២)។ ច្បាប់ NCLB (២០០១) ត្រូវបានអនុម័ត ដើម្បីបង្កើតប្រព័ន្ធអប់រំកាន់មានការទទួលខុសត្រូវ និងរឹងមាំ។ រដ្ឋនីមួយៗនៅសហរដ្ឋអាមេរិកត្រូវបង្កើតស្តង់ដារបស់ខ្លួន សម្រាប់អ្វីដែលសិស្សគួរតែដឹងនៅគ្រប់កម្រិតដូចជា គណិតវិទ្យា ភាសាអង់គ្លេស សិល្បៈ និងវិទ្យាសាស្ត្រ។ រដ្ឋទាំងអស់ត្រូវតែគ្រប់គ្រងការវាយតម្លៃការសិក្សាក្នុងការអាន និងគណិតវិទ្យាចំពោះសិស្សថ្នាក់ទី៣ ដល់៥ ទី៦ដល់៧ និង ថ្នាក់ទី១០ដល់១២។ នីតិបញ្ញត្តិតម្រូវឱ្យសាលានីមួយៗ និងសាលានៅតាមស្រុក និងរដ្ឋ អាចសម្រេចបានសមិទ្ធផលប្រចាំឆ្នាំ ឆ្ពោះទៅរកស្តង់ដារដ្ឋ(NCLB, ២០០១)។ ចលនាស្តង់ដាត្រូវបានរៀបចំ ដើម្បីអាចឱ្យសិស្សគ្រប់រូបឈានដល់កម្រិតកាន់តែខ្ពស់នៃការលទ្ធផលសិក្សា(Tucker និង Codding, ១៩៩៨)។ ការគាំទ្រចលនាស្តង់ដាគឺផ្អែកលើការសន្មតថាបញ្ហាប្រធានបទដែលត្រូវសិក្សាក្នុងសាលា គឺមានសារៈសំខាន់។ ចំណេះដឹងរបស់បុគ្គលម្នាក់ៗនឹងកំណត់ពីភាពជោគជ័យឬបរាជ័យក្នុងសាលា ហើយវាអាចវង្វាស់ដ៏ធំនៃភាពជោគជ័យ ឬការទទួលបរាជ័យក្នុងជីវិត (Hirsch, ១៩៩៦)។ រដ្ឋត្រូវតែបង្កើតស្តង់ដាសមស្របមួយសម្រាប់វាស់ភាពជោគជ័យ ហើយសិស្សត្រូវតែបង្ហាញ ពីចំណេះដឹងតាមប្រធានបទ និងជំនាញសិក្សាដែលរៀបរាប់តាមកម្រិតក្នុងស្តង់ដា។

ការយកស្តង់ដាជាធំក្នុងការសិក្សា បានបដិសេធវិធីសាស្ត្រសិក្សាផ្សេងៗទៀត។ នៅពេលដែលសាលារៀនផ្តោតលើគោលដៅខ្លឹមសារមេរៀនការ សិក្សាដោយសេរី ដូចជាការគោរពខ្លួនឯង ការស្វែងរកបច្ចេកទេស និងយុទ្ធសាស្ត្រសិក្សាបែបសហការ សិស្សគ្រប់រូបនឹងរងគ្រោះដោយសារតែពួកគេសិក្សាខ្លឹមសារមេរៀនបានតិចតួច (Hirsch, ១៩៩៦; Bennett et al., ១៩៩៧)។ មធ្យោបាយណាមួយឆ្ពោះទៅរកការសិក្សា ដែលបញ្ជាក់ពីដំណើរការកំណត់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពីអនាគតរបស់ក្មេង ដោយមិនឱ្យពួកគេទទួលបានមូលធនវ័យឆ្លាត ឱ.ការចាប់យកចំណេះដឹងត្រូវធ្វើឱ្យបានល្អទាំងក្នុងសាលា និងជីវិត។

សរុបមក ទ្រឹស្តីកំណែទម្រង់ការអប់រំបានបង្កើតឡើង ដើម្បីកែលម្អលទ្ធផលសិក្សា ដើម្បីឈានទៅរកតម្រូវការនៃការផ្លាស់ប្តូររបស់ប្រទេសនៅដំណាក់កាលខុសៗនៃការអភិវឌ្ឍសេដ្ឋកិច្ច។

## ២.២. តួនាទីនៃបំណិនចំណេះដឹង និងបំណិនទន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

ការស្រាវជ្រាវជំធំមួយបានចង្អុលបង្ហាញថា ជំនាញពុទ្ធិ (cognitive skills) និងជំនាញមិនមែនពុទ្ធិ ឬ ជំនាញទន់ (non-cognitive skills) មានសារៈសំខាន់ខ្លាំងណាស់ក្នុងដំណើរការអភិវឌ្ឍ។ លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា ការអប់រំដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើតពលករមានជំនាញ ហើយប្រជាជនមានការអប់រំកាន់តែមានផលិតភាពខ្ពស់ ដោយសារតែការអប់រំបង្កើតតម្លៃទាន់សម័យ អាកប្បកិរិយា និងឥរិយាបថសម្រាប់សេដ្ឋកិច្ចឧស្សាហកម្មទំនើប។ ទោះបីជាយ៉ាងណាក៏ដោយ Hanushek និង Woessmann (២០០៨) យល់ឃើញថា ការពង្រីកភាពជោគជ័យនៃការអប់រំមិនបានធានាលក្ខខណ្ឌសេដ្ឋកិច្ចឱ្យប្រសើរនោះទេ។ ពួកគេរក្សានូវសមត្ថភាពនិងបំណិនចំណេះដឹងរបស់ប្រជាជន - ជាជាងសម្រេចឱ្យបានការអប់រំដ៏កម្រ - គឺមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងប្រាក់ចំណូលរបស់បុគ្គលនីមួយៗ ការបែងចែកប្រាក់ចំណូល និងកំណើនសេដ្ឋកិច្ច។ ដូចនេះ បំណិនចំណេះដឹង និងបំណិនទន់ទាក់ទងគ្នានឹងភាពឆ្លាតវៃ និងសមត្ថភាពនៃការដោះស្រាយបញ្ហា (Falach et al., ២០១២)។ ប្រាកដណាស់ គោលបំណងនៃការអប់រំគឺដើម្បីអភិវឌ្ឍមនុស្សមានចំណេះដឹងល្អ និង ការចូលរួមរបស់មនុស្សជាតិ។ ជារួម តម្រូវការបំណិនចំណេះដឹង គឺជាគោលបំណងសំខាន់មួយនៃការអប់រំ។ ភាគច្រើននៃការវាយតម្លៃកំណែទម្រង់សាលាបានគូសបញ្ជាក់ពីការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កើនឡើងនៃកំណែទម្រង់ តាមរយៈការវាស់សមត្ថភាពជោគជ័យស្តង់ដា នៃការធ្វើតេស្ត (Heckman និង Rubinstein, ២០០១)។

ជំនាញពុទ្ធិ និងមិនមែនពុទ្ធិ (Cognitive and non-cognitive skills) ការអប់រំដើរតួនាទីសំខាន់ក្នុងការបង្កើតកម្លាំងជំនាញ។ ប្រជាជនដែលទទួលបានការអប់រំ គឺមានផលិតភាពខ្ពស់ ដោយសារការអប់រំបង្កើតបានជាតម្លៃទាន់សម័យ អាកប្បកិរិយា និងឥរិយាបថសម្រាប់សេដ្ឋកិច្ចឧស្សាហកម្មទំនើប។ Hanushek និង Woessmann (២០០៨) យល់ឃើញថា ការពង្រីកភាពជោគជ័យអប់រំ មិនអាចជានាលក្ខខណ្ឌសេដ្ឋកិច្ចឱ្យប្រសើរនោះទេ។ ការពិភាក្សាគោលនយោបាយកាន់តែច្រើនឡើងបានផ្តោតលើគុណភាពអប់រំ៖ (១) ជំនាញពុទ្ធិត្រូវបានចាត់ទុកជា «ជំនាញបច្ចេកទេស» នៃសមត្ថ-ភាពយល់ដឹងដោយញាណក្នុងផ្នែកអក្សរសាស្ត្រ និងតួលេខ (២) ជំនាញមិនមែនពុទ្ធិក៏មានសារៈសំខាន់សម្រាប់ផលិភាព និងលទ្ធផលសង្គម និង (៣) ការសិក្សាពេញមួយជីវិត។ ការសិក្សាចាប់ផ្តើមពីកុមារភាពមុន នឹងការអប់រំផ្លូវការចាប់ផ្តើម និងបន្តពេញមួយជីវិត។

ទោះបីជាយ៉ាងណាក៏ដោយការសិក្សាបច្ចុប្បន្នមួយចំនួនបង្ហាញថា ជំនាញពុទ្ធិមានសារៈសំខាន់សម្រាប់ផលិតភាព និងលទ្ធផលក្នុងសង្គម។ ដោយផ្អែកលើការសិក្សានាពេលបច្ចុប្បន្ន ទាក់ទងនឹងការអប់រំ និងបណ្តុះបណ្តាលHeckman(១៩៩៩) បានចង្អុលបង្ហាញពីការយល់ខុសជាមូលដ្ឋានអំពីមធ្យោបាយជំនាញដែលមានប្រយោជន៍ក្នុងសង្គមរបស់បុគ្គលម្នាក់ៗត្រូវបានបង្កើតមក។ ឧទាហរណ៍ជាច្រើន អាចបញ្ជាក់ថា មនុស្សមានIQខ្ពស់ដែលបរាជ័យក្នុងជីវិត គឺដោយសារពួកគេខ្វះខាតវិន័យចំពោះខ្លួនឯង និងមនុស្សមាន IQ ទាបដែលជោគជ័យដោយគុណធម៌នៃការតស៊ូ ក្តីសង្ឃឹម និងគោលការណ៍ផ្ទាល់ខ្លួន (Heckman និង Rubinstein ២០០១ និង Heckman et al. ២០១៣)។ Jencks (១៩៧៩) រកឃើញថាទម្លាប់បុគ្គលដូចជា ភាពជាអ្នកដឹកនាំ ឧស្សាហ៍ព្យាយាម និងការខិតខំជាបន្តបន្ទាប់ មានឥទ្ធិពលទាក់ទង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ផ្តោតទៅលើចំណូលបុគ្គល និងភាពជោគជ័ក្នុងការអប់រំ ដោយផ្អែកទៅលើចរិតលក្ខណៈរបស់គ្រួសារនិងជំនាញយល់ដឹងដោយញាណដែលមាន។

យោងតាមការស្រាវជ្រាវថ្មីផ្នែកចិត្តវិទ្យា និងជំនាញពុទ្ធិ Heckman (២០០០) សង្កត់ទៅលើសារៈសំខាន់នៃការបង្កើតជំនាញអំឡុងពេលឆ្នាំសិក្សាដំបូងនៅពេលដែលសមត្ថភាពរបស់មនុស្ស និងការលើកទឹកចិត្តគឺត្រូវបានកំណត់ដោយគ្រួសារ និងបរិស្ថាន មិនមែនស្ថាប័ន។ ជំនាញដែលបង្កើតក្នុងពេលវ័យកុមារ និងមុនពេលចូលសាលារៀន អាចក្លាយជាភាពជោគជ័យ និងបរាជ័យក្នុងសាលារៀន និងបន្ទាប់ពីបញ្ចប់ការសិក្សាក្នុងសាលារៀន។ ចំពោះហេតុផលនេះ គ្រួសារ និងបរិស្ថានដើរតួយ៉ាងសំខាន់ក្នុងការបង្កើតជំនាញនៅដំណាក់កាលដំបូង។ ភាគច្រើននៃប្រសិទ្ធភាពនៃអន្តរាគមន៍នៅវ័យកុមារអាចរួមចំណែកដល់ការបង្កើតជំនាញពុទ្ធិ និងបង្កើតជាការលើកទឹកចិត្តនៅក្នុងជីវិត (Heckman, ២០០០)។ ការសិក្សាបន្តបន្ទាប់ពីការសិក្សានៅសាលារៀន គឺត្រូវបានស្គាល់ថាជាការសិក្សាដោយការអនុវត្ត និងការអប់រំនៅកន្លែងការងារ។ ការសិក្សាក្រោយបញ្ចប់ការសិក្សានៅសាលារួមចំណែកយ៉ាងច្រើនចាប់ពីមួយភាគបី រហូតដល់ពាក់កណ្តាលនៃការបង្កើតជំនាញក្នុងសេដ្ឋកិច្ចទំនើប (Heckman, Lochner និង Taber ១៩៩៨)។

ពេលដែលប្រព័ន្ធអប់រំបរាជ័យក្នុងការបន្សុីគ្នានៃទីផ្សារការងារ គម្លាតជំនាញបានលេចឡើង។ គម្លាតជំនាញ ឬគម្លាតរវាងជំនាញរបស់អ្នករៀនចប់ និងជំនាញដែលទីផ្សារការងារត្រូវការធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។ គម្លាតជំនាញ គឺជាលក្ខណៈនៃទិដ្ឋភាពចម្រុះ (Gardner, ១៩៨៣, Guvenen et al., ២០១៥)។ គម្លាតនេះគឺផ្អែកលើភាពខុសគ្នារវាងជំនាញដែលត្រូវការដោយទីផ្សារការងារ (សម្រាប់បំពេញការដែលផលិតជាផលិតផល) និងសមត្ថភាពរបស់ពលករដែលបានរៀនចប់។

ការលេចចេញនៃគម្លាតជំនាញ គឺជាលទ្ធផលនៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងនយោបាយយ៉ាងឆាប់រហ័ស ដោយសារប្រព័ន្ធអប់រំមិន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាចតាមទាន់ការផ្លាស់ប្តូរនេះ។គម្លាតជំនាញសំដៅទៅលើបរាជ័យនៃការផ្គត់ផ្គង់ជំនាញឱ្យត្រូវទីផតម្រូវការជំនាញ (Gambin et al., ២០១៦; Gardner, ១៩៨៣; Guvenen et al., ២០១៥; World Bank ២០១០)។ គម្លាតជំនាញអាចមានបច្ច័យដូចតទៅ៖ (១) បន្សុីគ្នាសាលាទៅទីផ្សារការងារគឺមានការលំបាកដោយសារភាពខុសគ្នានៃទស្សនវិជ្ជាផ្នែកអប់រំ ព្រមទាំងការយល់ឃើញខុសគ្នារបស់ឪពុកម្តាយនិងអ្នករៀបចំផែនការជាតិ (២) គម្លាតជំនាញអាចធ្វើឱ្យកំណើនសេដ្ឋកិច្ចធ្លាក់ចុះ និង (៣) កំណែទម្រង់ការអប់រំតម្រូវឱ្យកែលម្អគុណភាពអប់រំ និងដោះស្រាយគម្លាតជំនាញនេះ។

ប្រទេសអភិវឌ្ឍភាគច្រើនសម្រេចបានវឌ្ឍនភាពគួរឱ្យកោតសរសើរក្នុងវិស័យអប់រំ (អត្រាចូលរៀន ការគង់វង្ស និងអត្រាបញ្ចប់ការសិក្សា)។ ក៏ប៉ុន្តែប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍ ការសិក្សានៅមានកម្រិតទាបនៅឡើយ ហើយកំណើនមិនបានឆាប់រហ័សនោះឡើយ។ ក្នុងប្រទេសមួយចំនួនស្ថានភាពក្នុងវិស័យអប់រំកាន់តែដុនដាបទៅ។ ទោះបីជាយ៉ាងណាក៏ដោយក្នុងប្រទេសខ្លះទៀត ដូចជា ប្រទេសវៀតណាម លទ្ធផលសិក្សាមានកម្រិតស្មើ ឬលើសប្រទេស អភិវឌ្ឍ OECD ទៅទៀត (Pritchett, ២០០៥)។ គណៈកម្មការអប់រំ (២០១៦) គិតថាត្រឹមឆ្នាំ ២០៣០ ជាងពាក់កណ្តាលនៃប្រជាជនវ័យក្មេងជំនាន់ថ្មី នឹងមិនមានអនាគតល្អឡើយ ដោយសារពួកគេគ្មានជំនាញដែលទីផ្សារការងារដែលផ្លាស់ប្តូរយ៉ាងលឿនត្រូវការ។ គណៈកម្មការគិតថាការកែលម្អក្នុងការរៀបចំ និងការផ្តល់សេវាអប់រំប្រកបដោយជោគជ័យប្រទេសទាំងនោះត្រូវពង្រឹងប្រព័ន្ធអប់រំទាំងមូល ហើយជាពិសេសត្រូវវិនិយោគទៅលើស្ថាប័នណាដែលអាចសម្រេចបានលទ្ធផលល្អ។ ដូចនេះកំណែទម្រង់ការគ្រប់គ្រងការអប់រំជាប្រព័ន្ធ គឺមានសារៈសំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដើម្បីធានាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព។ ដើម្បីពង្រឹងប្រព័ន្ធអប់រំ ដែលមានលទ្ធផលរឹងមាំ ទាមទារការធ្វើឱ្យស៊ីគ្នារវាងគោលនយោបាយ និងចំណាយថវិកា ព្រមទាំងទាមទារនូវការកំណត់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មាត់គោលនយោបាយច្បាស់លាស់ ដែលមានទិសដៅឆ្ពោះទៅរកការអនុវត្តការជាទាប្រសិទ្ធភាពរដ្ឋបាល និងគណនេយ្យភាព។

ដើម្បីទាញយកផលប្រយោជន៍ពីឱកាស ដែលបង្កើតឡើងដោយបដិវត្តន៍ឧស្សាហកម្មទី៤ប្រទេសកំពុងអភិវឌ្ឍត្រូវចាប់ផ្តើមធ្វើកំណែទម្រង់វិស័យអប់រំ ក្នុងគោលបំណងកែលម្អគុណភាពអប់រំ និងដោះស្រាយគម្លាតជំនាញ។កម្លាំងពលកម្មដែលមានជំនាញទាបនឹងបង្កើតការលំបាកសម្រាប់និយោជក ក្នុងការទទួលយកបច្ចេកវិទ្យាផលិតកម្មទំនើបថ្មីៗ (World Bank, ២០១០)។ លើសពីនេះទៅទៀត មិនមែនការខ្វះមូលធនទេ តែគឺកង្វះខាតនៃកម្លាំងពលកម្មដែលមានជំនាញ ដែលជាឧបសគ្គចម្បងសម្រាប់ការច្នៃប្រឌិត ភាពប្រកួតប្រជែង និងកំណើនសេដ្ឋកិច្ច (Schwab ២០១៦)។ ដូចនេះប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍត្រូវចាប់ផ្តើមកំណែទម្រង់ការគ្រប់គ្រងការអប់រំ ក្នុងគោលដៅធ្វើឱ្យការអប់រំឆ្លើយតបនឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសេដ្ឋកិច្ច។

## ២.៣. ចំណេះដឹងក្នុងយុគសម័យឌីជីថល

### ២.៣.១. ការផ្លាស់ប្តូរនិយមន័យនៃចំណេះដឹង

នៅក្នុងយុគសម័យសតវត្សទី២១ បច្ចេកវិទ្យាទំនើបៗបានផ្លាស់ប្តូរនិយមន័យ និងតម្រូវការចំណេះដឹងសម្រាប់ការអភិវឌ្ឍប្រទេសជាតិ (Bruce and Others, 2013; Sangob Intaramanee, 2019)។ នៅសតវត្សទី២០ អ្នកចេះ គឺជាអ្នកដឹងពីព្រឹត្តិការណ៍ជាច្រើន ហើយការសិក្សាទាមទារឱ្យសិស្សនិស្សិតត្រូវតែទន្ទេញឱ្យចាំមាត់។ ក៏ប៉ុន្តែការវិវឌ្ឍបច្ចេកវិទ្យាយ៉ាងលឿន ជាពិសេសការបង្កើតនូវ Internet និងគ្រឿងម៉ាស៊ីនដែលស្រាវជ្រាវរកព័ត៌មាន (Google search engine) បានធ្វើឱ្យនិយមន័យនៃចំណេះដឹងមានការផ្លាស់ប្តូរ។ តើមានអ្នកណាដែលដឹងរឿងនិងព័ត៌មានច្រើនជាង Google ទៀតនោះ។ ដូច្នេះអ្នកចេះមិនមែនត្រឹមតែអ្នកដឹងរឿងច្រើនទេ។

និយមន័យថ្មីនៃចំណេះដឹងមានដូចតទៅ៖ (១) ចំណេះដឹងដែលផ្សារភ្ជាប់គ្នាកម្រិតខ្ពស់ (Hyperlinked) ដើម្បីឱ្យគេអាចយកទៅប្រើការបានមានប្រយោជន៍ (២) ចំណេះដឹង ដែលដែលមានសមាសភាពច្រើន (Multi-dimensional) ដោយសារតែវិទ្យាសាស្ត្រមានការផ្សារភ្ជាប់គ្នា (៣) ចំណេះដឹងដែលបង្កើតឡើងដោយសិស្សខ្លួនឯង (Constructed) មិនមែនមានតែគ្រូបង្រៀនទេដែលចេះ តែសិស្សខ្លួនឯងក៏អាចបង្កើតចំណេះដឹងថ្មីដែរ (៤) ចំណេះដឹងមិនមែនមានតែនៅក្នុងសៀវភៅប៉ុណ្ណោះទេ ដោយសារតែទម្រង់នៃចំណេះដឹងមានច្រើនបែប និងច្រើនសណ្ឋាន ហើយមានទម្រង់ជាក្រាបសំឡេង និងវីដេអូ (Held in graphic, audio and video formats) ឬមានទម្រង់ផ្សេងៗទៀតហើយជាពិសេស(៥)ចំណេះដឹងដែលជួយគាំទ្រប្រកបដោយដំណើរការនូវអន្តរសកម្មជាមួយនឹងអ្នកប្រើប្រាស់ ហើយដែលអាចទទួលបានពី Internet ដោយប្រើម៉ាស៊ីនស្វែងរក (support dynamic interactions with the user and incorporate powerful search engines) និងពីប្រភពផ្សេងទៀតៗ

## ២.៣.២. ចំណាត់ថ្នាក់ពុទ្ធិរបស់លោក Bloom

ដើម្បីអាចរៀនសូត្រ និងទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទានិងចរិយាសម្បទានៅក្នុងយុគសម័យនៃសតវត្សទី២១ គេត្រូវសិក្សាពីចំណាត់ថ្នាក់ពុទ្ធិដែលស្នើដោយលោក Bloom (Bloom Taxonomy) និងនិយមន័យនៃសមាសភាគសំខាន់ៗនៃចំណេះដឹង (Anderson and Kreitzer, 2001) ដែលយើងអាចចាត់ថ្នាក់ពីសាមញ្ញ ទៅកម្រិតខ្ពស់ដូចតទៅ៖

(១) ការចងចាំ (Remembering)៖ គឺជាសមត្ថភាពក្នុងការរំឭកមេរៀនការអាចសូត្រឡើងវិញ និងសមត្ថភាពក្នុងការឆ្លើយនឹងសំណួរបាន

(២) ការយល់ (Understanding)៖ គឺជាសមត្ថភាពរបស់សិស្ស ក្នុងការឱ្យនិយមន័យ និងសមត្ថភាពក្នុងការធ្វើអធិប្បាយស្ដីពីទស្សនាទាន និងទ្រឹស្ដីបាន

(៣) ការអនុវត្ត (Applying)៖ គឺជាសមត្ថភាពរបស់សិស្សក្នុងការប្រើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណេះដឹង សម្រាប់ដោះស្រាយបញ្ហានានាដែលគេជួបប្រទះជាក់ស្តែង

(៤) ការវិភាគ (Analyzing)៖ គឺជាសមត្ថភាពរបស់សិស្ស ក្នុងការប្រៀបធៀប ធ្វើអធិប្បាយនិងធ្វើការអនុវត្តនាពេលបច្ចុប្បន្ន និងបកស្រាយភាពខុសគ្នារវាងទ្រឹស្តីផ្សេងៗគ្នាបាន

(៥) វាយតម្លៃ (Evaluating)៖ គឺជាសមត្ថភាពរបស់សិស្ស ក្នុងការផ្តល់មូលវិចារ និងការលើកឡើងពីគុណប្រយោជន៍របស់ទ្រឹស្តីណាមួយ

(៦) ការបង្កើតថ្មី (Creating)៖ គឺជាសមត្ថភាពរបស់សិស្ស ក្នុងការរៀបចំគម្រោងផែនការ និងបង្កើតថ្មីចេញពីទ្រឹស្តីចាស់ ដូចជាសិស្សអាចផ្តល់ជាគុច្ចូលផ្ទាល់ខ្លួនបាន។

## ២.៣.៣. អក្ខរកម្មក្នុងយុគសម័យឌីជីថល

ការវិវត្តយ៉ាងលឿននៃបច្ចេកវិទ្យានៅក្នុងយុគសម័យឌីជីថល បានធ្វើឱ្យនិយមន័យ និងសមាសភាគនៃអក្ខរកម្មបានប្រែប្រួលយ៉ាងខ្លាំង។ ដើម្បីទទួលបានជោគជ័យក្នុងការងារ និងដើម្បីមានជំនាញគ្រប់គ្រាន់ សម្រាប់បំពេញការងារបាន ពលករសម័យថ្មីត្រូវមានចំណេះដឹង និងបំណិនដូចខាងក្រោម។ ជារួមនិយមន័យនៃអក្ខរកម្មផ្លាស់ប្តូរពីអក្ខរកម្មតាមបែបបុរាណ (និយមន័យដើម ដែលមាន 3Rs ដោយត្រូវបន្ថែមនូវអក្ខរកម្មសតវត្សទី២១ 8Cs និងត្រូវមានបំណិន 2Ls ថែមទៀតផង (Anderson and Kreitzer, 2001; Sangob Intaramanee, 2019)៖

**I-3 Rs (និយមន័យដើម)**

តាមនិយមន័យដើម អក្ខរកម្មមានសមាសភាគបីយ៉ាងគឺ៖

១. អំណាន (Reading)

២. សំណេរ (W-Riting)

៣. លេខនព្វន្ត (A-Rithmetics)

## II- អក្ខរកម្មក្នុងសតវត្សទី២១

នៅសតវត្សទី២១ ពលករដែលមានតែបំណិនអក្ខរកម្មប្រពៃណីមិនអាចបំពេញការងារ ប្រកបដោយវិជ្ជាជីវៈបានឡើយ។ ពលករមានជំនាញត្រូវចេះអក្ខរកម្មសតវត្សទី២១ ឬ បំណិនសតវត្សទី២១ ថែមទៀត ដូចជា៖

១. បំណិនត្រិះរិះ និងដោះស្រាយបញ្ហា (Critical thinking and problem solving)

២. បំណិនច្នៃប្រឌិត និងនវានុវត្តន៍ (Creativity and innovation)

៣. ការយល់ពីវប្បធម៌ប្រទេសផ្សេងៗ (Cross-cultural understanding)

៤. បំណិនសហការ ធ្វើការជាក្រុម និងភាពជាអ្នកដឹកនាំ (Collaboration, teamwork & leadership)

៥. បំណិនគមនាគមន៍ ព័ត៌មាន និងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ (Communications, information & media literacy)

៦. អក្ខរកម្មកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មាន (Computing & ICT literacy)

៧. បំណិនអាជីព និងរៀន (Career & learning skills)

៨. បំណិនខាងផ្នែកផ្លាស់ប្តូរ (Change)

## III- 2 Ls

ម្យ៉ាងវិញទៀត ដោយសារតែបច្ចេកវិទ្យា បំណិន និងទីផ្សារការងារមានការផ្លាស់ប្តូរយ៉ាងខ្លាំង នៅក្នុងយុគសម័យនៃបដិវត្តន៍ឧស្សាហកម្មលើកទី៤ មានតែបំណិនខាងលើនៅមិនទាន់គ្រប់គ្រាន់ឡើយ។ ពលករ និងអ្នកដឹកនាំត្រូវមានបំណិនពីរថែមទៀត គឺ៖

១. បំណិនក្នុងការរៀន (Learning Skills)៖ រៀន, បំភ្លេចចំណេះដឹងចាស់, និងរៀនឡើងវិញ

២. ភាពជាអ្នកដឹកនាំ (Leadership)



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## IV- កម្មវិធីសិក្សាតាមបែបបញ្ញត្តិ

ការផ្លាស់ប្ដូរនិយមន័យនៃអក្ខរកម្ម និងចំណេះដឹងទាមទារឱ្យអ្នកអប់រំត្រូវធ្វើកំណែទម្រង់ក្នុងការរៀបចំកម្មវិធីសិក្សា និងក្នុងការអនុវត្តកម្មវិធីសិក្សា ជាពិសេសវិធីសាស្ត្របង្រៀនសិស្ស។ នៅក្នុងសតវត្សទី២០ គោលដៅនៃការសិក្សាគឺដើម្បីឱ្យសិស្សទទួលបាននូវចំណេះដឹង(គឺការចងចាំខ្លឹមសារមេរៀន ដែលជាហេតុការណ៍ ឬការពិត) និងទទួលបាននូវបំណិន (គឺការចេះធ្វើ) តែប៉ុណ្ណោះ។ ដូច្នេះ កម្មវិធីសិក្សាមានគោលដៅត្រឹមតែទន្ទេញចងចាំព្រឹត្តិការណ៍ និងចេះប្រើចំណេះដឹងទាំងនេះនៅក្នុងការបំពេញការងារប្រចាំថ្ងៃ។ នេះគឺជានិយមន័យនៃ «ចំណេះដឹង» នៅក្នុងសតវត្សទី២០។

**2D-កម្មវិធីសិក្សាផ្ដោតលើប្រធានបទ និងបំណិន**




**3D-កម្មវិធីសិក្សាផ្ដោតលើបញ្ញត្តិ**




ប្រភព៖ H. Lynn Erickson, 2012 in Erickson, Lanning and French (2017). Concept-Based Curriculum and Instruction for the Thinking Classroom. Sage: Singapore.

ក៏ប៉ុន្តែនៅក្នុងសតវត្សទី២១ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកាន់តែមាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លក្ខណៈស្មុគស្មាញ។ នាពេលបច្ចុប្បន្ននេះ ព័ត៌មានស្តីពី «ហេតុការណ៍ ឬការពិត» ត្រូវបានគេយកទៅដាក់ក្នុងប្រព័ន្ធ «Internet» ហើយដែលគេអាច ដឹងបានយ៉ាងឆាប់រហ័ស ដោយគ្រាន់តែប្រើម៉ាស៊ីនស្វែងរករបស់ក្រុមហ៊ុន Google។ ម្យ៉ាងវិញទៀត ពិភពលោកយើងទាំងមូលកំពុងជួបប្រទះនឹងបញ្ហា ធំៗជាច្រើនដែលមានលក្ខណៈកាន់តែស្មុគ្រស្មាញនិងទាក់ទងគ្នាទៅវិញទៅ មក។ ដូច្នេះ សមត្ថភាពត្រឹមតែការចងចាំហេតុការណ៍ និងការចេះបំណិន កម្រិតទាប មិនគ្រប់គ្រាន់ទេ សម្រាប់ទីផ្សារការងារក្នុងពេលបច្ចុប្បន្ន។

ជាការពិតណាស់សិស្សនៅតែត្រូវចងចាំនិងដឹងរឿងរ៉ាវហេតុការណ៍ ដែលកើតឡើង និងត្រូវមានបំណិនធ្វើដដែល។ ក៏ប៉ុន្តែចំណេះដឹងទាំងនេះ មិនគ្រប់គ្រាន់ឡើយ។ សិស្សត្រូវមានសមត្ថភាពក្នុងការវិភាគសំយោគ ត្រិះរិះ ពិចារណា សហការ ដោះស្រាយបញ្ហា ចាត់ថ្នាក់ព័ត៌មាន និងហេតុការណ៍ ទាំងនេះតាមក្រុម តាម «ហេតុ និងផល» ដើម្បីបង្កើតជាបញ្ញត្តិ និងចំណេះ ដឹងថ្មី។ បំណិននេះមានឈ្មោះថា «បំណិនសតវត្សទី២១»។ ដើម្បីបង្រៀន សិស្សឱ្យសម្រេចបានតាមគោលដៅ «បំណិនសតវត្សទី២១» អ្នកអប់រំត្រូវ រៀបចំ កម្មវិធីសិក្សាផ្តោតលើបញ្ញត្តិ (Concept-Based Curriculum) ឬកម្មវិធី សិក្សាដែលមានសមាសភាគបីផ្នែក (Three-dimentional curriculum) ដែលមាន គោលដៅ៖ (១) ប្រើប្រាស់ចំណេះដឹងពីហេតុការណ៍ ឬ ខ្លឹមសារក្នុងមេរៀន និង (២) បង្ហាត់ឱ្យសិស្សមានបំណិនក្នុងការប្រើប្រាស់ចំណេះដឹង ដើម្បី (៣) ធ្វើជាឧបករណ៍ ក្នុងការផ្សារភ្ជាប់ចំណុចសំខាន់ៗ ឬមុខវិជ្ជាផ្សេងៗដែលបាន រៀន ដើម្បីយល់ខ្លឹមសារមុខវិជ្ជានោះកាន់តែច្បាស់ ហើយបង្កើតបានជា បញ្ញត្តិថ្មី ដែលផ្សារភ្ជាប់ទ្រឹស្តី និងមុខវិជ្ជាដែលបានរៀន (Erickson, Lanning and French, 2017)។ ក្នុងទស្សនៈនេះហើយ ទើបក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តក្របខ័ណ្ឌកម្មវិធីសិក្សាថ្មី ក្នុងឆ្នាំ២០១៦ និងកម្មវិធីសិក្សាលម្អិត តាមបែបបញ្ញត្តិនៅឆ្នាំ២០១៨។

ដើម្បីអនុវត្តកម្មវិធីសិក្សាតាមបែបបញ្ញត្តិ គេត្រូវរៀបចំវិធីសាស្រ្ត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀនឡើងវិញ ដើម្បីលើកកម្ពស់ឱ្យសិស្សចេះ (Erickson, Lanning and French, 2017)៖

(១) គិតដើម្បីបង្កើតថ្មី (Creative thinking)៖ ដើម្បីផ្ដល់ឱកាសឱ្យសិស្សគិត វិភាគ ពិភាក្សា សំយោគ និងធ្វើអ្វីដោយខ្លួនឯង ក្នុងដំណើរការរៀនសូត្ររួមទាំងការរៀនសូត្រពីកំហុសរបស់ខ្លួនផងដែរ ដោយអនុវត្តវិធីសាស្ត្របង្រៀនតាមបែបសកម្ម និងតាមបែបស្ថាបនា។ តួនាទីរបស់គ្រូ គឺជួយដឹកនាំសិស្សឱ្យចេះគិត ដោយជួយបង្កើតសំណួរ ផ្ដល់យោបល់ និងដឹកនាំកិច្ចពិភាក្សាឱ្យមានប្រសិទ្ធភាព និងប្រកបដោយផ្លែផ្កា។

(២) គិតត្រិះរិះពិចារណា (Critical thinking)៖ ដោយបង្រៀនសិស្សឱ្យចេះសួរសំណួរ ផ្សារភ្ជាប់ចំណេះដឹងនៃមេរៀនផ្សេងៗក្នុងមុខវិជ្ជាទីមួយៗ និងរវាងមុខវិជ្ជាផ្សេងៗដែលបានរៀន ហើយចេះប្រៀបធៀប ដើម្បីយល់ដឹងកាន់តែស៊ីជម្រៅខ្លាំងឡើងថែមទៀត ចេះពន្យល់ទ្រឹស្ដី ចេះពិចារណាថ្លឹងថ្លែង និងចេះបកស្រាយទៅតាមទស្សនវិស័យផ្សេងៗ ចេះប្រមូល និងបកស្រាយទិន្នន័យ និងជាពិសេសយល់ច្បាស់ពីចំណុចសំខាន់នៃមេរៀនដែលបានរៀន។

(៣) គិតបែបឆ្លុះបញ្ចាំង (Reflective or Metacognitive thinking)៖ គឺជាវិធីសាស្ត្រក្នុងការគិត ដោយឈរលើមូលដ្ឋាននៃភាពជាក់ច្បាស់ ត្រឹមត្រូវ លម្អិត សមស្រប ស៊ីជម្រៅ មានអំណះអំណាង តក្កកម្ម និងសំខាន់។ និង

(៤) គិតដើម្បីបង្កើតបញ្ញត្តិ (Conceptual thinking)៖ សមត្ថភាពក្នុងការពិនិត្យព្រឹត្តិការណ៍ ហើយចេះផ្សារភ្ជាប់ចំណេះដឹងថ្មីជាមួយចំណេះដឹងដែលធ្លាប់រៀនកន្លងមក ដើម្បីយល់ឱ្យកាន់តែស៊ីជម្រៅនូវបញ្ញត្តិ វាយតម្លៃភាពត្រឹមត្រូវដោយឈរលើមូលដ្ឋាននៃទស្សនៈ ហើយប្រើប្រាស់បញ្ញត្តិថ្មីនេះ ដើម្បីដោះស្រាយបញ្ហា ឬបង្កើតចំណេះដឹងថ្មី។

កម្មវិធីសិក្សាថ្មីនេះមានគោលដៅរៀបចំដំណើរការរៀនសូត្រ ឱ្យឆ្លើយតបទៅនឹងរបៀបរៀនរបស់សិស្សដែលផ្លាស់ប្ដូរទៅតាមការប្រើប្រាស់បច្ចេក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិទ្យាផងដែរ។

## របៀបរៀនរបស់សិស្សមានការផ្លាស់ប្តូរ

| ពេលមុន | បច្ចុប្បន្ន |
|---|---|
| គ្រូប្រាប់ | សាកល្បងខ្លួនឯង (Experiential, discovery) |
| អសកម្ម | សកម្ម (Powerpoint, Action) |
| អត្ថបទ | រូបភាព (Image, Video, Multimedia) |
| សៀវភៅ | កុំព្យូទ័រ |
| ពិចារណាតាមអនុមានញែក (Deductive (linear) reasoning) | វិនិច្ឆ័យដោយប្រើមធ្យោបាយផ្សេងៗ(Bricolage+ Judgment (lateral)) |
| អត់ដឹង ហើយអត់ខ្វល់ | អត់ដឹង មើលតាម Internet ហើយសាកល្បង |
| | (Don't know/ Link/ Lurk/ Try) |

ប្រភព៖ កែសម្រួលពី John Seely Brown, *Learning in the Digital Age*

**ដើម្បីលើកកម្ពស់ «របៀបរៀនបែបថ្មី» គេត្រូវ៖**

១) ពិសោធន៍៖ ការរៀនដោយធ្វើពិសោធន៍ជាក់ស្តែង ដែលសិស្សត្រូវស្វែងរកប្រភពចំណេះដឹងដោយខ្លួនឯង និងខិតខំប្រឹងប្រែងត្រិះរិះពិចារណា ព្រមទាំងដោះស្រាយបញ្ហាដែលនឹងផ្តល់ឱ្យសិស្សនូវបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហា។

២) ការចូលរួមក្នុងសកម្មភាព ឬការរៀនតាមបែបសកម្ម៖ ដោយសិស្សត្រូវរៀបចំជាគម្រោងសិក្សា និងធ្វើការស្រាវជ្រាវ ដើម្បីលើកកម្ពស់បំណិនសហការ ដោយប្រើប្រាស់វិធីរៀនសូត្រដោយប្រើខួរក្បាល (Brain-Based Learning)។

៣) ការរៀនឱ្យចេះស្រមើស្រមៃ និងបង្កើតបញ្ញត្តិថ្មី៖ គោលដៅនៃការរៀនសូត្រមិនមែនត្រឹមតែទន្ទេញមេរៀនឱ្យចាំទេ តែសិស្សត្រូវចេះស្រមើស្រមៃ ចេះវិភាគ សំយោគព្រឹត្តិការណ៍ ចាត់ថ្នាក់ចំណេះដឹងតាមប្រភេទ និងតាមលក្ខណៈវិនិច្ឆ័យ ដើម្បីបង្កើតបញ្ញត្តិថ្មី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៤) ផ្សារភ្ជាប់បញ្ញត្តិផ្សេងៗ ដើម្បីបង្កើតគំនិតធំៗ៖ សិស្សត្រូវរេះរៀបចំធ្វើចំណាត់ថ្នាក់បញ្ញត្តិ ដោយបង្កើតជាផែនទីគំនិត និងផែនទីបញ្ញត្តិ ហើយផ្សារភ្ជាប់បញ្ញត្តិទាំងនេះឱ្យទៅជាគំនិតធំៗដែលមានគោលដៅដោះស្រាយបញ្ហាប្រឈមរបស់មនុស្សជាតិ។

**វិធីសាស្រ្តបង្រៀនតាមបែបស្ថាបនានិយម**

ដើម្បីអនុវត្តកម្មវិធីសិក្សាតាមបែបបញ្ញត្តិ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តនៅក្នុងឆ្នាំ២០២០ វិធីសាស្រ្តបង្រៀនតាមបែបស្ថាបនា ដែលរៀបចំដោយអង្គការ «សកម្មភាពកម្ពុជាដើម្បីការអប់រំបឋមសិក្សា (KAPE)» និងដែលត្រូវបានអនុវត្តសាកល្បងនៅសាលារៀនជំនាន់ថ្មី (New Generation School) ក្នុងគោលដៅអប់រំសិស្ស ដោយផ្តោតលើសមាសភាគបួន គឺ៖ (១) ខ្លឹមសារមេរៀន (ហេតុការណ៍ ឬការពិត) (២) បំណិន (៣) បញ្ញត្តិ និង (៤) បំណិនសតវត្សទី២១ និងការអប់រំចរិយាសម្បទា។

វិធីសាស្រ្តបង្រៀនតាមបែបស្ថាបនានិយមគឺជាវិធីសាស្រ្តបង្រៀនដែលប្រមូលផ្តុំវិធីសាស្រ្តជាច្រើនដូចជា៖ (១) ការសិក្សាតាមបែបរិះរក (២) ការសិក្សាបែបស្រាវជ្រាវ (៣) ការសិក្សាអាស្រ័យលើបញ្ហា (៤) ការគិតបែបស៊ីជម្រៅ (៥) បទពិសោធន៍ (៦) ការឆ្លុះបញ្ចាំង (៧) ការសហការ (៨) ប្លូមតាកសូណូមី (កម្រិតនៃចំណេះដឹង) (៩) បណ្តាញ (១០) ការវិភាគ (១១) ការបង្កើតបញ្ញត្តិ (១២) បរិបទ (១៣) ការប្រើប្រាស់បច្ចេកវិទ្យា និង (១៤) ការពិភាក្សាក្រុម (KAPE (2020). ការសិក្សាបែបស្ថាបនានិយម)។ ការអនុវត្តវិធីសាស្រ្តបង្រៀនថ្មីនេះទាមទារឱ្យមានបណ្ណាល័យស្តង់ដា ដែលមានធនធានសៀវភៅ និងឧបករណ៍សម្រាប់ស្រាវជ្រាវគ្រប់គ្រាន់ ដែលយើងអាចហៅថា «បណ្ណាល័យសតវត្សទី២១»។

ក្នុងការអនុវត្ត «វិធីសាស្រ្តបង្រៀនបែបស្ថាបនា»នេះ គ្រូត្រូវរៀបចំផែនការមេរៀនដែលមានធាតុស្នូល គឺការបណ្តុះសមត្ថភាពសិស្សក្នុងការបង្កើតបញ្ញត្តិ (គោលការណ៍ស្នូល) ការសហការក្នុងក្រុម ការឆ្លុះបញ្ចាំងបទ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពិសោធន៍ពីមុន ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការរៀន និងបង្រៀន ការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា និងការស្រមើស្រមៃៗលៗ គ្រូត្រូវរៀបចំសកម្មភាព «សួរ និងឆ្លើយសំណួរ» ដោយផ្តោតលើ (KAPE, 2020)៖

(១) ការសិក្សាអាស្រ័យលើបញ្ហា៖ ការផ្ទុះបញ្ចាំងបទពិសោធន៍ដែលធ្លាប់ដឹង និងបរិបទថ្មីដើម្បីស្វែងរក ឬ«ស្ថាបនា» គំនិតថ្មី ដែលអាចដោះស្រាយនោះបាន។

(២) ការសិក្សាតាមបែបរិះរក៖ សិស្សនឹងអាចចងចាំបានកាន់តែល្អប្រសិនបើសិស្សរិះរកចំណេះដឹងដោយខ្លួនឯង តាមរយៈការពិភាក្សា ការពិសោធ និងយុទ្ធសាស្ត្រសិក្សាបែបសកម្ម។

(៣) ប្លូមតាក់សូណូមី៖ ការសិក្សាដោយលើកកម្ពស់ឱ្យសិស្សមានបំណិនកម្រិតខ្ពស់ គឺការវិភាគ (ការបែងចែកបញ្ញត្តិជាផ្នែកតូចៗ ការសិក្សាពីរចនាសម្ព័ន្ធនៃបញ្ញត្តិ និងការបែងចែកភាពខុសគ្នារវាងខ្លឹមសារមេរៀន និងការសន្និដ្ឋាន) ការវាយតម្លៃ (ការបង្កើតស្តង់ដា និងលក្ខណៈវិនិច្ឆ័យ ដើម្បីវាយតម្លៃគំនិត និងហេតុការណ៍) និងការបង្កើតថ្មី(ការបង្កើតគំនិតថ្មី ដោយប្រមូលផ្តុំផ្នែកតូចៗដែលត្រូវបានលើកយកមកសិក្សាស្រាវជ្រាវ និងរៀបចំឱ្យមានរចនាសម្ព័ន្ធ ព្រមទាំងប្រើប្រាស់វិធីសាស្ត្រផែនទីគំនិត ឬផែនទីបញ្ញត្តិ)។

(៤) ការត្រិះរិះពិចារណាស៊ីជម្រៅ៖ ការសិក្សាដោយលើកកម្ពស់ឱ្យសិស្សមានបំណិនក្នុងការវិភាគវាយតម្លៃ និងបង្កើតថ្មី។

(៥) ការសហការ៖ ការបែងចែកសិស្សជាក្រុម ដើម្បីលើកកម្ពស់ការពិភាក្សាផ្លាស់ប្តូរគំនិត និងយោបល់ដែលនឹងនាំឱ្យមានការបង្កើតបញ្ញត្តិ និងជំរុញឱ្យសិស្សចេះសំយោគគំនិតប្លែកៗ។

(៦) ការប្រើបច្ចេកវិទ្យាក្នុងការរៀននិងបង្រៀន៖ បច្ចេកវិទ្យាព័ត៌មានបង្កើនប្រសិទ្ធភាពនៃការសិក្សាបែបស្ថាបនានិយម ដើម្បីលើកម្ពស់ការសហការ (សិស្សចងជាបណ្តាញ ដើម្បីទាក់ទងគ្នាតាមរយៈអ៊ីម៉ែល តេឡេក្រាម និងការប្រើប្រាស់អ៊ីនធឺណែត ដើម្បីស្រាវជ្រាវ និងសំយោគព័ត៌មាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថ្មីៗ) ការបណ្តុះបំណិនវិភាគ បំណិនសំយោគ បំណិនប្រាស្រ័យទាក់ទង និង បំណិនធ្វើការជាក្រុម (តាមរយៈការរៀបចំបទបង្ហាញជា Powerpoint និង ការបើកឱកាសឱ្យមានការសួរ និងការឆ្លើយ)។

(៧) ការសិក្សាតាមបែបសកម្មៈ ការប្រើប្រាស់វិធីសាស្ត្របង្រៀនដែលមានប្រើប្រាស់ការពិសោធនៅក្នុងបន្ទប់ពិសោធសម្រាប់ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងការប្រើប្រាស់ល្បែងសិក្សាផ្សេងៗ ដូចជាការបង្រៀបតាមបែបតុក្កតាគំនិត តាមបែប Jigsaw និងវិធីសាស្ត្របង្រៀនផ្សេងទៀត ដែលសិស្សត្រូវបំពេញកិច្ចការ និងសកម្មភាពជាក់ស្តែង ដើម្បីបញ្ជាក់ និងបកស្រាយទ្រឹស្តីពិបាកៗ ដែលមានលក្ខណៈអរូបីៗ ការប្រើវិធីសាស្ត្រ Jigsaw ត្រូវបែងចែកប្រធានបទធំមួយឱ្យទៅជាប្រធានបទតូចៗជា៣ ឬ៤ ហើយបែងចែកសិស្សជា៣ ឬ៤ក្រុមៗ ក្រុមនីមួយៗត្រូវសិក្សាស្រាវជ្រាវពីទិដ្ឋភាព និងចំណុចផ្សេងៗនៃប្រធានបទធំនោះ។ បន្ទាប់មក ក្រុមនីមួយៗត្រូវធ្វើបទបង្ហាញក្នុងថ្នាក់រៀន ដោយត្រូវមានការចោទសួរ និងការបំពេញបន្ថែមពីគ្រូបង្រៀន និងពីសិស្សរួមថ្នាក់ដទៃទៀតៗ

(៨) ការវាយតម្លៃសិក្សាតាមបែបស្ថាបនានិយមៈ ការអនុវត្តវិធីសាស្ត្របង្រៀនបែបស្ថាបនានិយមទាមទារនូវការប្រើប្រាស់វិធីសាស្ត្រវាយតម្លៃតាមបែបថ្មីៈ (ក) ការវាយតម្លៃតាមបែបឌីណាមិច ដោយគ្រូត្រូវវាយតម្លៃតាមដំណាក់ការនៃការបង្រៀនតែម្តង ដោយមិនត្រូវរង់ចាំពេលចុងក្រោយឡើយ (ខ) ការវាយតម្លៃកម្រងស្នាដៃសិស្ស ដែលជាគម្រោងតែងនិពន្ធ ការធ្វើបទបង្ហាញ និងការធ្វើតេស្ត (គ) ការវាយតម្លៃបែបដំណើរការ តាមរយៈការត្រួតពិនិត្យផ្ទៀងផ្ទាត់ ការសម្ភាស ការពិភាក្សាតាមក្រុម ការស៊ើបអង្កេត និងសកម្មភាព ដោះស្រាយបញ្ហា និង (ឃ) ការវាយតម្លៃក្រៅផ្លូវការ តាមរយៈការសង្កេតរបស់គ្រូទៅលើសកម្មភាពរបស់សិស្សៗ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី៣
# ទ្រឹស្តីនៃការគ្រប់គ្រងអប់រំ

## ៣.១. ទស្សនាទាននៃការគ្រប់គ្រងអប់រំ

«ការគ្រប់គ្រងអប់រំ» គឺជាការសិក្សា និងការអនុវត្តដែលដកស្រង់ចេញពីគោលការណ៍នៃការគ្រប់គ្រង ដែលធ្លាប់បានប្រើប្រាស់នៅក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្មពីពេលមុនមក។ ដូច្នេះហើយ ទើបនៅក្នុងការគ្រប់គ្រងអប់រំ គេអនុវត្តនូវគោលការណ៍ទូទៅនៃការគ្រប់គ្រង ដែលគេធ្លាប់យកទៅប្រើប្រាស់នៅក្នុងបរិបទនៃអង្គការផ្សេងៗដទៃទៀត ដូចជា៖ ការរៀបចំផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងទំនាក់ទំនងជាមួយអតិថិជន ជាដើម (Bush and Bell, 2009)។ ក៏ប៉ុន្តែ ការគ្រប់គ្រងអប់រំក៏មានលក្ខណៈពិសេសខុសពីការគ្រប់គ្រងវិស័យផ្សេងទៀត។ ដូច្នេះហើយ ទន្ទឹមនឹងការសិក្សាពីការយកគោលការណ៍រួមនៃការគ្រប់គ្រងមកប្រើប្រាស់ក្នុងការគ្រប់គ្រងអប់រំ គេត្រូវពិនិត្យមើលលក្ខណៈពិសេសនៃការគ្រប់គ្រងអប់រំ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសាលារៀន និងការគ្រប់គ្រងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

នៅក្នុង «ការគ្រប់គ្រងអប់រំ» គេសង្កេតឃើញមានទ្រឹស្តីជាច្រើន ដែលអ្នកស្រាវជ្រាវហៅថាជា «ពហុទ្រឹស្តី» (conceptual pluralism) (Bolman and Deal, 1984)។ លោក Tony Bush បានចាត់ទុកថា «ទ្រឹស្តីនៃការគ្រប់គ្រងអប់រំ»



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មានប្រភពមកពីទ្រឹស្ដីផ្សេងៗចំនួន ៦ គឺ ៖ (១) ការិយាធិបតេយ្យ (២) សមូហភាពនិយម (៣) នយោបាយខ្នាតតូច (៤) ទ្រឹស្ដីអត្តនោម័តិនិយម (៥) ទ្រឹស្ដីមិនច្បាស់លាស់ និង (៦) វប្បធម៌អង្គភាព។

## ៣.១.១. ការិយាធិបតេយ្យ

ទស្សនាទានការិយាធិបតេយ្យមានប្រភពមកពីស្នាដៃរបស់សង្គមវិទូអាឡឺម៉ង់ លោក Max Weber។ សាលារៀន គឺជារចនាសម្ព័ន្ធការិយាធិបតេយ្យដែលមានលក្ខណៈដូចខាងក្រោម៖ (១) រចនាសម្ព័ន្ធអំណាចតាមជាន់ថ្នាក់ដែលមានបុគ្គលិកទទួលខុសត្រូវ ចំពោះថ្នាក់លើរបស់ខ្លួននៅក្នុងរចនាសម្ព័ន្ធ៖ នៅក្នុងសាលារៀន គ្រូបង្រៀនទទួលខុសត្រូវចំពោះមុខប្រធានក្រុមបច្ចេកទេស ហើយប្រធានក្រុមបច្ចេកទេសទទួលខុសត្រូវចំពោះមុខនាយកសាលា (២) សាលារៀនមានបេសកកម្ម និងគោលដៅរបស់ខ្លួន (៣) នៅក្នុងសាលារៀនមានការបែងចែកពលកម្ម និងការទទួលខុសត្រូវ ដោយបុគ្គលិកអប់រំមានឯកទេសទៅតាមជំនាញរបស់ខ្លួន (៤) ការសម្រេចចិត្ត និងសកម្មភាពរបស់សាលារៀនត្រូវធ្វើឡើង តាមច្បាប់ និងលិខិតបទដ្ឋាន (៥) ការសម្រេចចិត្តត្រូវធ្វើឡើង តាមដំណើរការប្រកបដោយវិចារណញ្ញាណ (៦) នាយកសាលាទទួលខុសត្រូវចំពោះអង្គភាពខាងក្រៅ និងចំពោះមហាជន។

## ៣.១.២. ការដឹកនាំតាមបែបសមូហភាព

ទស្សនាទាននៃ«ការដឹកនាំតាមបែបសមូហភាព» (Collegiality) នៅក្នុងវិស័យអប់រំផ្ដល់ឱកាសឱ្យគ្រូបង្រៀនចូលរួមក្នុងការសម្រេចចិត្ត ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងាររបស់ខ្លួន ហើយទស្សនាទាននេះមានលក្ខណៈដូចតទៅ៖ (១) អំណាចដែលផ្ដោតលើជំនាញ៖ គ្រូបង្រៀនមានជំនាញខាងផ្នែកមុខវិជ្ជា និងមានសមត្ថភាពជំនាញទូទៅជាអ្នកឯកទេសខាងផ្នែកអប់រំ(២) គ្រូបង្រៀនមានក្រមវិជ្ជាជីវៈ និងតម្លៃរួមដែលទទួលបាន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៅក្នុងពេលបណ្ដុះបណ្ដាល និងការបំពេញការងារ ហើយតម្រង់ឆ្ពោះទៅការសម្រេចគោលដៅរួម (៣) ការសម្រេចចិត្តតាមរយៈការពិភាក្សាដើម្បីសម្រេចបាននូវកុងសង់សុស (Consensus)។

### ៣.១.៣. នយោបាយខ្នាតតូច

ទស្សនាទាន «នយោបាយខ្នាតតូច» (Micropolitics) គឺជាសកម្មភាពនយោបាយនៅក្នុងសាលារៀន ចំណែកឯ «នយោបាយខ្នាតធំ» (Macropolitics) គឺជានយោបាយកម្រិតជាតិ។ នយោបាយខ្នាតតូចមានន័យថា នៅក្នុងសាលារៀនការសម្រេចចិត្តធ្វើឡើង តាមរយៈការចរចា និងការតថ្លៃ ដោយមានបង្កើតជាបក្ស និងជាក្រុមតូចៗដើម្បីបម្រើផលប្រយោជន៍ និងការចងសម្ព័ន្ធភាព ដើម្បីសម្រេចនូវគោលដៅរួមអ្វីមួយ។ លក្ខណៈនៃ «នយោបាយខ្នាតតូច» មានដូចតទៅ៖ (១) ការផ្ដោតទៅលើសកម្មភាពតាមក្រុមជាជាងទៅលើស្ថាប័នទាំងមូល (២) ការផ្ដោតទៅលើផលប្រយោជន៍ និងក្រុមផលប្រយោជន៍ (៣) ទំនាស់រវាងក្រុមបក្សដែលគោលដៅខុសគ្នា (៤) ការសម្រេចចិត្តតាមរយៈដំណើរការតថ្លៃ និងការចរចា និង (៥) ការដោះស្រាយបញ្ហាទៅតាមតុល្យភាពនៃអំណាច។

### ៣.១.៤. ទ្រឹស្ដីអត្តនោម័តិនិយម

«ទ្រឹស្ដីអត្តនោម័តិនិយម» (Subjective theories) ផ្ដោតលើបុគ្គលនៅក្នុងអង្គភាព។ មនុស្សម្នាក់ៗមានទស្សនៈរៀងៗខ្លួនពីអង្គភាពរបស់ខ្លួន ហើយអង្គភាពនេះបង្ហាញពីតម្លៃរបស់បុគ្គលដែលបម្រើការនៅទីនោះ។ ទ្រឹស្ដីនេះមានលក្ខណៈដូចតទៅ៖ (១) ផ្ដោតលើជំនឿ ការយល់ឃើញ និងទស្សនៈរបស់បុគ្គលដែលជាសមាជិកនៃអង្គភាព។ នៅតាមសាលារៀន គ្រូបង្រៀន បុគ្គលិកសិក្សា និងសិស្សានុសិស្សមានតម្លៃ និងបំណងប្រាថ្នាខុសៗគ្នា (២) ផ្ដោតទៅលើអត្ថន័យ និងការបកស្រាយនៃព្រឹត្តិការណ៍ចំពោះបុគ្គលម្នាក់ៗ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(៣) វចនាសម្ព័ន្ធនៅក្នុងអង្គភាព គឺជាលទ្ធផលនៃអន្តរសកម្មរវាងបុគ្គលិកដែលបម្រើការងារ។

## ៣.១.៥. ទ្រឹស្តីមិនច្បាស់លាស់

«ទ្រឹស្តីមិនច្បាស់លាស់» (Ambiguity theories) ផ្តោតលើភាពមិនច្បាស់លាស់ អស្ថិរភាព និងភាពស្មុគស្មាញ នៅក្នុងស្ថាប័ន ហើយគេពិបាកកំណត់អាទិភាពនៃសកម្មភាពរបស់ស្ថាប័ននោះ។ ទ្រឹស្តីនេះមានលក្ខណៈដូចតទៅ៖ (១) គោលដៅរបស់អង្គភាពមិនច្បាស់លាស់៖ តួអង្គនីមួយៗនៅក្នុងសាលារៀនមានគោលដៅផ្សេងៗគ្នា ហើយផ្តល់អាទិភាពទៅលើបញ្ហាផ្សេងៗគ្នា ដើម្បីសម្រេចបានគោលដៅរួម ឬតួអង្គនីមួយៗមិនអាចកំណត់និយមន័យនៃគោលដៅរួមបាន (Bell, 1989) (២) ការបង្កើតក្រុមបក្សពួកនៅក្នុងអង្គភាព៖ សាលារៀនចែកជាក្រុមតូចៗ ហើយក្រុមនីមួយៗមានតម្លៃ និងគោលដៅរបស់ខ្លួន (៣) វចនាសម្ព័ន្ធនៃអង្គភាពនេះមិនច្បាស់លាស់ ដោយសារផ្នែកនីមួយៗមានអំណាចខុសៗគ្នា៖ គណៈកម្មការមានតួនាទី និងការកិច្ចដាច់គ្នា ក្រោមការគ្រប់គ្រងរបស់ប្រធានផ្នែករៀងៗខ្លួន ហើយពិបាកនឹងធ្វើការសម្រេចចិត្ត (៤) ការចូលរួមមិនមានសង្គតភាព ដោយសារសមាជិកចេញចូលៗ ដូចជាគណៈកម្មការទ្រទ្រង់សាលារៀន ដែលមាតាបិតាចូលរួមមិនសូវបានទៀងទាត់។

## ៣.១.៦. វប្បធម៌នៅក្នុងអង្គភាព

គេអាចវិភាគសាលារៀន ដោយឈរលើទស្សនវិស័យនៃវប្បធម៌ដែលផ្តោតលើតម្លៃ និងជំនឿរបស់បុគ្គលិក ដែលបម្រើការងារនៅក្នុងសាលារៀន។ ក្នុងន័យនេះ សាលារៀនមានវប្បធម៌ដាច់ដោយឡែកពីអង្គភាពផ្សេងៗទៀត ហើយទស្សនាទាននេះមានលក្ខណៈដូចតទៅ៖ (១) ផ្តោតទៅលើតម្លៃ និងជំនឿរបស់បុគ្គលិក ហើយជាកត្តាកំណត់នៃអាកប្បកិរិយា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់បុគ្គលិកសិក្សានៅក្នុងសាលារៀន (២) តម្លៃ និងជំនឿរបស់បុគ្គលិកសិក្សាប្រមូលផ្តុំគ្នា ហើយបង្កើតបានជារបៀបរបបធ្វើការរួមមួយ (៣) វប្បធម៌នេះស្តែងចេញតាមរយៈពិធីផ្សេងៗ ដែលរៀបចំឡើងដើម្បីប្រារព្ធព្រឹត្តិការណ៍ផ្សេងៗ ដូចជាពិធីចែកសញ្ញាបត្រជាដើម (៤) ការលើកតម្កើងដល់អ្នកដែលទទួលបានជោគជ័យនៅក្នុងអាជីវកម្ម ដូចជាអតីតនិស្សិត ដែលទទួលបានជោគជ័យក្នុងការងារ។

## ៣.២. ទ្រឹស្តីនៃការគ្រប់គ្រងអប់រំ

«ទ្រឹស្តីការគ្រប់គ្រងអប់រំ» ចែកចេញជាបួន គឺ៖ (១) ទ្រឹស្តីគ្រប់គ្រងតាមបែបប្រពៃណី (Classical Organizational Theory) (២) ទ្រឹស្តីទំនាក់ទំនងមនុស្ស (the human relations approach) (៣) ទ្រឹស្តីអកប្បកិរិយា (the behavioural science approach) និង (៤) ទ្រឹស្តីក្រោយ-វិទ្យាសាស្ត្រអាកប្បកិរិយា (post-behavioural Science)។

ទ្រឹស្តីនេះត្រូវបានបង្កើតឡើងនៅដើមសតវត្សទី២០ ដោយផ្តោតលើអង្គការចាត់តាំងផ្លូវការ និងទស្សនាទាននៃការបង្កើតប្រសិទ្ធភាពក្នុងការគ្រប់គ្រង។ អ្នកដែលបង្កើតទ្រឹស្តីនេះមាន៖ លោក Frederick Taylor, លោក Henri Fayol, លោក Luther Gulick និង លោក Max Weber។

ការគ្រប់គ្រងត្រូវផ្តោតលើគោលការណ៍ដូចតទៅ៖ (១) ខ្សែបន្ទាត់បណ្តោយនៃការទទួលខុសត្រូវ និងបុគ្គលិក (២) ខ្សែបន្ទាត់នៃការទទួលបញ្ជា (៣) ការលើកលែង៖ការប្រគល់ភារកិច្ចឱ្យបំពេញតាមតួនាទីប្រចាំថ្ងៃ និងករណីលើកលែង (៤) រយៈពេលត្រួតពិនិត្យ៖ ចំនួនមន្ត្រីដែលត្រូវធ្វើរបាយការណ៍ទៅឱ្យថ្នាក់លើ(អាចពី ៣ ទៅ ១២ នាក់)។ ទ្រឹស្តីនៃការគ្រប់គ្រងមានទស្សនវិស័យនៃការគ្រប់គ្រងពីរប្រភេទ៖ (១) ការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រ និង (២) ការគ្រប់គ្រងរដ្ឋបាល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.២.១. ទ្រឹស្តីការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រ

លោក Frederick Taylor (1856-1915) គឺជាអ្នកបង្កើតទ្រឹស្តីការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រនេះឡើង។ ទ្រឹស្តីនេះផ្តោតលើការគ្រប់គ្រងនៃការងារ និងអ្នកបំពេញការងារ។ គំនិតជាមូលដ្ឋាននៃទ្រឹស្តីនេះមានតែវិធីតែមួយគត់ក្នុងការបំពេញការងារ គឺការប្រើប្រាស់វិធីសាស្ត្រវិទ្យាសាស្ត្រ។ តាមយោបល់លោក ប្រសិនបើការងារត្រូវបានគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រ វានឹងបង្កើតប្រសិទ្ធភាពពលកម្ម តាមរយៈការបង្កើនប្រសិទ្ធភាព និងប្រាក់បៀវត្សរបស់អ្នកបំពេញការងារ។ ការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រត្រូវមានស្តង់ដានៃពេលវេលាក្នុងការបំពេញការងារ ការបែងចែកការងាររដ្ឋបាល និងការងាររបស់និយោជិត និងប្រព័ន្ធលើកទឹកចិត្ត ដើម្បីកែលម្អប្រសិទ្ធផលការងារ (performance) របស់អ្នកធ្វើការ។

ចំណុចសំខាន់ៗនៃទ្រឹស្តីនេះមានដូចតទៅ៖ (១) ត្រូវរកវិធីដែលល្អជាងគេ ដើម្បីបំពេញការងារនីមួយៗ (២) ត្រូវជ្រើសរើសបុគ្គលិក ដោយប្រើប្រាស់នីតិវិធីជ្រើសរើសតាមបែបវិទ្យាសាស្ត្រ (៣) ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងថ្នាក់ដឹកនាំ និងបុគ្គលិក និង (៤) ត្រូវប្រើប្រាស់គោលការណ៍នៃការបែងចែកពលកម្ម។ ទ្រឹស្តីនេះមានគោលដៅសម្រេចបានលទ្ធផលការងារជាអតិបរមា ដោយកំណត់ស្តង់ប្រសិទ្ធផលការងារសម្រាប់តួនាទីនីមួយៗ និងមានប្រព័ន្ធផ្តល់ប្រាក់បៀវត្សផ្សេងៗគ្នាសម្រាប់ការផលិត ឬផលិតផលនៃការងារនីមួយៗ។

ដើម្បីអនុវត្តទ្រឹស្តីនៃការគ្រប់គ្រងនេះបាន គេត្រូវមានគោលការណ៍ច្បាស់លាស់។ នៅឆ្នាំ ១៩១១ លោក Taylor បានដាក់ចេញនូវគោលការណ៍ ៤ សម្រាប់អនុវត្តន៍ការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រ៖ (១) ការវិភាគមុខងារតាមបែបវិទ្យាសាស្ត្រ៖ មុខងារត្រូវតែវិភាគតាមបែបការសង្កេត ការប្រមូលទិន្នន័យ ការវាស់វែង និងការគ្រប់គ្រងដោយប្រុងប្រយ័ត្ន (២) ការជ្រើសរើសបុគ្គលិក៖ បន្ទាប់ពីវិភាគមុខងាររួចគេត្រូវជ្រើសរើសបណ្តុះបណ្តាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បង្រៀន និងអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិក។ ពីពេលមុនបុគ្គលិកជ្រើសរើសការងារដោយខ្លួនឯង និងបណ្តុះបណ្តាលខ្លួនដោយខ្លួនឯង (៣) ការគ្រប់គ្រងតាមបែបសហការ៖ ថ្នាក់ដឹកនាំត្រូវសហការជាមួយបុគ្គលិក ដើម្បីធានាថា ការងារដែលត្រូវបំពេញត្រូវធ្វើឡើងដោយឈរលើគោលការណ៍វិទ្យាសាស្ត្រ (៤) ការត្រួតពិនិត្យតាមមុខងារ៖ អ្នកដឹកនាំរៀបចំផែនការរៀបចំការអនុវត្តសកម្មភាព និងធ្វើការសម្រេចចិត្ត ចំណែកឯបុគ្គលិកបំពេញការងាររបស់ខ្លួនរៀងៗខ្លួន។ ពីពេលមុនការងារទាំងអស់ និងការទទួលខុសត្រូវភាគច្រើនត្រូវបានប្រគល់ឱ្យបុគ្គលិក។

ក្រៅពីនេះ លោក Taylor បានរៀបចំនូវគោលការណ៍ពីរទៀតគឺ៖ (១) ស្តង់ដាសមិទ្ធផល៖ ដើម្បីអាចប្រៀបធៀបប្រសិទ្ធភាពការងាររបស់ពលករ និង (២) ប្រព័ន្ធប្រាក់បៀវត្សខុសៗគ្នាតាមចំនួនផលិតកម្ម (Differential Piece RateSystem)៖ ប្រាក់បៀវត្សទាបសម្រាប់ពលករដែលផលិតមិនដល់ស្តង់ដានៃផលិតកម្ម និងប្រាក់បៀវត្សខ្ពស់សម្រាប់ពលករដែលផលិតលើសស្តង់ដានៃផលិតកម្ម។ ប្រព័ន្ធនេះជួយឱ្យពលករខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយប្រសិទ្ធភាព។

### ៣.២.២. ទ្រឹស្តីការគ្រប់គ្រងរដ្ឋបាល

«ទ្រឹស្តីការគ្រប់គ្រងតាមបែបវិទ្យាសាស្ត្រ» ផ្តោតលើការងាររបស់ពលករជាបុគ្គល ចំណែកឯ «ទ្រឹស្តីការគ្រប់គ្រងរដ្ឋបាល» ប្រើប្រាស់ក្នុងការគ្រប់គ្រងក្នុងអង្គភាពទាំងមូលតែម្តង។ ទ្រឹស្តីនេះពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ និងការគ្រប់គ្រងនៃអង្គភាពតែម្តង។ លោក Henri Fayol, Luther Gulick និងលោក Max Weber គឺជាអ្នកបង្កើតទ្រឹស្តីនេះឡើង។

តាមមតិរបស់លោក Fayol អ្នកគ្រប់គ្រងទាំងអស់បំពេញមុខងារជាមូលដ្ឋាននៃការគ្រប់គ្រង ដែលមានជាអាទិ៍៖ (១) ការធ្វើផែនការ (២) ការចាត់ចែង (៣) ការបញ្ជា (៤) ការសម្របសម្រួល និង (៥) ការត្រួតពិនិត្យ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រៅពីមុខងារជាមូលដ្ឋានទាំង ៥ នេះ លោក Fayol បានកត់សម្គាល់ថា អ្នកគ្រប់គ្រងអនុវត្តគោលការណ៍ដូចតទៅៈ (១) ការបែងចែកការងារ (២) អំណាច (៣) វិន័យ (៤) ការគោរពតាមបញ្ជារួម (៥) ការកំណត់ទិសដៅរួម (៦) ការដាក់ផលប្រយោជន៍បុគ្គលក្រោមផលប្រយោជន៍រួម (៧) ការធ្វើមជ្ឈការ (៨) ការរៀបចំបណ្ដាញ (៩) សមធម៌ (១០) ស្ថិរភាពនៃបុគ្គលិក និង (១១) ការផ្ដួចផ្ដើមគំនិត។ គោលការណ៍ទាំងនេះគូសបញ្ជាក់ពីខ្សែចង្វាក់នៃការបញ្ជាការបែងចែកអំណាច ការរៀបចំសណ្ដាប់ធ្នាប់ ប្រសិទ្ធភាព សមធម៌ និងស្ថិរភាព។ លោក Max Weber ក៏យល់ឃើញថា ការគ្រប់គ្រងត្រូវគោរពតាមគោលការណ៍ទាំងនេះដែរ។

លោក Luther Gulick បានដាក់ចេញនូវគោលការណ៍ទាំង ៧ នៃការគ្រប់គ្រង ៖ (១) ការធ្វើផែនការ ៖ ការរៀបចំសេចក្ដីព្រាងនៃសកម្មភាព ដែលត្រូវធ្វើ និងវិធីសាស្ត្រក្នុងការបំពេញការងារ (២) ការចាត់ចែង ៖ ការបង្កើតរចនាសម្ព័ន្ធផ្លូវការ ដោយមានការបែងចែកការងារ និងការសម្របសម្រួលក្នុងការអនុវត្តផែនការ (៣) ការរៀបចំបុគ្គលិក ៖ ការជ្រើសរើស និងបណ្ដុះបណ្ដាលបុគ្គលិក និងការបង្កើតលក្ខខណ្ឌការងារអំណោយផល ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់បុគ្គលិក (៤) ការកំណត់ទិសដៅ ៖ ការសម្រេចចិត្តការផ្សព្វផ្សាយសេចក្ដីសម្រេចចិត្តដល់បុគ្គលិក និងការអនុវត្តសេចក្ដីសម្រេចចិត្ត (៥) ការសម្របសម្រួល ៖ ការខិតខំប្រឹងប្រែងរក្សាឯកភាព ក្នុងអង្គភាព ដើម្បីសម្រេចគោលដៅរួម (៦) ការធ្វើរបាយការណ៍ ៖ ការពិនិត្យវឌ្ឍនភាព តាមរយៈការកត់ត្រា ការស្រាវជ្រាវ និងការធ្វើអធិការកិច្ច ដើម្បីធានាសង្គតភាពជាមួយផែនការ និង (៧) ការរៀបចំថវិកាៈ ការរៀបចំផែនការចំណូល និងចំណាយ ការរៀបចំបញ្ជិកាគណនេយ្យ និងការត្រួតពិនិត្យ។

## ៣.២.៣. ទ្រឹស្ដីទំនាក់ទំនងមនុស្ស

«ទ្រឹស្ដីទំនាក់ទំនងមនុស្ស» មានឥទ្ធិពលយ៉ាងខ្លាំងលើទ្រឹស្ដីការគ្រប់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រងរដ្ឋបាល។ ទ្រឹស្តីនេះសិក្សាពីទំនាក់ទំនងរវាងនិយោជិត និងនិយោជក ដែលជាទិដ្ឋភាពដ៏សំខាន់នៃការគ្រប់គ្រង ហើយលើកកម្ពស់ដល់ការសិក្សាចិត្តសាស្ត្រសង្គម ដើម្បីកសាងទំនាក់ទំនងសហការ និងសហប្រតិបត្តិការរវាងបុគ្គលិក និងអ្នកគ្រប់គ្រង។ ទ្រឹស្តីទំនាក់ទំនងមនុស្សសង្កត់ធ្ងន់លើការលើកទឹកចិត្តបុគ្គលិក និងស្ទីលនៃភាពជាអ្នកដឹកនាំ។ ទ្រឹស្តីនេះដាក់ចេញនូវគំនិតសំខាន់ៗដូចតទៅ៖

ទី១-បុគ្គលិកលើកទឹកចិត្តដោយតម្រូវការសង្គម និងចិត្តសាស្ត្រ និងដោយការលើកទឹកចិត្តខាងផ្នែកសេដ្ឋកិច្ច។ ការលើកទឹកចិត្តនេះរួមមានការទទួលស្គាល់ ការរួមរស់ជាមួយគ្នា និងសន្តិសុខ ដែលមានសារៈសំខាន់ក្នុងការកំណត់ទឹកចិត្ត និងប្រសិទ្ធភាពរបស់ពលករ ច្រើនជាងលក្ខខណ្ឌនៃបរិស្ថានការងារ។

ទី២-ការយល់ឃើញ ជំនឿ ការលើកទឹកចិត្ត ការទទួលស្គាល់ ការឆ្លើយតបទៅនឹងការមិនពេញចិត្ត តម្លៃ និងកត្តាដូចគ្នានេះនឹងជះឥទ្ធិពលទៅលើអាកប្បកិរិយារបស់បុគ្គលិកក្នុងការបំពេញការងារ។

ទី៣ - បុគ្គលិកដែលបំពេញការងារនៅក្នុងអង្គភាពណាក៏ដោយតែងតែបង្កើតអង្គការសង្គមក្រៅផ្លូវការ ដែលដំណើរការជាមួយគ្នានឹងអង្គការផ្លូវការដែលអាចជួយ ឬជាឧបសគ្គសម្រាប់ការគ្រប់គ្រង។

ទី៤-ក្រុមសង្គមក្រៅផ្លូវការនៅតាមកន្លែងធ្វើការបង្កើត និងអនុវត្តវិធាន និងក្រមវិជ្ជាជីវៈរបស់ខ្លួន។ ការខិតខំប្រឹងប្រែងរបស់ក្រុម ទំនាស់រវាងក្រុមផ្សេងៗ ភាពស្មោះត្រង់ចំពោះក្រុមទំនាក់ទំនង ភាពជាអ្នកដឹកនាំ គឺជាទស្សនាទានដ៏សំខាន់ ក្នុងការកំណត់ឥរិយាបថបុគ្គល និងឥរិយាបថក្រុម។

ទី៥-និយោជិតមានការលើកទឹកចិត្តខ្ពស់ និងធ្វើការខ្លាំងជាង ប្រសិនបើអ្នកដឹកនាំគាំទ្រ ហើយនឹងជួយបង្កើតប្រសិទ្ធភាពការងារ។

ទី៦-ទំនាក់ទំនង អំណាច ឥទ្ធិពល ការលើកទឹកចិត្ត និងការទាក់ទាញ គឺជាទំនាក់ទំនងដ៏សំខាន់នៅក្នុងអង្គភាពនីមួយៗ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៣.២.៤. ទ្រឹស្តីវិទ្យាសាស្ត្រឥរិយាបថ

«អ្នកវិទ្យាសាស្ត្រខាងផ្នែកឥរិយាបថ» យល់ឃើញថា ទ្រឹស្តីសេដ្ឋកិច្ច និងទ្រឹស្តីទំនាក់ទំនងមនុស្សមិនគ្រប់គ្រាន់សម្រាប់ការយល់ពីនិយោជិតនៅកន្លែងធ្វើការឡើយ។ លោក Barnard គឺជាអ្នកឯកទេសទី១ ដែលសិក្សាពីប្រព័ន្ធសហប្រតិបត្តិការ ដែលបញ្ចូលក្របខ័ណ្ឌពីរ គឺទំនាក់ទំនងមនុស្ស និងគោលការណ៍នៃការគ្រប់គ្រង។ នៅឆ្នាំ ១៩៣៨ លោកលើកឡើងថា ការជានាកិច្ចសហប្រតិបត្តិការ និងភាពជោគជ័យហិរញ្ញវត្ថុទាមទារលក្ខខណ្ឌពីរគឺ៖ (១) អ្នកដឹកនាំត្រូវសង្កត់ធ្ងន់លើភាពស័ក្តិសិទ្ធិ (effectiveness) ពោលគឺកម្រិតនៃការសម្រេចបាននូវគោលដៅរួមរបស់អង្គភាព និង (២) អ្នកដឹកនាំត្រូវយល់ពីប្រសិទ្ធភាព (efficiency) ពោលគឺការបំពេញនូវការលើកទឹកចិត្តជាបុគ្គលដល់បុគ្គលិក។ លោក Barnard យល់ឃើញថា អង្គភាពមួយអាចដំណើរការ និងរស់បានទាល់តែរក្សាឱ្យមានតុល្យភាពរវាងគោលដៅរបស់អង្គភាព និងគោលដៅរបស់បុគ្គលិកដែលធ្វើការឱ្យអង្គភាពនោះ ពោល គឺអ្នកគ្រប់គ្រងត្រូវមានបំណិតមនុស្ស និងបំណិនបច្ចេកទេស ដើម្បីសម្រេចបានតាមគោលដៅ។ នៅឆ្នាំ ១៩៧០ លោក Abraham Maslow គឺជាចិត្តវិទូដែលបង្កើតទ្រឹស្តី «ការលើកទឹកចិត្តរបស់មនុស្ស» ដែលអ្នកគ្រប់គ្រងជាច្រើនបានយកទៅអនុវត្តតាម។

ទ្រឹស្តី Maslow មានមូលដ្ឋានលើការលើកទឹកចិត្ត ហើយលោកមានទស្សនៈដូចតទៅ៖ (ក) មនុស្សមានតម្រូវការដែលមិនអាចបំពេញបានទាំងស្រុង (ខ) សកម្មភាពរបស់មនុស្សមានគោលដៅបំពេញតាមតម្រូវការដែលមិនគ្រប់គ្រាន់ (គ) តម្រូវការទាំងនេះអាចចាត់ថ្នាក់ពីទាប ទៅខ្ពស់៖ (១) តម្រូវការខាងផ្នែករាងកាយ (២) សុវត្ថិភាព (៣) សង្គម (៤) ការគោរព (៥) ការសម្រេចបានតាមសក្តានុពល។

ក៏ប៉ុន្តែលោក McGregor បានបង្កើតនូវទស្សនវិស័យថ្មីមួយទៀត ដោយជំរុញឱ្យអ្នកគ្រប់គ្រងចាត់ទុកបុគ្គលិករបស់ខ្លួនជាអ្នកដែលទទួលខុស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ត្រូវមានសមត្ថភាព និងចេះច្នៃប្រឌិត។ លោកបានបង្កើតទ្រឹស្តីចំនួន ២ គឺៈ ទ្រឹស្តី X និងទ្រឹស្តី Y ។

អ្នកគ្រប់គ្រងតាមទ្រឹស្តី X គឺជាអ្នកគ្រប់គ្រងដែលផ្តាច់ការ ត្រួតពិនិត្យ និងមិនទុកចិត្តអ្នកខាងក្រោម។ គេធ្វើសេចក្តីសន្និដ្ឋានដូចតទៅៈ (១) មនុស្សមិនចូលចិត្តធ្វើការឡើយ ហើយនឹងគេចមិនចង់ធ្វើការនៅពេលដែលគេមានឱកាស (២) ដូច្នេះ គេត្រូវបង្ខំមនុស្ស ត្រួតពិនិត្យ តម្រង់ទិស និងត្រូវដាក់ទោសទណ្ឌ ដើម្បីបង្ខំឱ្យគេបំពេញការងារ និងសម្រេចបានតាមគោលដៅ។

ផ្ទុយទៅវិញ អ្នកគ្រប់គ្រងទ្រឹស្តី Y គឺជាអ្នកគ្រប់គ្រងដែលចាត់ទុកកូនចៅជាបុគ្គលដែលចង់ទទួលយកបញ្ហាប្រឈមក្នុងការបំពេញការងារ ចូលចិត្តស្វ័យគ្រប់គ្រង និងមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធ្វើសេចក្តីវិនិច្ឆ័យដោយឯករាជ្យ។ គេធ្វើសេចក្តីសន្និដ្ឋានដូចតទៅៈ (១) មនុស្សមិនមែនមិនចូលចិត្តធ្វើការទេ (២) មនុស្សនឹងតម្រង់ទិសខ្លួនឯង និងគ្រប់គ្រងខ្លួនឯងដើម្បីសម្រេចបានតាមគោលដៅដែលគេបានដាក់ចេញ (៣) ការប្តេជ្ញាចិត្តសម្រេចបានតាមគោលដៅ គឺជាតួនាទីនៃការផ្តល់រង្វាន់នៅពេលសម្រេចបានសមិទ្ធផល (៤) មនុស្សរៀនក្នុងលក្ខខណ្ឌសមស្រប ហើយមនុស្សមិនមែនត្រឹមតែទទួលយកនូវការទទួលខុសត្រូវឡើយ តែថែមទាំងស្វែងរកការទទួលខុសត្រូវទៀតផង (៥) មិនមែនមនុស្សទាំងអស់សុទ្ធតែចេះមានការស្រមើស្រមៃ និងចេះច្នៃប្រឌិត ក្នុងការរកដំណោះស្រាយនៃបញ្ហាក្នុងអង្គភាពឡើយ និង (៦) នៅក្នុងសង្គមឧស្សាហកម្ម សក្តានុពលខាងផ្នែកបញ្ញារបស់មនុស្សប្រើប្រាស់បានតែមួយភាគប៉ុណ្ណោះ។

នាពេលបច្ចុប្បន្ន មានទ្រឹស្តីថ្មីៗទៀតបានលេចចេញជារូបរាងឡើង ដូចជាទ្រឹស្តីកែលម្អសាលារៀន ទ្រឹស្តីសហគមន៍ប្រជាធិបតេយ្យ និងទ្រឹស្តីយុត្តិធម៌សង្គម។ តាមទ្រឹស្តីកែលម្អសាលារៀន គណនេយ្យភាពនៃការកែលម្អសាលារៀន គឺជាចំណុចស្នូលនៃគោលនយោបាយរបស់រដ្ឋ ហើយដែលបង្កើតឡើងនូវចលនាដែលទាមទារ ឱ្យបង្កើតស្តង់ដានៃលទ្ធផលសិក្សារបស់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សិស្ស ហើយនាយកសាលា និងគ្រូបង្រៀនត្រូវទទួលខុសត្រូវចំពោះលទ្ធផលសិក្សារបស់សិស្ស។ ការធ្វើអធិការកិច្ចត្រូវផ្តោតលើការរៀន និងការបង្រៀន។ ដើម្បីវាស់វែងលទ្ធផលសិក្សារបស់សិស្ស គេរៀបចំឱ្យមានរង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ហើយគ្រូត្រូវមានការបណ្តុះបណ្តាល មានសម្ភារឧបទេស និងឯកសារ ដើម្បីបង្រៀនសិស្សឱ្យសម្រេចបានតាមស្តង់ដារ។

ទ្រឹស្តីសហគមន៍ប្រជាធិបតេយ្យលើកកម្ពស់ការផ្លាស់ប្តូរគំនិត ដែលជួយឱ្យមនុស្សទទួលបាននូវព័ត៌មាន ការត្រិះរិះពិចារណា និងការវិភាគដើម្បីវាយតម្លៃគំនិត និងគោលនយោបាយ។ បុគ្គលនីមួយៗមានការទទួលខុសត្រូវក្នុងការចូលរួមក្នុងការពិភាក្សា ការជ្រើសរើស និងការអនុវត្តសកម្មភាពរួម ដើម្បីសម្រេចបាននូវផលប្រយោជន៍រួមក្នុងសង្គម។

ទ្រឹស្តីយុត្តិធម៌សង្គមចាត់ទុកយុត្តិធម៌សង្គម ជាស្នូលនៃលទ្ធិប្រជាធិបតេយ្យ ដែលប្រជាពលរដ្ឋគ្រប់រូបត្រូវមានសិទ្ធិស្មើៗគ្នា ក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ និងការអប់រំ។ ដើម្បីសម្រេចបាននូវយុត្តិធម៌សង្គម គេត្រូវយកចិត្តទុកដាក់ដល់គុណភាពអប់រំ និងសមធម៌ ក្នុងការទទួលសេវាអប់រំគ្រប់ប្រភេទ។

ជារួម ការគ្រប់គ្រងអប់រំ គឺជាការសម្រេចបាននូវគោលដៅនៃការអប់រំតាមរយៈការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃធាតុចូលដែលមាន។ ការគ្រប់គ្រងអប់រំ ផ្តោតទៅលើការប្រើប្រាស់នូវធនធានដែលមានក្នុងបរិស្ថាន ដើម្បីឈានទៅសម្រេចបានតាមគោលដៅរៀន និងបង្រៀន។ ការគ្រប់គ្រងអប់រំ គឺជាការគ្រប់គ្រងនូវទិដ្ឋភាពផ្សេងៗ ក្នុងការផ្តល់សេវាអប់រំ រួមទាំងការគ្រប់គ្រងទំនាក់ទំនងរវាងតួអង្គផ្សេងៗ ដែលពាក់ព័ន្ធក្នុងការផ្តល់សេវាអប់រំ ដើម្បីសម្រេចបានតាមគោលដៅនៃការអប់រំអ្នកសិក្សា។

ការគ្រប់គ្រងអប់រំ មានមុខងារដូចជា៖ (១) ការធ្វើផែនការ (២) ការអនុវត្តផែនការ (៣) ការលើកទឹកចិត្ត (៤) ការត្រួតពិនិត្យ (៥) ការសម្រប



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រួល (៦) ការសម្រេចចិត្ត និង (៧) ការត្រួតពិនិត្យ និងរបាយការណ៍។ ការគ្រប់គ្រង ការអប់រំ ត្រូវផ្តោតលើការគ្រប់គ្រង តាមបីកម្រិត គឺ៖

ទីមួយ-ការគ្រប់គ្រង «គោលនយោបាយអប់រំ» តាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) និងយន្តការអនុវត្ត ដូចជាការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP) ការអនុវត្តថវិកាប្រចាំឆ្នាំ ដោយផ្តោតលើសកម្មភាព ដែលបានកំណត់នៅក្នុងផែនការប្រតិបត្តិ ដូចជាការរៀបចំកម្មវិធីសិក្សា ការផ្តល់សៀវភៅសិក្សាគោល ការបើកផ្តល់ប្រាក់បៀវត្ស និងការបើកផ្តល់ថវិកាដំណើរការសាលារៀន

ទីពីរ- ការគ្រប់គ្រង «ការអប់រំគ្រូបង្រៀន» មានការអប់រំដំបូង (PRE-SERVICE) ការអភិវឌ្ឍវិជ្ជាជីវៈបន្ត(CPD) គ្រូបង្រៀន និងនាយកសាលារៀន ការរៀបចំវគ្គបំប៉នទ្វី។

ទីបី-«ការគ្រប់គ្រងគ្រឹះស្ថានសិក្សា» ដែលត្រូវផ្តោតលើ ៖

(១) ការគ្រប់គ្រង និងដឹកនាំរបស់នាយក

(២) ការរៀន និងការបង្រៀន

(៣) លទ្ធផលសិក្សារបស់សិស្ស

(៤) ការចូលរួមរបស់មាតាបិតា និងសហគមន៍



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ជំពូកទី ៤
# ទ្រឹស្តីស្តីពីកំណែទម្រង់ការអប់រំ

## ៤.១. ការវិវត្តនៃទ្រឹស្តីនៃកំណែទម្រង់ការអប់រំ

*ប្រព័ន្ធអប់រំ គឺជាវិស័យមួយដែលគេតែងតែមានទស្សនៈខុសៗគ្នា* (Vergugo, 2014)។ *ការអភិវឌ្ឍឧស្សាហកម្មតម្រូវឱ្យប្រទេសមួយត្រូវបណ្តុះបណ្តាលកម្លាំងពលកម្មឱ្យបានល្អ ទៅតាមតម្រូវការរបស់សេដ្ឋកិច្ច។ ដើម្បីសម្រេចបានតាមគោលដៅនេះ កំណែទម្រង់ និងគោលនយោបាយអប់រំត្រូវឆ្លើយតបសមស្របទៅនឹងតម្រូវការខុសៗគ្នា ក្នុងដំណាក់កាលផ្សេងៗនៃការអភិវឌ្ឍសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយ ប្រវត្តិសាស្ត្រ វប្បធម៌ និងរបបគ្រប់គ្រងរដ្ឋបាលបានកំណត់ពីបរិបទសម្រាប់គោលនយោបាយអប់រំ និងកំណែទម្រង់* (Verdugo, ២០១៤)។ *ដូចនេះ កំណែទម្រង់ការអប់រំ គឺមិនអាចមានដំណើរការដូចគ្នានោះទេ។ លើសពីនេះទៀត ក្រុមបក្សផ្សេងៗតែងតែប្រកួតប្រជែងជាញឹកញាប់ ដើម្បីមានឥទ្ធិពលលើដំណើរការកំណែទម្រង់។*

*គេសង្កេតឃើមានទ្រឹស្តីជាច្រើនស្តីពីកំណែទម្រង់ការអប់រំ ហើយទ្រឹស្តីទាំងនេះបានវិវឌ្ឍអស់ជាច្រើនឆ្នាំមកហើយ។* Paulston (១៩៧៦) *បែងចែកទ្រឹស្តីកំណែទម្រង់ការអប់រំជាបីក្រុម៖*

(១) *កំណែទម្រង់ការអប់រំ គឺជាផ្នែកមួយនៃការផ្លាស់ប្តូរសង្គម ដែលកើតចេញពីជម្លោះ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(២) កំណែទម្រង់ការអប់រំ គឺជាការផ្លាស់ប្តូរមនោគមវិជ្ជា និង

(៣) កំណែទម្រង់ការអប់រំ គឺជាការផ្លាស់ប្តូរគំរូៗ

Paulston(១៩៧៦) បានវិភាគទ្រឹស្តីកំណែទម្រង់ការអប់រំ ដែលជាផ្នែកនៃការផ្លាស់មនោគមវិជ្ជានិងសង្គម និងកើតចេញពីតុល្យភាព និងជម្លោះ។ គាត់ចាត់ថ្នាក់ទ្រឹស្តីជា៦ផ្នែក (និងបែងចែកជាពីក្រុម)៖ (ក) ទ្រឹស្តីលំនឹងរួមមាន៖ (១) ការបដិវត្តន៍ និងការបដិវត្តន៍ថ្មី (២) ទ្រឹស្តីជាប្រព័ន្ធ (៣) មុខងារ និងរចនាសម្ព័ន្ធ និង (ខ) ទ្រឹស្តីជម្លោះរួមមាន៖ (៤) ទ្រឹស្តីម៉ាក្សនិយម និងម៉ាក្សនិយមបែបថ្មី (៥) ការរស់រៀននៃវប្បធម៌ និង (៦) ទ្រឹស្តីស្រមើស្រមៃនិយមគ្មានសណ្តាប់ធ្នាប់ (anarchistic-utopian)។ គាត់ក៏បានសន្មតជាកំណែទម្រង់ការអប់រំគឺជាការផ្លាស់ប្តូរគំរូមួយៗ យើងនឹងប្រើប្រាស់ទ្រឹស្តីនៃកំណែទម្រង់ការអប់រំ គឺជាការផ្លាស់ប្តូរគំរូ ដើម្បីណែនាំក្នុងការស្រាវជ្រាវបច្ចុប្បន្ននេះៗ តើអ្វីទៅជាកំណែទម្រង់ការអប់រំ ហើយកំណែទម្រង់ការអប់រំនាំមកនូវអ្វីខ្លះ? ខាងក្រោមនេះ គឺជាទស្សនៈរបស់អ្នកប្រាជ្ញដែលបានសិក្សាពីកំណែទម្រង់ការអប់រំក្នុងរយៈពេលជាច្រើនឆ្នាំៗ ទស្សនាទានទាំងអស់នេះបង្ហាញឱ្យឃើញពីកត្តាសំខាន់ៗដែលគេត្រូវកែលម្អ ដើម្បីលើកកម្ពស់គុណភាពអប់រំ និងដើម្បីធ្វើឱ្យវិស័យអប់រំឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិៗ

កំណែទម្រង់អប់រំផ្អែកយ៉ាងខ្លាំងលើមូលដ្ឋាននៃមនោគមវិជ្ជានយោបាយ ជាជាងឈរលើមូលដ្ឋាននៃភស្តុតាងទទួលបានពីការស្រាវជ្រាវ គួរឱ្យទុកចិត្តៗ ជាទូទៅកំណែទម្រង់ការអប់រំមានគោលបំណងកែលម្អកម្មវិធីអប់រំ ហើយការអនុវត្តនឹងជួយសម្រេចគោលបំណងទូទៅនៃការអប់រំកាន់តែមានប្រសិទ្ធភាព (Fullan, ២០០៧)ៗ កំណែទម្រង់ការអប់រំទាក់ទងនឹងការផ្លាស់ប្តូរក្នុងរចនាសម្ព័ន្ធស្ថាប័ន ទំនាក់ទំនង ការបែងចែកធនធាន ការអនុវត្តជំនឿ និងអាកប្បកិរិយាៗ Paulston (១៩៧៦) យល់ឃើញថា កំណែទម្រង់ការអប់រំដ៏ធំ តែងតែទាក់ទងនឹងដំណើរការនយោបាយ និងការអនុវត្ត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់ការបែងចែកអំណាចឡើងវិញ។ ការផ្លាស់ប្តូរការអប់រំត្រូវបានពិនិត្យដោយអ្នកគាំទ្រមួយចំនួននៃទ្រឹស្តីជម្លោះ (Applebaum, 1970 cited in Fagerlind & Saha, 1989; Horton, 1966) ជាផ្នែកមួយដ៏ធំនៃការផ្លាស់ប្តូរសង្គម។ Freire (១៩៧១) ពន្យល់ថា យុទ្ធសាស្ត្រមនោគមវិជ្ជាដ៏ខ្លាំងសម្រាប់ការអប់រំដែលសន្មតថានឹងផ្តល់សេរីភាពដល់ប្រជាជន ដែលរងការកៀបសង្កត់ តាមរយៈការពិគ្រោះយោបល់ ការអភិវឌ្ឍភាសា និងគេចផុតពីការចាត់ទុកខ្លួនឯងថា មានកម្រិតវប្បធម៌ទាប (self-perceived cultural inferiority)។

លើសពីនេះទៀត Paulston (១៩៧៦) ប្រៀបធៀបកំណែទម្រង់ការអប់រំទៅនឹងការផ្លាស់ប្តូរម៉ូដែលរបស់លោក Kuhn ឬការផ្លាស់ប្តូរគំនិតចំពោះពិភពលោក។ ពេលដែលមានការផ្លាស់ប្តូរម៉ូដែល កំណែទម្រង់ការអប់រំបាននាំមកនូវក្របខ័ណ្ឌគំនិតថ្មីមួយ ដោយចាប់ផ្តើមមានគោលបំណងការអប់រំថ្មីមួយ និងមើលឃើញពីរបៀបដែលប្រជាជនសិក្សា និងតម្រូវការក្នុងការទទួលនូវការបង្រៀនថ្មី មធ្យោបាយវាយតម្លៃ និងសម្ភារថ្មី ជាដើម (Irez & Han, 2011)។

ផ្នែកសំខាន់នៃការស្រាវជ្រាវបានចង្អុលពីការផ្លាស់ប្តូរការអប់រំ ដែលផ្អែកលើមនោគមនវិជ្ជានយោបាយជាជាងភស្តុតាងពីការស្រាវជ្រាវ។ វាបានពន្យល់ពីមូលហេតុដែលមានករណីបរាជ័យជាច្រើននៃកំណែទម្រង់រហូតមកដល់បច្ចុប្បន្ន (Levin, ២០១០)។ Verdugo (២០១៤) គិតថាគោលនយោបាយកំណែទម្រង់ការអប់រំត្រូវបានកំណត់ក្នុងបរិបទនៃរបបនយោបាយក្នុងចំណោមប្រទេសជាតិដែលបានរៀបចំ និងគ្រប់គ្រង។

Fägerlind និង Saha (១៩៨៩) ឱ្យនិយមន័យថា កំណែទម្រង់ការបែងចែកធនធានអប់រំ ផ្តល់ជាលទ្ធផលនៃការកែប្រែជាមូលដ្ឋាននៃគោលនយោបាយអប់រំជាតិ។ វាបណ្តាលឱ្យមានការផ្លាស់ប្តូរដ៏ធំក្នុងផ្នែកខ្លះនៃវិស័យអប់រំ ឬទាំងស្រុងដូចខាងក្រោម៖ (១) បង្កើនការបែងចែកធនធានថ្នាក់ជាតិដល់វិស័យអប់រំទាំងមូល (២) បង្កើនការបែងចែកធនធានក្នុង

ប្រព័ន្ធអប់រំដល់គ្រប់កម្រិតក្នុងប្រព័ន្ធ (៣) ភាគរយសិស្សដែលបញ្ចប់កម្រិតខុសៗគ្នាក្នុងប្រព័ន្ធអប់រំ (៤) ភាគរយសិស្សមកពីស្រទាប់សង្គមខុសៗគ្នា ឬភាគរយសិស្សស្រី ដែលបញ្ចប់ការសិក្សាក្នុងភូមិសិក្សាខុសគ្នាក្នុងប្រព័ន្ធអប់រំ និង (៥) គោលបំណងនៃកម្មវិធីសិក្សា និងមាតិកា។

កំណែទម្រង់ការអប់រំក្នុងប្រទេសកំពុងអភិវឌ្ឍគ្របដណ្ដប់លើបញ្ហាជាច្រើន បញ្ហាទាំងនោះគឺមិនត្រឹមតែការអប់រំពីធម្មជាតិនោះទេ។ ក្នុងអំឡុងពីរទសវត្សចុងក្រោយ កំណែទម្រង់ការអប់រំបានផ្លាស់ប្ដូរពីការផ្លាស់ប្ដូរផ្អែកលើមនោគមវិជ្ជា ឆ្ពោះទៅរកការផ្លាស់ប្ដូរជាម៉ូដែល។ ពេលដែលពិនិត្យកត្តាជាច្រើន ដែលកំណត់ចំនួនឆ្នាំរបស់កុមារត្រូវចុះឈ្មោះចូលរៀនក្នុងសាលារៀន និងកម្រិតនៃការសិក្សាដែលពួកគេបានរៀនក្នុងសាលា។ Glewwe (២០១៤) បានចាត់ថ្នាក់កត្តាធំៗដែលមានឥទ្ធិពលលើគុណភាពនៃការអប់រំជា ៤ ក្រុមធំៗ៖ (១) កត្តាគ្រូបង្រៀន (២) កត្តាសាលារៀន (៣) កត្តាសិស្ស និង (៤) កត្តាគ្រួសារ។

Wideen (១៩៩៤) បានកំណត់បរិបទនៃការផ្លាស់ប្ដូរការអប់រំ ដោយផ្អែកលើផ្នែកទាំង៥ នៃប្រព័ន្ធអប់រំ៖ (១) កំណែទម្រង់កម្មវិធីសិក្សា (២) ការកែលម្អសាលារៀន (៣) ប្រសិទ្ធភាពសាលារៀន (៤) ការស្រាវជ្រាវរបស់គ្រូបង្រៀន និង (៥) ការអភិវឌ្ឍន៍គ្រូបង្រៀន។ កំណែទម្រង់កម្មវិធីសិក្សាទាក់ទងនឹងការប្រើប្រាស់សម្ភារសិក្សាកាន់តែប្រសើរ។ កំណែទម្រង់កែលម្អសាលាចាត់ទុក សាលាជាឯកត្តាដែលត្រូវផ្លាស់ប្ដូរ។ ដូច្នេះ កំណែទម្រង់មានគោលបំណងដោះស្រាយបញ្ហា និងលក្ខខណ្ឌខាងក្នុងដែលសាលាកំពុងប្រឈម។ មធ្យោបាយបង្កើនប្រសិទ្ធភាពសាលាផ្ដោតលើភាពជោគជ័យរបស់សិស្ស។ មធ្យោបាយឆ្ពោះទៅរកការស្រាវជ្រាវរបស់គ្រូបង្រៀនតម្រូវឱ្យគ្រូបង្រៀនធ្វើការស្រាវជ្រាវដើម្បីកែលម្អការបង្រៀន។ មធ្យោបាយអភិវឌ្ឍន៍គ្រូបង្រៀនផ្ដោតលើគ្រូបង្រៀនជាអ្នកច្នៃប្រឌិត និងជាភ្នាក់ងារនៃការផ្លាស់ប្ដូរ។ ក្នុងចំណោមមធ្យោបាយទាំងអស់នេះ គ្រូបង្រៀន គឺជាបេះដូង

នៃដំណើរការកំណែទម្រង់សាលា។

Fullan (២០០៧) យល់ឃើញថា កំណែទម្រង់ការគ្រប់គ្រងការអប់រំបង្កើតបានជាដំណើរការនៃការផ្លាស់ប្តូរ ដែលរួមមាន៣ដំណាក់កាលបន្តបន្ទាប់៖ (១) ការចាប់ផ្តើម (២) ការអនុវត្ត និង (៣) ការបង្កើតស្ថាប័ន។ ទំនាក់ទំនងរវាងដំណាក់កាលទាំងបីមានលក្ខណៈស្មិតរមួតនឹងគ្នា។ Fullan (២០០៧) បានកំណត់កត្តា ៣ ផ្តោះទៅរកការចាប់ផ្តើមកំណែទម្រង់ការអប់រំ៖ (១) ទំនាក់ទំនង (២) ការត្រៀមខ្លួន និង (៣) ធនធាន។ នៅដំណាក់កាលបង្កើតស្ថាប័ន អ្នកពាក់ព័ន្ធទាំងអស់ត្រូវចូលរួមក្នុងការផ្លាស់ប្តូរ ហើយកំណែទម្រង់បានបង្កប់ក្នុងសកម្មភាពប្រចាំថ្ងៃ។ ការស្រាវជ្រាវបានបង្ហាញថា មានកត្តាដ៏មានឥទ្ធិពលជាច្រើនដែលបង្កើតបានជាអញ្ញត្តិទំនាក់ទំនងគ្នា យ៉ាងសកម្មដើម្បីកំណត់ពីភាពជោគជ័យ ឬបរាជ័យនៃកំណែទម្រង់ការអប់រំ។

យោងតាម Cheng (២០០១) មានរលកបីនៃកំណែទម្រង់ការគ្រប់គ្រងការអប់រំ។ ប្រទេសខុសគ្នា ប្រឈមនឹងលក្ខខណ្ឌបរិបទសេដ្ឋកិច្ច និងប្រវត្តិសាស្ត្រខុសគ្នា គឺមានដំណាក់កាលកំណែទម្រង់ខុសគ្នា។ ខាងក្រោមនេះគឺជាលក្ខណៈគំរូតន្ទឹះ នៃរលកទាំងបីនៃកំណែទម្រង់ការគ្រប់គ្រងការអប់រំ។ យើងឃើញថា មានប្រទេសជាច្រើនដែលធ្វើកំណែទម្រង់ការអប់រំ តែមុខសញ្ញានៃកំណែទម្រង់ការអប់រំផ្តោតលើអាទិភាពខុសៗគ្នា ទៅតាមដំណាក់កាលនីមួយៗ។ លទ្ធផលនៃកំណែទម្រង់ក្នុងដំណាក់កាលទី១ បានជំរុញឱ្យមានការកែលម្អ និងការយកចិត្តទុកដាក់ ក្នុងការរៀបចំកម្មវិធីកំណែទម្រង់នៅតាមដំណាក់កាលបន្តបន្ទាប់ទៀត។

ដំណាក់កាលទី១៖ កំណែទម្រង់ការគ្រប់គ្រងការអប់រំផ្តោតលើប្រសិទ្ធភាពខាងក្នុង ដោយពង្រឹងដំណើរការសាលារៀនខាងក្នុង ជាពិសេសមានគោលដៅកែលម្អវិធីសាស្ត្របង្រៀន និងដំណើរការនៃការរៀន និងការបង្រៀន។ ការអនុវត្តកំណែទម្រង់ពីលើចុះក្រោម មានគោលបំណងធ្វើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឱ្យប្រសើរនូវដំណើរការគ្រប់គ្រងសាលារៀន ហើយការធ្វើកំណែទម្រង់ការអប់រំមានគោលបំណងសម្រេចគោលដៅ និងវត្ថុបំណងនៅកម្រិតសាលា ឬប្រព័ន្ធទាំងមូល។ គោលដៅសំខាន់ គឺ ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស។ ដូច្នេះ នៅដំណាក់កាលទីមួយ គោលដៅសំខាន់នៃកំណែទម្រង់ការអប់រំ គឺការកែលម្អការរៀន និងការបង្រៀននៅក្នុងសាលារៀន។

ដំណាក់កាលទី២ ៖ កំណែទម្រង់ការគ្រប់គ្រងការអប់រំផ្តោតលើប្រសិទ្ធភាពនៃប្រព័ន្ធអប់រំទាំងមូល ក្នុងគោលបំណងទទួលបាននូវគុណភាពអប់រំ ការពេញចិត្តរបស់អ្នកចូលរួម និងភាពប្រកួតប្រជែងរបស់ប្រទេសលើទីផ្សារការងារ។ ទំនាក់ទំនងរវាងសាលា និងសហគមន៍តម្រូវឱ្យមានការធានាគុណភាពអប់រំ ការធ្វើអធិការកិច្ចតាមសាលារៀន ការចូលរួមរបស់ឪពុកម្តាយនិងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀន និងការបង្កើតមូលនិធិដំណើរការសាលារៀន។ ដូច្នេះ នៅដំណាក់កាលទីពីរ គោលដៅសំខាន់នៃកំណែទម្រង់ការអប់រំ គឺការធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ចដោយប្រើយន្តការទីផ្សារជាធំ ហើយកំណែទម្រង់ គឺមានគោលដៅពង្រឹងភាពប្រណាំងប្រជែងរបស់ប្រទេស។

ដំណាក់កាលទី៣ ៖ កំណែទម្រង់ការគ្រប់គ្រងការអប់រំផ្តោតលើប្រសិទ្ធភាពអនាគតក្នុងគោលបំណងឆ្លើយតបនឹងមុខងារអប់រំថ្មីក្នុងសតវត្សទី២១ និងធានាទំនាក់ទំនងទៅនឹងការសិក្សា ការបង្រៀន និងការរៀនក្នុងសាលា ក្នុងបរិបទនៃសកលភាវូបនីយកម្ម មូលដ្ឋានភាវូបនីយកម្ម និងបុគ្គលភាវូបនីយកម្ម។ សកលភាវូបនីយកម្មការអប់រំផ្តល់នូវឱកាសសម្រាប់ការសិក្សាតាមអ៊ីនធឺណែត សន្និសីទតាមវីឌីអូ និងកិច្ចសហការណ៍អន្តរជាតិក្នុងការសិក្សានិងបង្រៀន។ មូលដ្ឋានភាវូបនីយកម្មក្នុងការអប់រំរួមមាន ការគាំទ្ររបស់សហគមន៍ និងការចូលរួមរបស់មាតាបិតា ក្នុងការគ្រប់គ្រងសាលារៀន (school-based management) និងកម្មវិធីសិក្សាទាក់ទងនឹងសហគមន៍។ កម្មវិធីអប់រំជាបុគ្គល ហើយគោលបំណង និងវិធីសាស្ត្រនៃការសិក្សា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាបុគ្គល បានលើកទឹកចិត្តកូនសិស្ស និងគ្រូបង្រៀនឱ្យធ្វើស្វ័យសិក្សា ការកំណត់កាលត្រឹមត្រូវ និងចាប់ផ្តើមសិក្សាដោយខ្លួនឯង (Cheng, ២០០១)។

ទីក្រុងហុងកុងបានចាប់ផ្តើមកំណែទម្រង់ការគ្រប់គ្រងការអប់រំលើកទី១ ក្នុងអំឡុងទសវត្សរ៍១៩៧០ ដោយប្រើប្រាស់កំណែទម្រង់ពីលើចុះក្រោម និងបង្កើនធាតុចូលជាធនធាន ដោយមានបំណងធ្វើឱ្យប្រសើរការបង្រៀនភាសា និងលក្ខខណ្ឌសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ឥទ្ធិពលនៃកំណែទម្រង់លើកទី១នេះនៅមានកម្រិត ដោយសារកំណែទម្រង់មិនបានគិតគូរពីដំណើរការសាលា និងតម្រូវការរបស់សាលារៀន (Cheng, ២០០១)។ ដើម្បីដោះស្រាយចំណុចខ្វះខាតទាំងនេះ ហុងកុងបានផ្តើមកំណែទម្រង់ការគ្រប់គ្រងការអប់រំលើកទី២ក្នុងឆ្នាំ ១៩៩៧ ដោយមានចរិតលក្ខណៈដូចជា៖ (១) មធ្យោបាយការគ្រប់គ្រងផ្អែកលើសាលារៀន (សាលារៀនគឺមិនដូចគ្នា សាលារៀន គឺជាក្រុមនៃការកែលម្អ) (២) កំណែទម្រង់ពីក្រោមទៅលើ (នាយកសាលារៀន និងគ្រូបង្រៀនគឺជាខ្សែខាងមុខនៃកំណែទម្រង់ការគ្រប់គ្រងការអប់រំក្នុងនាមជាអ្នកអនុវត្តការអប់រំ និងការលើកកម្ពស់គុណភាព (៣) ការធានាគុណភាព និងគណនេយ្យភាព (សាលារៀនមានស្វ័យភាព និងភាពបត់បែនក្នុងការប្រើប្រាស់ធនធានសាធារណៈ ដើម្បីអនុវត្តសកម្មភាពក្នុងក្របខ័ណ្ឌគណនេយ្យភាព) (៤) ចំណេះដឹងផ្អែកតម្រូវការស្រាវជ្រាវ (ការប្រើប្រាស់ចំណេះដឹង និងការស្រាវជ្រាវដើម្បីគាំទ្រការពិភាក្សា និងបង្កើតគោលនយោបាយ និងធ្វើឱ្យប្រសើរការអនុវត្តការអប់រំ)។ នាពេលបច្ចុប្បន្ន ហុងកុង កំពុងចាប់ផ្តើមកំណែទម្រង់ការគ្រប់គ្រងការអប់រំលើកទី៣ ក្នុងការឆ្លើយតបទៅនឹងបច្ចេកវិទ្យា សេដ្ឋកិច្ច សង្គម នយោបាយ វប្បធម៌ និងសិក្សាពីសកលភាវូបនីយកម្ម។ គោលបំណងនៃកំណែទម្រង់នេះ គឺដើម្បីគាំទ្រសិស្សឱ្យក្លាយជាប្រជាពលរដ្ឋមានប្រាជ្ញាច្រើនផ្នែក (Multiple intelligence)។ ក្នុងក្របខ័ណ្ឌរបស់ Howard Gardner (១៩៨៣) ប្រាជ្ញាទាំង៧របស់មនុស្សរួមមាន៖ (១) ប្រាជ្ញាផ្នែកតន្ត្រី (២) ប្រាជ្ញាដោយញាណរបស់រាងកាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(៣) ប្រាជ្ញាគណិតវិទ្យា (៤) ប្រាជ្ញាផ្នែកអក្សរសាស្ត្រ (៥) ប្រាជ្ញាផ្នែកលំហអាកាស (៦) ប្រាជ្ញាអន្តរបុគ្គល និង (៧) ប្រាជ្ញាខាងក្នុងរបស់ បុគ្គល។

Tan និង Gopinathan (២០០០) បានធ្វើសំយោគនៃកំណែទម្រង់ ការគ្រប់គ្រងការអប់រំក្នុងប្រទេសសិង្ហបុរីជាបន្តបន្ទាប់។ តាំងពីពាក់កណ្តាលទសវត្ស ១៩៨០ ប្រទេសសិង្ហបុរីបានអនុវត្តកម្មវិធីកំណែទម្រង់គ្រប់គ្រងការអប់រំជាបន្តបន្ទាប់ ដោយមានគោលបំណងពង្រឹងភាពប្រកួតប្រជែងសេដ្ឋកិច្ចជាតិ ក្នុងសេដ្ឋកិច្ចពិភពលោក។ កំណែទម្រង់ការគ្រប់គ្រងការអប់រំក្នុងប្រទេសសិង្ហបុរីផ្តោតលើបង្កើនស្វ័យភាពសាលារៀន និងការប្រកួតប្រជែងរវាងសាលារៀន។ ជាការចាប់ផ្តើម ក្រសួងអប់រំផ្តល់ជំនួយចំនួន៨ (ឬ ៥% នៃសាលារៀនមធ្យមសិក្សាចំនួន ១៦៣) ដោយស្វ័យប្រវត្តិ និងអាចបទបែនក្នុងការបណ្តុះបណ្តាល ការពង្រាយ និងលើកទឹកចិត្តបុគ្គលិក ហិរញ្ញវត្ថុការគ្រប់គ្រង និងកម្មវិធីសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយសាលារៀនឯករាជ្យទាំងនោះ ត្រូវបានរិះគន់ចំពោះការជ្រើសរើសជាពិសេសនេះ និងថ្លៃសិក្សាមានកម្រិតខ្ពស់។ បន្ទាប់មក វាបានឈានទៅរកការបង្កើតក្នុងទសវត្សឆ្នាំ១៩៩០ នូវសាលារៀនមានស្វ័យភាពចំនួន១៨ ដែលតម្លៃសិក្សាអាចទទួលយកបាន ប៉ុន្តែការផ្តល់សញ្ញាបត្រមានកម្រិតតិចតួច សម្រាប់ប្រតិបត្តិការស្វ័យភាពនេះ។

ចរិតលក្ខណៈផ្សេងទៀតនៃកំណែទម្រង់ការគ្រប់គ្រងការអប់រំក្នុងប្រទេសសិង្ហបុរីបានបញ្ជាក់ពីការប្រកួតប្រជែកក្នុងចំណោមសាលារៀន។ សាលារៀនផ្តោតលើកការកែលម្អកម្មវិធីរបស់ពួកគេ ហើយឪពុកម្តាយអាចជ្រើសរើសផ្អែកតាមលំដាប់ថ្នាក់។ សាលារៀនមធ្យមសិក្សាត្រូវបានចាត់ថ្នាក់ផ្អែកលើលក្ខណៈចំនួន៣៖ (១) រួមមានការវាស់វែងលទ្ធផលរួមរបស់សិស្សក្នុងសញ្ញាបត្រទូទៅប្រចាំឆ្នាំ (ធម្មតា) នៃការធ្វើតេស្តកម្រិតអប់រំ (២) ការប្រព្រឹត្តទៅនៃការធ្វើតេស្តសិស្សដោយផ្អែកលើពិន្ទុនៃការប្រលងចូលសាលារៀន (បន្ទាប់ពីកម្រិតធម្មតា) និង (៣) ថ្លឹងថ្លែងសន្ទស្សន៍នៃការប្រតិបត្តិ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

របស់សាលាចំពោះគេស្តកាយសម្បទានថ្នាក់ជាតិ និងការរេយសិស្សលើស ទំងន់ក្នុងសាលា។

បន្ទាប់ពីការចាប់ផ្តើមនៃវិបត្តិហិរញ្ញវត្ថុអាស៊ីក្នុងឆ្នាំ ១៩៩៧ គំនិតផ្តួចផ្តើមកំណែទម្រង់ការគ្រប់គ្រងអប់រំដ៏ធំមួយ ត្រូវបានដាក់ឱ្យដំណើរការ ដើម្បីព្យាករការបង្កើតថ្មី និងការច្នៃប្រឌិតរបស់សិស្ស។

គំនិតផ្តួចផ្តើមទី១៖ គឺ Thinking School Learning Nation (សាលារៀនគិតប្រទេសជាតិរៀនសូត្រ)។ យុទ្ធសាស្ត្រកំណែទម្រង់ការអប់រំរួមមាន៖ (១) បង្រៀនជំនាញត្រិះរិះពិចារណា និងការច្នៃប្រឌិត (២) កាត់បន្ថយមាតិកាប្រធានបទសិក្សា (content knowledge) (៣) កែតម្រូវគំរូវាយតម្លៃ និង (៤) ការសង្កត់ធ្ងន់កាន់តែខ្លាំងលើដំណើរការ ជំនួសឱ្យលទ្ធផលពេលវាយតម្លៃសាលា។

គំនិតផ្តួចផ្តើមទី២៖ គឺ «ផែនការមេបច្ចេកវិទ្យាព័ត៌មានក្នុងការអប់រំ» ដើម្បីជំរុញបច្ចេកវិទ្យាព័ត៌មានក្នុងការបង្រៀន និងសិក្សាក្នុងសាលា។ គំនិតផ្តួចផ្តើមនេះមានគោលបំណងដើម្បីបង្កើតបណ្តាញសាលាទាំងអស់ និងផ្តល់កុំព្យូទ័រដល់សិស្សនិងគ្រូបង្រៀន (Tan និង Gopinatha, ២០០០)។

## ៤.២. ទ្រឹស្តីពលរដ្ឋមានគុណភាព

តើអ្វីទៅជាគោលដៅនៃកំណែទម្រង់ការអប់រំ ហើយគេធ្វើកំណែទម្រង់ការអប់រំដើម្បីអ្វី? ខាងក្រោមនេះ គឺជាទស្សនាទានសំខាន់ៗនៃគោលដៅចុងក្រោយនៃកំណែទម្រង់ការអប់រំ គឺការអប់រំមនុស្សឱ្យក្លាយជាពលរដ្ឋល្អ ជាពលរដ្ឋដែលមានលក្ខណសម្បត្តិពេញលេញ ដែលយើងសន្មតិហៅថា «ពលរដ្ឋមានគុណភាព»។

### ៤.២.១. ការវិវត្តនៃទស្សនាទានពលរដ្ឋ

ការអប់រំ មិនត្រឹមតែរៀបចំប្រជាពលរដ្ឋឱ្យឆ្លើយតបទៅនឹងតម្រូវការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នៃការអភិវឌ្ឍសេដ្ឋកិច្ចប៉ុណ្ណោះទេ តែកំណែទម្រង់ត្រូវរៀបចំឱ្យប្រជាពលរដ្ឋត្រៀមលក្ខណៈ ដើម្បីប្រឈមនឹងបញ្ហាសកលលោក និងរួមចំណែកដល់ការជានាសមភាព និងនិរន្តរភាពរបស់ពិភពលោកផងដែរ។ ដើម្បីសម្រេចគោលដៅដ៏ពិសិដ្ឋនេះ អ្នកអប់រំបានធ្វើសមាហរណកម្មការអប់រំប្រជាពលរដ្ឋទៅក្នុងកម្មវិធីសិក្សាតាមសាលារៀន និងបានធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីកែលម្អលទ្ធផលសិក្សា។

ទោះបីជាយ៉ាងណាក៏ដោយ គំនិតប្រជាពលរដ្ឋគឺជាសញ្ញានៃការប្រកួតប្រជែង។ នៅក្នុងឯកសារស្រាវជ្រាវវិទ្យាសាស្ត្រ គេបានផ្តល់និយមន័យផ្សេងៗគ្នាពីប្រជាពលរដ្ឋ។ ប្រាកដណាស់ ប្រជាពលរដ្ឋ គឺជាទស្សនាទានស្មុគស្មាញ ពហុទិដ្ឋភាព និងសកម្ម។ ដូច្នេះ គ្មានទេនិយមន័យតែមួយគត់នៃគុណភាពប្រជាពលរដ្ឋ។ គុណភាពប្រជាពលរដ្ឋ គឺជាទស្សនៈដែលមិនច្បាស់លាស់។ គេអាចចាត់ទុកថា ប្រជាពលរដ្ឋ គឺជាទស្សនៈដែលប្រជាជនរស់នៅក្នុងសហគមន៍មួយ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងអក្សរសិល្ប៍ស្រាវជ្រាវ មានការសិក្សាជាច្រើនលើទស្សនាទាននៃគុណភាពប្រជាពលរដ្ឋ ឬប្រជាពលរដ្ឋមានគុណភាពនេះ។

នៅក្នុងប្រវត្តិសាស្ត្រ នៅក្នុងទស្សនាទានប្រជាពលរដ្ឋមិនរួមបញ្ចូលពលរដ្ឋគ្រប់រូបនោះទេ ដោយសារតាំងតែពីយូរលង់ណាស់មកហើយ មានតែបុរស ឬម្ចាស់ទ្រព្យសម្បត្តិ ដែលនៅក្នុងសង្គមរ៉ូមបុរាណទេ ដែលគេចាត់ទុកថាជាពលរដ្ឋ (UNESCO, ២០១៤)។ គំនិតនេះបានវិវត្តជាបន្តបន្ទាប់ដើម្បីរួមបញ្ចូលថា ពលរដ្ឋ គឺជាបុគ្គលទាំងឡាយដែលរស់នៅក្នុងសហគមន៍នយោបាយក្នុងព្រំដែននៃប្រទេសមួយ (Tawil, ២០១៣)។ សញ្ញាណប្រជា-ពលរដ្ឋរងឥទ្ធិពល ដោយសារការពង្រីកសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោ-បាយ។ សិទ្ធិទាំងនេះត្រូវបានពង្រីកបន្ថែមទៀត ដើម្បីផ្តោតលើទិដ្ឋភាពច្បាប់ដោយផ្តោតលើសិទ្ធិទាំងអស់ រួមទាំងសិទ្ធិក្នុងការកាន់កាប់កម្មសិទ្ធិ ព្រមទាំងភារកិច្ច និងការទទួលខុសត្រូវរបស់ពលរដ្ឋមួយរូបក្នុងរដ្ឋនៃជាតិមួយ (Lynch,

១៩៩២, Davies, ២០០៦, យោងតាម Tawil, ២០១៣)។

ដោយសារឥទ្ធិពលសកលភាវូបនីយកម្ម ដែលបង្កើតនូវឥទ្ធិពលវប្បធម៌ សង្គម និងសេដ្ឋកិច្ចថ្មីលើសពីព្រំដែនជាតិ គំនិត«ពលរដ្ឋ»បានវិវត្តហួសពីព្រំដែនរបស់ប្រជាជាតិមួយៗ ពលរដ្ឋក្នុងរដ្ឋមួយអាចបង្កើតសញ្ញាណរបស់សហគមន៍សកល តាមរយៈតម្លៃមនុស្សជាតិជាច្រើន ដូចជា សិទ្ធិមនុស្ស ការគោរពគុណធម៌មនុស្ស យុត្តិធម៌សង្គម និងសាមគ្គីភាពអន្តរជាតិ។ ក្នុងទសវត្ស ១៩៩០ Falk (១៩៩៤ យោងដោយ Tawil ២០១៣) ស្នើនូវសញ្ញាណនៃ «ប្រជាជនសកល» ដែលរួមមានសកម្មភាពសកល និងអន្តរកាល។ គេបានពង្រីកនិយមន័យចង្អៀតនេះនាពេលបច្ចុប្បន្ន ដោយបញ្ចូលសញ្ញាណមនុស្សជាតិជាប្រជាពលរដ្ឋសកលដែលមានសក្តានុពល ដោយសារមនុស្សរស់នៅលើភពផែនដីទាំងមូល ហើយពួកគេមានកាតព្វកិច្ចក្នុងការថែរក្សាភពផែនដីនេះ ដែលជាទ្រព្យសម្បត្តិរួមរបស់មនុស្សជាតិទាំងមូល (Meyer និង Sandy ២០០៩ យោងដោយ Tawil ២០១៣)។ ដូច្នេះ ទស្សនាទានថ្មីនៃ «ពលរដ្ឋ»ត្រូវមានការចូលរួមដោយការទទួលខុសត្រូវនិងសកម្មភាពរបស់ប្រជាជនក្នុងសហគមន៍ ប្រទេស តំបន់ និងភពផែនដីទាំងមូល (Education Above All, ២០១២)។ នាពេលបច្ចុប្បន្ននេះ និយមន័យ «ពលរដ្ឋ» បានវិវត្តដោយក្តោបក្រសោបទស្សនាទានដែលស្ថិតនៅខាងក្រៅផ្នែកនៃទស្សនាទានបង្អៀតនៃរដ្ឋនៃប្រជាជាតិមួយ ដែលភាសាអង់គ្លេសហៅថា post-national state paradigm (UNESCO, ២០១៦)។

គេឱ្យនិយមន័យ «ពលរដ្ឋ» ខុសៗគ្នា ហើយនិយមន័យនេះមានលក្ខណៈទូលំទូលាយៗ Torney-Purta et al. (២០០១) បានសង្ខេបការសិក្សាជាច្រើន និងកំណត់ទស្សនាទាន «ពលរដ្ឋ» ដោយរួមបញ្ចូលអត្តសញ្ញាណជាតិដូចតទៅ៖ «ពលរដ្ឋ» គឺជា៖ (១) អ្នកដែលចូលរួមបោះឆ្នោតក្នុងពេលបោះឆ្នោត អ្នកចូលរួមក្នុងកិច្ចការពារបរិស្ថាន អ្នកដែលគោរពច្បាប់កម្មសិទ្ធិសង្គម ឬអ្នកដែលគោរពច្បាប់របស់ប្រទេស អ្នកដែលអនុវត្តកាតព្វកិច្ចក្នុង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សង្គម ដូចជាយុវជនដែលបានបំពេញកាតព្វកិច្ចយោធា និងអ្នកដែលចូលរួមក្នុងដំណើរការនយោបាយ (Torney-Purta et al., ២០០១) (២) អ្នកដែលទទួលខុសត្រូវចំពោះមុខអ្នកបោះឆ្នោត ដែលរួមមានអ្នកដែលហ៊ានតស៊ូមតិតាមរយៈការតវ៉ា និងការជឿជាក់លើតំណាងរាស្ត្រដែលរាស្ត្របានជ្រើសរើស ព្រមទាំងការចូលជាសមាជិកក្នុងគណបក្សនយោបាយ (Theiss-Morse, ១៩៩៣) (៣) ការគោរពសួររបស់ប្រជាពលរដ្ឋ ការគោរពច្បាប់ និងស្មារតីជាតិនិយម (Anderson, Avery, Pederson, Smith និង Sullivan, ១៩៩៧) (៤) ការដោះស្រាយបញ្ហាសង្គម ការតស៊ូដើម្បីយុត្តិធម៌សង្គម ការចូលរួមក្នុងកិច្ចការសង្គម និងការចេះអត់ឱនឱ្យគ្នា និងការទទួលយកវប្បធម៌សម្បូណ៌បែប (Davies Gregory និង Riley, ១៩៩៩)។

## ៤.២.២. គោលដៅនៃការអប់រំ

គោលដៅមួយនៃការអប់រំនៅក្នុងប្រទេសកម្ពុជា គឺដើម្បីអប់រំអ្នកសិក្សាឱ្យក្លាយជាពលរដ្ឋល្អមួយរូប។ ការអប់រំប្រជាពលរដ្ឋជាមូលដ្ឋាន គឺចាប់ពីថ្នាក់ទី១ ដល់ ទី៦ ដោយប្រើប្រាស់សៀវភៅក្នុងផ្នែក «វិទ្យាសាស្ត្រនិងការសិក្សាសង្គម»។ ពីថ្នាក់ទី៩ ដល់ ថ្នាក់ទី១២ ការអប់រំប្រជាពលរដ្ឋល្អ ត្រូវបានបង្រៀនដោយប្រើប្រាស់សៀវភៅ «វិទ្យាសាស្ត្រសង្គម» និង «ការអប់រំប្រជាពលរដ្ឋល្អ»។ ការអប់រំឱ្យក្លាយជាពលរដ្ឋល្អក្នុងប្រទេសកម្ពុជាអាចធ្វើការវិភាគ និងសំយោគដើម្បីផ្តោតលើទិដ្ឋភាពខាងក្រោម៖ (១) ចែករំលែកតម្លៃនិងមនុស្សជាតិរួម៖ ដូចជា តម្លៃមនុស្ស ក្តីស្រលាញ់ មេត្តាធម៌ ភាពត្រឹមត្រូវពិតប្រាកដ ការអត់ឱន គុណធម៌ និងគ្មានអំពើហិង្សា (២) សិទ្ធិនិងការទទួលខុសត្រូវរបស់ប្រជាជនដូចជា៖ ការប្តេជ្ញាចិត្តស្រឡាញ់សេរីភាព លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សរួមមានសិទ្ធិកុមារនិងការគោរពអ្នកដទៃ (៣) ការចូលរួមរបស់សហគមន៍និងសង្គម៖ ដូចជា ការអភិវឌ្ឍសហគមន៍ សាមគ្គីភាព តម្លាភាព ជំរុញយេនឌ័រ គោរពសេរីភាពសាសនា និងពិពិធកម្មវប្បធម៌



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សន្តិភាព និងការការពារជនជាតិដើមភាគតិច និង (២) សកម្មភាពប្រជាជនក្នុងនយោបាយ៖ យល់ពីប្រព័ន្ធច្បាប់និងនយោបាយ តួនាទីច្បាប់ ដំណើរការនៃការបោះឆ្នោត និងគណបក្សនយោបាយ។

ជាមួយនឹងបញ្ហាប្រឈមជាសកលកំពុងកើនឡើង ការអប់រំត្រូវបានមើលឃើញថាជាមធ្យោបាយដ៏ល្អបំផុតដើម្បីដោះស្រាយបញ្ហាជាច្រើនដែលកំពុងប្រឈមក្នុងសហគមន៍។ ដូចនេះ ប្រព័ន្ធអប់រំជាតិមានតួនាទីជាមូលដ្ឋានក្នុងការបង្កើតប្រជាពលរដ្ឋ និងពង្រឹងភាពស៊ីចង្វាក់គ្នាក្នុងសង្គមជាតិ។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ UNESCO បានចាប់ផ្តើមការអប់រំសម្រាប់ការយល់ដឹងជាអន្តរជាតិ ការសហការ និងសេរីភាពសន្តិភាព (UNESCO, ១៩៧២)។ ក្នុងទសវត្ស ១៩៩០ UNESCO បានចាប់ផ្តើមជាមួយនឹងគំនិតផ្តួចផ្តើមនៃការអប់រំសម្រាប់សន្តិភាព សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ (UNESCO, ១៩៩៥)។ ក្រោយមកទៀត ភាពត្រឹមត្រូវនៃរបាយការណ៍របស់ Delors ទាក់ទងនឹងការអប់រំសម្រាប់ការរួមរស់នៅជាមួយគ្នា៖ រៀនដើម្បីចំណេះ រៀនដើម្បីបំណិន រៀនដើម្បីមានចរិយាធម៌ និងរៀនដើម្បីរួមរស់នៅជាមួយគ្នា ហើយទស្សនាទាននេះបានក្លាយជាសសរស្តម្ភនៃក្រមខ័ណ្ឌការអប់រំរបស់ UNESCO (Delors, ១៩៩៦)។

នៅដើមសតវត្សទី ២១ ដំណើរការសកលភាវូបនីយកម្មបានរីកដុះដាលយ៉ាងឆាប់រហ័ស ហើយបាននាំមកនូវបញ្ហាប្រឈមធំៗជាច្រើន ដូចជា អំពើភេរវកម្មជាសាកល វិបត្តិហិរញ្ញវត្ថុសាកលលោក បម្រែបម្រួលអាកាសធាតុ ជម្លោះនៅតាមចំណុចក្តៅជាច្រើនក្នុងពិភពលោក ភាពក្រីក្រ ភាពអត់ឃ្លាន និងបញ្ហាជាច្រើនដែលពាក់ព័ន្ធនឹងសមធម៌និងនិរន្តរភាពជាដើម។ គឺនៅក្នុងបរិបទនេះហើយ ដែលគំនិត«ពលរដ្ឋល្អ»បានពង្រីកបន្ថែមទៀតនិងរួមជាមួយនឹងទិដ្ឋភាពសាកល ព្រមទាំងទិដ្ឋភាពជាច្រើននៃការអប់រំដូចជា ជំនាញ ចំណេះដឹង ឥរិយាបថ និងការចូលរួមក្នុងសង្គម។

ក្នុងបរិបទនៃការកសាងពលរដ្ឋ Siribanpitak (២០០៨) គិតថាការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អប់រំមានតួនាទីចំនួន២៖ (១) ដើម្បីបង្កើតនូវទិដ្ឋភាពជាក់លាក់នៃសង្គមបច្ចុប្បន្ន និង (២) ដើម្បីរៀបចំសិស្សធ្វើការផ្លាស់ប្តូរសង្គមនាពេលអនាគត។ ការអប់រំគួរជួយសិស្ស ក្នុងការកំណត់នូវអ្វីដែលល្អបំផុត ដើម្បីអភិរក្សកេរ្តិ៍តំណែលវប្បធម៌ ធម្មជាតិ និងសេដ្ឋកិច្ច និងគាំទ្រតម្លៃ និងយុទ្ធសាស្ត្រ ក្នុងគោលដៅសម្រេចឱ្យបាននិរន្តរភាពក្នុងសហគមន៍ក្នុងស្រុក ពេលដែលរួមចំណែក ក្នុងពេលដំណាលគ្នា ចំពោះគោលដៅសាកលនិងជាតិ។ ដូចនេះ ការអប់រំត្រូវតែជាផ្លាស់ប្តូរ ដើម្បីជំរុញតម្លៃរួមគ្នា ទាក់ទងនឹងការដោះស្រាយបញ្ហានៅថ្ងៃនេះ (Ban, ២០១២)។ ប្រព័ន្ធអប់រំមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍចំណេះដឹង ជំនាញ និងតម្លៃដែលអាចឱ្យអ្នកសិក្សា (១) បង្កើតសញ្ញាណនៃជោគវាសនារួមគ្នា (២) អាចដឹងពីបញ្ហាប្រឈមរួមគ្នា (៣) ចូលរួមក្នុងសកម្មភាពសង្គមនិងប្រជាជន (Tawil, ២០១៣)។

ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមខាងលើ UNESCO បានចាប់ផ្តើមចក្ខុវិស័យសម្រាប់ការអប់រំសតវត្សទី ២១ (UNESCO, ២០១៥a)។ វាបង្កើតបានជាសមាសធាតុមួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងរបៀបវារៈការអប់រំឆ្នាំ ២០៣០ (UNESCO, ២០១៥b)។ ដូចដែលបានកត់សម្គាល់ក្នុងគំនិតផ្តួចផ្តើមការអប់រំសាកលដំបូងរបស់អង្គការសហប្រជាជាតិ «វាមិនគ្រប់គ្រាន់សម្រាប់ការអប់រំ ដែលអាចឱ្យបុគ្គលម្នាក់រូបអាចអានសរសេរ និងរាប់នោះទេ»។ ការអប់រំត្រូវតែសន្មតិឱ្យបានពេញលេញ តួនាទីស្នូលក្នុងការជួយប្រជាពលរដ្ឋបង្កើតសង្គមកាន់តែមានការអត់ឱន និងមានសន្តិភាព (Ban, ២០១២)។ សម្រាប់ហេតុផលនេះ ការអប់រំពលរដ្ឋសាកល (GlobalCitizenshipEducation(GCED)) បានក្លាយជាសសរស្តម្ភមួយនៃរបៀបវារៈការអប់រំឆ្នាំ ២០៣០។ GCED បានឱ្យនិយមន័យថាជា «គំរូក្របខ័ណ្ឌដែលសង្ខេបពីរបៀបដែលការអប់រំអាចបង្កើតចំណេះដឹង ជំនាញ តម្លៃ និងតម្រូវការឥរិយាបថរបស់អ្នកសិក្សា ដើម្បីធានានូវពិភពលោកមួយកាន់តែមានសន្តិភាព ការអត់ឱន បរិយាបន្ន និងនិរន្តរភាព» (UNESCO, ២០១៥a)។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដូចនេះ GCED រួមបញ្ចូលធាតុនៃការអប់រំប្រជាពលរដ្ឋលើសពីព្រំដែនជាតិ។ វាជាបញ្ហាពីការផ្លាស់ប្តូរគំនិតដោយតម្រូវឱ្យការអប់រំជួយដោះស្រាយបញ្ហាសាកល ជាពិសេសបញ្ហាបរិស្ថាន សេដ្ឋកិច្ច វប្បធម៌ នយោបាយ និងសង្គម។ ការអប់រំអាចជួយអ្នកសិក្សាបង្កើនចំណេះដឹង និងជំនាញពុទ្ធិ ដើម្បីបង្កើតតម្លៃ ជំនាញទន់ និងឥរិយាបថក្នុងគោលបំណងជំរុញសហប្រតិបត្តិការអន្តរជាតិ និងការផ្លាស់ប្តូរសង្គម (UNESCO, ២០១៤a)។

ក្នុងការឆ្លើយតបទីងនិន្នាការសាកលខាងលើនៃការពង្រីក «ពលរដ្ឋសកល» ក្រសួងអប់រំ យុវជន និងកីឡា ក្នុងកិច្ចសហការជាមួយមជ្ឈមណ្ឌលអប់រំអាស៊ីប៉ាស៊ីហ្វិកសម្រាប់ចំណេះដឹងអន្តរជាតិ (Asia-Pacific Center of Education for International Understanding (APCEIU)) ដែលឧបត្ថម្ភដោយ UNESCO បានចាប់ផ្តើមកម្មវិធីមួយសហការជាមួយកម្មវិធីការអប់រំប្រជាពលរដ្ឋសាកល(GlobalCitizenshipEducation(GCED))ក្នុងកម្មវិធីសិក្សាជាតិប្រទេសកម្ពុជា និងអនុវត្តក្នុងសាលារៀនទូទាំងប្រទេសក្នុងប្រទេសកម្ពុជា។ GCED បានបណ្តុះបណ្តាល និង អប់រំសិស្សកាន់តែទាន់សម័យនៃនិរន្តរភាព សន្តិភាព បរិយាប័ន្ន សមភាព មនុស្សជាតិក្នុងពិភពលោក។ វា អាចឱ្យសិស្សចូលរួមក្នុងពិភពលោក ក្នុងនាមជាសមត្ថភាពរបស់ពលរដ្ឋសាកល ដើម្បីរួមចំណែកជាវិជ្ជមានក្នុងការផ្លាស់ប្តូរសង្គម។ ក្នុងបរិបទប្រទេសកម្ពុជា GCED មានគោលបំណងចំនួន៤៖ (១) បង្កើតឥរិយាបថនៃការគោរពចំពោះ ភាពចម្រុះខុសគ្នា និងពហុអត្តសញ្ញាណដោយមិនគិតពីជាតិសាសន៍ សាសនា និន្នាការនយោបាយ វប្បធម៌ យេនឌ័រ និងស្ថានភាពសេដ្ឋកិច្ច សង្គម (២) បណ្តុះគំនិតសិស្សពីកាតព្វកិច្ចសង្គម និងសីលធម៌ដើម្បីប្រឆាំង ទីងគំរូនៃការប្រឆាំងជាតិសាសន៍និយម និងជាតិនិយមជ្រុល (៣) ជំរុញ បង្កើនភាពអត់ធ្មត់ សន្តិភាព ការអត់ឱន ការផ្សះផ្សានិង ការទទួលខុសត្រូវសង្គម និង (៤)ក្លាយជាពលរដ្ឋសាកល ដែលអាចឆ្លើយតបទីងការទទួលខុសត្រូវក្នុងការចូលរួម និងផ្តល់ព័ត៌មាន។

*ការទាញចេញពីតួនាទីថ្មីនៃការអប់រំ គំនិតស្នូលនៃគុណភាពប្រជាពលរដ្ឋអាចត្រូវបានឱ្យនិយមន័យ ផ្អែកលើទិដ្ឋភាពទាំងបីខាងក្រោម* (UNESCO, ២០១៥b)៖ *(១) វិជ្ជាសម្បទា៖ ចំណេះដឹង ការយល់ដឹង និងការគិតត្រិះរិះពិចារណាអំពីសកលលោក តំបន់ ជាតិ និងបញ្ហាក្នុងស្រុក (២) បំណិនសម្បទា៖ សញ្ញាណនៃកម្មសិទ្ធិចំពោះមនុស្សជាតិរួម តម្លៃរួមគ្នា និងការទទួលខុសត្រូវ ភាពអត់ធ្មត់ សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងពិពិធកម្ម (៣) ចរិយាសម្បទា៖ សកម្មភាពទទួលខុសត្រូវ និងប្រសិទ្ធភាពនៅកម្រិតសកល ជាតិ និងក្នុងស្រុកសម្រាប់ពិភពលោកកាន់តែមាននិរន្តរភាព និងសន្តិភាព។*

*ដូចនេះ ទស្សនាទាន «ពលរដ្ឋមានគុណភាព» ដែលជាគោលដៅនៃការអប់រំបានវិវត្ត និងពង្រីកការគ្របដណ្តប់កាន់តែធំទៅៗជាងគុណភាពអប់រំ។ គុណភាពអប់រំគឺគ្រាន់តែជាផ្នែកមួយនៃគោលបំណងនៃសិក្សានៅក្នុងកម្មវិធីសិក្សា។ គុណភាពអប់រំ គឺជាលក្ខខណ្ឌមួយ ដើម្បីឱ្យប្រជាពលរដ្ឋមានគុណភាពក្លាយជាការពិត។ ក្នុងន័យនេះ ការអប់រំគួរតែបង្កើតពលរដ្ឋមានគុណសម្បត្តិពេញលេញ ដែលយើងហៅថា «ពលរដ្ឋល្អ» ឬ «ពលរដ្ឋមានគុណភាព» ។*

## ៤.២.៣. ទស្សនាទានពលរដ្ឋមានគុណភាព

*និយមន័យខាងលើគឺទូលំទូលាយណាស់ ហើយដូចនេះ អាចប្រើប្រាស់ក្នុងក្របខ័ណ្ឌគំនិតដើម្បីបង្កើតយុទ្ធសាស្ត្រមួយសម្រាប់កំណែទម្រង់ការគ្រប់គ្រងការអប់រំសម្រាប់ពង្រីកគុណភាពពលរដ្ឋក្នុងប្រទេសកម្ពុជា។ គំនិត «ពលរដ្ឋមានគុណភាព» តំណាងឱ្យទំនាក់ទំនងវិចារវិទ្យា រវាងទិដ្ឋភាពខាងក្នុង «ពលរដ្ឋជាតិល្អ» និងតួនាទីខាងក្រៅរបស់ពលរដ្ឋមួយរូប «ពលរដ្ឋសកលល្អ»។ ក្នុងការស្រាវជ្រាវនេះ គំនិត «ពលរដ្ឋមានគុណភាព» រួមមានសមាសធាតុដូចខាងក្រោម* (Ban, 2012; OXFAM, 2015; Tawil, 2013;



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Torney-Purta et al., 2001; UNESCO, 2014, 2015a, 2015b, 2016)៖

(I) **«ពលរដ្ឋជាតិមានគុណភាព» មួយរូបមាន៖**

*(១) សមាសធាតុសេដ្ឋកិច្ចនៃ «ពលរដ្ឋជាតិមានគុណភាព» មួយរូប ៖ (ក) ចំណេះដឹង (ខ) បំណិនបច្ចេកទេស និងបំណិនទន់ រួមមានបំណិនអន្តរបុគ្គល ដូចជាទំនាក់ទំនង ការចេះសហការ បំណិនដោះស្រាយបញ្ហា និងដោះស្រាយជម្លោះ (គ) បំណិនជីវិតស្នូល និងប្រាជ្ញាផ្នែកអារម្មណ៍* (Emotional intelligence) *និង*

*(២) សមាសធាតុនយោបាយសង្គមនៃ«ពលរដ្ឋជាតិមានគុណភាព» មួយរូប៖(ក)ប្រជាពលរដ្ឋដែលចេះអភិរក្សគោរពច្បាប់អត្តសញ្ញាណជាតិ គ្រួសារនិយម និងស្មោះត្រង់នឹងប្រទេសជាតិ ព្រមទាំងចូលរួមក្នុងសង្គម និងគោរពពិពិធកម្ម (ខ) សកម្មភាពដែលធ្វើដោយបុគ្គល ឬសមូហភាព ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋមានគុណភាព (គ) សកម្មភាពប្រជាពលរដ្ឋ ទាក់ទងនឹងចលនាសង្គម ដូចជាការប្តេជ្ញាចិត្តចំពោះយុត្តិធម៌សង្គម សមភាព សិទ្ធិមនុស្ស ការការពារបរិស្ថាន ការអភិវឌ្ឍប្រកបដោយចីរភាព និងការអភិវឌ្ឍសហគមន៍ និង (ឃ) សកម្មភាពនយោបាយអភិរក្ស សមាជិកភាពក្នុងគណបក្សនយោបាយ ការចូលរួមក្នុងការពិភាក្សានយោបាយ និងបោះឆ្នោតកល់ការបោះឆ្នោត ។*

(II) **«ពលរដ្ឋសកលមានគុណភាព» មួយរូប៖**

*(១)សមាសធាតុសេដ្ឋកិច្ចនៃ«ពលរដ្ឋសកលមានគុណភាព» មួយរូប៖ (ក )ចំណេះដឹងស្តីពីពិភពលោកយ៉ាងទូលំទូលាយ និងការយល់ដឹងពីតួនាទីរបស់ខ្លួនជាពលរដ្ឋពិភពលោក (ខ) ការគោរព និងការឱ្យតម្លៃលើភាពចម្រុះ និងសម្បូណ៌បែប និង*

*(២) សមាសធាតុនយោបាយ និងសង្គមនៃ «ពលរដ្ឋសកលមាន*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គុណភាព៣ ល្អមួយរូប៖ (ក) ធនធៈ និងការប្ដេជ្ញាចិត្តធ្វើឱ្យពិភពលោកមាន សមភាព និងនិរន្តរភាព និង (ខ) ការទទួលខុសត្រូវសម្រាប់សកម្មភាព របស់ខ្លួន (Oxfam undated)។

Tawil (២០១៣) គិតថា ពលរដ្ឋសកលរួមមានលក្ខណសម្បត្តិដូច ខាងក្រោម៖

(១). បញ្ហាសិទ្ធិមនុស្ស៖ សិទ្ធិមនុស្សជាមូលដ្ឋាន និងការទទួលខុស ត្រូវ សិទ្ធិកុមារ សមភាពយេនឌ័រ សិទ្ធិវប្បធម៌ សេរីភាពក្នុងការបញ្ចេញមតិ

(២). បញ្ហាបរិស្ថាន៖ ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធាន ធម្មជាតិ ផលប៉ះពាល់លើផលិតកម្មនិងការប្រើប្រាស់ បម្រែបម្រួលអាកាស ធាតុ ជីវសាស្ត្រ ការអប់រំបរិស្ថាន និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកប ដោយនិរន្តរភាព

(៣). បញ្ហាយុត្តិធម៌សេដ្ឋកិច្ចសង្គម៖ ភាពក្រីក្រ សុខភាព និង សុខមាលភាព វិសមភាព ការផ្លាស់ប្ដូរជនបទ គំរូនៃភាពរីកចម្រើន

(៤). បញ្ហាទំនាក់ទំនងវប្បធម៌៖ អត្តសញ្ញាណ ភាពចម្រុះវប្បធម៌ កេរ្តិ៍ ដំណែលពិភពលោក សិល្បៈ ភាសា ប្រវត្តិសាស្ត្រពិភពលោក ប្រព័ន្ធចំណេះ ដឹងជនជាតិដើម សន្តិភាពនិងជម្លោះ

## ៤.២.៤. ទំនាក់ទំនងរវាងគំរូនៃការគ្រប់គ្រង ការអប់រំជាមួយនឹងពលរដ្ឋមានគុណភាព

ការអប់រំមានគោលបំណងរៀបចំឱ្យយុវជនត្រៀមខ្លួន ក្នុងការបំពេញ តួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ក្នុងនាមជាពលរដ្ឋមួយរូប ហើយ ការអប់រំនេះមានទិសដៅ និងប្រធានបទខុសៗគ្នាក្នុងប្រទេសផ្សេងៗគ្នា។ កម្មវិធីសិក្សារួមបញ្ចូលមុខវិជ្ជា ពលរដ្ឋវិទ្យា វិទ្យាសាស្ត្រសង្គម ការសិក្សា សង្គម បំណិនជីវិត និងការអប់រំសីលធម៌ (Kerr, ១៩៩៩)។ ចាប់តាំងពីឆ្នាំ ១៩៧១ សមាគមអន្តរជាតិសម្រាប់ការវាយតម្លៃភាពជោគជ័យការអប់រំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(Evaluation of Educationnal Achiement, (IEA)) បានធ្វើការសិក្សាប្រៀបធៀបលើភាពជោគជ័យក្នុងការអប់រំ ហើយផ្តល់ជារបាយការណ៍គន្លឹះសំខាន់មួយចំនួននៃឥទ្ធិពលនៃការសិក្សាក្នុងសាលារៀន ទៅលើចំណេះដឹងរបស់សិស្ស និងអាកប្បកិរិយារបស់ប្រជាពលរដ្ឋ។ ចាប់តាំងពីពេលនោះមក ចំណាប់អារម្មណ៍នៃការអប់រំប្រជាពលរដ្ឋកើនឡើងហើយក្នុងឆ្នាំ២០០៩ ការសិក្សាស្តីពីការអប់រំប្រជាពលរដ្ឋនិងពលរដ្ឋអន្តរជាតិ (International Civic and Citizenship Education Study) ត្រូវបានសិក្សាដោយIEA ដោយប្រើប្រាស់ទិន្នន័យដែលប្រមូលពីសិស្សថ្នាក់ទី៨ ចំនួន១៤០,០០០ គ្រូបង្រៀនចំនួន ៦២,០០០ និងនាយកសាលាចំនួន ៥,៣០០ ពីប្រទេសចំនួន៣៨។ ការកើនឡើងបញ្ហាប្រឈមពិភពលោកបានជំរុញប្រទេស និងស្ថាប័នអន្តរជាតិជាច្រើន ឱ្យសង្កត់ធ្ងន់កាន់តែខ្លាំងទៅលើការអប់រំប្រជាពលរដ្ឋ និងការអប់រំប្រជាពលរដ្ឋជាសកល ដើម្បីត្រៀម និងរៀបចំយុវជនឱ្យចេះដោះស្រាយបញ្ហា និងរស់នៅក្នុងពិភពលោកមួយដែលមានលក្ខណៈមិនប្រាកដប្រជា។

នាពេលបច្ចុប្បន្ន ការអប់រំប្រជាពលរដ្ឋដែលរួមមាន GCED បានក្លាយជាគំរូនៃការអប់រំជាអន្តរជាតិថ្មីមួយ ដែលជាផ្នែកគោលដៅនៃការអប់រំសតវត្សទី២១។ វាក៏ជាគោលដៅអប់រំរបស់ UNESCO រយៈពេល៨ឆ្នាំ (២០១៤-២០២១) ហើយជាគោលដៅអភិវឌ្ឍន៍និរន្តរភាពសកលកាន់តែធំ ដើម្បីសម្រេចឱ្យបានត្រឹមឆ្នាំ២០៣០។ ប្រទេសកាន់តែច្រើនឡើងៗបាន និងកំពុងការធ្វើកំណែទម្រង់ការអប់រំកាន់តែធំ ដោយផ្តោតលើកំណែទម្រង់សាលារៀន និងកម្មវិធីសិក្សាក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការនៅសតវត្សទី២១។ ទោះបីជាមាននិន្នាការនេះក៏ដោយ មុនដំបូងការសិក្សាបានរៀបចំផែនការ ដើម្បីផ្សារភ្ជាប់កំណែទម្រង់ការគ្រប់គ្រងការអប់រំ ទៅនឹងពលរដ្ឋមានគុណភាព។ ដើម្បីធានាទំនាក់ទំនងកំណែទម្រង់ការគ្រប់គ្រងការអប់រំ ទៅនឹងពលរដ្ឋមានគុណភាពគេត្រូវផ្តោតលើលទ្ធផលនៃកំណែទម្រង់ការអប់រំ ជាពិសេស ការធ្វើឱ្យសិស្ស និងអ្នកសិក្សាទទួលបាននូវវិជ្ជា

សម្បទាចំណិនសម្បទានិងចរិយាសម្បទាជាពិសេសតាមរយៈនៃគុណភាពអប់រំ។

## ៤.៣. លក្ខខណ្ឌចាំបាច់សម្រាប់កំណែទម្រង់ការអប់រំប្រកបដោយជោគជ័យ

នៅក្នុងស្ទើតែគ្រប់ប្រទេសអភិវឌ្ឍ គេសង្កេតឃើញថាវិស័យអប់រំមានវឌ្ឍនភាពយ៉ាងខ្លាំង (ការចុះឈ្មោះ អត្រាគង់វង្ស និងអត្រាបញ្ចប់ការសិក្សាបានកើនឡើង)។ ប៉ុន្តែក្នុងប្រទេសកំពុងអភិវឌ្ឍ វឌ្ឍនភាពក្នុងវិស័យអប់រំនៅមានកម្រិតនៅឡើយ ហើយក្នុងប្រទេសមួយចំនួន ស្ថានភាពនេះ កាន់តែជុនដាបទៅ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួនដូចជា ប្រទេសវៀតណាម លទ្ធផលសិក្សាមានកម្រិតស្មើ ឬលើសប្រទេសអភិវឌ្ឍOECD ថែមទៀតផង(Prtchett, ២០០៥)។ គណៈកម្មការអប់រំ (២០១៦) គិតថាត្រឹមឆ្នាំ២០៣០ ជាងពាក់កណ្តាលនៃប្រជាជនវ័យក្មេងជំនាន់ថ្មីនឹងបាត់បង់អនាគត ប្រសិនបើពួកគេគ្មានជំនាញដែលទីផ្សារការងារដែលកំពុងផ្លាស់ប្តូរយ៉ាងខ្លាំងត្រូវការ។ គណៈកម្មការយល់ឃើញថា ប្រសិនបើចង់ផ្តល់ការអប់រំប្រកបដោយជោគជ័យ ចាំបាច់គេត្រូវតែវិនិយោគលើការពង្រឹងប្រព័ន្ធអប់រំទាំងមូលដែលផ្តល់លទ្ធផលជោគជ័យ។ ដូចនេះ កំណែទម្រង់ជាប្រព័ន្ធនៃការគ្រប់គ្រងការអប់រំ គឺមានសារៈសំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដើម្បីធានាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព។ ប្រព័ន្ធអប់រំផ្អែកលើលទ្ធផលដ៏រឹងមាំមួយ គឺជាប្រព័ន្ធ ដែលធានាការស៊ីគ្នារវាងគោលដៅ គោលនយោបាយ និងចំណាយថវិកា ព្រមទាំងកំណត់មាត់យ៉ាងច្បាស់លាស់នៃគោលនយោបាយ ឆ្ពោះទៅរកការអនុវត្ត ប្រសិទ្ធភាពរដ្ឋបាល និងគណនេយ្យភាព។

ក្នុងគោលបំណងទាញយកផលប្រយោជន៍ពីឱកាស ដែលបង្កើតដោយបដិវត្តន៍ឧស្សាហកម្មលើកទី៤ ប្រទេសកំពុងអភិវឌ្ឍត្រូវចាប់ផ្តើមធ្វើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កំណែទម្រង់ការអប់រំ ក្នុងគោលបំណងកែលម្អគុណភាពអប់រំ និងដោះស្រាយគម្លាតជំនាញ។ កម្លាំងពលកម្មដែលមានជំនាញទាបមិនអាចឱ្យប្រទេសមួយទទួលយកបច្ចេកវិទ្យា និងវិស័យផលិតកម្មថ្មីៗបានឡើយ (World Bank, ២០១០)។ លើសពីនេះទៅទៀត មិនមែនកង្វះមូលធនទេ តែគឺកង្វះកម្លាំងពលកម្មមានជំនាញឯណោះទេ ដែលជាឧបសគ្គដ៏ចម្បង ក្នុងការលើកកម្ពស់ការច្នៃប្រឌិត នវានុវត្តន៍ ការប្រកួតប្រជែង និងកំណើនរយៈពេលវែង (Schwab ២០១៦)។ ដូចនេះ ប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍត្រូវចាប់ផ្ដើមធ្វើកំណែទម្រង់ជាប្រព័ន្ធនៃការអប់រំ ក្នុងគោលបំណងធ្វើឱ្យការអប់រំទាក់ទងកាន់តែខ្លាំង និងឆ្លើយតបទៅនឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសេដ្ឋកិច្ច។

កំណែទម្រង់ជាប្រព័ន្ធនៃការអប់រំ គឺជាគំនិតដែលលេចចេញពីកំណែទម្រង់គោលនយោបាយអប់រំក្នុងអំឡុងដើមទសវត្ស ១៩៩០។ វារួមមានធាតុសំខាន់ចំនួន៣៖ (១) ជំរុញមហិច្ឆតានៃលទ្ធផលរបស់សិស្សសម្រាប់សិស្សគ្រប់គ្នា (២) ភាពស្របគ្នានៃគោលនយោបាយនិងសកម្មភាពនៃស្ថាប័ន គោលនយោបាយយ៉ាងច្រើនដើម្បីសម្រេចបានលទ្ធផលសិក្សា និង (៣) កែរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលដើម្បីគាំទ្រការសម្រេចការកែលម្អ (Margaret E. Goertz, Robert E. Floden និង Jennifer O'Day. «ការសិក្សាពីកំណែទម្រង់ ការអប់រំ ៖ កំណែទម្រង់ជាប្រព័ន្ធ»; Smith, M.S. និង O'Day, J. ១៩៩១, «កំណែទម្រង់សាលាជាប្រព័ន្ធ» នៅក្នុង S.H. Fuhrman, និង B. Malen (Eds.), «នយោបាយនៃកម្មវិធីសិក្សានិងការធ្វើតេស្ត» ១៩៩០; សៀវភៅប្រចាំឆ្នាំស្ដីពីនយោបាយនៃការអប់រំ, London និង Washington, DC: Falmer Press, ២៣៣-២៦៧)។ គំនិតនេះសន្មតិថាមិនថាកំណែទម្រង់ពីលើចុះក្រោម ឬកំណែទម្រង់ពីក្រោមឡើងលើទេវានឹងកែលម្អសាលារៀននិងលទ្ធផលនៃការសិក្សារបស់សិស្ស។ ឧបសគ្គជាប្រព័ន្ធចំពោះការប្រែប្រួលការអប់រំរួមមាន៖ កំណែទម្រង់ដែលមានច្រើនស្រទាប់ស្មុគស្មាញ និងដាច់ដោយឡែកពីគ្នា។ ដូចនេះ តម្រូវការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំពោះមុខ គឺជា «យុទ្ធសាស្ត្រកំណែទម្រង់ជាប្រព័ន្ធស៊ីចង្វាក់គ្នា»។

«កំណែទម្រង់ជាប្រព័ន្ធនៃការអប់រំ» ទាមទារឱ្យកែលម្អលទ្ធផលនៃការសិក្សា ការសម្របសម្រួលនៅគ្រប់កម្រិតនៃប្រព័ន្ធ ការអនុវត្តអន្តរាគមន៍គោលនយោបាយពហុចម្រុះ និងការគិតជាថ្មីពីដៃគូរដ្ឋបាល (Cohen, D.K., និង Spillan, J.P. (១៩៩៣) «គោលនយោបាយ និងការអនុវត្តៈទំនាក់ទំនងរវាងរដ្ឋបាលនិងការណែនាំ»។ ក្នុង S.H. Fuhrman (Ed.) បានរៀបចំគោលនយោបាយអប់រំស៊ីគ្នា៖ ធ្វើឱ្យប្រព័ន្ធកាន់តែប្រសើរ (San Francisco: Jossey-Bass, ៣៥-៩៥)។ ធាតុគន្លឹះនៃកំណែទម្រង់ជាប្រព័ន្ធរួមមានគ្រប់ទ័ណ្ឌបង្រៀន សម្ភារបង្រៀន ការវាយតម្លៃការអនុវត្តរបស់សិស្ស និងតម្រូវការនៃប្រព័ន្ធកំណែទម្រង់ការអប់រំជាប្រព័ន្ធ៖ (i) កំណែទម្រង់គោលនយោបាយគ្រូបង្រៀន (ii) អធិការកិច្ចគ្រូបង្រៀន (iii) ការវាយតម្លៃការសិក្សា (iv) ការពិនិត្យកម្មវិធីសិក្សា និង (v) ធ្វើឱ្យប្រសើរវចនាសម្ព័ន្ធសាលា។

«កំណែទម្រង់ការគ្រប់គ្រងការអប់រំ» គ្របដណ្តប់បញ្ហាជាច្រើនពីការពិនិត្យកម្មវិធីសិក្សា ទៅការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន និងការច្នៃប្រឌិតក្នុងសកម្មភាពរៀនក្នុងថ្នាក់។ កំណែទម្រង់ការអប់រំ គឺជាការផ្លាស់ប្តូរជាប្រព័ន្ធយ៉ាងទូលំទូលាយនៃគោលដៅ អាទិភាព និងវចនាសម្ព័ន្ធអប់រំ។ អ្នកឯកទេសក្នុងវិស័យអប់រំបានបោះពុម្ពផ្សាយឯកសារស្រាវជ្រាវជាច្រើន ស្តីពីកំណែទម្រង់ជាប្រព័ន្ធនៃការគ្រប់គ្រងការអប់រំ (Conley, 1993; Anson, 1994; Fuhrman, Elmore & Massell, 1993; Fullan, 2007; Glewwe, 2014; Pritchett, 2015; Education Commission, 2016)។ លទ្ធផលនៃការសិក្សាទាំងនេះ បានបង្ហាញថា ការធ្វើកំណែទម្រង់ការគ្រប់គ្រងការអប់រំប្រកបដោយជោគជ័យទាមទារនូវលក្ខខណ្ឌចំនួន២ គឺ៖ (i) កំណែទម្រង់ជាប្រព័ន្ធ (ii) ការសម្របសម្រួលរវាងកំណែទម្រង់ពីលើចុះក្រោម និងកំណែទម្រង់ពីក្រោមឡើងលើ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.៤. កំណែទម្រង់ជាប្រព័ន្ធនៃការគ្រប់គ្រងអប់រំ

### ៤.៤.១. និយមន័យកំណែទម្រង់ជាប្រព័ន្ធ

តើអ្វីទៅជាកំណែទម្រង់ជាប្រព័ន្ធនៃការគ្រប់គ្រងការអប់រំ? Anson (១៩៩៤) ស្នើក្របខ័ណ្ឌកំណែទម្រង់ការគ្រប់គ្រងសាលាជាប្រព័ន្ធ ដែលរួមមានទិដ្ឋភាពជាច្រើននៃសេវាអប់រំដូចជា ការអនុវត្តវាយតម្លៃការសិក្សា ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ការគ្រប់គ្រងសាលារៀន (School Based Management) និងការប្រើប្រាស់បច្ចេកវិទ្យាជាដើម។ Fuhrman (១៩៩៤) ចាត់ទុកគំនិតកំណែទម្រង់ជាប្រព័ន្ធគ្របដណ្តប់លើក្របខ័ណ្ឌកម្មវិធីសិក្សា វាយតម្លៃការសិក្សារបស់សិស្ស ការកែលម្អសម្ភារសិក្សា ការផ្តល់អាជ្ញាបណ្ណដល់គ្រូបង្រៀន និងការអភិវឌ្ឍបុគ្គលិក។ Tiongson (២០០៥) គិតថាកំណែទម្រង់ការអប់រំត្រូវផ្តោតលើការផ្លាស់ប្តូរគោលនយោបាយ ចំពោះរចនាសម្ព័ន្ធចំណាយការផ្តល់ហិរញ្ញវត្ថុ និងការគ្រប់គ្រង។ Ouellette (២០០០) បានឱ្យនិយមន័យកំណែទម្រង់ជាប្រព័ន្ធរួមមាន៖ ស្តង់ដាមាតិកា ស្តង់ដាប្រតិបត្តិវាយតម្លៃការសិក្សារបស់សិស្ស ប្រព័ន្ធគណនេយ្យភាព ការអប់រំគ្រូបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន រចនាសម្ព័ន្ធរដ្ឋបាល និងការគាំទ្រដោយមាតាបិតា។ Fullan (២០០៧) យល់ឃើញថា ការអនុវត្តប្រកបដោយជោគជ័យនៃកំណែទម្រង់ជាប្រព័ន្ធទាមទារនូវការបញ្ជាក់ឱ្យច្បាស់ពីគោលបំណងនៃកំណែទម្រង់ សមត្ថភាពស្ថាប័ន ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុដល់គ្រូបង្រៀន នាយកសាលា និងអ្នកពាក់ព័ន្ធផ្សេងទៀត ព្រមទាំងយន្តការវាយតម្លៃ និងតាមដានសមស្រប។

Conley(1993,citedinThompson,1994) បានបង្កើតក្របខ័ណ្ឌនៃកំណែទម្រង់ជាប្រព័ន្ធនៃការអប់រំ ដែលមានសមាសភាគចំនួន ១២ ហើយដែលអាចចាត់ថ្នាក់ទៅក្នុងក្រុមចំនួន៣ គឺ៖ (i) វិធានការកំណែទម្រង់សំខាន់ៗរួមមានលទ្ធផលសិក្សារបស់សិស្ស កម្មវិធីសិក្សា ការរៀននិងការបង្រៀន និងវាយតម្លៃ (ii) កត្តាអំណោយផល ដូចជាបរិយាកាសសិក្សា បច្ចេកវិទ្យា ទំនាក់ទំនងរវាងសហគមន៍និងសាលារៀន និងពេលវេលា និង (iii) កត្តាគាំទ្រ ដូចជាអភិបាលកិច្ច ភាពជាអ្នកដឹកនាំរបស់គ្រូបង្រៀន រចនាសម្ព័ន្ធ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បុគ្គលិក និងទំនាក់ទំនងការងារ។

កំណែទម្រង់ជាប្រព័ន្ធនៃការគ្រប់គ្រងអប់រំ គឺជាកម្មវិធីផ្លាស់ប្តូរយ៉ាងទូលំទូលាយ ដែលរៀបចំដើម្បីកែលម្អសាលារៀន ក្នុងលក្ខណៈប្រុងប្រយ័ត្នបញ្ចូល ស៊ីសាច់គ្នា ដោយសម្របសម្រួល និងសមាហរណកម្មចូលគ្នា ទាំងស្រុង ដើម្បីសម្រេចបានលទ្ធផលអប់រំដែលបានកំណត់យ៉ាងច្បាស់លាស់ (Fuhrman, Elmore & Massell, 1993 cited in Hoy & Miskel, 2008)។ អាទិភាពនៃកំណែទម្រង់ជាប្រព័ន្ធ គឺការដាក់ចេញក្នុងកម្មវិធីសិក្សានូវគោលដៅយ៉ាងខ្ពស់ ខាងផ្នែកចំណេះដឹងតាមមុខវិជ្ជា និងស្តង់ដាលទ្ធផលសិក្សា ដោយផ្សារភ្ជាប់ទៅនឹងកម្មវិធីវាយតម្លៃច្បាស់លាស់។ ការបន្សីគ្នាក្នុងក្របខ័ណ្ឌតែមួយនៃចំណេះដឹងតាមមុខវិជ្ជា និងស្តង់ដាលទ្ធផលសិក្សាជាមួយនឹងយន្តការវាយតម្លៃបង្កើតបានជាប្រព័ន្ធគណនេយ្យភាព សម្រាប់ការត្រួតពិនិត្យប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃកម្មវិធីសិក្សាពីថ្នាក់ទី១ ដល់ថ្នាក់ទី១២។

Ogawa (1994, 2002, 2003 cited in Hoy and Miskel, 2008) លោទជាសំណួរ ជាចំណុចសំខាន់ក្នុងការធ្វើកំណែទម្រង់ជាប្រព័ន្ធគឺថា «តើវិធានការកំណែទម្រង់នាពេលបច្ចុប្បន្នអាចលើកកម្ពស់ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិខាងបច្ចេកទេស ឬការគាំទ្ររបស់សង្គម ជំរុញឱ្យរដ្ឋាភិបាលបង្កើតស្តង់ដាបន្ថែមទៀត និងការចូលរួមពីគ្រូបង្រៀនបានដល់កម្រិតណា?»ដើម្បីឱ្យកំណែទម្រង់នេះមានចីរភាព។ ដើម្បីសម្រេចបានតាមគោលដៅនៃអ្នកធ្វើកំណែទម្រង់ជាប្រព័ន្ធ គេនឹងបង្កើតបរិយាកាសបច្ចេកទេសសម្រាប់សាលារៀនក្នុងការកែលម្អ ហើយគេនឹងមានបង្កើតយន្តការយ៉ាងរឹងមាំសម្រាប់ធានាគណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ប្រសិនបើគេមិនអាចបង្កើតបរិយាកាសបច្ចេកទេសសម្រាប់ការកែលម្អសាលារៀនទេ នោះកិច្ចប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់ជាប្រព័ន្ធនឹងបង្កើតជាសុបិនយ៉ាងក្រាស់ ហើយនឹងធ្វើឱ្យកម្មវិធីសិក្សាពីថ្នាក់ទី១ ដល់ទី១២ កាន់តែមានភាពស្មុគស្មាញខ្លាំងឡើង។ ម្យ៉ាងវិញទៀត ដោយសារតែសាធារណជនទាមទារឱ្យមានកំណែ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទម្រង់ ក៏ប៉ុន្តែកំណែទម្រង់មិនអាចអនុវត្តទៅបាន វាទីងបង្កើតជាទីផ្សារប្រកួតប្រជែងសម្រាប់ការអប់រំមធ្យមសិក្សា តាមរយៈការរីកដុះដាលនៃវិទ្យាល័យឯកជន។

ដើម្បីអនុវត្តកំណែទម្រង់ជាប្រព័ន្ធគេត្រូវយល់ច្បាស់ជាមុនសិន នូវសមាសភាគសំខាន់ៗនៃការគ្រប់គ្រងការអប់រំ ដោយសារតែកំណែទម្រង់ជាប្រព័ន្ធនៃការគ្រប់គ្រងការអប់រំ ទាមទារនូវការធ្វើកំណែទម្រង់គ្រប់សមាសភាគទាំងអស់នៃការគ្រប់គ្រងការអប់រំតែម្តង។

## ៤.៤.២. សមាសភាគនៃការគ្រប់គ្រងអប់រំ

ការអប់រំ គឺជាប្រព័ន្ធស្មុគស្មាញដែលបង្កប់ក្នុងបរិបទសេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។ មិដ្ឋភាពសេដ្ឋកិច្ច វប្បធម៌ និងនយោបាយនៃការអប់រំ គឺមានអន្តរទំនាក់គ្នានិងមានឥទ្ធិពលទៅគ្នាទៅវិញទៅមក។ ដូចនេះ ការអប់រំ គឺមានលក្ខណៈជាប្រព័ន្ធពីធម្មជាតិ។ ការសិក្សាកន្លងមកមួយចំនួនបង្ហាញថា គន្លឹះឈានទៅរកកំណែទម្រង់ជោគជ័យ គឺចាប់ផ្តើមពីការកំណែទម្រង់ជាប្រព័ន្ធ ដែលត្រូវដោះស្រាយបញ្ហានៅតាមអង្គភាពដ៏ស្មុគស្មាញ ដោះស្រាយសមាសភាគ និងបញ្ហាជំពាក់គ្នាជាច្រើន ក្នុងពេលដំណាលគ្នា (Anson, 1994; Fullan, 2007)។ ការសិក្សានាពេលថ្មីៗនេះក៏បានបង្ហាញថា ការកើនឡើងនៃការវិនិយោគលើធាតុចូលការអប់រំ មិនបានធ្វើឱ្យវិស័យអប់រំមានភាពប្រសើរឡើងនោះទេ ដោយសារកំណែទម្រង់ការអប់រំផ្អែកលើការគ្រប់គ្រងជាប្រព័ន្ធ (Pritchett, ២០១៥)។ ប្រសិនបើប្រព័ន្ធអប់រំខ្សោយ ការបន្ថែមធនធាននឹងមិនអាចនាំមកនូវការពង្រឹងគុណភាពអប់រំនោះទេ។ Pritchett (២០១៥) ផ្តល់ការពន្យល់ដូចខាងក្រោម៖

- ប្រទេសឥណ្ឌូនេស៊ីដំឡើងប្រាក់បៀវត្សគ្រូបង្រៀនទ្វេដង និងការវាយតម្លៃយ៉ាងម៉ត់ចត់បង្ហាញថាមានគ្មានឥទ្ធិពលសោះទៅលើការសិក្សា។
- ប្រទេសឥណ្ឌាបង្កើនការចំណាយ ១០ដង និងការចំណាយសរុប



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សម្រាប់សិស្សម្នាក់កើនឡើង៣ដង ប៉ុន្តែមួយទសវត្សនៃការវាយតម្លៃរបស់ ASER និងប្រភពវាយតម្លៃផ្សេងទៀតបានបង្ហាញថា ការសិក្សាគឺកាន់តែដុនដាបទៅ។

• ការវាយតម្លៃយ៉ាងម៉ត់ចត់នៃការបន្ថយទំហំថ្នាក់ក្នុងប្រទេសកេនយ៉ាដោយជួលគ្រូបង្រៀនជាប់កិច្ចសន្យាបង្ហាញពីភាពប្រសើរឡើងនៃការសិក្សា នៅពេលដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែកម្មវិធីដូចគ្នានេះមានឥទ្ធិពលសូន្យ នៅពេលអនុវត្តដោយក្រសួងអប់រំ ។

• ការផ្តល់សៀវភៅសិក្សាបន្ថែមមានឥទ្ធិពលសូន្យ ប្រសិនបើគ្មានការផ្លាស់ប្តូរក្នុងការលើកចិត្តគ្រូបង្រៀន។

• គណៈកម្មការអប់រំរកឃើញថា«ការកែលម្អក្នុងការរៀបចំ និងការផ្តល់សេវាអប់រំឱ្យបានជោគជ័យ ទាល់តែត្រូវពង្រឹងប្រព័ន្ធដែលបានបង្កើតលទ្ធផលជោគជ័យ»។

ប្រព័ន្ធគ្រប់គ្រងការអប់រំមានលក្ខណៈស្មុគស្មាញ។ UNESCO (១៩៨៩) បានកំណត់ចំណាត់ថ្នាក់ជា៣ធំៗនៃទ្រឹស្តីការគ្រប់គ្រងការអប់រំ និងបានបង្កើតម៉ូដែល ផ្អែកលើលក្ខណៈវិនិច្ឆ័យទាំង៤៖ (១) រដ្ឋបាលដែលមានប្រសិទ្ធភាព (២) រដ្ឋបាលដែលមានភាពស័ក្តិសិទ្ធិ (៣) រដ្ឋបាលដែលមានការឆ្លើយតប និង (៤) រដ្ឋបាលដែលសមស្រប។ សូមមើលទ្រឹស្តីនីមួយៗខាងក្រោម៖

(i) **រដ្ឋបាលដែលមានប្រសិទ្ធភាព៖** គឺកើតចេញពីសាលារដ្ឋបាលបែបបុរាណ និងកើតចេញពីការអនុវត្តនៃការដំណើរការរបស់សាលាដែលធ្វើទៅតាមការយល់ឃើញនៃការគ្រប់គ្រងបែបការិយាធិបតេយ្យ និងវិទ្យាសាស្ត្រជាទូទៅ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃប្រសិទ្ធភាពសេដ្ឋកិច្ច។ គោលបំណងនៃរដ្ឋបាលអប់រំ គឺជានាមធ្យោបាយសមស្របសម្រាប់សម្រេចបានគោលដៅ ផលិតកម្ម និងកម្រិតខ្ពស់នៃផលិតភាព។

(ii) **រដ្ឋបាលដែលមានភាពស័ក្តិសិទ្ធិ៖** គឺទាក់ទងនឹងផ្នែករដ្ឋបាល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាលាចិត្តវិទ្យា ហើយ កើតចេញពីការវាយតម្លៃបទពិសោធនៃការអនុវត្ត របស់សាលា ដែលប្រកាន់យកគោលការណ៍ឥរិយាបថផ្នែករដ្ឋបាល។

(iii) ***រដ្ឋបាលដែលមានការឆ្លើយតប៖*** *គឺផ្អែកលើទ្រឹស្តីគ្រប់គ្រង និង បង្កើតបានជាការវិភាគបទពិសោធនៃការអនុវត្តខុសៗគ្នាក្នុងរដ្ឋបាលអប់រំ និងសាធារណៈ។ អ្នកគាំទ្រនៃចលនាសហសម័យ គិតថាស្ថាប័ន គឺជាប្រព័ន្ធបើកចំហ និងអាចផ្លាស់ប្តូរបាន។*

(iv) ***រដ្ឋបាលដែលសមស្រប៖*** *គឺកើតចេញពីទស្សនវិជ្ជាបាតុភូតិនិយម អត្ថិភាពនិយម វិធីសាស្ត្រវិចារវិទ្យា និងទ្រឹស្តីសកម្មភាពរបស់មនុស្ស។*

UNESCO *(១៩៨៩) បានសំយោគគំរូនៃការគ្រប់គ្រងការអប់រំឱ្យទៅជាប្រព័ន្ធគ្រប់គ្រងមួយ ដែលមានសមាសភាគច្រើនដែលទាក់ទងគ្នា និងអាចបញ្ចូលបានជាបួនក្រុមធំៗ៖ សេដ្ឋកិច្ច នយោបាយ គរុកោសល្យ និងវប្បធម៌។*




រូបភាព(២)៖ ការគ្រប់គ្រងការអប់រំមានសមាសភាគពហុវិស័យ (UNESCO, ១៩៨៩)

***១. សមាសភាគនយោបាយ ឬ ការគ្រប់គ្រងរដ្ឋបាលនិងទូទៅ ៖*** *ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនៃសកម្មភាពជាក់ស្តែងនៃតួអង្គអប់រំនិងសហគមន៍។ ដើម្បីសិក្សានិងស្វែងយល់ពីទិដ្ឋភាពនយោបាយនៃរដ្ឋបាលអប់រំ គេអាចសិក្សាគោលការណ៍មូលដ្ឋានទៅក្នុងវិទ្យាសាស្ត្រនយោបាយ ច្បាប់រដ្ឋបាល និងរដ្ឋបាលសាធារណៈ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

២. សមាសភាគគរុកោសល្យ ឬ ការគ្រប់គ្រងការសិក្សា ៖ សំដៅទៅលើគោលការណ៍អប់រំ ពាក់ព័ន្ធនឹងការបង្រៀននិងការរៀន និងបច្ចេកទេសនិងវិធីសាស្ត្របង្រៀន ដែលនឹងជួយឱ្យសម្រេចបានគោលបំណងនៃប្រព័ន្ធអប់រំ។

៣. សមាសភាគសេដ្ឋកិច្ច ៖ ពាក់ព័ន្ធនឹងធនធានសម្ភារនិងហិរញ្ញវត្ថុ រចនាសម្ព័ន្ធ របៀបរបបការងារ និងយន្តការនៃការសម្របសម្រួល និងទំនាក់ទំនង។ ក្នុងទិដ្ឋភាពនេះ រដ្ឋបាលអប់រំត្រូវផ្ដោតលើការបែងចែកនិងការគ្រប់គ្រងធនធាន អង្គភាព/ស្ថាប័ន ការកំណត់តួនាទីនិងការទទួលខុសត្រូវនិងការបែងចែកការងារ។

៤. សមាសភាគវប្បធម៌ឬការគ្រប់គ្រងធនធានមនុស្ស ៖ សំដៅលើតម្លៃនិងចរិតលក្ខណៈរបស់អ្នកចូលរួមក្នុងប្រព័ន្ធអប់រំនិងសង្គមជាទូទៅ។ តួនាទីរបស់រដ្ឋបាលអប់រំគឺ ត្រូវសម្របសម្រួលសកម្មភាព និងធ្វើអន្តរទំនាក់ទំនងរវាងបុគ្គលនិងក្រុម ដែលចូលរួមដោយផ្ទាល់ឬដោយប្រយោលក្នុងដំណើរការអប់រំរបស់សហគមន៍។

នៅកម្រិតខ្សែទទឹង ប្រព័ន្ធគ្រប់គ្រងអប់រំ រួមមានការគ្រប់គ្រងគោលនយោបាយអប់រំ (ក្រសួងអប់រំ) ប្រព័ន្ធបណ្ដុះបណ្ដាលគ្រូបង្រៀន និងសាលារៀន។ Hoy និង Miskel (២០០៨) បានធ្វើសំយោគអំពីការគ្រប់គ្រងអប់រំនៅកម្រិតសាលារៀន។ សាលារៀនគឺជាប្រព័ន្ធសង្គមបើកចំហ និងមានធាតុសំខាន់ ឬអនុប្រព័ន្ធចំនួន ៥ ៖ រចនាសម្ព័ន្ធ បុគ្គល វប្បធម៌ នយោបាយ និងគរុកោសល្យ។ ឥរិយាបថស្ថាប័ន គឺជាមុខងារនៃអន្តរទំនាក់ទំនងនៃធាតុទាំងនេះ ក្នុងបរិបទនៃការបង្រៀននិងរៀន។ ដំណើរការនៃការរៀនសូត្រតាមរយៈការបង្រៀន គឺជាបច្ចេកទេសស្នូលនៃប្រព័ន្ធសង្គមរបស់សាលារៀន។ វាមិនត្រឹមតែផ្តល់ជាធនធានសម្រាប់ប្រព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបង្កើតនូវបញ្ហាប្រឈម និងឱកាសបន្ថែម។ ស្ថានភាពរស់រវើកប្រសិទ្ធភាពកើតចេញពីដំណាក់កាលនីមួយៗនៃប្រព័ន្ធបើកចំហ cycle-input (ធន-



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជានមនុស្ស និងហិរញ្ញវត្ថុ) ការផ្លាស់ប្តូរ (ដំណើរការខាងក្នុង និងរចនាសម្ព័ន្ធ) និងលទ្ធផល (លទ្ធផលអនុវត្ត)។

សាលារៀនជាប្រព័ន្ធបើកចំហមួយ ដែលពាក់ព័ន្ធនឹងការដាក់ធាតុចូល ដំណើរការ និងបម្លែងទៅជាលទ្ធផល ។ ធនធានមនុស្ស វត្ថុធាតុដើម ព័ត៌មាន និងថវិកា គឺជាតុចូលទូទៅសម្រាប់សាលារៀន។ ក្នុងដំណើរការនៃការផ្លាស់ប្តូរធាតុចូលទាំងនេះ ត្រូវបានផ្លាស់ប្តូរទៅជាតម្លៃដែលហៅថាលទ្ធផល និងផ្តល់ផលវិញទៅក្នុងសង្គម។ លទ្ធផលគឺ ផលិតផលនិងសេវាដែលរាប់បញ្ចូលទាំង ការពេញចិត្តរបស់និយោជក និងអ្នកពាក់ព័ន្ធផ្សេងទៀត។ ថ្នាក់រៀន សៀវភៅ កុំព្យូទ័រ សម្ភារសិក្សា គ្រូបង្រៀន និងសិស្សក៏ជាធាតុចូលសំខាន់សម្រាប់សាលារៀនផងដែរ។

លក្ខណៈវិនិច្ឆ័យនៃការផ្លាស់ប្តូរសំដៅទៅលើបរិមាណ គុណភាព និងការស៊ីចង្វាក់គ្នានៃដំណើរការផ្នែកខាងក្នុង និងរចនាសម្ព័ន្ធ ដែលបានផ្លាស់ប្តូរធាតុចូលទៅជាលទ្ធផល។ ឧទាហរណ៍ នៃលក្ខណៈវិនិច្ឆ័យការផ្លាស់ប្តូរ គឺរចនាសម្ព័ន្ធនិងមាតិការបស់កម្មវិធីសិក្សា បរិយាកាសអន្តរបុគ្គល កម្រិតនៃការលើកទឹកចិត្តរបស់សិស្សនិងគ្រូបង្រៀន ភាពដឹកនាំរបស់អ្នករដ្ឋបាលនិងគ្រូបង្រៀន គុណភាពនិងបរិមាណនៃការបង្រៀន និងនីតិវិធីនៃការត្រួតពិនិត្យគុណភាពដូចជាចំនួនតេស្ត ការវាយតម្លៃការបង្រៀន ការប្រើប្រាស់បច្ចេកវិទ្យា និងការវាយតម្លៃបុគ្គល។ អតិបរមានៃប្រសិទ្ធភាពរបស់សាលារៀន ជាតុខាងក្នុងនៃការបង្រៀននិងរៀន ការរំពឹងទុកនៃការិយាធិបតេយ្យ វប្បធម៌ក្រុម ការរំពឹងទុកផ្នែកនយោបាយ តម្រូវការបុគ្គល ត្រូវតែធ្វើការដោយស៊ីចង្វាក់គ្នា ដើម្បីសម្រេចបានតាមគោលដៅចង់បាន។

លទ្ធផលបង្កើតបានជាគុណភាពនៃសេវារបស់សាលារៀន និងផលិតផលសម្រាប់សិស្ស អ្នកអប់រំ និង អ្នកពាក់ព័ន្ធផ្សេងទៀត។ តាមរយៈទស្សនវិស័យប្រព័ន្ធសង្គម លទ្ធផលសំខាន់រួមមាន (i) សម្រាប់សិស្ស៖ ភាពជោគជ័យក្នុងការសិក្សា ការបង្កើតថ្មី ភាពជឿជាក់ ការជំរុញទឹកចិត្ត ក្តីរំពឹងទុក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វត្តមាន ការបញ្ចប់ការសិក្សា និងអត្រាត្រួតថ្នាក់ (ii) សម្រាប់អ្នកស្រាវជ្រាវ៖ ភាពពេញចិត្តការងារ អវត្តមាន និងផលត្រឡប់វិញ និង (iii) សម្រាប់អ្នករដ្ឋបាល៖ ក្ដីពេញចិត្តលើការងារ ថវិកា និងការប្ដេជ្ញាចិត្តចំពោះសាលារៀន។

ភាពស្មុគស្មាញ នៃប្រព័ន្ធគ្រប់គ្រងអប់រំពហុកម្រិត បានឈានទៅដល់ការរីកសាយភាយនៃគំរូគ្រប់គ្រងអប់រំខុសៗគ្នា។ Bush និង Bell (២០០៩) បានស្នើទ្រឹស្ដីបទ (ឬម៉ូ) ទាក់ទងនឹងម៉ូដែលគ្រប់គ្រង។ យើងអាចធ្វើការអង្កេតដូចខាងក្រោម៖

(i) ម៉ូដែលផ្លូវការនៃការគ្រប់គ្រងត្រូវបានស្នើឡើង ក្នុងអំឡុងដំណាក់កាលដំបូងនៃការបង្កើតទ្រឹស្ដីគ្រប់គ្រងការអប់រំ។ ម៉ូដែលទាំងនេះបានបញ្ជាក់ពីរចនាសម្ព័ន្ធផ្លូវការ ការសម្រេចចិត្ត សនិទានកម្ម និងភាពដឹកនាំពីលើមកក្រោម។

(ii) ម៉ូដែល collegial នៃការគ្រប់គ្រង អាចឱ្យមានការចូលរួមរបស់គ្រូបង្រៀនក្នុងការសម្រេចចិត្ត។ នាយកសាលារៀនជាច្រើនជំរុញទៅ collegiality។ ម៉ូដែល collegial ផ្ដល់នូវបរិយាកាសសម្រាប់ការសម្រេចពីលើមកក្រោម។

(iii) ម៉ូដែលនៃការគ្រប់គ្រងផ្អែកលើតម្លៃនិងផលប្រយោជន៍ និងបញ្ជាក់ពីសារៈសំខាន់នៃអត្ថន័យរបស់បុគ្គល។ ម៉ូដែលនេះ អាចប្រើប្រាស់ដោយអ្នកដឹកនាំ ដែលស្វែងរកតម្លៃផ្ទាល់ខ្លួននៅសាលារៀន។

(iv) ម៉ូដែលនៃការគ្រប់គ្រងតាមបែប ambiguity បញ្ជាក់ពី turbulence និង anarchy។ មធ្យោបាយនេះផ្ដល់គោលការណ៍មួយចំនួនសម្រាប់សកម្មភាពគ្រប់គ្រង។

## ៤.៤.៣. កំណែទម្រង់ការគ្រប់គ្រងអប់រំតាមនិន្នាការបច្ចេកទេស

តាមនិយមន័យខាងលើ យើងអាចសន្និដ្ឋានថា កំណែទម្រង់ការគ្រប់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រងការអប់រំជាប្រព័ន្ធ សំដៅលើសកម្មភាពដែលពាក់ព័ន្ធគ្រប់ទិដ្ឋភាពនៃកំណែទម្រង់ការគ្រប់គ្រងអប់រំ ដូចជាកំណែទម្រង់ការគ្រប់គ្រងទូទៅនិងរដ្ឋបាល កំណែទម្រង់ការគ្រប់គ្រងការសិក្សា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស (MoEYS, ២០១៧)។ ក្នុងរយៈពេលខ្លី កំណែទម្រង់ការអប់រំជាប្រព័ន្ធ ទាមទារនូវទំនាក់ទំនងជាប្រព័ន្ធដ៏រឹងមាំ រវាងគោលនយោបាយអប់រំនៅកម្រិតក្រសួង គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងសាលារៀនឬថ្នាក់រៀន។

**កំណែទម្រង់ការគ្រប់គ្រងទូទៅនិងរដ្ឋបាល៖** ទាមទារឱ្យមានទំនាក់ទំនងរវាងការអនុវត្តគោលនយោបាយនៅថ្នាក់ជាតិ ដូចជាគោលនយោបាយអប់រំជាតិ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ច្បាប់ស្តីពីការអប់រំ ភ្ជាប់គ្នាជាមួយនឹងគោលនយោបាយនិងរចនាសម្ព័ន្ធរដ្ឋបាល (ឧទា. ការបែងចែកការគ្រប់គ្រងការអប់រំនៅថ្នាក់ខេត្ត ស្រុក និងសាលារៀន) និងម្យ៉ាងវិញទៀតការអនុត្តគោលនយោបាយនៃកម្រិតសាលារៀន ដូចជាការគ្រប់គ្រងតាមសាលារៀន និងចូលរួមរបស់សហគមន៍ក្នុងសកម្មភាពសាលារៀន។

**កំណែទម្រង់ការគ្រប់គ្រងការសិក្សា៖** ទាមទារឱ្យមានការសម្របសម្រួលរវាងស្តង់ដាកម្មវិធីសិក្សាជាតិ ការធ្វើតេស្ត និងការវាយតម្លៃការសិក្សានៅកម្រិតជាតិ និងការបង្រៀននិងការរៀន អធិការកិច្ចសាលារៀន និងលទ្ធផលនៃការសិក្សារបស់សិស្សនៅកម្រិតសាលារៀន។ កំណែទម្រង់ ទទួលបានជោគជ័យ គ្រូបង្រៀនត្រូវការពេលវេលាដើម្បីសិក្សា បង្រៀន ច្នៃប្រឌិតសិក្សាជំនាញនិងគំនិតថ្មី អនុវត្តការងាររដ្ឋបាល និងដោះស្រាយបញ្ហា (Joseph Cambone in Anson, ១៩៩២)។ គាត់បានសង្កត់ធ្ងន់ថា កំណែទម្រង់មិនគួររងឥទ្ធិពលជាមួយនឹងពេលវេលាបង្រៀនរបស់គ្រូបង្រៀននោះទេ។ លើសពីនេះទៀត គ្រូបង្រៀនគួរតែធ្វើសមាហរណកម្មកំណែទម្រង់ទៅក្នុងបរិបទនៃបង្រៀនរបស់ពួកគេ។ កិច្ចសហការ ត្រូវចាំបាច់ ដើម្បី ជំរុញអន្តរទំនាក់ទំនង គាំទ្រ និងកំណើនភាពវៃឆ្លាត។ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

ជំរុញនូវការពាក់ព័ន្ធទស្សនៈជាបុគ្គលទៅលើការផ្លាស់ប្តូរ (Judith Warren Little in Anson, ១៩៩៤)។

Priscilla Wohlstetter, Roxane Smyer និង Susan Albers Mohrman (in Anson, ១៩៩៤) បានកំណត់ប្រភពធនធានចំនួន ៤ ដើម្បីធ្វើឱ្យការគ្រប់គ្រងតាមសាលារៀន ក្លាយជាសក្តានុពលសម្រាប់កំណែទម្រង់ការអប់រំ។ បន្ថែមទៅនឹងអំណាចដែលផ្តល់ឱ្យ ចំណេះដឹងនិងជំនាញត្រូវតែអភិវឌ្ឍ ព័ត៌មានស្តីពីបរិបទនិងគោលដៅរបស់អង្គភាពត្រូវតែមាន និងការផ្តល់ប្រាក់រង្វាន់ត្រូវតែផ្អែកលើការអនុវត្ត។ ពួកគេរកឃើញថា ភាពជោគជ័យមានទំនាក់ទំនងទៅនឹងការចែករំលែកអំណាចក្នុងចំណោមអ្នកចូលរួម ការបណ្តុះបណ្តាល គត់ម៉ត់ ដើម្បីទាញយកផលប្រយោជន៍ ឱកាស និងប្រព័ន្ធសហការ និងការចែករំលែកព័ត៌មាន។

Jane David (in Anson, ១៩៩៤) បានស្នើឱ្យប្រើប្រាស់នូវអំណាចនៃបច្ចេកវិទ្យា ដើម្បីជំរុញកំណែទម្រង់សាលារៀន។ ទោះបីជា បច្ចេកវិទ្យាមិនអាចឆ្លើយតបទៅនឹងបញ្ហានានានៃកំណែទម្រង់ក៏ដោយ ប៉ុន្តែវាអាចជាផ្នែកដ៏មានឥទ្ធិពលមួយនៃដំណោះស្រាយ។ បច្ចេកវិទ្យាព័ត៌មានវិទ្យាគួរត្រូវបានគេប្រើប្រាស់ ដំណើរការ និងគាំទ្រដោយមានការបណ្តុះបណ្តាលត្រឹមត្រូវ។

***កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ៖*** ពាក់ព័ន្ធនឹងការបែងចែកធនធានកាន់តែច្រើនផ្សារភ្ជាប់ទៅនឹងគោលនយោបាយអប់រំ។ កំណែទម្រង់ត្រូវប្រាកដថា ថវិកាសាលារៀន និងការផ្តល់ធនធានបន្ថែម គឺត្រូវបានគ្រប់គ្រងយ៉ាងល្អនៅកម្រិតសាលារៀន។ រដ្ឋាភិបាលអាចនឹងធ្វើការកែលម្អរចនាសម្ព័ន្ធចំណាយ ដើម្បីបែងចែកធនធានឡើងវិញពីការអប់រំកម្រិតឧត្តមសិក្សា ទៅឱ្យការអប់រំកម្រិតក្រោមជាងនេះ (Tiongson, ២០០៥)។ កំណែទម្រង់ហិរញ្ញវត្ថុរួមបញ្ចូលទាំងការផ្ទេរធនធានថវិកាដោយផ្ទាល់ពីរតនាគារជាតិទៅកាន់សាលារៀន ឬក៏ការកែលម្អនីតិវិធីនិងរដ្ឋបាលហិរញ្ញវត្ថុ ដើម្បីកែលម្អលទ្ធផលសិក្សាឱ្យកាន់តែប្រសើរ (Hang-Chuon, ២០១៦)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

***កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស*** ទាមទារឱ្យមានការសម្របសម្រួលរវាងការបណ្តុះបណ្តាលគ្រូបង្រៀន ប្រកបដោយវិជ្ជាជីវៈនៅកម្រិតជាតិ ជាមួយនិងការអភិវឌ្ឍធនធានមនុស្សនៅកម្រិតសាលារៀន ឆ្ពោះទៅលើកកម្ពស់ជំនាញរបស់សិស្សានុសិស្ស។ កំណែទម្រង់ជាប្រព័ន្ធមិនគ្រាន់តែជាការផ្តល់ហេដ្ឋារចនាសម្ព័ន្ធនោះទេ ប៉ុន្តែថែមទាំងកសាងសមត្ថភាពនៅគ្រប់កម្រិត ជាពិសេសសាលារៀន (Levin, ២០១០)។ កំណែទម្រង់ត្រូវការកិច្ចសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធទាំងអស់។ កំណែទម្រង់ប្រព័ន្ធស៊ីជម្រៅ តម្រូវឱ្យចាប់ផ្តើមកែទម្រង់ទាំងធនធានមនុស្សនិងសម្ភារ ដូចនេះកំណែទម្រង់ត្រូវតែកំណត់ចក្ខុវិស័យឱ្យបានស៊ីជម្រៅ ច្បាស់លាស់ និងមានភាពច្នៃប្រឌិតប្រកបដោយនិរន្តរភាព (Kurth-Schai និង Green, ២០០៨)។ វិធានការកំណែទម្រង់គួរតែជំរុញការលើកទឹកចិត្ត និងបង្កើនសមត្ថភាពអ្នកពាក់ព័ន្ធទាំងអស់។ Fullan (២០០៧) បានគិតថាភាពជោគជ័យ ឬបរាជ័យនៃការផ្លាស់ប្តូរការអប់រំ គឺកើតឡើងពីដំណើរការឌីណាមិក ដែលពាក់ព័ន្ធនឹងអញ្ញត្តិជាច្រើនក្នុងរយៈពេលយូរ ហើយគាត់ស្នើឡើងថា កំណែទម្រង់ជោគជ័យត្រូវការកិច្ចសម្របសម្រួលរវាងកំណែទម្រង់ពីលើមកក្រោម និងពីក្រោមទៅលើ។

***កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលនិងទូទៅ*** ៖ ប្រសិនបើយើងវិភាគកំណែទម្រង់ការគ្រប់គ្រងអប់រំតាមប្រព័ន្ធរដ្ឋបាល យើងអាចចែកកំណែទម្រង់ ការគ្រប់គ្រងការអប់រំតាមសមាសភាគដូចតទៅ៖ (១) កំណែទម្រង់គោលនយោបាយនិងយុទ្ធសាស្ត្រវិស័យអប់រំ (២) កំណែទម្រង់ការបណ្តុះបណ្តាលគ្រូ និង (៣) កំណែទម្រង់ការគ្រប់គ្រងសាលារៀន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.៥. ការសម្របសម្រួលរវាងកំណែទម្រង់ពីលើចុះក្រោមនិងកំណែទម្រង់ពីក្រោមឡើងលើ

ដូចបានរៀបរាប់ខាងលើ កំណែទម្រង់ការគ្រប់គ្រងការអប់រំជាប្រព័ន្ធប្រកបដោយជោគជ័យ ទាមទារឱ្យមានទំនាក់ទំនងរវាងកំណែទម្រង់ពីលើមកក្រោម និងពីក្រោមទៅលើ (Fullan យោងដោយ Ason ១៩៩៤;Pauls ton និង LeRoy,១៩៨២)។ Paulston និង LeRoy (១៩៨២, យោងដោយ Arnove, ២០០៧) បានផ្តល់ជាក្របខ័ណ្ឌគំនិតសម្រាប់កំណែទម្រង់ការអប់រំ ដែលរួមមានគោលការណ៍អាក់ស៊ីស ចំនួន ២ ៖ (i) អាក់ស៊ីសដេក ពាក់ព័ន្ធនឹងចំណុចដែលកំណែទម្រង់ចាប់ផ្តើម ទោះបីជានៅផ្នែកខាងលើជាមានលក្ខណៈការិយាធិបតេយ្យកម្រិតជាតិឬអន្តរជាតិ ឬក៏នៅផ្នែកខាងក្រោមមានលក្ខណៈ ជាចលនានៅថ្នាក់មូលដ្ឋានក៏ដោយ និង (ii) អាក់ស៊ីសឈរពាក់ព័ន្ធនឹងគោលដៅនៃការផ្លាស់ប្តូរការអប់រំ ដើម្បីស្របនឹងតម្រូវការរបស់វិស័យសេដ្ឋកិច្ច ឬក៏ជំរុញការផ្លាស់ប្តូរផ្នែកនយោបាយ និងសង្គម វប្បធម៌ក៏ដោយ។

ការសិក្សារបស់ Paulston និង LeRoy's (១៩៨២ យោងដោយ Arnove, ២០០៧) បានបង្ហាញថា កម្មវិធីកំណែទម្រង់ការអប់រំភាគច្រើនផ្តោតត្រង់ផ្នែកខាងឆ្វេងនៀងខាងលើ (ដូចរូបទី ១) ហើយត្រូវបានរៀបចំឡើងឱ្យស្របនឹងតម្រូវការ «មូលធនមនុស្ស» និងតម្រូវការរបស់ក្រុម។ អ្នកសម្រេចចិត្តនៅថ្នាក់ជាតិបានផ្តោតខ្លាំងលើការប្រកួតប្រជែងជាអន្តរជាតិ លើវិស័យសេដ្ឋកិច្ច និងផលិតផល (ធនធានមនុស្ស) ដែលកើតចេញពីប្រព័ន្ធអប់រំ (Arnove, ២០០៧)។

ក្របខ័ណ្ឌគំនិតខាងលើ មានសារៈសំខាន់ណាស់សម្រាប់ស្វែងយល់ពីទ្រឹស្តីនៃកំណែទម្រង់ការអប់រំ។ នៅពេលដែលកិច្ចប្រឹងប្រែងក្នុងផ្លាស់ប្តូរការអប់រំ រាប់ចាប់តាំងពី គំនិតបង្កើតថ្មីក្នុងថ្នាក់រៀន រហូតដល់កំណែទម្រង់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទូលំទូលាយ ត្រូវការការផ្លាស់ប្តូរនៅកម្រិតប្រព័ន្ធ ដូចជាគោលដៅអប់រំ អាទិភាពអប់រំ និងរចនាសម្ព័ន្ធអប់រំ។




រូបភាព (៣) ៖ កំណែទម្រង់ពីលើមកក្រោម និងពីក្រោមទៅលើ (Arnove, ២០០៥)

ដំណើរការកំណែទម្រង់ការគ្រប់គ្រងការអប់រំមានភាពស្មុគស្មាញ និងបត់បែន។ ការផ្លាស់ប្តូរការអប់រំរងឥទ្ធិពលពីកត្តាជាច្រើន។ ការផ្លាស់ប្តូរនឹងអនុវត្តទៅបាន នៅពេលដែលកត្តាជាច្រើនគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងការអប់រំ។ Fullan (២០០៧) យល់ឃើញថាកត្តាដែលមានឥទ្ធិពលច្រើនតែមានផលប៉ះពាល់ខុសៗគ្នា នៅតាមទម្រង់នៃការផ្លាស់ប្តូរ។ ការសិក្សាជាច្រើនបង្ហាញថា នៅពេលកំណែទម្រង់ធ្វើឡើងដាច់ដោយឡែកពីគ្នា កំណែទម្រង់ពីលើមកក្រោមនិងពីក្រោមទៅលើត្រូវទទួលបរាជ័យ។ Fullan ធ្វើការសន្និដ្ឋានថា ការសម្របសម្រួលយុទ្ធសាស្ត្រពីលើមកក្រោម និងពីក្រោមទៅលើ បង្កើតបានជាម៉ូដែលកាន់តែទូលំទូលាយនិងស៊ីចង្វាក់គ្នាសម្រាប់ការផ្លាស់ប្តូរកាន់តែមានប្រសិទ្ធភាព។

ការសម្របសម្រួលរវាងកំណែទម្រង់ពីលើមកក្រោមនិងពីក្រោមទៅលើត្រូវការលក្ខខណ្ឌដូចខាងក្រោម៖

ជំហានដំបូងនៅថ្នាក់ជាតិ វិធានការកំណែទម្រង់ការគ្រប់គ្រងការអប់រំផ្តោតលើការផ្តល់ការ គាំទ្រហិរញ្ញវត្ថុនិងការលើកទឹកចិត្តព្រមទាំងជំរុញសម្ពាធពីខាងក្រៅ និងការគាំទ្រដល់សាលារៀន ដើម្បីអនុវត្តកម្មវិធីកំណែ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទម្រង់។ កា រគាំទ្រពីខាងក្រៅបានគាំទ្រដល់គ្រូបង្រៀនចេញថ្មី និងផ្តល់ការណែនាំសម្រាប់គ្រូបង្រៀនដែលត្រូវការដូចជា កម្មវិធីវិក្រឹតការដើម្បីកែលម្អវិធីសាស្ត្របង្រៀន ជាដើម។

ជំហានទីពីរ នៅកម្រិតសាលារៀន ទាំងបេនាសម្ព័ន្ធសាលារៀន (ដូចជាបរិយាកាសសាលាវិជ្ជមាន) ទាំងគ្រូបង្រៀន ជាកត្តាគាំទ្រគ្នាទៅវិញទៅមក តាមរយៈសហគមន៍សិក្សាធ្វើការផ្លាស់ប្តូរគំនិតនិងបទពិសោធន៍ និងជួយសម្រួលដល់កម្មវិធីកំណែទម្រង់។

Fullan (២០០៧) បានបរិយាយពីលក្ខខណ្ឌដែលត្រូវការ សម្រាប់កំណែទម្រង់ការអប់រំជាប្រព័ន្ធទាំងមូលឱ្យទទួលបានជោគជ័យ។ កំណែទម្រង់គួរតែធ្វើឡើងក្នុងថ្នាក់រៀនផ្តោះទៅកែលម្អការសិក្សា។ Fullan (២០០៧) យល់ឃើញថា វប្បធម៌ប្រចាំថ្ងៃនៃប្រព័ន្ធសាលារៀន គឺជាធាតុដ៏សំខាន់ដែលជំរុញកំណែទម្រង់ទៅមុខ និងមាននិរន្តរភាព។ ដូចនេះ ការលើកទឹកចិត្ត ការកែលម្អការបង្រៀន ការងារជាក្រុម និងការចូលរួមទាំងអស់គ្នា គឺជាគ្រឹះនៃកំណែទម្រង់សាលារៀន (Fullan, ២០០៧)។ កំណែទម្រង់ការអប់រំជោគជ័យ តម្រូវឱ្យមានទំនាក់ទំនងគ្នារវាងយុទ្ធសាស្ត្រពីលើមកក្រោមនិងពីក្រោមទៅលើ។ កំណែទម្រង់នេះត្រូវអនុវត្តនៅកម្រិតមូលដ្ឋាន រវាងស្រុក និងសាលារៀន និងអនុវត្តនៅកម្រិតខេត្ត រវាងរដ្ឋាភិបាល និងសាលារៀន។ កម្លាំងនៃការផ្លាស់ប្តូរមានភាពស្មុគស្មាញ ប៉ុន្តែមានគោលវិធីមួយគឺ ការស្វែងរកយុទ្ធសាស្ត្ររួមគ្នា សិក្សាពីភាពស្មុគស្មាញ ទាំងនោះ ធ្វើការសម្រួល និងពង្រឹងសមត្ថភាពធ្វើការជាមួយគ្នា។

ជាសរុប សមាសធាតុ ៤ នៃការផ្លាស់ប្តូរការអប់រំ មានដូចជា ៖ មនុស្ស ការអនុវត្ត ដំណើរការ និងគោលនយោបាយ។ កត្តាមនុស្សត្រូវចូលរួមក្នុងការផ្លាស់ប្តូរក្នុងបរិបទនៃការអនុវត្ត និងធ្វើឱ្យមានការគាំទ្រផ្នែកនយោបាយដែលអាចធ្វើឱ្យអ្នកចូលរួមទាំងអស់ធ្វើការរួមគ្នា (Suzanne Stiegelbauer in Anson, ១៩៩៤)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.៦. ការសម្របសម្រួលរវាងការផ្ដត់ផ្គង់ និងតម្រូវការរបស់សាលារៀន

ប្រសិទ្ធភាពកំណែទម្រង់ការអប់រំ ពាក់ព័ន្ធនឹងសមាសធាតុផ្សេងៗគ្នានៃប្រព័ន្ធអប់រំ ដូចជា (១) លក្ខណសម្បត្តិរបស់គ្រូបង្រៀននិងសាលារៀន និង (២) លក្ខណសម្បត្តិរបស់សិស្សនិងគ្រួសារ។ គោលនយោបាយរដ្ឋាភិបាលអាចមានឥទ្ធិពលដោយផ្ទាល់និងដោយប្រយោល លក្ខណសម្បត្តិរបស់គ្រូបង្រៀននិងសាលារៀន។ គោលនយោបាយមានគោលបំណងផ្លាស់ប្ដូរលក្ខណសម្បត្តិរបស់គ្រូបង្រៀននិងសាលារៀន គឺជាគោលនយោបាយដែលផ្ដោតលើការផ្គត់ផ្គង់។ Glewwe, Hanushek, Humpage និង Ravina (២០១៤) បានពិនិត្យមើលករណីសិក្សាចំនួន ៧៩ ទាក់ទងនឹងឥទ្ធិពលនៃអញ្ញាត្តជាច្រើនទៅលើការសិក្សារបស់សិស្សតាមរយៈពិន្ទុតេស្ត។ លក្ខណសម្បត្តិរបស់សាលារៀននិងគ្រូបង្រៀនជាង ៣០ចំណុច ដែលអាចមានឥទ្ធិពលទៅពិន្ទុរបស់សិស្ស។ ចំណុចទាំងនោះអាចបែងចែកជា ៣ ប្រភេទ៖ (១) ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងសម្ភារតុកោសល្យ (២) លក្ខណសម្បត្តិគ្រូបង្រៀន និងនាយកសាលា និង (៣) រចនាសម្ព័ន្ធសាលារៀន។

Glewwe និងសហសេវិករបស់គាត់បានពិនិត្យលើការសិក្សាទាំងនេះដោយរកឃើញថា ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងសម្ភារតុកោសល្យមានឥទ្ធិពលជាវិជ្ជមានទៅលើពិន្ទុតេស្ត។ ការសិក្សាភាគច្រើន (៣៦) បានផ្ដល់នូវភស្តុតាងយ៉ាងរឹងមាំថា សៀវភៅសិក្សានិងសម្ភារសិក្សា (សៀវភៅកិច្ចការ សៀវភៅលំហាត់) បានបង្កើនលទ្ធផលសិក្សារបស់សិស្ស។ ឥទ្ធិពលដែលមានជាទូទៅបំផុតគឺ គ្រឿងសង្ហារិមជាមូលដ្ឋាន (តុការិយាល័យ តុ និងកៅអី) និងកុំព្យូទ័រ និងល្បែងអេឡិចត្រូនិក។ ភាពមានគ្រប់គ្រាន់នៃតុការិយាល័យ តុ និងកៅអី បានបង្កើនពិន្ទុតេស្ត។ ទោះបីជាយ៉ាងណា លទ្ធផលបង្ហាញថា សម្រាប់កុំព្យូទ័រពុំមានភាពច្បាស់លាស់ឡើយ។ កត្តានេះបង្ហាញ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថា ត្រូវមានការប្រុងប្រយ័ត្នពេលប្រើប្រាស់ធនធានដែលកំពុងកម្រសម្រាប់ទិញកុំព្យូទ័រ និងផលិតផលដែលពាក់ព័ន្ធផ្សេងទៀត។ អគ្គិសនីក៏មានឥទ្ធិពលជាវិជ្ជមានទៅការសិក្សារបស់សិស្សដែរ ដូចជាអំពូលភ្លើងជួយដល់ការអានរបស់សិស្ស ការមើលឃើញអក្សរលើក្ដារខៀន និងកង្ហារជួយរក្សាបន្ទប់សិស្សឱ្យត្រជាក់។ ក្ដារខៀន និងជំនួយផ្នែកចក្ខុក៏មានឥទ្ធិពលជាវិជ្ជមានដូចគ្នាដែរ។

លក្ខណសម្បត្តិគ្រូបង្រៀន (នាយកសាលា) គឺមានសារៈសំខាន់ណាស់ក្នុងការកំណត់លទ្ធផលសិក្សារបស់សិស្ស។ ក្នុងស្ថានភាពដែលសាលារៀនមានលទ្ធភាពថវិកាដូចគ្នា សាលារៀនមួយចំនួនមានគុណភាពខ្ពស់ ប៉ុន្តែសាលារៀនផ្សេងទៀតមានគុណភាពទាបជាង ដោយសារភាពខុសគ្នានៃកម្រិតសមត្ថភាពរបស់នាយកសាលា។ Glewwe Hanushek Humpage និង Ravina (២០១៤) បានពិនិត្យលើការស្រាវជ្រាវក្នុងអំឡុងពីរទសវត្សចុងក្រោយទាក់ទងនឹងឥទ្ធិពលទៅលើឆ្នាំសិក្សារបស់សិស្ស និងការរៀនរបស់សិស្ស ដោយយកកត្តាជាច្រើនដូចជា លក្ខណសម្បត្តិរបស់គ្រូបង្រៀន និងសាលារៀនជាមូលដ្ឋាន (ឧទា. កម្រិតនៃការអប់រំរបស់គ្រូបង្រៀន បទ-ពិសោធន៍ ចំណេះដឹង យេនឌ័រ ការបណ្ដុះបណ្ដាល និងកម្រិតនៃការបង្រៀន ព្រមទាំងវិធីសាស្ត្រគរុកោសល្យដែលប្រើប្រាស់)។

របនាសម្ព័ន្ធសាលារៀន រួមមានទំហំថ្នាក់ (ផលធៀបសិស្ស-គ្រូបង្រៀន) អវត្តមានគ្រូបង្រៀន ចំនួនដងនៃការដាក់កិច្ចការផ្ទះឱ្យសិស្ស អាហារនៅសាលារៀន ការបង្រៀនច្រើនកម្រិតថ្នាក់ ចំនួនម៉ោងក្នុងសាលារៀន ថ្ងៃសិក្សា ប្រៀវត្សគ្រូបង្រៀន គ្រូជាប់កិច្ចសន្យា ការចំណាយក្នុងសិស្សម្នាក់ វត្តមានក្នុងថ្នាក់ ការចុះឈ្មោះចូលរៀនសរុប ការងារជាក្រុម ចំនួនដងនៃការលើកឧទាហរណ៍របស់គ្រូបង្រៀន និងវត្តមានរបស់សិស្ស។

ការកែលម្អលទ្ធផលសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍតម្រូវឱ្យមានការអនុវត្តគោលនយោបាយក្នុងគោលបំណងធ្វើឱ្យលក្ខណសម្បត្តិរបស់គ្រូសារ និងសិស្សកាន់តែប្រសើរឡើង។ ទោះបីជាលក្ខណសម្បត្តិរបស់សិស្សនិង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

គ្រួសារជាញឹកញាប់មានការលំបាកក្នុងការផ្លាស់ប្តូរក៏ដោយ តាមរយៈគោលនយោបាយរបស់រដ្ឋាភិបាល គោលនយោបាយមួយចំនួនមានគោលបំណងកែលម្អសុខភាពកុមារដែលអាចមានឥទ្ធិពលយ៉ាងសំខាន់។ ដូចនេះ Glewwe (២០១៤) បានចាត់ថ្នាក់គោលនយោបាយទាំងនេះជា ៣ ប្រភេទ៖ គោលនយោបាយរៀបចំលក្ខណសម្បត្តិរបស់សិស្សមុនពេលពួកគេចាប់ផ្តើមចូលសាលាបឋមសិក្សា គោលនយោបាយរៀបចំត្រៀមជាមុនសម្រាប់សិស្ស និងឥរិយាបថរបស់ឪពុកម្តាយ និងគោលនយោបាយផ្លាស់ប្តូរដំណើរការរបស់សាលារៀន ទាំងរចនាសម្ព័ន្ធគ្រប់គ្រងនិងការលើកទឹកចិត្តគ្រូបង្រៀន និងរដ្ឋបាលសាលារៀន។

លក្ខណសម្បត្តិរបស់សិស្ស ក្នុងឆ្នាំដំបូងនៃជីវិតអាចនឹងផ្លាស់ប្តូរយ៉ាងខ្លាំង តាមរយៈការអប់រំកុមារតូច និងកម្មវិធីសុខភាព អាហារូបត្ថម្ភ និងសុខភាពកុមារ។ កស្តុតាងយ៉ាងរឹងមាំបានបង្ហាញថា សាលាមត្តេយ្យសិក្សាអាចនឹងមានឥទ្ធិពលជាវិជ្ជមានទៅលើការអប់រំរបស់កុមារ និងលទ្ធផលនៃការកចំណូលរបស់ពួកគេក្នុងរយៈពេលវែង។ ពេលដែលក្មេងជាច្រើនក្នុងប្រទេសកំពុងអភិវឌ្ឍរងគ្រោះពីកង្វះអាហារូបត្ថម្ភ និងសុខភាពខ្សោយ លទ្ធផលសិក្សារបស់សិស្ស ពឹងផ្អែកលើស្ថានភាពអាហារូបត្ថម្ភនិង សុខភាពរបស់ពួកគេ។ Alderman និង Bleakley (2014) បានសិក្សាលើឥទ្ធិពលនៃកម្សោយសុខភាព ទៅលើលទ្ធផលអប់រំក្នុងប្រទេសកំពុងអភិវឌ្ឍ និងបានកត់សម្គាល់ថា ការឆ្លងប៉ារ៉ាស៊ីត និងកង្វះអាហារូបត្ថម្ភ គឺជាទិដ្ឋភាពគន្លឹះដែលមានសក្តានុពលមិនត្រឹមតែបង្កើនចំនួនឆ្នាំនៃការសិក្សាក្នុងសាលាប៉ុណ្ណោះទេ ប៉ុន្តែក៏បង្កើនការសិក្សាពេញមួយឆ្នាំផងដែរ។ អន្តរាគមន៍ជាសាធារណៈដើម្បីធ្វើឱ្យសុខភាពកុមារប្រសើរ មិនត្រឹមតែឈានទៅរកការបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច តាមរយៈដំណោះស្រាយពីខាងក្រៅប៉ុណ្ណោះទេ ប៉ុន្តែបានកាត់បន្ថយវិសម- ភាពចំពោះគ្រួសារក្រីក្រដែរ។ ការរៀនសូត្រគឺជាដំណើរការជាបន្តបន្ទាប់សម្រាប់សិស្សម្នាក់ៗ។ ដូចគ្នានេះដែរ ការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អភិវឌ្ឍសង្គមគឺពឹងផ្អែកលើបទពិសោធន៍ និងការស្វែងយល់ពីសិស្ស (Barron et al., ២០១៧)។

គោលនយោបាយផ្លាស់ប្តូរការលើកទឹកចិត្តសិស្សនិងឪពុកម្តាយ ត្រូវបានគិតថាជាគោលនយោបាយផ្នែកតម្រូវការ ដែលគាំទ្រដល់សាលារៀន។ កម្មវិធីផ្តល់សាច់ប្រាក់ភ្ជាប់ជាមួយនឹងលក្ខខណ្ឌបានក្លាយទៅប្រជាប្រិយទូទៅក្នុងប្រទេសកំពុងអភិវឌ្ឍ (World Bank, ២០០៩)។ កម្មវិធីលើកទឹកចិត្តចំនួន ៤ ត្រូវបានគេប្រើប្រាស់ជាទូទៅក្នុងកម្មវិធីអភិវឌ្ឍ មានដូចជា ៖ (១) កម្មវិធីផ្តល់សាច់ប្រាក់ភ្ជាប់ជាមួយលក្ខខណ្ឌ ដែលផ្តល់ឱ្យឪពុកម្តាយជាប្រចាំខែ ដោយភ្ជាប់ជាមួយលក្ខខណ្ឌបញ្ជូនកូនរបស់ពួកគេទៅសាលាជាទៀងទាត់ (២) ការផ្តល់ប្រាក់ទៅឱ្យសិស្សផ្អែកលើលទ្ធផលសិក្សា ដូចជាពិន្ទុតេស្ត (៣) កម្មវិធីលិខិតជានា ដែលផ្តល់មូលនិធិដល់ឪពុកម្តាយអាចប្រើប្រាស់សម្រាប់ចុះឈ្មោះកូនរបស់ពួកគេក្នុងសាលារៀន និង (៤) កម្មវិធីអប់រំតាមរយៈចំណីអាហារ ដែលផ្តល់ឱ្យក្មេងនូវអាហារនៅក្នុងសាលារៀន ឬផ្គត់ផ្គង់គ្រួសាររបស់ពួកគេជាមួយអាហារប្រើប្រាស់នៅផ្ទះ។ គោលនយោបាយ ប្រភេទទី ៣ ផ្តោតលើបញ្ហាផ្នែកផ្គត់ផ្គង់ដល់សាលា និងស្វែងរកការផ្គត់ផ្គង់សេវាអប់រំ (ឧទា. ការបង្រៀន សេវាបណ្ណាល័យ ការគ្រប់គ្រងជាដើម) កាន់តែទទួលខុសត្រូវចំពោះតម្រូវការសម្រាប់ការអប់រំ។ ជាញឹកញាប់គោលនយោបាយទាំងនេះត្រូវបានអនុវត្តតាមទម្រង់ការគ្រប់គ្រងតាមសាលារៀន ដើម្បីដោះស្រាយបញ្ហាផ្គត់ផ្គង់។

## ៤.៧. កំណែទម្រង់ជាប្រព័ន្ធ និងការគ្រប់គ្រងតាមសាលារៀន

កំណែទម្រង់ការគ្រប់គ្រងការអប់រំជាប្រព័ន្ធមាននិយមន័យជាច្រើនដោយសំដៅទៅលើការសម្រេចចិត្តនៅតាមសាលារៀន ឬការគ្រប់គ្រងតាម



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សាលារៀន (School-Based Management (SBM))។ SBM គឺជាវិមជ្ឈការអំណាចពីរដ្ឋាភិបាលទៅកាន់កម្រិតសាលារៀន។ ការទទួលខុសត្រូវនិងការសម្រេចចិត្តលើដំណើរការសាលារៀន ត្រូវបានផ្ទេរទៅកាន់ភ្នាក់ងារកម្រិតស្រុក។ ភ្នាក់ងារទាំងនេះ ជាការរួមបញ្ចូលគ្នានៃនាយកសាលា គ្រូបង្រៀន ឪពុកម្តាយ សិស្ស និងសមាជិកសហគមន៍ផ្សេងទៀត។ SBM មានគោលបំណងកែលម្អគណនេយ្យភាពដោយ ៖ (i) ផ្តល់ភាពស្វ័យ ភាពដល់សាលារៀនក្នុងធ្វើសេចក្តីសម្រេចចិត្ត ក្នុងគោលបំណងកែលម្អភាពច្បាស់លាស់រវាងអ្នកត្រួតពិនិត្យការផ្តល់សេវា និងអ្នកដែលផ្តល់សេវា និង (ii) លើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមក្នុងដំណើរការសម្រេចចិត្តក្នុងគោលបំណងបង្កើនសំឡេងក្នុងការផ្តល់សេវា (Bruns et al. ២០១១)។

Bruns et al (២០១១) បានផ្តល់ការវិភាគក្នុងការផ្តល់សេវាអប់រំគ្រប់ជ្រុងជ្រោយ អំពីទិដ្ឋភាពនៃបញ្ហាគោលការណ៍របស់ភ្នាក់ងារផ្តល់ការអប់រំ។ ក្រសួងអប់រំគឺជាភ្នាក់ងាររបស់ប្រជាជន នៅពេលដែលឪពុកម្តាយនិងសិស្សអាចត្រូវគេចាត់ទុកជានាយកសាលា។ អ្នកប្រើប្រាស់សេវាអប់រំទទួលខុសត្រូវចំពោះប្រទេសជាតិ។ ក្នុងពេលជាមួយគ្នា រដ្ឋក៏ដើរតួនាទីជាអ្នកផ្តល់សេវា (សាលារៀន និងគ្រូបង្រៀន) ទទួលខុសត្រូវចំពោះការអនុវត្ត។ របាយការណ៍អភិវឌ្ឍន៍ពិភពលោក ២០០៤ បានពិពណ៌នាទូវក្របខ័ណ្ឌមួយអំពីទំនាក់ទំនងស្នូលចំនួន ៣ គឺរវាងប្រជាជន អ្នកនយោបាយ និងអ្នកផ្តល់សេវា។ ទំនាក់ទំនងការផ្តល់សេវា និងការទទួលខុសត្រូវក្នុងចំណោមតួអង្គទាំងនេះមានភាពស្មុគស្មាញ។ តួអង្គជាច្រើនពាក់ព័ន្ធគ្នា។ ទំនាក់ទំនងនៃការលើកទឹកចិត្តនិងការទទួលខុសត្រូវ របស់ក្រុមមួយអាចនឹងខុសគ្នាពីក្រុមដទៃ (World Bank, ២០០៣)។ ដូចនេះ SBM អាចត្រូវបានគេគិតថា ជាទម្រង់នៃកំណែទម្រង់ការគ្រប់គ្រងការអប់រំជាប្រព័ន្ធពីក្រោមទៅលើ។

និន្នាការក្នុងប្រទេសជាច្រើន បានធ្វើការបង្កើនស្វ័យភាព ការទទួលខុសត្រូវបែបវិមជ្ឈការ និងជំរុញការលើកទឹកចិត្តដល់តម្រូវការក្នុងតំបន់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដើម្បីធ្វើការកែលម្អការអនុវត្ត (Bruns et al., ២០១១)។ ទោះបីជាយ៉ាងណា ពីពេលមួយទៅមួយ ទីផ្សារសម្រាប់ការអប់រំរងគ្រោះពីបរាជ័យទីផ្សារ។ នេះតម្រូវឱ្យរដ្ឋាភិបាលអន្តរាគមន៍ និងកែតម្រូវបញ្ហា។ ក្នុងគោលបំណងធ្វើឱ្យប្រសើរសេវាអប់រំ ប្រទេសជាច្រើនបានអនុម័តនូវយុទ្ធសាស្ត្រកំណែទម្រង់គណនេយ្យភាពទាំង ៣ (Bruns et al., ២០១១)៖

**ព័ត៌មានសម្រាប់គណនេយ្យភាព៖** សំដៅទៅលើការបង្កើត និងការផ្សព្វផ្សាយព័ត៌មានស្តីពីសិទ្ធិរបស់សាលារៀននិងការទទួលខុសត្រូវ ជាតុចូល លទ្ធផលរយៈពេលខ្លី និង លទ្ធផលរយៈពេលវែង

**ការគ្រប់គ្រងតាមសាលារៀន៖** សំដៅលើវិមជ្ឈការការសម្រេចចិត្តនៅកម្រិតសាលារៀន និងស្វ័យភាពរបស់សាលារៀន

**ការលើកទឹកចិត្តគ្រូបង្រៀន៖** សំដៅលើគោលនយោបាយដែលផ្សារភ្ជាប់នឹងប្រាក់រង្វាន់ ឬមុខតំណែងស្របទៅនឹងការអនុវត្ត។

## ៤.៨. គំនិតផ្តួចផ្តើមសកល និងនិន្នាការនៃកំណែទម្រង់ការអប់រំ

នាពេលបច្ចុប្បន្ន គំនិតផ្តួចផ្តើមសកលស្តីពីការអប់រំបានឆ្លុះបញ្ចាំងពីតម្រូវការរបស់ប្រទេសជាច្រើនក្នុងការចាប់ផ្តើមធ្វើកំណែទម្រង់ការគ្រប់គ្រងការអប់រំជាប្រព័ន្ធ ក្នុងគោលបំណងសម្រេចឱ្យបានគោលដៅ។

ក. គោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងការអប់រំ ឆ្នាំ ២០៣០៖ របៀបវារៈការអប់រំសកល(ការអប់រំឆ្នាំ២០៣០)គឺជាផ្នែកមួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១៧ របស់អង្គការសហប្រជាជាតិ ដែលជារបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ គោលបំណងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ គឺធានាសមធម៌ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងបង្កើនឱកាស



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទទួលបានការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ការអប់រំគឺជាផ្នែកមួយដ៏សំខាន់នៃគោលដៅផ្សេងទៀតទាក់ទងនឹងហិរញ្ញវត្ថុសាធារណៈនៃសេវាមូលដ្ឋាន និងក្របខ័ណ្ឌច្បាប់/នយោបាយ ដែលជានាទូវឱកាសអប់រំ និងសមាហរណកម្មគោលបំណងខុសៗគ្នា (ឧ. ប្រជាពលរដ្ឋសកល ការឆ្លើយតបនឹងវិបត្តិ បរិយាកាសចំណោះដឹង) ទៅក្នុងគោលនយោបាយ និងកម្មវិធីសិក្សាអប់រំជាតិ។

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤គ្របដណ្តប់លើការសិក្សាពីកុមារតូចរហូតដល់ពេញវ័យ ដោយផ្តោតសំខាន់លើគុណភាពអប់រំ ការសិក្សា បរិយាបន្ន និងសមភាព។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ផ្តោតលើទិសដៅសកល និងគោលដៅសម្រាប់ប្រទេសនៅគ្រប់កម្រិតនៃការអភិវឌ្ឍ។ របៀបវារៈការអប់រំឆ្នាំ ២០៣០ បង្ហាញពីការចូលរួមរបស់អ្នកពាក់ព័ន្ធវិស័យអប់រំទាំងផ្នែកជាតិនិងអន្តរជាតិ ជាមួយនឹងបញ្ហាប្រឈម២ គឺលទ្ធផលនៃការសិក្សា និងសមភាពនៃគុណភាពអប់រំ(UNESCO, ២០១៥)។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤- ក្របខ័ណ្ឌការអប់រំ ឆ្នាំ ២០៣០ រួមមាន ៖

១. ការប្តេជ្ញាចិត្ត៖ (១) ចំពោះសកលកម្មអន្តរកម្ម យ៉ាងហោចណាស់យុវជនទទួលបានការអប់រំមួយឆ្នាំនៃថ្នាក់មត្តេយ្យសិក្សា ១២ ឆ្នាំនៃការអប់រំបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ ដោយឥតបង់ថ្លៃ (យ៉ាងហោចណាស់បញ្ចប់ការសិក្សារយៈពេល ៩ ឆ្នាំ) និង (២) ជានាឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំនៅកម្រិតក្រោយការអប់រំមូលដ្ឋាន និងតម្រូវការការបណ្តុះបណ្តាលដែលត្រូវកែតម្រូវ/ពង្រឹងនីតិបញ្ញត្តិរបស់ជាតិ។

២. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្តោតលើការអប់រំពេញមួយជីវិត ចាប់ពីកុមារតូចរហូតដល់ពេញវ័យ។ គោលដៅទាំងនេះផ្តោតលើវិធានការពង្រឹងការអាន និងគណិតវិទ្យា ដើម្បីឆ្លុះបញ្ចាំងពីការពិនិត្យរួមគ្នា និងគ្រប់ជ្រុងជ្រោយអំពីជំនាញដែលត្រូវការសម្រាប់សង្គម និងបរិស្ថាន។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

៣. កត្តាសមភាពត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ដោយបានចាត់វិធានការជាច្រើន ផ្តោតលើគុណភាពអប់រំ។ ដូចនេះ ជាចាំបាច់ត្រូវជំរុញការអនុវត្តគោលនយោបាយលើកកម្ពស់គុណភាពអប់រំ និងបង្កើនការសិក្សាជាបន្តបន្ទាប់ ។

៤. ការពង្រីកការទទួលបានការអប់រំគ្រប់កម្រិត និងការសិក្សាពេញមួយជីវិត ដោយផ្អែកលើគោលការណ៍នៃការអប់រំស្តីពីសិទ្ធិមនុស្សជាមូលដ្ឋាន និងផលិតផលសាធារណៈ។

៥. ការកែតម្រូវនានាដោយផ្តោតលើសមភាពយេនឌ័រ និងបរិយាបន្ន។

៦. ការយកចិត្តទុកដាក់ជាថ្មីលើប្រសិទ្ធភាពនៃការសិក្សា ដោយផ្តោតលើកម្មវិធីសិក្សា និងការបណ្តុះបណ្តាលគ្រូបង្រៀន រួមមានមាតិកាបង្រៀន និងការបង្រៀន គរុកោសល្យ សម្ភារ និងការបង្រៀនក្នុងថ្នាក់ ក្របខ័ណ្ឌវាយតម្លៃ ព្រមទាំងការបណ្តុះបណ្តាលគ្រូបង្រៀននិងការអភិវឌ្ឍវិជ្ជាជីវៈ។ មធ្យោបាយសន្តនិយមនិងស៊ីចង្វាក់គ្នា គឺតម្រូវឱ្យមានភាពស្របគ្នារវាងកម្មវិធីសិក្សា ការវាយតម្លៃ ការបណ្តុះបណ្តាលគ្រូបង្រៀន ព្រមទាំងភាពដឹកនាំ និងការគ្រប់គ្រងសាលារៀន។

៧. ការផ្តោតលើការសិក្សាអំពីកិច្ចការអន្តរជាតិ និងភាពជាពលរដ្ឋសកល។ កត្តានេះមានន័យថា (i) ការវាយតម្លៃលទ្ធផលសិក្សា ដោយសារការសិក្សា មានប្រសិទ្ធភាពនិងពាក់ព័ន្ធគ្នា តម្រូវឱ្យស្មើភាពនិងយន្តការមានតុល្យការ និងវាយតម្លៃចំណេះដឹង ជំនាញនិងការប្រកួតប្រជែងគ្រប់ទិដ្ឋភាពរបស់អ្នកប្រើប្រាស់សមត្ថភាព និងភាពបត់បែនក្នុងការអនុវត្តការវាយតម្លៃ និង (ii) ការធានាគុណភាពនិងក្របខ័ណ្ឌគុណសម្បត្តិ។

៨. គណៈកម្មការអប់រំ (២០១៦) បានកំណត់ថា ត្រឹមឆ្នាំ ២០៣០ ជាងពាក់កណ្តាលនៃប្រជាជន វ័យក្មេងជំនាន់ថ្មីនឹងជួបបញ្ហាប្រឈមនាពេលអនាគត ដោយសារតែពួកគេពុំមានជំនាញដែលត្រូវការសម្រាប់ទីផ្សារការងារដែលតែងតែផ្លាស់ប្តូរ។ ដូចនេះ កំណែទម្រង់ការគ្រប់គ្រងការអប់រំ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាប្រព័ន្ធ គឺមានសារៈសំខាន់សម្រាប់ប្រទេសកំពុងអភិវឌ្ឍដើម្បីធានាការអនុវត្ត។ ប្រព័ន្ធតាមដានលទ្ធផលដ៏រឹងមាំគឺជាប្រព័ន្ធដែលធានាថា គោលដៅ គោលនយោបាយនិងការចំណាយមានភាពស៊ីចង្វាក់គ្នា ដែលជាមាគ៌ាដ៏ច្បាស់លាស់មួយសម្រាប់គោលនយោបាយឆ្ពោះទៅការអនុវត្ត និងរដ្ឋបាលមានប្រសិទ្ធភាពនិងគណនេយ្យភាព។ ដូចនេះ ការរកឃើញដោយគណៈកម្មការនេះ ស៊ីចង្វាក់គ្នាជាមួយក្របខ័ណ្ឌគំនិតដែលស្នើដោយការសិក្សានាពេលបច្ចុប្បន្ន។ គណៈកម្មការអប់រំ (២០១៦) ស្នើឱ្យមានការផ្លាស់ប្តូរការអប់រំ និងផ្តល់ជាអនុសាសន៍ដូចខាងក្រោម៖

ហិរញ្ញវត្ថុ៖ (១) បែងចែកហិរញ្ញវត្ថុកាន់តែច្រើន និងកាន់តែប្រសើរសម្រាប់ការអប់រំ (២) ធានាភាពជាអ្នកដឹកនាំសម្រាប់ការបង្កើតការសិក្សា។

ការប្រតិបត្តិ៖ (១) កំណត់ស្តង់ដាតាមដានការរីកចម្រើន និងផ្តល់ព័ត៌មានជាសាធារណៈដោយបង្កើតក្របខ័ណ្ឌវាយតម្លៃការសិក្សាកម្រិតជាតិនៅតាមសាលាបឋមសិក្សា និងផ្តល់ព័ត៌មានឱ្យមានប្រយោជន៍និងងាយស្រួលយល់ (២) វិនិយោគលើអ្វីដែលផ្តល់កស្តុតាងជាលទ្ធផលនៃការផ្តល់សេវាដូចជាការវិនិយោគលើសាលាមត្តេយ្យសិក្សា និងការអប់រំមូលដ្ឋាន ការអប់រំវេជ្ជសាស្ត្រ វិធីសាស្ត្របង្រៀនកាន់តែប្រសើរ សេចក្តីណែនាំនៃការប្រើប្រាស់ពីរភាសា ការសិក្សាជំនួយដោយកំព្យូទ័រ និងសម្ភារ និងការត្រួតពិនិត្យផ្អែកលើសហគមន៍ (៣) កាត់បន្ថយការខ្ជះខ្ជាយដោយបង្ក្រាបអំពើពុករលួយដែលអាចជួយគ្រូបង្រៀនចំណាយពេលបង្រៀន និងកាត់បន្ថយចំណាយលើសម្ភារសិក្សា។

ការច្នៃប្រឌិត៖ (១) ការអប់រំត្រូវតែផ្លាស់ប្តូរដោយបច្ចេកវិទ្យា ការច្នៃប្រឌិតក្នុងការរៀបចំ និងការស្វែងយល់ថ្មីនៃរបៀបរៀនសូត្រ (២) ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀននិងរៀន និង (៣) ការធ្វើឱ្យកាន់តែប្រសើរឡើងនូវភាពជាដៃគូជាមួយតួអង្គមិនមែនរដ្ឋ។

បរិយាបន្ន៖ការវិនិយោគចម្រុះវិស័យដើម្បីដោះស្រាយកត្តាបោះបង់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ការសិក្សាដូចជា ៖ ហេដ្ឋារចនាសម្ព័ន្ធ សុខភាព សុវត្ថិភាព និងសន្តិសុខ ជាដើម។

តាមរយៈ ទ្រឹស្តីនិងលទ្ធផលស្រាវជ្រាវស្តីពីទិដ្ឋភាពកំណែទម្រង់ការអប់រំសម្រាប់គុណភាពអប់រំ ដូចដែលបានរៀបរាប់ខាងលើ យើងអាចឈានដល់ការសន្និដ្ឋានថា ការអប់រំគឺជាកត្តាសំខាន់មួយក្នុងការទទួលបានសេវាអប់រំ និងផ្តល់ផលប្រយោជន៍ផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា សម្រាប់កំណើនសេដ្ឋកិច្ច។ ជាពលរដ្ឋដែលទទួលបានការអប់រំ នឹងក្លាយជាកម្លាំងពលកម្មចាំបាច់សម្រាប់ការអភិវឌ្ឍ។ ចំណេះនិងជំនាញមានសារៈសំខាន់សម្រាប់បង្កើនផលិតភាពនិងលទ្ធផលសង្គម ដូចនេះហើយការពិភាក្សាគោលនយោបាយជាញឹកញាប់ច្រើនពាក់ព័ន្ធនឹងគុណភាពអប់រំ។ ទោះបីជាយ៉ាងណា ភាពមិនស៊ីគ្នាផ្នែកជំនាញបានលេចចេញជាលទ្ធផលនៃការផ្លាស់ទិដ្ឋភាពសេដ្ឋកិច្ចនិងសង្គមយ៉ាងឆាប់រហ័ស នៅពេលដែលវិទ្យាស្ថានអប់រំមានភាពយឺតយ៉ាវក្នុងការតាមឱ្យទាន់នឹងការផ្លាស់ប្តូរបច្ចេកវិទ្យា និងសង្គម។

យុទ្ធសាស្ត្រដោះស្រាយបញ្ហាទាំងនេះ ទាមទារឱ្យការអនុវត្តនូវកំណែទម្រង់ជាប្រព័ន្ធក្នុងគោលបំណងដោះស្រាយជាមួយអង្គភាពស្មុគស្មាញ និងដោះស្រាយសមាសធាតុជាច្រើន ក្នុងពេលដំណាលគ្នា។ កំណែទម្រង់ការអប់រំគួរតែធ្វើឡើងផ្តោតនៅកម្រិតសាលារៀន។ ក្នុងប្រទេសជាច្រើន មានគោលបំណងលើកកម្រិតប្រតិបត្តិនិងមាននិន្នាការឆ្ពោះទៅរកស្វ័យភាព ការផ្តល់សិទ្ធិទទួលខុសត្រូវ និងការឆ្លើយតបទៅនឹងតម្រូវការក្នុងតំបន់ តាមរយៈការអនុវត្តការគ្រប់គ្រងផ្អែកលើសាលារៀន។ ដូចនេះ ប្រទេសកំពុងអភិវឌ្ឍគួរតែពិចារណាយកចិត្តទុកដាក់ពីការចាប់ផ្តើមកំណែទម្រង់ការអប់រំ ក្នុងគោលបំណងធ្វើឱ្យប្រសើរ លក្ខណសម្បត្តិរបស់គ្រូបង្រៀន និងសាលារៀន ព្រមទាំងលក្ខណសម្បត្តិរបស់សិស្សនិងគ្រួសារ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# សេចក្តីសន្និដ្ឋាន

ជាទូទៅ គំនិតនិងទ្រឹស្តីទាក់ទងនឹងការគ្រប់គ្រងការអប់រំ កំណែទម្រង់ការគ្រប់គ្រងការអប់រំ និងគុណភាពរបស់ប្រជាពលរដ្ឋ អាចវិភាគនិងសំយោគដូចខាងក្រោម៖

កំណែទម្រង់ការគ្រប់គ្រងការអប់រំ ៖ យោងទៅតាមគំនិតនៃកំណែទម្រង់ការគ្រប់គ្រងការអប់រំ ជាប្រព័ន្ធ (UNESCO, ១៩៨៩; Hoy និង Miskel, ២០០៨; MoEYS, ២០១៧) កំណែទម្រង់ការគ្រប់គ្រងការអប់រំរួមមានជាតុគន្លឹះសំខាន់ដូចខាងក្រោម៖

១. កំណែទម្រង់ការគ្រប់គ្រងទូទៅនិងរដ្ឋបាល៖ (ក) គោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រ (ខ) ការគ្រប់គ្រងផ្អែកលើសាលារៀន និង (គ) ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន។

២. កំណែទម្រង់ការគ្រប់គ្រងការសិក្សា៖ (ក)កម្មវិធីសិក្សា និងការគ្រប់គ្រងសៀវភៅសិក្សា (ខ) ដំណើរការបង្រៀននិងរៀន និង(គ) ការវាយតម្លៃ សិស្ស និងអធិការកិច្ចសាលារៀន។

៣.កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ៖(ក) ការបែងចែកហិរញ្ញវត្ថុអប់រំ ដោយភ្ជាប់ជាមួយថវិកាអប់រំទៅនឹងគោលនយោបាយអប់រំ (ខ) ស្វ័យភាពហិរញ្ញវត្ថុនិងការទទួលខុសត្រូវរបស់សាលារៀន និង (គ) សវនកម្មថវិកាអប់រំ។

៤.កំណែទម្រង់គ្រប់គ្រងបុគ្គលិក៖(ក) ការបណ្តុះបណ្តាលគ្រូបង្រៀន (ខ) វិក្រឹតការគ្រូបង្រៀន និង (គ) ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន។

ភាពជាពលរដ្ឋមានគុណភាព៖ យោងតាម UNESCO (២០១៤, ២០១៥) និង OXFAM (២០១៥) គំនិតគុណភាពប្រជាពលរដ្ឋបង្ហាញពីទំនាក់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទំនងរវាងពលរដ្ឋក្នុងស្រុកល្អ និងពលរដ្ឋសកលល្អ (មើលរូបភាព ៣) និងរួមមានដូចខាងក្រោម៖

១. ភាពជាពលរដ្ឋមានគុណភាព រួមមាន៖ (១) សមាសធាតុសេដ្ឋកិច្ច ៖ (ក) ចំណេះដឹង (ខ) ជំនាញទន់ ជំនាញរឹង និងជំនាញអន្តរបុគ្គល ដូចជា ទំនាក់ទំនង សហប្រតិបត្តិការ ដោះស្រាយបញ្ហា និងដោះស្រាយជម្លោះ (គ) បំណិនជីវិត និង (២) សមាសធាតុនយោបាយសង្គម ៖ (ក) ភាពជាពលរដ្ឋ ៖ ការគោរពច្បាប់ អត្តសញ្ញាណជាតិ គ្រួសារនិយម និងការស្មោះត្រង់ចំពោះប្រទេស ការទទួលយកភាពខុសគ្នានៃសង្គមនិងការគោរពភាពចម្រុះ (ខ) សកម្មភាពជាលក្ខណៈបុគ្គលឬប្រមូលផ្តុំដើម្បីជំរុញគុណភាពប្រជាពលរដ្ឋ (គ) សកម្មភាពប្រជាពលរដ្ឋទាក់ទងនឹងចលនាសង្គម ដូចជា ការប្តេជ្ញាចិត្តចំពោះយុត្តិធម៌សង្គម សមភាព សិទ្ធិមនុស្ស ការការពារបរិស្ថាន ការអភិវឌ្ឍប្រកបដោយចីរភាព និងការអភិវឌ្ឍសហគមន៍ និង (ឃ) សកម្មភាពនយោបាយ ៖ សមាជិកភាពក្នុងគណបក្សនយោបាយ ការចូលរួមក្នុងការពិភាក្សានយោបាយ និងការជ្រើសរើសរាល់ការបោះឆ្នោត។

២. ភាពជាពលរដ្ឋសកលមានគុណភាព៖ (១) សមាសធាតុសេដ្ឋកិច្ច (ក). ចំណេះដឹងស្តីពីសកលលោក និងអាចដឹងពីតួនាទីក្នុងនាមជាពលរដ្ឋរបស់ពិភពលោកមួយរូប (ខ) ការគោរពនិងឱ្យតម្លៃពិពិធកម្ម និង (២) សមាសធាតុសង្គម (ក) ឆន្ទៈក្នុងការធ្វើឱ្យពិភពលោកក្លាយជាកន្លែងកាន់តែមានសមភាព និងនិរន្តរភាព និង (ខ)ការទទួលខុសត្រូវសម្រាប់សកម្មភាពរបស់ខ្លួន (Oxfam,២០១៤)។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**កំណែទម្រង់ការគ្រប់គ្រងការអប់រំ**

**១. កំណែទម្រង់ការគ្រប់គ្រងទូទៅ និងរដ្ឋបាល**

១.១ គោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រ

១.២ ការគ្រប់គ្រងតាមសាលារៀន

១.៣ ការចូលរួមរបស់សហគមន៍ ក្នុងការគ្រប់គ្រងសាលា

**២.កំណែទម្រង់ការគ្រប់គ្រងការសិក្សា**

២.១. កម្មវិធីសិក្សា និងសៀវភៅសិក្សា

២.២. ដំណើរការបង្រៀននិងរៀន

២.៣. ការវាយតម្លៃសិស្ស និងអធិការកិច្ចសាលា

**៣.កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំ**

៣.១. ការបែងចែកហិរញ្ញវត្ថុអប់រំភ្ជាប់ថវិកាទៅនឹងគោលនយោបាយអប់រំ

៣.២. ស្វ័យភាពហិរញ្ញវត្ថុនិងការទទួលខុសត្រូវរបស់សាលារៀន

៣.៣. សវនកម្មថវិកាអប់រំ

**៤.កំណែទម្រង់ការគ្រប់គ្រងបុគ្គលិក**

៤.១. ការបណ្តុះបណ្តាលគ្រូបង្រៀន

៤.២. វិក្រឹតការគ្រូបង្រៀន

៤.៣. ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន

➡

គុណភាពប្រជាពលរដ្ឋ

១.១. សមាសធាតុសេដ្ឋកិច្ចគុណភាពប្រជាពលរដ្ឋ

**១. ភាពជាពលរដ្ឋមានគុណភាព**

១.១.សមាសធាតុសេដ្ឋកិច្ច

(១) ចំណេះដឹងនិងជំនាញរឹង

(២) ជំនាញរឹង និងជំនាញទន់

១.២. សមាសធាតុសង្គម នយោបាយ

(១) គោរពច្បាប់និងបទបញ្ជា

(២) សហគមន៍និងការអភិវឌ្ឍប្រកបដោយចីរភាព

(៣)ការចូលរួមក្នុងសកម្មភាពនយោបាយ

**២. ភាពជាពលរដ្ឋសកលមានគុណភាព**

២.១. សមាសធាតុសេដ្ឋកិច្ច

(១) ការទទួលស្គាល់បញ្ហាសកល

(២) គោរពពិពិធភាពនិងតម្លៃរបស់មនុស្ស

២.២. សមាសធាតុសង្គមនយោបាយ

(១) ធ្វើឱ្យពិភពលោកក្លាយជាកន្លែងកាន់តែប្រសើរ

(២) ទទួលខុសត្រូវចំពោះសកម្មភាព

តារាង(២)៖ ក្របខ័ណ្ឌគំនិតនៃការស្រាវជ្រាវ

# គន្ថនិទ្ទេស


Adamson, F., Astrand, B. & Darling-Hammond, L. (2016). *Global Education Reform: How Privatization and Public Investment Influence Education Outcomes.* New York: Routledge.

Alderman, H. & Bleakley, H. (2014). *Child Health and Education Outcome.* Chicago: The Universityof Chicago Press.

Anderson, C., Avery, P. G., Pederson, P. V., Smith, E. S. & Sullivan, J. L. (1997). "Divergent Perspectives on Citizenship Education: A Q-method Study and Survey of Social Studies Teachers," *American Educational Research Journal*, 34(2), pp. 333-364.

Anson, R. J. (1994). *Systemic Reform: Perspectives on Personalizing Education.* Washington DC: US Department of Education Report.

Antikainen, A. & Pitkänen, A. (2014). A History of Educational Reforms in Finland. In Rechard R. Verdugo (Ed.), *Educational Reform in Europe: History, Culture and Ideology*, pp.1-24.

Arnove, R. F. (2005). To what ends: Educational reform around the world. *Indiana Journal of Global Legal Studies*, 12(1), pp.79-95.

Ban, K.-M. (2012). The Global Education First Initiative. UN doc A/66/874.

Barron, A. B., Hebets, E. A., Cleland, T. A., Fitzpatrick, C. L., Hauber, M. E. & Stevens, J. R. (2015). Embracing multiple definitions of learning. *Trends in Neurosciences*, 38(7), pp. 405-407.

Becker, G. S. (1960). Underinvestment in college education? *The American Economic Review*, 50(2), pp. 346-354.

Benhabib, J. & Spiegel, M. M. (1994). The role of human capital in economic development evidence from aggregate cross-country data. *Journal of Monetary Economics*, 34(2), pp. 143-173.

Bennett, S. J. (1999). Effect of slope on the growth and migration of headcuts in rills. *Geomorphology*, 30(3), pp. 273-290.

Bruns, B., Filmer, D. & Patrinos, H. A. (2011). *Making Schools Work: New Evidence on Accountability Reforms.* World Bank Publications.

Bush, T. & Bell, L. (2009). *The Principles and Practice of Educational Management.* Sage.

Cheng, Y. C. (2001). *Education reforms in Hong Kong: Challenges, strategies and international implications.* Paper presented at the plenary speech presented at the International Forum on Education Reform: Experiences in Selected Countries.

Comenus (2002). *La Grande didactique ou l'art universel de tout enseigner à*





fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*tous*. traduction de Marie-Françoise Bosquet-Frigout, Dominique Saget, Bernard Jolibert. 2e édition revue et corrigée, Paris: Klincksieck.

Conley, D. T. (1993). *Roadmap to Restructuring: Policies, Practices and the Emerging Visions of Schooling*. ERIC.

Creemers, B. P. (1997). School effectiveness and school improvement: Sustaining links. *School Effectiveness and School Improvement*. 8(4), pp. 396–429.

Davies, I., Gregory, I. & Riley, S. (1999). *Good Citizenship and Educational Provision*. New York: Falmer Press.

Delors, J. (1996). *Learning: The Treasure Within*. Report to UNESCO of the International Commission on Education for the Twenty-first Century, 141-142.

Dewey, J. (1916). *The Child and the Curriculum*. Chicago: The University of Chicago Press.

------------ (1931). *Les écoles de demain*, (*Schools of Tomorrow*, 1915). Paris: Flammarion.

------------ (1938, 1974). *Expérience et éducation*, (*Experience and Education*) Paris: Armand Colin.

------------ (1956). *The School and Society*. Phoenix Edition.

------------ (1967). *Logique: la théorie de l'enquête*, (*Logic: The Theory of Inquiry*, 1938). Paris: Presses universitaires de France.

------------ (2004). *Democracy and Education*. Courier Corporation.

Dolto, F. (1981). *Le Jeu du désir*. Paris: Seuil.

------------ (1985). *La Cause des enfants*. Paris: Robert Laffont.

Education Commission (2016). *The Learning Generation: Investing in Education for a Changing World*.

Elmore, R. F. (2004). *School Reform from the Inside Out: Policy, Practice, and Performance*.

Érasme, D. (1991). *Oeuvres choisies*. Paris: Librairie générale Française.

Fagerlind, I. & Saha, L. (1989). *Education and National Development: A Comparative. Perspective*. Oxford: Pergamon Press.

Falch, T., Nyhus, O. & Strom, B. (2014). Performance of Young Adults: The importance of cognitive and non-cognitive skills. *CESifo Economic Studies*. 60(2), pp. 435–462.

Faure, P. (1945). *L'école et la cité*. Paris: Mame.

------------ (1958). *Au sciècle de l'enfant*. Paris: Mame.

Fidler, I. J. (2002). *Strategic Management for School Development*. London: Paul Chapma Publishing in association with BELMAS.

Fonvieille, R. (1996). *De l'écolier écoeuré à l'enseignant novateur*. Vauchrétien, Ivan Davy.

---------------- (1999). *Naissance de la pédagogie autogestionnaire*. Paris:



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Anthropos.

Francia, G. (2014). Education Reform in Sweden. From "*One School for All Children*" to "*One school for Each Child*".

Freinet, C. (1969). *Pour l'école du peuple. Guide pratique pour l'organisation matérielle, technique et pédagogique de l'école populaire*. Paris: Maspéro.

------------ (2001). *Comment susciter le désir d'apprendre?* Mouans-Sartoux, Publications de l'école moderne française.

Freire, P. (1983). *Pédagogie des oprimés. Suvi de Conscientiation et révolution*. Paris: Maspéro.

---------- (1996). *L'éducation, pratique de la liberté*. Lyon: éditions W.

Fuhrman, S. (1994). *Politics and Systemic Education Reform*. CPRE Policy Briefs.

Fuhrman, S., Elmore, R. F. & Massell, D. (1993). School reform in the United States: Putting it into context. In S.L. Jacobsen & R. Berne (Eds.) *Reforming Education: The Emerging Systemic Approach*, pp. 3-27.

Fullan, M. (2007). *The New Meaning of Educational Change*. New York: Routledge.

Gambin, L., Hogarth, T., Murphy, L., Spreadbury, K., Warhurst, C. & Winter-botham, M. (2016). *Research to understand the extent, nature and impact of skills mismatches in the economy*. May 2016.

Gardner, H. (1983). *Frames of Mind: The Theory of Multiple Intelligences*. Basic books.

Glewwe, Hanushek, E. A., Humpage, S. D. & Ravina, R. (2014). *School resources and educational outcomes in developing countries: A review of the literature from 1990 to 2010*. National Bureau of Economic Research.

Glewwe, P. (2014). *Education Policy in Developing Countries*. University of Chicago Press.

Glewwe, P. W., Hanushek, E. A., Humpage, S. D. & Ravina, R. (2011). *School resources and educational outcomes in developing countries: A review of the literature from 1990 to 2010*. National Bureau of Economic Research.

Gutman, L. M. & Schoon, I. (2013). *The Impact of Non-Cognitive Skills on Outcomes for Young People*. Education Empowerment Foundations, London: Guvenen, F., Kuruscu, B., Tanaka, S. & Wiczer, D. (2015). *Multidimensional skill mismatch*. National Bureau of Economic Research.

Hallinger, P. & Bryant, D. A. (2013). Synthesis of findings from 15 years of educational reform in Thailand: Lessons on leading educational change in East Asia. *International Journal of Leadership in Education*. 16(4), pp. 399-418.

Hang-Chuon Naron. (2016a). *Education Reform in Cambodia: Towards a Knowl-edge- Based Society and Shared Prosperity.* (In Khmer) Phnom Penh: Preah-



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

Vihear Editions.
Hanushek, E. & Woessmann, L. (2007). *The Role of Education Quality for Economic Growth*.
Hanushek, E. A. & Woessmann, L. (2008). The Role of Cognitive Skills in Economic Development. *Journal of Economic Literature*. 46(3), pp. 607-668.
Hanushek, E. A. & Zhang, L. (2009). Quality-consistent estimates of international schooling and skill gradients. *Journal of Human Capital*. 3(2), pp. 107-143.
Hargreaves, A. & Fink, D. (2004). The seven principles of sustainable leadership. *Educational Leadership*. 61(7), pp. 8-13.
Hargreaves, D. (2011). *The Challenge for the Comprehensive School: Culture, Curriculum and Community*. New York: Routledge.
Hargreaves, D. H. (2010). *Leading a self-improving school system*. Nottingham: National Colledge for Leadership.
Heckman. (2000). Policies to foster human capital. *Research in Economics*. 54(1), pp. 3-56.
Heckman, Lochner, L. & Taber, C. (1998). Explaining rising wage inequality: Explorations with a dynamic general equilibrium model of labor earnings with heterogeneous agents. *Review of Economic Dynamics*. 1(1), pp. 1-58.
Heckman, Pinto, R. & Savelyev, P. (2013). Understanding the mechanisms through which an influential early childhood program boosted adult outcomes. *The American Economic Review*. 103(6), pp. 2052-2086.
Heckman & Rubinstein, Y. (2001). The importance of noncognitive skills: Lessons from the GED testing program. *The American Economic Review*. 91(2), pp. 145-149.
Herbart, J. F. (2007). *Tact, autorité, expérience et sympathie en pédagogie*. Paris: J. Vrin.
Hill, D. (2003). Global Neo-Liberalism, the Deformation of Education and Resistance. *Journal for Critical Education Policy Studies*. 1(1).
Hirsch Jr, E. D. (1996). The schools we need: And why we don't have them: Anchor.
Horton, J. (1966). *Order and Conflict theories of Social Problems as Competing Ideologies*. University of Chicago Press.
Hoy, W. K. & Miskel, C., G. (2008). *Educational Administration–Theory, Research and Practice*. New York: McGraw-Hill.
Humboldt, W.V. (2004). *Essai sur les limites de l'action de l'État*. Paris: Belles lettres.
Irez, S. & Han, C. (2011). Educational Reforms as Paradigm Shifts: Utilizing Kuhnian Lenses for a Better Understanding of the Meaning of, and Resistance to, Educational Change. *International Journal of Environmental and Science*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*Education*. 6(3), pp. 251-266.
Jencks, C. (1979). *Who Gets Ahead? The Determinants of Economic Success in America*. New York: Basic Books.
Kergomard, P. (1889). *Les écoles maternelles*. Monographies pédagogiques, Paris: Imprimerie nationales.
Kerr, D. (1999). *Citizenship Education: An International Comparison*. Qualifications and Curriculum Authority.
Key, E. (1900). *Le Siècle de l'enfant*. Paris: Flammarion.
Korczack, J. (1984). *Les Colonies de vacances*. Paris: La pensée Universelle.
-------- (1984). *Les moments pédagoqiques*. Paris: Anthropos.
Kurth-Schai, R. & Green, C. (2008). Education and democracy. *Encyclopedia of the Social and Cultural Foundations of Education*. 1-8.
Lobrot, M. (1966). *La pédagogie institutionnelle, l'école vers l'autogestion*. Paris: Gauthier-Villars.
Lapassade, G. (1971a). *L'Arpenteur*. Paris: Épi.
—————— (1971b). *L'Autogestion pédagogique*. Paris: Gauthier-Villars.
—————— (2006). *Groupes, organisations et institutions*. Paris: Gauthier-Villars, Anthropos, 5e édition.
La Salle, D. J-B. (1711). Recueil de différents petits traités à l'usage des Frères des écoles chrétiennes.
Levin, B. (2010). Governments and education reform: some lessons from the last 50 years. *Journal of Education Policy*. 25(6), pp. 739-747.
Lucas, R. E. (1988). On the Mechanics of Economic Development. *Journal of Monetary Economics*. 22, pp. 3-42.
Lynch, L. M. (1992). Differential effects of post-school training on early career mobility: *National Bureau of Economic Research*.
Matthey, M.P. (1998). *Les courants de la pédagogie contemporaine:La pédagogie institutionnelle*. Université de Neuchâtel, No 49, 1998.
Mankiw, N. G., Romer, D. & Weil, D. N. (1992). A contribution to the empirics of economic growth. *The Quarterly Journal of Economics*. 107(2), pp. 407-437.
Mincer, J. A. (1974). Education, Experience, and the Distribution of Earnings and Employment: An Overview. In *Education, Income and Human Behavior*. F. Thomas Juster, (ed.)
MoEYS. (2013-2018). *Education Statistical Yearbook*. Phnom Penh.
——— (2014). *Education Congress Report*. Phnom Penh.
——— (2015a). *Education Congress Report*. Phnom Penh.
——— (2015b). *Teacher Policy Action Plan*. Phnom Penh.
——— (2016). *Mid-Term Review of the Education Strategic Plan 2014-2018 with a projection until 2020*. Phnom Penh.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

——— (2017). *School-Based Management Guidelines: Administrative Management, Academic Management, Financial Management and Human Resources Management*. Phnom Penh.

Montaigne. (2009). *Les Essais*. Paris: Gallimard.

Montessori, M. (1996). *De l'enfant à l'adolescent*. Paris: Desclée de Brouwer.

——— (1996). *La formation de l'homme*. Paris: Desclée de Brouwer.

——— (1992). *L'esprit absobant de l'enfant*. Paris: Desclée de Brouwer.

——— (2004). *L'enfant*. Paris: Desclée de Brouwer.

——— (1909, 1916, 2001, 2000). *Pédagogie scientique 1, La maison des enfants. 2. Éducation élémentaire*. Paris: Desclée de Brouwer.

Na Ayudhaya, S. N., Siribanpitak, P. & Sumettikoon, P. (2016). Designing Simulation for Assessing People Skills and Competencies of School Leaders in Thailand. *ABAC*. 2(36), 19.

Neill, A. (2004). *Libres enfants de Summerhill*. Paris: La découverte.

Nelson, J. L., Palonsky, S. B. & McCarthy, M. R. (2012). *Critical issues in Education: Dialogues and Dialectics*. Waveland Press.

Newby, T., Stepich, D., Lehman, J. & Russell, J. (2000). Instructional technology for teaching and learning: Designing instruction, integrating computers, and using media. *Educational Technology & Society*. 3(2).

Ouellette, M. (2000). *Maintaining Progress Through Systemic Education Reform*.

Oury, F. et Vasquez A. (1967). Vers une pédagogie institutionnelle? Vauchrétien, Matrice.

OXFAM. (2015). *Education for Global Citizenship: A Guide for Schools*. Oxford: Oxfam UK. Oxford.

Paulston, R. G. (1976). Social and educational change: Conceptual frameworks. *Comparative Education Review*. 21(2/3), pp. 370-395.

Paulston, R. G. & LeRoy, G. (1982). Nonformal education and change from below. *Comparative Education*. pp. 336-362.

Pech, S., Siribanpitak, P. & Sumettikoon, P. (2015). Development of a Dual-System School Management Model for the Kingdom of Cambodia. *Scholar*. 7(1).

Pestalozzi, J. H. (1801). *Comment Gertrud instruit ses enfants*.

——— (1996). *Lettres de Stans*. Carouge-Genève, Minizoé.

——— (1797). *Mes recherches sur la marche de la nature dans le développement du genre humain*. Lausanne/Paris: Payot.

Plaisance, E. (1996). *Pauline Kergomard et l'école maternelle*. Paris: Presses universitaires de la France.

Pont, B., Deborah, N. & Hunter, M. (2008). Improving School Leadership, *Policy and Practice*. (Vol. 1) OECD publishing.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Pritchett, L. (2015). Creating education systems coherent for learning outcomes: Making the transition from schooling to learning. Research on Improving Systems of Education (RISE) Working Paper, Preliminary draft.

Psacharopoulos, G. (1985). Returns to education: a further international update and implications. *Journal of Human Resources*. pp. 583-604.

Psacharopoulos, G. & Patrinos, H. A. (2004). Human capital and rates of return. *International Handbook on the Economics of Education.* 1-57.

Pyhältö, K., Soini, T. & Pietarinen, J. (2011). A systemic perspective on school reform: Principals' and chief education officers' perspectives on school development. *Journal of Educational Administration*. 49(1), pp. 46-61.

Rabelais, F. (1912-1955). *Oeuvres*. Paris: Honoré Champion.

Research, H. (2014). *Incorporating Soft Skills into the K-12 Curriculum*.

Rivkin, S. G., Hanushek, E. A. & Kain, J. F. (2005). Teachers, schools, and academic achievement. *Econometrica*, 73(2), pp. 417-458.

Romer, P. M. (1990). Endogenous technological change. *Journal of Political Economy*. 98(5, Part 2), S71-S102.

Rousseau, J-J. (1995). *Émile ou de l'éducation*. Paris: Gallimard.

Sammons, P., Hillman, J. & Mortimore, P. (1995). Key characteristics of effective schools. *A Review of School Effectiveness Research*.

Schleiermarcher, F. (1997). *Dialectique*. pour une logique de la vérité. Pressess de l'Université de Laval; Genève, Labor et Fides, Paris: Cerf.

Schultz, T. W. (1961). Investment in human capital. *The American Economic Review*, 51(1), pp. 1-17.

Schwab, K. (2016). *The Fourth Industrial Revolution*. Geneva: World Economic Forum.

Siribanpitak, P. (2009). Reorienting Teacher Education to Address Sustainable Development: Lessons from Chulalongkorn University, Thailand: Management and Provision of Education for a Small Planet. Bangkok: Prikwan Graphic.

Siribanpitak, P. & Kijtorntham, W. (2014). A Comparative Study of Educational Cooperation between Thailand and Neighboring Countries: Lao PDR and Cambodia. *Scholar*. 6(2).

Tan, J. & Gopinathan, S. (2000). *Education Reform in Singapore: Towards Greater Creativity and Innovation?*

Tandon, P. & Fukao, T. (2015). *Educating the Next Generation : Improving Teacher Quality in Cambodia*. Directions in Development. Washinton, DC: World Bank.

Tawil, S. (2013). Education for 'Global Citizenship': A framework for discussion. Education Research and Foresight: Working papers UNESCO, http://www.

unesco.org/new/fileadmin/MULTIMEDIA/HQ/ED/pdf/PaperN7 Educfor-GlobalCitizenship. pdf.

Theiss-Morse, E. (1993). Conceptualizations of good citizenship and political participation. *Political Behavior*. 15(4), pp. 355-380.

Thompson, J. (1994). Systemic Education Refrom. *OSSC Bulletin*, v37n4, Eric Digest.

Thomson, S. (2016). *The Most Important Skills of Tomorrow, According to Five Global Leaders*. World Economic Forum.

Tiongson, E. R. (2005). Education policy reforms. In *Analyzing the Distributional Impact of Reforms: A Practitioner's Guide to Trade, Monetary and Exchange Rate Policy, Utility Provision, Agricultural Markets, Land Policy, and Education.* Aline Coudouel & Stefano Paternos tro (eds.).

Torney-Purta, J., Lehmann, R., Oswald, H. & Schulz, W. (2001). *Citizenship and education in twenty-eight countries: Civic knowledge and engagement at age fourteen*. ERIC.

Tucker, M. S. & Codding, J. B. (1998). *Standards for Our Schools: How to Set Them, Measure Them, and Reach Them*. ERIC.

UNESCO (1974). *Recommendation Concerning Education for International Unders tanding, Cooperation and Peace and Education Relating to Human Rights and Fundamental Freedoms*. Paris: UNESCO.

---------- (1989). *Administration and Management of Education: The Challenges Faced*. Paris: IIEP.: Booklet No. 2.

---------- (1995). *Declaration and Integrated Framework for Action: Education for Peace, Human Rights and Democracy*. Paris: UNESCO.

---------- (2014). *Global Citizenship Education: Preparing Learners for the Challenges of the 21st Century*. Paris: UNESCO.

---------- (2015a). Global Citizenship Education: Topics and Learning Objectives. Paris: UNESCO.

---------- (2015b). *Education 2030. Incheon Declaration and Framework for Action. Toward Inclusive and Equitable Quality Education and Lifelong Learning*. Paris: UNESCO.

---------- (2015c). *Education for All 2000-2015: Achievements and Challenges*. Paris: UNESCO.

---------- (2016a). *Assessment of Transversal Competencies: Policy and Practice in the Asia-Pacific Region.*

---------- (2016b). *Global Citizenship Concepts in Curriculum Guidelines of 10 Countries: Comparative Analysis*. Paris: UNESCO.

Verdugo, G. (2014). The great compression of the French wage structure, 1969–2008. *Labour Economics*. 28, pp. 131-144.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Wideen, M. (1994). *The Struggle for Change: The Story of One School*: Psychology Press.

Woessmann, L. (2011). Education policies to make globalization more inclusive. In *Making Globalization Socially Sustainable*. Marc Beauhetta & Marion Jamsen (Eds.), (pp. 404-418). Switzerland: WTO Secretariat.

Wongwanich, S., Piromsombat, C., Khaileng, P. & Sriklaub, K. (2015). 'Policy delivery strategies for educational reform: A formative research and develop ment. Paper presented at the Social and Behavioral Sciences 171 (2015).

World Bank (2003). *World Development Report 2004: Making Services Work for Poor People*. World Development Report.

-------------- (2010). *Providing Skills for Equity and Growth: Preparing Cambodia's Youth for the Labor Market*. Washington, DC: The World Bank. .

———— (2018). *Growing Smarters: Learning and Equitable Development in East Asia and Pacific*.

Young, M. R. (2003). Enhancing learning outcomes: The effects of instructional technology, learning styles, instructional methods, and student behavior. *Journal of Marketing Education*. 25(2), pp. 130-142.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៦នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរ-ជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកជានាភិបាលពីវិទ្យាស្ថានជានាភិបាល(CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានជានាភិបាលម៉ាឡេស៊ី(MII)។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅកម្ពុជានិងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិត្យសភា Rhodes ផ្នែកនីតិសាស្ត្រនិងគោលនយោបាយសមុទ្រ។ នៅឆ្នាំ២០១៤ លោកបណ្ឌិតទទួលបានសញ្ញាបត្របណ្ឌិតផ្នែកអប់រំពីសាកលវិទ្យាល័យចូឡាឡុងកន។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងវិស័យឯកជន អ្នកជំនាញការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្ម ហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិ

រូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបូកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះ លោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសីទអន្តរជាតិ ដូចជា មហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិកាអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយ ក្រោមចំណងជើងថា «Cambodian Economy: Charting the Course for a Bright Future» ត្រូវបានជ្រើសរើសបោះពុម្ពផ្សាយដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ «ប្រវត្តិសាស្ត្រកម្ពុជា ក្នុងបរិបទសកលលោក» ។

# ស្នាដៃរបស់អ្នកនិពន្ធ

១- L'Économie du Cambodge : La lutte pour le développement, 2005

២- Essais économiques, 2007

៣- Les finances publiques du Cambodge, 2007

៤- Cambodia: Recent Macroeconomic and Financial Sector Development, 2008

៥- Three Essays on Macroeconomic Management of Cambodia, 2008

៦- Introduction to Insurance, 2008

៧- ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩

៨- Public Finance in Cambodia, 2009

៩- ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩

១០- ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩

១១- Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009

១២- L'économie du Cambodge: Nouvelles frontières du développement socio-économique, 2010

១៣- Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012

១៤- ទស្សនាទានស្តីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ - ឆ្នាំ២០១៣

១៥- សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៦- កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖
មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦

១៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា
នាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា( ទសវត្សរ៍
ឆ្នាំ១៩៨០) - ឆ្នាំ២០១៧

១៨- នីតិអន្តរជាតិសេដ្ឋកិច្ច - ឆ្នាំ២០១៧

១៩- *Series of Lectures in Public International Law, 2018*

២០- សិក្សាសង្ខេបស្តីពីទស្សនវិជ្ជា - ឆ្នាំ២០១៨

២១- *Droit International Économique, 2018*

២២- *Education Reform in Cambodia, 2018*

២៣-វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាន
នៅកម្ពុជា - ឆ្នាំ២០១៩

២៤- ប្រវត្តិសាស្ត្រកម្ពុជា ក្នុងបរិបទសកលលោក - ឆ្នាំ ២០១៩

២៥- អក្សរសិល្ប៍ និងភាសាខ្មែរសម័យមុនអង្គរ និងសម័យអង្គរ តាមរយៈ
សិលាចារឹក-ឆ្នាំ២០២០